អាន តាំគីម

# ប្រយោជន៍ នៃការកាន់ ព្រះពុទ្ធសាសនា

## តាមការយល់ និង ការពិសោធន៍ខ្លះ របស់ខ្ញុំ

បោះពុម្ពដោយការឧបត្ថម្ភរបស់
វត្តពោធិវង្ស ប្រទេសបារាំង
ព.ស. ២៥៦១ គ.ស. ២០១៧

អ្នកនិពន្ធខ្ញុំអនុញ្ញាតលោកអ្នក អាចយកអត្ថបទខ្លះ ឬ សៀវភៅនេះ ទៅបោះពុម្ពបានដោយសេរី ។
Tous droits de diffusion, de reproduction, d'adaptation et de traduction réservés pour tous pays.
Website : www.btkhmer.com

<u>សៀវភៅដែលខ្ញុំបានបោះពុម្ពរួចហើយ</u> ( * )

1- Méthode Pratique de la Méditation.
[4ème édition - 2015 - Editions ANN AMATA]

2-Le Bouddhisme (son origine, ses principes de base et ses applications dans la vie).
[2ème édition - 2006 - Editions de Vatt Bodhivansa]

3-Hommage au Triple Joyau - Cérémonies religieuses et fêtes traditionnelles khmères.
[2014 - Editions de Vatt Bodhivansa]

4-នមស្ការព្រះរតនត្រ័យ - ពិធីបុណ្យព្រះពុទ្ធសាសនា និងបុណ្យប្រពៃណីខ្មែរ

[2014 - បោះពុម្ពដោយ វត្តពោធិវង្ស ប្រទេសបារាំង ]

5- Le Bouddhisme – Son utilité d'après mes expériences dans la vie. (<u>A paraître</u>)
[ ដោយប្រែសៀវភៅនេះ ជាភាសាបារាំង ទុកជាបណ្តាំទៅកូនចៅខ្ញុំ ]

---

( * ) លោកអ្នកអាចអានសៀវភៅដែលខ្ញុំបានសរសេរហើយ នៅ វេបសាយត៍ (website)

www.btkhmer.com (ជាភាសាបារាំង និង ជាភាសាខ្មែរ) ។

**ខ្ញុំសូមឧទ្ទិស** *កុសលផលបុណ្យ ដែលបានកើតឡើងអំពីធម្មទាននេះ ជូនចំពោះ លោកអ្នកដ៏មានគុណទាំងឡាយ ដែលធ្វើមរណកាលទៅហើយ មាន មាតា បិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ បង ប្អូន មីងមា ទាំងអស់ និង សព្វសត្វទាំងអស់ ។*

*ប្រសិនបើជានៅមានទុក្ខ សូមឲ្យឆាប់រួចចាកទុក្ខនោះ បានដូចសេចក្តីប្រាថ្នា ។*

## *អារម្ភកថា*

*សៀវភៅនេះខ្ញុំរៀបរៀងឡើង ដោយមានបំណងចែករំលែកការពិសោធន៍ របស់ខ្ញុំផ្ទាល់ បន្ទាប់ពីបានយកធម៌ព្រះពុទ្ធ មកអនុវត្តក្នុងជីវិតខ្ញុំសព្វថ្ងៃ ។*

*តាមខ្ញុំសង្កេតឃើញ មានបងប្អូនខ្មែរយើងខ្លះកាន់ព្រះពុទ្ធសាសនា តាមទម្លាប់ ពីដូនតា ម៉ែឪមក ហើយក៏ធ្វើតាមនោះតទៅទៀតទៅ តែពុំទាន់បានប្រើបញ្ញា រកហេតុផល ឲ្យយល់ពីជម្រៅនៃព្រះពុទ្ធសាសនានៅឡើយទេ ។ ដូចអ្នកខ្លះមានគេ បបួលទៅវត្តក៏ទៅនឹងគេទៅ គេបបួលទៅផឹកស្រាគោះកែវ ក៏គោះនឹងគេទៅ ។ តាមពិត ការកាន់ព្រះពុទ្ធសាសនា មានប្រយោជន៍ច្រើន ដល់យើងផង និងដល់អ្នកដទៃផង ពោលគឺ បានសេចក្តីសុខទាំងយើងផង និងទាំងគេផង ។ លោកអ្នកក៏នឹងសង្កេតឃើញ ដូចខ្ញុំដែរថា ដើម្បីយើងបានសុខ លុះត្រាតែអ្នកនៅជុំវិញយើងបានសុខ និងអ្នកដទៃបាន សុខ ។ បើគេមិនបានសុខ យើងក៏ពិបាកនឹងបានសុខដែរ ។*

*ខ្ញុំសូម អរព្រះគុណ អរគុណ ព្រះអង្គគ្រូ ងិន គេន និង ព្រះអង្គចៅអធិការ ពេជ្រ សាម៉ុន ដែលបានផ្ទៀងផ្ទាត់កែតម្រូវ និងសម្រួលពាក្យពេចន៍ផ្សេងៗ ព្រមទាំង ព្រះសង្ឃនិង ពុទ្ធបរិស័ទវត្តពោធិវង្ស ដែលបានជួយជ្រោមជ្រែង ដោយសទ្ធាជ្រះថ្លា ធ្វើឲ្យសៀវភៅ នេះកើតឡើង គ្រាន់នឹងចែកជូនជាធម្មទាន ។*

ខ្ញុំសង្ឃឹមថាសៀវភៅនេះ អាចផ្តល់ប្រយោជន៍ខ្លះ ជូនលោកអ្នកអានជាមិនខាន ។

សង់ សៀម៉ាន ថ្ងៃ ១៥ ឧសភា ឆ្នាំ ២០១៧ ។

មាតិកា………………………………………………………………….. ទំព័រ

លំនាំដើម ………………………………………………………………………… 6

១- គុណព្រះពុទ្ធ……………………………………………………………………….8

២- សេចក្ដីស្ងប់ និងសតិ ………………………………………………………………13

៣- បុណ្យ និង បាប ……………………………………………………………………18

៤- សីល ៥ …………………………………………………………………………..23

៥- ហេតុអ្វីបានជា ជីវិតរស់នៅសព្វថ្ងៃ ជាទុក្ខ តាមព្រះពុទ្ធសាសនា ………..28

៦- ធម៌ទាំងឡាយកើតមកអំពីហេតុ ………………………………………………..33

៧- ធម៌ ………………………………………………………………………………..44

៨- ធម៌ អនត្តា …………………………………………………………………………..51

៩- ប្រយោជន៍ នៃធម៌ អនត្តា ……………………………………………………………..58

១០- ប្រយោជន៍នៃសមាធិ និង បញ្ញា (វិបស្សនា) ……………………………….62

១១- អំពីសិស្សពូកែជាងគ្រូ ……………………………………………………………..76

១២- តើយើងស្លាប់ទៅ សូន្យ ឬ កើតទៀត ………………………………………..80

១៣- ការបកស្រាយធម៌ព្រះពុទ្ធ ខុសរបៀប ខុសពេលវេលា………………..89

១៤- អតីត អនាគត និងបច្ចុប្បន្ន ……………………………………………………..100

១៥- ត្រូវចេះធ្វើបុណ្យ ទើបបានបុណ្យច្រើន……………………………………..103

១៦- អារម្មណ៍ ដែលត្រូវមានមុនពេលស្លាប់ ………………………………………..105

១៧- ធម៌ព្រះពុទ្ធ តាមការយល់និងការបដិបត្តិ របស់ខ្ញុំ …………………….112

១៨ ពាក្យមុននឹងបញ្ចប់ (pg.122) ជីវប្រវត្តិអ្នកនិពន្ធ (pg.134) - សៀវភៅយោង (pg.139)

-ស្នាដៃខ្ញុំនៅធនាគារ (pg.140) - ការសង្កេត (pg.142).

# លំនាំដើម

បុព្វហេតុដំបូង ក្នុងការសរសេរសៀវភៅនេះ គឺខ្ញុំចង់បានសៀវភៅធម៌មួយ ចែកជូនជាធម្មទាន នៅពេលធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលទៅ ឪពុកខ្ញុំ ដែលគាត់បានទទួលអនិច្ចកម្មសម័យប៉ុលពត ដូចឪពុកម្តាយរបស់លោកអ្នកខ្លះដែរ ។ ប្រសិនបើជាគាត់រស់នៅរហូតដល់ឆ្នាំ ២០១៧ នេះ នោះគាត់ត្រូវបានអាយុ ១០០ឆ្នាំ ។ ដោយខ្ញុំពុំទាន់បានសងគុណគាត់ផង នៅពេលដែលគាត់នៅរស់ ពីព្រោះខ្ញុំទើបនឹងចេញប្រកបការងារ ហើយប៉ះចំពេលស្រុកកើតសង្គ្រាមទៀត ហេតុនេះហើយទើបនៅពេលនេះ ខ្ញុំខំសរសេរសៀវភៅធម៌នេះ ដើម្បីនឹងបានជាកុសលជូនទៅគាត់ ។ ខ្ញុំសូមលោកអ្នកដែលបានជួយឧបត្ថម្ភខ្ញុំ ទាំងខាងសំភារៈ ទាំងខាងចំណេះវិជ្ជា ដូចជា មាតាបិតាជីដូនជីតា និងគ្រូឧបជ្ឈាយាចារ្យជាដើម សូម អនុមោទនាទទួលយកនូវកុសលដែលនឹងកើតអំពីសៀវភៅនេះរៀងៗខ្លួន។

លោកអ្នកអាចសួរថា ចាំបាច់សរសេរសៀវភៅធម៌ធ្វើអ្វីទៀត បើសៀវភៅធម៌ មានច្រើនរួចទៅហើយ រកតែពេលមើលគ្មាន ហើយសុទ្ធតែជាសៀវភៅធម៌ សរសេរដោយលោកគ្រូធំៗ មានឈ្មោះល្បីល្បាញទៀតផង ។ ខ្ញុំក៏មានគំនិតយ៉ាងនេះដែរ ហើយខ្ញុំក៏មិនចង់ចំណាយពេល សរសេរនូវអ្វីៗ ដែលធ្វើឲ្យអ្នកអានគេខាតពេលដែរ ។ តែខ្ញុំសរសេរនេះ ដោយមានបំណង លើកបញ្ហាបីយ៉ាង មកជូនលោកអ្នកគ្រាន់នឹងពិចារណាទាំងអស់គ្នា ៖

១- ដោយឃើញការបកស្រាយធម៌ព្រះពុទ្ធខ្លះ ពីបាលី មកជាភាសាខ្មែរយើង មិនស្របតាមន័យធម្មតា ដែលអ្នកស្រុកធ្លាប់យល់ ដូចជាពាក្យ **អនត្តា** បកប្រែថា មិនមែនយើង មិនមែនខ្លួនយើង ឬក៏ថា ឥតមានយើង ***ឥតមានខ្លួនយើង*** ហើយនៅក្នុងធម៌ព្រះពុទ្ធដដែល មានចែងថា « ខ្លួន ទីពឹង ខ្លួន » ។ ចុះឲ្យទៅពឹងខ្លួនដូចម្តេចកើត បើឥតមាន

ខ្លួនផង ?

២- សព្វថ្ងៃនេះ មានក្រុមលោកគ្រូមួយចំនួន ពន្យល់ថា ឲ្យតែយល់ធម៌អភិធម្មច្បាស់លាស់ទៅ បានសម្រេចព្រះនិព្វានហើយ មិនចាំបាច់ ធ្វើសមាធិនាំឲ្យខាតពេលទេ ។

៣- ដោយខ្ញុំធ្លាប់បានគិតពិចារណានូវធម៌ព្រះពុទ្ធខ្លះដែរ និងបានប្រតិបត្តិធម៌ព្រះអង្គជារៀងរាបដរាបមក ខ្ញុំចង់ចែករំលែក ការពិសោធន៍ខ្ញុំនេះ ជូនលោកអ្នក ទុកដូចជាឧទាហរណ៍ជាក់ស្តែង ដោយគ្មានបំណងចង់ប្រដែប្រដៅលោកអ្នក ឬក៏ចង់ឲ្យលោកអ្នកយល់តាមខ្ញុំនោះទេ ។ ពីព្រោះបើខាងផ្លូវកាយអាចបង្ខំគេបាន នោះខាងផ្លូវចិត្តមិនអាចបង្ខំគេបានទេ ។

# ១

## គុណព្រះពុទ្ធ

*ពាក្យថា ព្រះពុទ្ធ មិនមែនជាឈ្មោះទេ តែជាបរមងារ ដែលមានន័យថា* **អ្នកត្រាស់ដឹង** *។ ព្រះនាមព្រះអង្គ គឺ* **គោតម** *ព្រះអង្គជាព្រះរាជបុត្រនៃព្រះបាទ សុទ្ធោទន៍ និង ព្រះនាង សិរិមហាមាយា ។*

*ក្នុងព្រះជន្ម ១៦ព្រះវស្សា ទ្រង់បានអភិសេកជាមួយនឹង ព្រះអង្គម្ចាស់ក្សត្រី យសោធរា។ ព្រះអង្គគង់នៅក្នុងវាំងដោយ សុខសប្បាយពុំដែលស្គាល់អ្វីដែលហៅថាទុក្ខនោះទេ ។ តែមានពេលមួយ ព្រះអង្គបានយាងកំសាន្តនៅខាងក្រៅព្រះរាជវាំង ក៏បានជួបនូវហេតុការណ៍ដ៏សង្វេគខ្វះ ដែលធ្វើឲ្យព្រះអង្គពិចារណាទៅលើ សេចក្តីទុក្ខទាំងពួង នៃមនុស្សលោកយើងនេះ និងធ្វើឲ្យព្រះអង្គចង់រកផ្លូវដោះស្រាយ ។*

*ក្នុងព្រះជន្ម ២៩ព្រះវស្សា បន្ទាប់ពីព្រះមហេសី បានប្រសូតព្រះរាជបុត្រជាលើកដំបូង ព្រះនាម រាហុល មក នៅវេលាយប់ ព្រះអង្គ និងនាយឆន្នអាមាត្យ បានចាកចេញពីព្រះរាជវាំង ដោយគ្មានអ្នកណាម្នាក់ដឹង។ ក្នុងការស្វែងរកចម្លើយខាងលើនេះ ព្រះអង្គបានជួបនឹងគ្រូខ្វះដែរ តែធម៌របស់គ្រូទាំងនោះ ពុំអាចដោះស្រាយចំណោទ របស់ព្រះអង្គបានឡើយ។ ចំណោទ គឺ « ដោយឃើញថា ជីវិតជាទុក្ខ តើត្រូវធ្វើដូចម្តេចដើម្បី រំលត់ទុក្ខ »។*

*ធម៌ដែលព្រះអង្គត្រាស់ដឹង ដើម្បីដោះស្រាយនូវចំណោទនោះ គឺ* **អរិយសច្ចៈ ៤** *ដែលមាន៖*

**១-ទុក្ខ អរិយសច្ច** : *ទុក្ខ ជារបស់ពិតដ៏ប្រសើរ*

**២-ទុក្ខសមុទយ អរិយសច្ច** : *ហេតុឲ្យកើតទុក្ខ ជារបស់ពិតដ៏ប្រសើរ*

**៣- ទុក្ខនិរោធ អរិយសច្ច** : *ការរលត់ទុក្ខ ជារបស់ពិតដ៏ប្រសើរ*

**៤-ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ច** : *ផ្លូវបដិបត្តិឲ្យដល់នូវការរំលត់ទុក្ខ ជារបស់*

ពិតដ៏ប្រសើរ ។

ខ្ញុំ រំលឹក ពុទ្ធប្រវត្តិខ្លះតែប៉ុណ្ណោះ ដើម្បីជូនលោកអ្នកគ្រាន់នឹងពិចារណានូវ មនសិការ និង ការតស៊ូ យ៉ាងស្វិតស្វាញ របស់ព្រះពុទ្ធដើម្បីជួយសត្វលោកឲ្យរួចផុតចាកទុក្ខ ក៏ដូចជួយយើងឲ្យបានសេចក្តីសុខដែរ ។ ពីព្រោះទុក្ខ និង សុខ បដិបក្ខ (ប្រឆាំង) នឹងគ្នា ៖ បើមួយមាន មួយទៀតត្រូវតែគ្មាន គឺថា របស់ទាំងពីរហ្នឹង មិនអាចកើតឡើងជាមួយគ្នានៅពេលតែមួយបានទេ ។ ឧបមាដូចជា (សោមនស្ស និង ទោមនស្ស ) ( បញ្ញា និង អវិជ្ជា ) (កុសល និង អកុសល) ជាដើម ។ ចំពោះអ្នកដែលសង្ស័យ ថាតើព្រះពុទ្ធមានមែន ឬមិនមាន ។ តើព្រះពុទ្ធត្រាស់ដឹងពិតមែន ឬមិនពិត ខ្ញុំសូមជូនចម្លើយ គ្រាន់នឹងយកទៅពិចារណា ដូចតទៅ ៖

១- ព្រះពុទ្ធសាសនា កើតក្រោយ សាសនាជាច្រើន ដូចជាព្រហ្មញ្ញសាសនា ជាដើម ពីព្រោះបន្ទាប់ពីចេញពីព្រះរាជវាំង ព្រះអង្គបានជួបគ្រូជាតាបសខ្លះដែរ មុននឹងព្រះអង្គស្វែងរកមោក្ខធម៌(ធម៌រួចផុត)ដោយពឹងតែទៅលើព្រះអង្គឯង ។

២- ធម៌ ក្នុងព្រះពុទ្ធសាសនា មានស្តីពី ព្រះនិព្វាន ដែលមានន័យខុសពីនិព្វានរបស់សាសនាឯទៀតនៃសម័យនោះ ។ ដូច្នេះនិយមន័យថ្មីរបស់ពាក្យ **និព្វាន** តាមព្រះពុទ្ធសាសនា ព្រមទាំងផ្លូវបដិបត្តិដើម្បីបានសម្រេចនិព្វាន តើចេញមកពីណា ? អ្នកណាជាអ្នកបង្កើត ?

៣- ប្រសិនបើជាមិនមែនជានិយមន័យតាមព្រះពុទ្ធសាសនា ហើយជានិយមន័យរបស់សាសនាដទៃដែលមាននៅពេលនោះ ម្តេចក៏អ្នកបួសក្នុងសាសនាដទៃនោះមិនតវ៉ានៅពេលដែលព្រះអង្គប្រើពាក្យ និព្វាន ព្រមទាំងផ្លូវនាំទៅនិព្វាន គឺ អរិយសច្ចៈ ៤ ?

៤- ប្រសិនបើជាឆ្លើយនូវសំណួរខាងលើនេះមិនរួចទេ នោះយើងអាចសន្និដ្ឋាន ថា ៖ ពាក្យនិព្វានក្នុងព្រះពុទ្ធសាសនា ព្រមទាំង **អរិយសច្ចៈ ៤** គឺចេញមកពីព្រះពុទ្ធពិត ។

បើព្រះពុទ្ធ រកឃើញ អរិយសច្ចៈ ៤ បានន័យថា អ្នកដែលបង្កើត អរិយសច្ចៈ ៤ ពិតជាកើតនៅស្ថានមនុស្សលោកយើងនេះ កាលពីជាង ២៥០០ឆ្នាំមុន ។

មនសិការរបស់ព្រះអង្គដើម្បីជួយសត្វលោក មិនមែនទើបតែជាតិចុងក្រោយនេះទេ ប្រសិនបើជាព្រះអង្គចង់សម្រេចព្រះនិព្វាននោះព្រះអង្គអាចសម្រេចអរហត្តផលបានតាំងពីកាលសម័យ ព្រះពុទ្ធព្រះនាម **ទីបង្ករ** ម៉្លេះ។ តែដោយព្រះអង្គចង់ប្រោសសត្វលោកនេះហើយ បានជាកាលសម័យព្រះពុទ្ធ **ទីបង្ករ** ព្រះអង្គមានកំណើតជាព្រាហ្មណ៍នាម **សុមេធបណ្ឌិត** បានខំកសាងបារមីចំនួន បួនអសង្ខេយ្យនិងមួយសែនកប្បថែមទៀត ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធនៃយើងសព្វថ្ងៃនេះ ។ មកដល់ត្រង់នេះយើងឃើញថា សូម្បីតែ សាសនាព្រះពុទ្ធក៏មិនទៀងដែរ ថ្វីបើធម៌របស់ព្រះពុទ្ធជាសច្ចធម៌ មិនផ្លាស់ប្តូរទៅតាមកាលក៏ដោយ។ ពីព្រោះថា បើសាសនាព្រះពុទ្ធ **ទីបង្ករ**ទៀងនោះ ធម៌ដែលព្រះអង្គបានត្រាស់ដឹងនោះ ក៏នឹងនៅរហូតដល់ព្រះពុទ្ធ **គោតម** យើងទៅហើយ ។ តែព្រោះតែធម៌នោះវិនាសសាបសូន្យហើយបានជាព្រះពុទ្ធយើងទ្រង់ខំរក ធ្វើទុក្ករកិរិយាទំរាំបានត្រាស់ដឹង។ យើងសួរថា ហេតុអ្វីបានជាត្រូវដឹងគុណព្រះ ? ពីព្រោះព្រះអង្គ ទ្រង់ធ្វើពលិកម្មគ្រប់បែបយ៉ាងនេះ គឺដើម្បីខ្លួនព្រះអង្គទេតើ ? ការសួរយ៉ាងនេះមិនខុសទេ បើយើងប្រដូចមកខ្លួនយើងម្នាក់ៗ ដែលខំរៀនសូត្រ ដោយធ្វើពលិកម្មគ្រប់បែបយ៉ាង ព្រោះដើម្បីថ្ងៃមុខមានអនាគតល្អ ។ តែចំពោះព្រះពុទ្ធ មានចេតនា ខុសពីយើងតាំងពីដើមមក ដូចខ្ញុំបានជំរាបខាងលើរួចមកហើយ ថាព្រះអង្គ អាចសម្រេចនិព្វានបាន តាំងពីព្រះពុទ្ធទីបង្ករ ម៉្លេះ។ តែយើងអាចសួរថា តើមានអ្វីជាភស្តុតាង។ ឆ្លើយថា ភស្តុតាងគឺនៅពេលដែលព្រះអង្គសម្រេចព្រះទ័យចេញចាកពីវាំង សព្វព្រះទ័យប្តូរ ការរស់នៅដោយសុខសប្បាយជួបជុំគ្រួសារនិងបុត្រដែលទើបនឹងប្រសូត មករស់នៅក្នុងព្រៃវិញ ហាលភ្លៀងហាលខ្យល់។ លុះព្រះអង្គបានត្រាស់ដឹងហើយ **មារ**ចិត្តបាប បាននិមន្ត

ព្រះអង្គឲ្យចូលនិព្វាន តែព្រះអង្គមិនព្រមចូល ពីព្រោះព្រះអង្គចង់នៅប្រោសសត្វលោក ដោយយកធម៌ព្រះអង្គទៅទូន្មាន ចំនួន៤៥ វស្សា ទាំងថ្ងៃទាំងយប់ ទុកពេលសម្រាក តែបន្តិចបន្តួច ។ បើព្រះអង្គ ចង់បានសុខតែត្រឹមព្រះអង្គឯង ឬ ត្រឹមតែគ្រួសារព្រះ រាជវង្សព្រះអង្គ នោះព្រះអង្គ មិនខំនិមន្តទៅពន្យល់រហូតដល់ដង្ហើមចុងក្រោយនោះទេ ។ ការដឹងគុណព្រះអង្គ បានប្រយោជន៍មកយើង មិនមែនបានប្រយោជន៍ ដល់ព្រះអង្គ ឬ ដល់ញាតិវង្សព្រះអង្គឡើយ ពីព្រោះព្រះអង្គ ព្រមទាំងញាតិវង្សខ្លះ បានសម្រេចនិព្វាន រួចទៅហើយ អស់ត្រូវការគុណបំណាច់ ឬ កិត្តិយស អ្វីទៀតឡើយ។

ពាក្យថាដឹងគុណព្រះពុទ្ធ គឺ ទទួលស្គាល់ គុណធម៌របស់ព្រះអង្គកាលព្រះអង្គគង់នៅ លើលោកយើងនេះនៅឡើយ បើនិយាយអំពីគុណសម្បត្តិព្រះអង្គ ដូចជាព្រះអង្គជា ព្រះអរហន្ត ឆ្ងាយចាកកិលេស គឺគ្រឿងសៅហ្មង តាំងពីកិលេសគ្រោតគ្រាត រហូតដល់ កិលេសដែលល្អិតសុខុមដេកត្រាំក្នុងសន្តាន បីដូចជាធូលីដែលតោងលើស្បែក ហើយក៏ ក្លាយទៅជាក្អែល ទាល់តែង្ងូតទឹកដុះលាងស្បែក ទើបអស់ធូលីនោះ ។

បើនិយាយពីគុណបំណាច់វិញ ដូចជាព្រះអង្គចែកធម៌ព្រះអង្គ ទុកដូចជាកេរមរតក មកឲ្យយើងរហូតដល់សព្វថ្ងៃនេះ ។ ពីព្រោះធម៌ព្រះអង្គ បង្ហាញផ្លូវដែលយើងគប្បីដើរ ដើម្បីបានសេចក្តីសុខ។ កេរមរតកនេះមានតម្លៃ ជាង លុយកាក់មាសប្រាក់ផ្ទះសំបែង ដែលឪពុកម្តាយចែកឲ្យយើងទៅទៀត ពីព្រោះយើងចំណាយប្រាក់កាសសព្វថ្ងៃ ក៏ដើម្បី បានសេចក្តីសុខដែរ ។

ខ្ញុំបានអានសៀវភៅអប់រំ ជាភាសាបរទេសខ្លះ គេសរសេរថាបើយើងស្រឡាញ់ ឬ ចង់ បានកាយវិការ សំដីសំដៅ ចរិយា ឬចិត្តគំនិតដូចអ្នកណាមួយ នោះគេឲ្យយើងយកអ្នក នោះធ្វើជាគំរូ យើងថតទុកក្នុងចិត្តយើង នូវចិត្តគំនិតពាក្យសំដីកាយវិការរបស់អ្នកនោះ។ យើងធ្លាប់ឃើញហើយ មានអ្នកខ្លះដោយស្រឡាញ់អ្នកចម្រៀងល្បីៗណាមួយ ក៏ខំស្លៀក

*ពាក់ខោអាវ ធ្វើឫកពា ធ្វើសម្លេងច្រៀងឲ្យដូចអ្នកចម្រៀងនោះ។ ចុះបើយើងឃើញថា ព្រះពុទ្ធ ព្រះអង្គមានគុណធម៌ដែលយើងចង់បាន នោះយើងយកព្រះអង្គជាគ្រូ ជាគំរូ នៃយើង ហើយនៅពេលមានបញ្ហាណាមួយចោទឡើង យើងនឹកទៅគុណធម៌នោះៗ ។ ឧបមា មាន បញ្ហា ឬ ការចោទសួរម្តងៗ យើងនឹកថា បើព្រះពុទ្ធ ព្រះអង្គនឹងដោះស្រាយ តាមរបៀបនេះ ។ នេះហើយដែលថា យើងនឹកគុណព្រះពុទ្ធ ដោយយើងលើកព្រះអង្គ ជាគំរូ ។ ដោយធម៌ព្រះ នាំយើងទៅរកសេចក្តីសុខ ដូច្នេះការបដិបត្តិធម៌ព្រះ ឬ ការនឹក គុណព្រះនឹងនាំយើងទៅរកសេចក្តីសុខ។ តែត្រូវប្រយ័ត្នដែរ ថ្វីបើធម៌ព្រះមានតែមួយ ការបកស្រាយអាចមានច្រើន ហើយមិនដូចគ្នា[1]ក៏មាន ។ មនុស្សយើងគ្រប់រូប ទាំងយើង ទាំងគេ សុទ្ធតែចង់បាន សេចក្តីសុខ ។ សូម្បីតែសត្វតិរច្ឆាន ក៏វាចង់បានសេចក្តីសុខដែរ ! ហើយភ័យខ្លាច កាលណាវាឃើញទុក្ខ ឃើញសេចក្តីស្លាប់ជិតមកដល់ ។ ដូច្នេះ បើយើង យកវាជាអាហារ មុននឹងសម្លាប់ កុំធ្វើបាបវាពេក រហូតដល់យកវាទៅស្ងោរទាំងរស់ ដូចជាការស្ងោរអណ្តើក ឬ ស្ងោរបង្កងទាំងរស់ជាដើម ។*

[1] *សូមមើល កាលាមក្សត្រិយ៍ នៅក្នុង បិដកលេខ៤១ ទំព័រ ២១៦ មាននៅ* site internet [www.btkhmer.com](http://www.btkhmer.com) *ផ្នែក* **ជាតាសាខ្មែរ** ។

# ២

# សេចក្តីស្ងប់ និង សតិ

## 1- សេចក្តីស្ងប់

*ពាក្យស្ងប់ សំដៅ សេចក្តីស្ងប់ក្នុងខ្លួនយើង និងសេចក្តីស្ងប់ក្រៅខ្លួនយើង។ សេចក្តីស្ងប់ ក្នុងខ្លួនយើងម្នាក់ៗ គឺ ចិត្តយើងស្ងប់ ហើយសេចក្តីស្ងប់ក្រៅខ្លួនយើង គឺស្ងប់បានដោយសារអ្នកដទៃ ដែលគេមិនមករំខានយើង ដូចជាស្ងប់ដោយគ្មានឮសំឡេងជាដើម ។ សេចក្តីស្ងប់ទាំងពីរនេះ មានប្រយោជន៍ដូចគ្នា តែចំពោះយើង មានតែសេចក្តីស្ងប់ចិត្តទេ ដែលយើងអាចធ្វើឲ្យកាន់តែចំរើនឡើងបាន។ ព្រះពុទ្ធទ្រង់មានបន្ទូលថា* **មិនមានសុខ អ្វី ស្មើនឹងសេចក្តីស្ងប់**។ *ក្នុងការប្រកបការងារ បើចិត្តយើងស្ងប់ អារម្មណ៍យើងក៏មូលតែទៅលើការងារនោះ ហាក់ដូចជាចិត្តហើយនឹងការងារ រលាយចូលគ្នាតែម្តង ភ្លេចអស់អ្វីៗដែលនៅជុំវិញខ្លួនយើង នៅពេលនោះ តាមការពិសោធន៍របស់ខ្ញុំ ការងារនោះនឹងធ្វើបានល្អ ហើយប្រើពេលតិចទៀតផង។ នេះហើយប្រយោជន៍នៃសេចក្តីស្ងប់ ។ យើងសួរថា តើត្រូវធ្វើដូចម្តេចដើម្បី នឹងបានសេចក្តីស្ងប់ ? របៀបមួយ គឺ ត្រូវបំបាត់ហេតុ ដែលធ្វើឲ្យចិត្តមិនស្ងប់ ។ ឧបមា បើមានបញ្ហាដែលដោះស្រាយមិនទាន់ទាំងរួចផង ហើយយើងយកកិច្ចការថ្មីមួយទៀតមកធ្វើ បើធ្វើរបៀបនេះ នៅពេលដែលកំពុងធ្វើកិច្ចការថ្មីនោះ អារម្មណ៍យើងមិនបានមូលទេ ព្រោះជួនកាលយើងនឹកទៅរកបញ្ហាចាស់នោះ។ ដូច្នេះមានតែធ្វើគម្រោងចែកការ ដោយសម្រេចថា រវាងបញ្ហាដែលពុំទាន់ដោះស្រាយរួច និង កិច្ចការដែលកំពុងធ្វើ តើធ្វើការណាមុន ? បើសម្រេចថា ត្រូវធ្វើកិច្ចការដែលកំពុងធ្វើនេះមុន យើងត្រូវប្រមូលអារម្មណ៍ ផ្ចង់ស្មារតី តែទៅលើកិច្ចការនោះ ។ ប្រសិនបើជាមានពេលខ្លះ យើងភ្លេចខ្លួននឹកទៅរកការដោះស្រាយបញ្ហាចាស់វិញ បើ*

មានសតិចាប់ដឹងទាន់ ត្រូវទាញអារម្មណ៍មករកកិច្ចការដែលយើងកំពុងធ្វើនោះវិញ ។ រួមសេចក្ដីទៅ ដើម្បីឲ្យចិត្តមូលទៅលើ អារម្មណ៍តែមួយ យើងត្រូវមានសតិ គឺការប្រុងប្រយ័ត្នមិនឲ្យភ្លេច ។ ដើម្បី ចំរើននូវការប្រុងប្រយ័ត្ន ក្នុងព្រះពុទ្ធសាសនាមាន **សមាធិ** ដូចជា **អានាបានស្សតិ** ឬ **សមថវិបស្សនា** ជាដើម ។

**2-** <u>សតិ</u>

សតិ គឺ ការប្រុងប្រយ័ត្នមិនឲ្យភ្លេច យើងប្រើសតិតាំងតែពីនៅរៀនសាលាបឋមសិក្សាម៉្លេះ កាលណាយើងភ្លេចខ្លួន នឹកគិតលន្ទង់លន្ទោចទៅរឿងអ្វីមួយ ដល់លោកគ្រូមើលឃើញទឹកមុខយើង គាត់ស្ដីឲ្យយើង។ រហូតមកដល់សព្វថ្ងៃនេះទៀត ថ្វីបើមានអាយុច្រើនហើយក៏ដោយ ក៏នៅតែមានពេលខ្លះភ្លេចខ្លួន យើងគិតទៅរឿង ដែលមិនគួរគិតក៏មាន ហើយទំរាំនឹងដឹង នោះខាតពេល អស់មួយសន្ទុះធំ ។ នេះមកពីនៅពេល <u>ចាប់ផ្ដើមគិតនោះ</u> យើងមិនមានសតិដឹងទាន់។ ការអត់សតិ អាចនាំឲ្យយើងមានគ្រោះថ្នាក់ ដូចជាគ្រោះថ្នាក់ចរាចរណ៍ជាដើម អាចឲ្យយើងបាបក៏បាន បើនៅពេលនោះយើងគិតទៅអ្វីដែលជាអកុសល ដូចជាការខឹងនឹងគេជាដើម ។ បើយើងមានសតិដឹងទាន់ កំហឹង ដែលជាអកុសល ក៏នឹងគេចបាត់ ទុកកន្លែងឲ្យកុសល មកតាំងនៅម្ដងពីព្រោះ សតិជាកុសល ។ កុសល និង អកុសល មិនអាចនៅជាមួយគ្នាបានទេ។ ដូចយើងធ្លាប់ឃើញស្រាប់ហើយ បើអ្នកណាមួយកំពុងតែខឹងនោះ មុខឡើងក្រហម ហើយជាមួយគ្នានោះ អ្នកនោះសើចមិនរួចទេ ពីព្រោះការសើចសប្បាយ ជាសោមនស្សវេទនា ហើយ កំហឹង ជា ទោមនស្សវេទនា ហើយវេទនាទាំងពីរនេះ នៅជាមួយគ្នាមិនបានទេ ពីព្រោះវាជា សត្រូវនឹងគ្នា ។

<u>ដើម្បីយល់ពាក្យសតិ ខ្ញុំសូមលើកជាសំណួរដូចតទៅ ៖</u>

សតិសម្រាប់តែ ដឹងទាន់ នូវព្រឹត្តិការណ៍អ្វីមួយដែលកើតឡើងតែប៉ុណ្ណោះ ។ តែព្រឹត្តិ

ការណ៍ទាំងនោះ មិនមែនយើងទេដែលជាអ្នកបង្កើត គឺវាកើតឡើងដោយខ្លួនវា ដូចជាភ្លើងឆេះផ្ទះ បើយើងឆាប់ដឹងទាន់ នោះយើងអាចពន្លត់ភ្លើងនោះបានមុននឹងវារាលដាលឆេះអស់ផ្ទះទាំងមូល ។ ចំពោះយើង ដែលមានតែកាយនិងចិត្ត ព្រឹត្តិការណ៍ទាំងអស់ក្នុងខ្លួនយើង គឺចេញតែពីកាយនិងចិត្តទាំងអស់  ដូចជា ចិត្តខឹង (ទោសៈ) ជាដើម ។ យើងដកដង្ហើម ទាំងយប់ទាំងថ្ងៃ អត់មានពេលឈប់ឈរឡើយ តើយើងដឹង ថាយើង កំពុងតែដកដង្ហើមទេ ? តាមធម្មតាយើងមិនដែលនឹកឃើញថាយើងកំពុងតែដកដង្ហើមចេញចូលទេ ថ្វីបើដង្ហើមចេញចូលមានគ្រប់នាទីឬ វិនាទី ។

កាលណាយើងមិនដឹង នោះបានន័យថានៅពេលនោះយើងមិនមានសតិជាប់នឹងដង្ហើមចេញចូលទេ តែមិនមែនមានន័យថា យើងគ្មានសតិសោះក៏ទេដែរ គឺយើងអាចមានសតិជាប់នឹងកិច្ចការដែលយើងកំពុងតែធ្វើ ក៏មាន។ កាលណាដកដង្ហើមចេញយើងដឹង ហើយកាលណាដកដង្ហើមចូលយើងដឹង  នោះគេថា យើងមានសតិជាប់នឹងដង្ហើមចេញ និង ដង្ហើមចូល ។ ដើម្បីដឹងបាន ទាល់តែចិត្តយើងផ្តោតតែទៅលើអារម្មណ៍តែមួយគឺដង្ហើមចេញនិងដង្ហើមចូល ចិត្តដែលប្រុងប្រយ័ត្នរបៀបនេះហៅថាសតិ ។

<u>មធ្យោបាយខ្លះ ដើម្បីបានសេចក្តីស្ងប់</u>

ដើម្បីបាន សេចក្តីស្ងប់  យើងគួរសង្កេតមើលនូវហេតុដែលនាំឲ្យចិត្តយើង <u>មិនស្ងប់</u> ដូចជានៅពេលយើងប្រកបការងារអ្វីមួយ ។ យើងម្នាក់ៗ ដើម្បីចិញ្ចឹមជីវិត  សុទ្ធតែធ្លាប់ធ្វើការងារអ្វីមួយជានិច្ច  ដូច្នេះយើងអាចពិចារណារកហេតុផលនៅពេលណាដែលចិត្តយើងមិនស្ងប់ នៅពេលកំពុងធ្វើការងារនោះ។  ហេតុអាចមានច្រើន ខ្ញុំសូមជូនហេតុមួយដែលខ្ញុំបានសង្កេតឃើញចំពោះអ្នកដទៃ ៖

១-  គិតមួយរយ (១០០) ជំពូក ក្នុងពេលតែមួយ  ឬ ធ្វើការ មួយរយ (១០០) មុខក្នុងពេលតែមួយ   បានន័យថា ម្តងគិតទៅការនេះ ម្តងគិតទៅការនោះ  ដល់សម្រេចទៅ

គ្មានការណាមួយគិតបានដិតដល់ ហើយបើធ្វើកិច្ចការវិញ គឺ កំពុងតែធ្វើ មានអ្នកនេះទូរស័ព្ទមក ឬ មានកូនចៅនៅក្រោមបង្គាប់ មកសួរយោបល់ដោយមិនហ៊ានសម្រេចដោយខ្លួនឯងឬឲ្យជួយដោះស្រាយចំណោទដែលជាបន្ទាន់...... ។ល។

របៀបដោះស្រាយមានជានិច្ច ឲ្យតែយើងចង់ដោះស្រាយ ។ របៀបមួយគឺត្រូវមាន តារាងចែកពេលវេលា (emploi du temps ) ចែកកិច្ចការទាំងពួងទៅតាមថ្ងៃ ដើម្បីកុំឲ្យកិច្ចការពីរជាន់គ្នា នៅថ្ងៃតែមួយ ។ បើក្នុងថ្ងៃតែមួយ មានកិច្ចការពីរ ឧបមា ធ្វើការផង ទទួលភ្ញៀវផងនោះត្រូវចែក ពេលណាធ្វើការ ពេលណាទទួលភ្ញៀវ ។ បើយើងធ្វើជាចៅហ្វាយគេ ត្រូវចេះចាត់ចែងឲ្យមាន ចៅហ្វាយរង ដែលទទួលបញ្ជាផ្ទាល់ពីយើងជាចៅហ្វាយ ហើយចៅហ្វាយរងនេះ មានកូនចៅធ្វើការជាមួយ បើអ្នកនោះមានសំណួរ ឬចំណោទផ្សេងៗនោះ គេអាចសួរទៅចៅហ្វាយផ្ទាល់របស់គេ មិនចាំបាច់មកសួរដល់យើង។ តែក៏មានចៅហ្វាយធំខ្លះ ចង់ក្ដាប់អំណាច មិនចង់ឲ្យមានអ្នកជំនួយផ្ទាល់ នោះកុំថ្ងូរថា កិច្ចការច្រើនឡើងវិលមុខ ។ កំហុសមកពីយើង គេមានមនុស្សឲ្យប្រើ មិនចេះប្រើ ។ កុំចេះតែបន្ទោសគេ ចូរមើលកំហុសខ្លួនឯងផង បើចង់បានសេចក្ដីសុខសប្បាយ ទាំងអស់គ្នា នៅក្នុងគ្រួសារក្ដី នៅក្នុងសង្គមការងារ ឬនៅក្នុងប្រទេសជាតិទាំងមូលក្ដី ។

ចំពោះ **សតិ** យើងអាចសួរថា « តើនៅពេលណា ដែលថាយើងខ្វះសតិ ? » ។ តាមការពិសោធន៍ ខ្ញុំថា នៅពេលណាដែលយើងធ្វើឲ្យខូចការអ្វីមួយ ដោយអចេតនា ឬដោយ មិនដឹងខ្លួន ។ ដូចជាយើងដើរទៅជាន់អាចម៍ឆ្កែជាដើម ពីព្រោះយើងសុទ្ធតែចង់ចៀសអាចម៍ឆ្កែ បើយើងត្រឡប់ជាទៅជាន់វិញ មកពីយើងខ្វះសតិ មើលវាមិនឃើញ ។ ពីព្រោះថាបើយើងមានសតិដឹងទាន់ មុនពេលជាន់អាចម៍ឆ្កែ នោះដោយដឹងថាជាអាចម៍ឆ្កែហើយ ម៉្លេះយើងមិនទៅជាន់វា នាំឲ្យប្រឡាក់ជើងនោះទេ ។ អ្នកខ្លះគេថាមកពីកម្មផល ពីអតីត បានជាទៅជាន់អាចម៍យ៉ាងនេះ ។ ខ្ញុំយល់ថា បើយើងប្រយ័ត្នហើយ

នៅតែដើរជាន់វាទៀត នោះប្រហែលជាកម្មផលពីអតីតមែន ។

មនុស្សយើងម្នាក់ៗ មិនចង់បានបាបទេ ចង់តែបានបុណ្យ ពីព្រោះបុណ្យ នាំមកឲ្យយើងនូវសេចក្តីសុខសប្បាយ ទៅថ្ងៃមុខ ទៅជាតិមុខ ។ បាបនិងបុណ្យ ចូលតាមទ្វារទាំងប្រាំមួយ របស់យើង គឺ ៖ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។ ដូច្នេះ យើងត្រូវមានសតិដឹងគ្រប់កាល ដឹងថា « **ធម៌អ្វីដែលកើតឡើងហ្នឹង** »។ ធម៌បច្ចុប្បន្នយើងត្រូវឃើញ តែមិនឃើញទាន់ទេ ធម៌នោះទៅជាធម៌ អតីត ដែលជាហេតុ ឲ្យកើតធម៌ផ្សេងទៀត ។ ដូចជា បើ លោភៈ មានបច្ច័យហើយ លោភៈនោះក៏កើតឡើង ដូច្នេះត្រូវកំនត់ដឹងបច្ច័យនោះ (ធម៌នោះ) ដើម្បីកុំឲ្យលោភៈកើតបាន ។

ចំពោះ ទោសៈ ក៏ដូចគ្នា បើយើងដឹងទាន់ថាគេកំពុងតែនិយាយឲ្យយើងខឹង ធម៌ដែលជាបច្ច័យឲ្យយើងខឹងនោះ គឺ « ពាក្យសំដីដែលគេកំពុងតែនិយាយ » ជាធម៌ចូលតាមទ្វារត្រចៀក ហើយអាចជាបច្ច័យ ឲ្យកើតទោសៈ។ តែបើយើងឃើញធម៌នោះក្នុងពេលបច្ចុប្បន្នទាន់ ធម៌នោះ មិនអាចជាបច្ច័យ ឲ្យទោសៈ កើតឡើងបានទេ ។

ចំពោះ សេចក្តីនេះ លោកអ្នកអាចយកទៅធ្វើការពិសោធន៍ ដោយខ្លួនលោកអ្នកបាន ។

រួមសេចក្តីទៅ យើងឃើញថា **សតិ** មានប្រយោជន៍ខ្លាំងណាស់ ចំពោះយើង ។ ធម៌ព្រះពុទ្ធ ដូចជា សតិបដ្ឋានបួន ជាដើម ក៏ស្ថិតពី សតិ នេះដែរ ។

# ៣

# បុណ្យ និង បាប

**បុណ្យ** គឺអំពើល្អ អំពើកុសល **បាប** គឺអំពើអាក្រក់ អំពើអកុសល ។

ក្នុងធម៌ គេប្រើ ពាក្យ **កម្ម** ជំនួសពាក្យ អំពើ ដូចជាពាក្យថា កម្មចាស់ គឺកម្មពីអតីតកាល ឬ ពីជាតិមុន កម្មថ្មី គឺកម្ម បច្ចុប្បន្ន។ ដូច្នេះ អត់មានកម្មអនាគតទេ ពីព្រោះមិនទាន់បានធ្វើផង ម្តេចនឹងមានកម្មទៅកើត ។

ចំពោះមនុស្សយើងម្នាក់ៗ យើងអាចធ្វើកម្ម ដោយកាយ ហៅថា **កាយកម្ម** ដោយវាចា ហៅថា **វចីកម្ម** និងដោយចិត្ត ហៅថា **មនោកម្ម** ។

កម្មដែលអ្នកដទៃមើលមិនឃើញ ហើយមានតែអ្នកដែលធ្វើកម្មនោះទេដែលដឹង គឺកម្មដោយចិត្ត ។ តើកម្មដោយចិត្ត ធ្វើ ដោយរបៀបណា ? លក្ខណរបស់ចិត្ត គឺដឹង អារម្មណ៍ ហើយអារម្មណ៍មាន រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ (ការប៉ះខ្ទប់កាយទៅនឹងវត្ថុផ្សេងៗ ) និង ធម្មារម្មណ៍ (គឺអារម្មណ៍ចាស់ដែលចិត្តធ្លាប់សោយ ហើយនឹកទៅរកអារម្មណ៍នោះម្តងទៀត )។ កាលណាភ្នែកឃើញរូប ចិត្តកើតឡើង អាចពេញចិត្ត ឬ មិនពេញចិត្តនឹងរូបនោះ ពោលគឺកើត សេចក្តីស្រឡាញ់ ឬ ស្អប់ ឬ មិនស្រឡាញ់ មិនស្អប់ ។ បើស្រឡាញ់ អាចកើតតណ្ហា មានការចង់បាន រហូតដល់មាន លោភៈ បើស្អប់ អាចកើតចិត្តមួម៉ៅ ចិត្តទោសៈ ជាដើម ។ យើងអាចមិនធ្វើបាប ដោយកាយ ដោយវាចាបាន តែដោយចិត្តពិបាកនឹងថាណាស់ ពីព្រោះ កាលណាយើងនឹកគិតទៅអ្វីមួយជា <u>អកុសល</u> នឹកខឹងនឹងអ្នកណាមួយ ដែលធ្វើឲ្យយើងខូចប្រយោជន៍ នៅពេលនោះចិត្តក៏ខឹងឡើង ហើយគិតរកមធ្យោបាយ នឹងសងសឹកអ្នកនោះ ។ ការគិតសងសឹកនេះ គឺមនោកម្ម ជាអំពើអកុសល ដូច្នេះជាបាប ។ ដោយ បុណ្យនិងបាប ច្រើន

តែយល់មិនដូចគ្នា យើងថាល្អ គេថាអាក្រក់ យើងថាអាក្រក់ គេថាល្អ តើត្រូវយកអ្វីជាគ្រឿងកំណត់ ជាគ្រឿងសំរាប់វាស់ ឲ្យដឹងថា ណាល្អ ណាអាក្រក់? ឆ្លើយថា យកលទ្ធផលរបស់វា ជាគ្រឿងកំណត់ ជាគ្រឿងសំរាប់វាស់ ។

យកលទ្ធផលបានន័យថា

- អំពើណាឲ្យ សេចក្តីសុខដល់ខ្លួនឯងផង និងដល់ អ្នកដទៃផង អំពើនោះ ជា បុណ្យ ។
- អំពើណាឲ្យសុខដល់អ្នកដទៃ តែឲ្យទុក្ខដល់ខ្លួនឯងនៅពេលដំបូង បន្ទាប់មកក៏ឲ្យសុខរហូត អំពើនោះក៏ជាបុណ្យដែរ ។
- អំពើណាឲ្យ ទុក្ខដល់ខ្លួនឯង ឬ ឲ្យទុក្ខដល់ អ្នកដទៃ អំពើនោះជា បាប ។
- អំពើណាឲ្យ ទុក្ខដល់ខ្លួនឯងផង និងដល់អ្នកដទៃផង អំពើនោះរឹតតែជា បាប ។
- អំពើណាឲ្យ សុខដល់ខ្លួនឯង តែឲ្យទុក្ខដល់អ្នកដទៃ អំពើនោះជា បាប ។
- អំពើណា មិនទាន់ឲ្យទុក្ខ ក្នុងបច្ចុប្បន្ននេះទេ តែនឹងឲ្យទុក្ខនៅពេលខាងមុខ ឬ នៅជាតិខាងមុខតៗទៅ អំពើនោះក៏ជា បាប ដែរ ។

តាមការយល់ឃើញរបស់ខ្ញុំ យកលទ្ធផលរបស់កម្មជាខ្នាត ជាការជាក់ស្តែងជាងគេ។ ពីព្រោះបាបនិងបុណ្យ យើងមើលមិនឃើញទេ គេថាចុះនរក យមបាលបោះចូលក្នុងខ្ទះស្ពោតស្លោរទាំងរស់ យើងគ្រាន់តែឮ តែមិនដែលឃើញទេ តែចំពោះអ្នកធ្វើអំពើអាក្រក់ ធ្វើឲ្យអ្នកដទៃរងទុក្ខវេទនា ព្រោះតែអំពើអាក្រក់នោះ យើងធ្លាប់ឃើញ មិនត្រឹមតែបាបទេ អ្នកនោះអាចត្រូវទណ្ឌកម្មដោយច្បាប់រដ្ឋប្បវេណីទៀតផង។ ចំពោះអំពើអាក្រក់បែបនេះ បើមានអ្នកណាមួយគេថាអត់បាបទេ អ្នកឯងគ្រាន់តែសារភាពកំហុសនោះទៅ រួចខ្លួនទៅហើយ តើយើងជឿថាអត់បាបរួចខ្លួនដែរទេ? មុននឹងឆ្លើយថាយ៉ាងណា គប្បីយកបញ្ញាមកប្រើ តើអំពើនោះ ជាបាប ឬជាបុណ្យ?

បើអំពើណាមួយយើងយល់ថាជាបាប ហើយគេថាជាបុណ្យ តើអំពើនោះឲ្យលទ្ធផល

ជាបុណ្យតាមមាត់អ្នកនោះឬទេ? ការពិតនៅតែការពិតដដែល ហើយអ្នកទទួលផល គឺអ្នកដែលធ្វើ មិនមែនអ្នកអះអាងជានានោះទេ។ ដូច្នេះ **ខ្លួនទីពឹងខ្លួន** (នេះតាមពុទ្ធដីកា) យើងជឿតែអ្វីដែលគួរជឿ ដែលសមហេតុសមផល។

ឧទាហរណ៍មួយ ដែលថា ការយល់ បុណ្យនិងបាប មិនដូចគ្នា

លោក « ក » រើសបាន កញ្ចប់ប្រាក់មួយព្រមទាំងសំបុត្រអត្តសញ្ញាណ នៅតាមផ្លូវ។ ដោយគាត់ខ្លាចបាប គាត់មិនហ៊ានទុកកញ្ចប់ប្រាក់នោះទេ? ហើយគាត់សួរថាតើឲ្យគាត់ធ្វើដូចម្តេច?

- អ្នកមួយឆ្លើយថា ឲ្យយកទៅប្រគេនព្រះសង្ឃ។
- ម្នាក់ទៀតឆ្លើយថា ឲ្យយកទៅប្រគល់ឲ្យប៉ូលីសនៅស្នងការដ្ឋាន។

តាមខ្ញុំយល់ ហេតុដែលនាំឲ្យ បុណ្យ និង បាប យល់មិនដូចគ្នា មកពីយើងមិនហ៊ានទទួលការពិត។ ការពិតយ៉ាងណា? ការពិតគឺ « ***ទាំងយើងទាំងគេ សុទ្ធតែចង់បានសេចក្តីសុខទាំងអស់គ្នា*** » មិនដែលនរណា ចង់បានទុក្ខទេ (នេះជាច្បាប់ធម្មជាតិមួយដែរ) ហើយដែលហៅថា បាប គឺអំពើណា ដែលនាំមកនូវទុក្ខ ដល់ខ្លួនយើង ឬ នាំមកនូវទុក្ខដល់អ្នកដទៃ។ ឧបមា ធម៌ព្រះ ក្នុងសីល ៥ ថា « ផឹកស្រាបាប »។ ហេតុអ្វីក៏បាប ពីព្រោះកាលណាយើងផឹកស្រា យើងធ្វើបាបខ្លួនយើង ។ យើងធ្វើបាបខ្លួនយើង ដោយរបៀបណា? ពីព្រោះស្រា ដល់ផឹកច្រើនទៅវាអាចធ្វើឲ្យយើង រលាកក្រពះ ឬធ្វើទុក្ខថ្លើម ជាដើម។ ដូច្នេះ តើអ្នកណា ជាអ្នកឈឺ? គឺខ្លួនយើងនេះឯងដែលឈឺ មិនមែនមិត្តសំឡាញ់ មកឈឺជំនួសយើងទេ។ ហេតុនេះហើយបានជាថា « ផឹកស្រាបាប »។ ហើយ បាបនេះទៀត មិនមែនព្រះពុទ្ធ ឬ ព្រះអាទិទេពណា ឲ្យមកយើង ដោយដាក់ទណ្ឌកម្មនោះទេ។ គឺ កម្ម (អំពើ) របស់យើង ដែលវាឲ្យ បាប មកយើង។ ដូច្នេះ បុណ្យ ឬ បាប

មិនមែន ជារង្វាន់ ឬជា ទណ្ឌកម្ម ដែលព្រះពុទ្ធ ឲ្យមកយើងនោះទេ ។ ព្រះពុទ្ធគ្រាន់តែប្រាប់យើងថា បើយើងធ្វើបែបនេះ យើងនឹងបានបុណ្យ បើយើងធ្វើបែបនោះ យើងនឹងបានបាប ។ តែកុំភ្លេចថាយើងជាអ្នកធ្វើ មិនមែនព្រះពុទ្ធធ្វើជំនួសយើងទេ ។ មានអ្នកខ្លះនិយាយថា « ខ្ញុំឃើញ គេធ្វើបាប ធ្វើអំពើអាក្រក់ទៅលើអ្នកដទៃ យ៉ាងច្រើន ហើយគេនៅតែសុខសប្បាយ មានទ្រព្យសម្បត្តិកាន់តែច្រើនទៅៗ » ។ នេះជាការពិត ហើយ ខ្ញុំក៏ធ្លាប់បានឃើញដែរ ។ តែខ្ញុំសូមសួរថា៖ បើសិនជាយើងកំពុងតែរស់នៅ បានសុខសប្បាយស្រាប់តែមានអ្នកដទៃមកធ្វើឲ្យយើងកើតទុក្ខ ហើយបើមានទ្រឹស្តីណាមួយថា អំពើអ្នកដទៃនោះជា បុណ្យ តើយើងយល់ព្រមទេ ?

ខ្ញុំសូមឆ្លើយជំនួសថាយើងមិនសុខចិត្តទេ ។ ចុះហេតុអ្វី ក៏នៅមានអ្នកធ្វើបាបគេ ហើយនៅតែបានសុខសប្បាយ ? មកដល់សំណួរនេះ ខ្ញុំទាល់ហើយ ពីព្រោះទាក់ទងនឹងការជឿ ឬ មិនជឿរបស់យើងម្នាក់ៗ ឬក៏ថា គួរជឿ ឬមិនគួរជឿ របស់យើងម្នាក់ៗ ។ តាមទ្រឹស្តីព្រះពុទ្ធសាសនា កាលណាយើងនៅជា បុថុជ្ជន នៅឡើយ « យើងស្លាប់ទៅកើតទៀត » ។ ដោយយើងសព្វថ្ងៃនេះ ធ្វើបុណ្យផង ហើយក៏ធ្លាប់ធ្វើបាបដែរ ដូច្នេះគ្រប់តែជាតិដែលយើងកើត យើងតែងតែធ្វើ បុណ្យនិងបាប មិនខុសពីជាតិនេះប៉ុន្មានទេ ហើយបុណ្យនិងបាបដែលសន្សំពីអតីតជាតិទាំងអស់នេះហើយ ជាពិសេស គឺបុណ្យពីអតីតជាតិ ដែលធ្វើឲ្យមនុស្សធ្វើបាបគេ នៅតែបានសុខសប្បាយដដែល ។ តែបើជឿទៅលើកម្មផលនេះត្រូវឲ្យឆាប់ឈប់ធ្វើអំពើអាក្រក់ទៀតទៅ ពីព្រោះបើប្រាក់ដែលសន្សំអាចចាយវាយអស់ យ៉ាងណាបុណ្យដែលបានសន្សំទុកពីមុនមក ក៏អាចនឹងអស់យ៉ាងនោះដែរ។ ហើយតែអស់បុណ្យហើយ ទុក្ខក៏វាមកដល់ជាមួយគ្នាដែរ ។ ជាទូទៅ ការប្រើបញ្ញាជាការសំខាន់ណាស់ មានអ្នកខ្លះឈប់កាន់សាសនាព្រះពុទ្ធ ហើយទៅកាន់សាសនាដទៃ ដោយនិយាយថា សាសនាយើងព្រះមិនជួយដូចសាសនាគេដទៃទេ។ ពីព្រោះ

សាសនាគេ ព្រះគេជួយ គឺព្រះគេអាច ពិន័យ ឬ ឲ្យរង្វាន់ដល់អ្នកដែលកាន់សាសនារបស់គេនោះ។ តែជំនឿបែបនេះតាមខ្ញុំបានស្តាប់តាមទូរទស្សន៍ថា ពួកក្មេងៗជំនាន់ក្រោយនៃប្រទេសដែលកាន់សាសនានោះ ចាប់ឈប់ជឿហើយ។ ចំពោះខ្ញុំឥតមានអ្វីប្លែកទេ អ្នកណាធ្វើ គឺអ្នកនោះឯងជាអ្នកទទួលផល បើយើងខំរៀន គឺយើងជាអ្នកទទួលចំណេះ មិនដែលអត់ទាំងបានរៀនផង ហើយស្រាប់តែចេះដូចគេដែរ គ្រាន់តែទៅបន់ព្រះ នោះពុំសមទេ ។ ចុះហេតុអ្វី បានជាក្នុងកម្មវិធីបុណ្យ ច្រើនតែមានការទទួល សីល៥ ពីព្រះសង្ឃ ? ចម្លើយគឺ មុននឹងធ្វើបុណ្យ យើងត្រូវជម្រះចិត្តយើងឲ្យបានស្អាតបរិសុទ្ធ ជាមុនសិន ដើម្បីនឹងបានទទួល កុសលច្រើនពីបុណ្យដែលយើងនឹងធ្វើនោះ ។

# ៤

## សីល៥

*សីល៥ គឺ ការកាន់ចរិយាមារយាទល្អ ដោយកាយ ដោយវាចា ការមិនប្រព្រឹត្តកន្ទង់វិនយប្បញ្ញត្តិ ក្នុងព្រះពុទ្ធសាសនា ។ សីល៥ មាន ៖*

១- **បាណាតិបាតា វេរមណី** : *វៀរ[2] ចាកកិរិយាធ្វើសត្វមានជីវិត ឲ្យអស់ជីវិត គឺសម្លាប់សត្វ*

២- **អទិន្នាទានា វេរមណី** : *វៀរ ចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដោយកាយឬ ដោយវាចា*

៣- **កាមេសុ មិច្ឆាចារា វេរមណី** : *វៀរ ចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ*

៤- **មុសាវាទា វេរមណី** : *វៀរ ចាកកិរិយាពោលនូវពាក្យកុហក*

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** : *វៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺ សុរានិងមេរ័យ ។*

*ខ្ញុំសូមធ្វើការអធិប្បាយ ដូចតទៅ ៖*

*សីលទាំង ៥ មានមុខងារខុសៗគ្នាពិតមែន តែក៏ជាប់ទាក់ទងគ្នាដែរក្នុងការរស់នៅ ដើម្បីឲ្យបានសេចក្តីសុខដល់ខ្លួនយើងផង និងសេចក្តីសុខដល់អ្នកដទៃផង ហេតុនេះហើយបានជាមានពាក្យហៅសីល៥ ថាជានិច្ចសីល គឺសីលដែលគេកាន់ជានិច្ចកាល គឺរាល់ថ្ងៃ ។*

*- សីលទីមួយ វៀរចាកការសម្លាប់សត្វ មានន័យជ្រៅទូលំទូលាយណាស់ ថ្វីបើសីល*

---

[2] *តម ឈប់ អត់មិនធ្វើ*

ទូន្មាន តែចំពោះកាយកម្មនិងវចីកម្ម កិរិយាមិនសម្លាប់សត្វ បណ្ដុះចិត្តយើងឲ្យមានធម៌មេត្តាដល់សត្វលោកទាំងមូល គឺរាប់ទាំងមនុស្ស និង សត្វតិរច្ឆានផងដែរ ។ បើយើងគោរពជីវិតមនុស្សលោកទាំងអស់គ្នា នោះសង្គ្រាមរវាងប្រទេសនិងប្រទេសក៏គ្មាន ហើយសង្គ្រាមពិភពលោកក៏គ្មាន។ បើយើង គោរពជីវិតសត្វ ចិត្តយើងមិនអាចទៅជាឃោរឃៅបានដោយងាយឡើយ។ មានអ្នកខ្លះបំពានសីលទី១នេះ ដោយទាំងបង្ខំចិត្ត ពីព្រោះគ្មានមធ្យោបាយអ្វីផ្សេងដើម្បីចិញ្ចឹមជីវិត ។ ដូចជា អ្នកនេសាទខ្លះ ដល់ពេលគាត់ចាស់ គាត់ឈប់នេសាទ ហើយទៅវត្តកាន់សីលក៏មាន ដូចនៅក្នុងភូមិខ្ញុំ អ្នកប្រកប របរលីសែង ដល់ពេលគាត់ចាស់លីសែងលែងរួច គាត់ក៏ឈប់ទទួលទានស្រា ។ ចំពោះព្រះពុទ្ធសាសនា ដោយបានចែងយ៉ាងច្បាស់នូវ ការវៀរបាណាតិបាតនេះ អ្នកដែលថាខ្លួនធ្វើសង្គ្រាម ដើម្បីផ្សាយសាសនា ឬ ធ្វើឲ្យសាសនាកាន់តែរីកធំលើពិភពលោកនោះពុំអាចតាំងខ្លួនថាជាអ្នកបម្រើ ព្រះពុទ្ធសាសនាបានឡើយ។ ពីព្រោះធម៌ក្នុងព្រះពុទ្ធសាសនា គឺគោរព ជីវិតសត្វ ដូច្នេះមិនត្រូវសម្លាប់គេឯង ដើម្បីវាតយកទឹកដីហើយតែងតាំងសាសនាព្រះពុទ្ធនោះទេ ។ ប្រសិនបើជាមានអ្នកធ្វើនូវអំពើឃោរឃៅបែបនេះ គឺមិនមែនជាអ្នកកាន់ព្រះពុទ្ធសាសនាទេ មិនមែនជាអ្នកបម្រើព្រះពុទ្ធសាសនាទេ ផ្ទុយទៅវិញមានតែធ្វើឲ្យខូចឈ្មោះព្រះពុទ្ធសាសនា។

- សីលទីពីរ វៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដោយកាយឬដោយវាចា

មានអ្នកខ្លះ អត់ការងារធ្វើ ដោយគេបញ្ឈប់ មកពីបានលួចរបស់នៅកន្លែងធ្វើការ។ ពាក្យចាស់លោកថា លួចគេធ្លាប់ដៃ។ បើ ម្ចាស់គេដឹង គេផ្សាយចេញទៅក្រៅ តើអាម៉ាស់មុខយ៉ាងណាទៅ ។ ឯណាទៅសេចក្ដីសុខ ។

- សីលទីបី វៀរចាក កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ

តាមព្រះពុទ្ធសាសនា កាម ដូចជា កាមគុណ កាមតណ្ហា ជាប្រភពនៃទុក្ខទៅហើយ ហើយបើប្រព្រឹត្តខុសក្នុងកាមថែមទៀត នោះទុក្ខកាន់តែខ្លាំងទៅទៀត។ ការប្រព្រឹត្តិខុសក្នុងកាមនៅទីនេះ មានការលួច ប្តី ប្រពន្ធ កូនគេ ។ អំពើនេះ ធ្វើឲ្យមានការបែកបាក់គ្នាក្នុងគ្រួសារ ។ លុះឪពុកម្តាយបែកបាក់គ្នា កូនចៅក៏ទទួលការលំបាកផ្សេងៗ ព្រោះតែកំហុសអ្នកដទៃ ។ ម្យ៉ាងទៀត ឪពុកម្តាយដែលមានកូនត្រូវគេបំពានបំពារនឹងកើតទុក្ខក្រៀមក្រំ ។ អ្នកដែលធ្វើអំពើបែបនេះ គួរតែគិតដល់ចិត្តអ្នកដទៃផង យើងចង់សុខសប្បាយ គេក៏ចង់សុខសប្បាយដែរ ។

- សីលទីបួន វៀរចាកកិរិយាពោលនូវពាក្យកុហក

មនុស្សគេយកសំដី ដំរីគេយកភ្លុក។ មនុស្សនិយាយពាក្យមិនពិតច្រើនដង លុះគេឈប់ជឿនោះទៅជាខូចប្រយោជន៍ខ្លួនឯងវិញពីព្រោះថា លុះត្រឡប់មកនិយាយពិតវិញគេក៏នៅតែមិនជឿ ដោយហេតុមកពីទម្លាប់និយាយពាក្យមិនពិត ។ នៅក្នុងកម្មបថ ១០ វចីកម្មមាន៤ ហើយទាំង៤ នេះសុទ្ធតែមានប្រយោជន៍ទាំងអស់ក្នុងជីវិតរស់នៅរាល់ថ្ងៃ ។

- ដូចជាការ និយាយញុះញង់ ធ្វើឲ្យគេឈ្លោះគ្នា តើបានប្រយោជន៍អ្វីដល់អ្នកដែលញុះញង់គេនោះទេ? ថ្ងៃក្រោយលុះគេដឹងការពិត ចំណេញតែគេស្តីបន្ទោសអាប់កិត្តិយស។

- ការនិយាយ ពាក្យមិនពីរោះ យើងច្រើនតែនិយាយពាក្យមិនពីរោះនៅពេលយើងខឹង។ ដូច្នេះទាល់តែអប់រំ ចិត្តផង និង សំដីផង ។ ឃ្លាមួយដែលខ្ញុំឃើញក្នុងសៀវភៅធម៌ ហើយគួរចាំសម្រាប់ដាស់សតិយើងនោះ គឺ ៖

ពេលណាគេធ្វើអំពើអាក្រក់ដល់យើង ត្រូវជម្នះនូវការអាក់អន់ស្រពន់ចិត្តនោះចេញ ហើយពោលថា ៖

« ចិត្តរបស់អាត្មាអញមិនត្រូវមានការសៅហ្មងត្រឹមតែហេតុការណ៍នោះៗឡើយ ។ អាត្មាអញមិនអនុញ្ញាតឲ្យផរុសវាចាណាមួយ សូម្បីតែមួយម៉ាត់ ផុសចេញពី

បប្អូនម្នាក់ អាត្មាអញឡើយ » ។

បើពាក្យ ខាងលើនេះវែងពេក ពិបាកនឹងចាំ យើងអាចតែងជាឃ្លាដោយខ្លួនយើងក្នុងការ តាំងចិត្តនេះ ហើយយើងទន្ទេញឃ្លានោះឲ្យចាំ សម្រាប់**សតិ**យើងដឹងទាន់ កាលណា មានអាសន្ន ។ ដូចជាឃ្លាពីរខាងលើ មួយស្តីពី ការសៅហ្មងចិត្ត ហើយមួយទៀតអំពី ផរុសវាចា យើងអាចបង្រួញថា ៖

« ខ្ញុំមិនអនុញ្ញាតឲ្យ ទោសៈនេះ មកធ្វើឲ្យខូច ធម៌ខន្តី របស់ខ្ញុំ »

« ខ្ញុំមិនអនុញ្ញាតឲ្យ ផរុសវាចានេះ មកធ្វើឲ្យខូច សុវាចា របស់ខ្ញុំ » ជាដើម ។

យើងទន្ទេញ ឃ្លាទាំងនោះឲ្យចាំ ដូចទន្ទេញធម៌ ដើម្បីឲ្យការសម្រេចចិត្តនេះជ្រួតជ្រាប ក្នុងចិត្តយើង (បារាំងហៅថា autosuggestion គឺយើងធ្វើឲ្យកាន់តែជឿខ្លួនយើងនូវអ្វីមួយ ដែលយើងយល់ថាល្អ ថាត្រូវ ហើយយើងចង់បាន) ។

- ការនិយាយរោយរាយ និយាយពាក្យឥតប្រយោជន៍ យកជាការពិតពុំបាន។

- សីលទីប្រាំ វៀរ ចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺ សុរា និងមេរ័យ ក្នុងសីលទីប្រាំនេះ មានពាក្យពីរម៉ាត់ គឺ សេចក្តីប្រមាទ និងទឹកស្រវឹង ។ សេចក្តី**ប្រមាទ** គឺការធ្វេសប្រហែស ។ ពាក្យនេះមានន័យសំខាន់ណាស់ ពីព្រោះជា ពាក្យបណ្តាំចុងក្រោយរបស់ព្រះពុទ្ធ មុននឹងព្រះអង្គចូលនិព្វាន ។ ការធ្វេសប្រហែស នាំឲ្យទុក្ខ ដល់ខ្លួនឯងផង និងឲ្យទុក្ខដល់អ្នកដទៃផង ។ កាលខ្ញុំនៅរៀននៅឡើយ ផ្ទះខ្ញុំ នៅជិតរោងចក្រធ្វើប៉ោតប្រេងកាត ថ្ងៃមួយ មានអ្នកធ្វើការម្នាក់ដែលខ្ញុំស្គាល់ ត្រូវម៉ាស៊ីន កាត់ដែកប៉ោត វាកាត់ម្រាមដៃគាត់ស្ទើរតែគ្រប់ម្រាមទាំងអស់ ។ នេះហេតុមកពីការធ្វេស ប្រហែស តែមួយប៉ប្រិចភ្នែក ។ ផឹកទឹកស្រវឹងដូចសុរាជាដើម អាចឲ្យភ្លេចស្មារតី ធ្វើ ឲ្យមានការក្លាហានមិនស្គាល់គ្រោះថ្នាក់ រហូតដល់មានការធ្វេសប្រហែស ។ ដូចយើង ធ្លាប់ឮហើយ គ្រោះថ្នាក់ចរាចរភាគច្រើនមកពីអ្នកបើកបរ ផឹកស្រា។ ហើយពេលគ្រោះ

ថ្នាក់ម្តងៗ អ្នករង់គ្រោះ មានទាំងអ្នកបើក មានទាំងអ្នកជិះ និងជូនកាលបណ្តាលឲ្យ
រថយន្តផ្សេងទៀត ដែលបើកធម្មតាសោះ មករងគ្រោះជាមួយដែរ។

ពាក្យ **ប្រមាទ** គឺ ការធ្វេសប្រហែស មានន័យជ្រៅ មួយទៀត គឺការធ្វេសប្រហែសឲ្យ
ពេលវេលាកន្លងទៅ ដោយមិនបានធ្វើអំពើល្អ ព្រោះថាជីវិតមិនទៀង ។ អំពើល្អ គឺអំពើ
ជាកុសល ជាបុណ្យ ។ ដូចជាការឈឺឆ្អាលជួយអ្នកដទៃ ក៏ជាបុណ្យដែរ ការដឹកដៃមនុស្ស
ចាស់ឆ្លងផ្លូវ ក៏បានបុណ្យដែរ ដូច្នេះ បុណ្យមិនចាំបាច់មានប្រាក់កាសទើបធ្វើបុណ្យបាន
នោះទេ ។

ដើម្បី ឲ្យសីលយើងកាន់តែជាត់ជំ មិនស្ងាប់ យើងត្រូវមាន ការសង្រួមថែមទៀត ហៅថា
ឥន្ទ្រិយសំវរសីល គឺការសង្រួមឥន្ទ្រិយ មានទ្វារទាំងប្រាំមួយជាដើម គឺ ទ្វារ ( ភ្នែក
ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ) ។

រួមសេចក្តិទៅ ការប្រតិបត្តិ តាមសីល៥ មានប្រយោជន៍ច្រើនណាស់ អាចនាំមកនូវ
សេចក្តីសុខដល់ ខ្លួនយើងផង ដល់គ្រួសារយើងផង និងដល់អ្នកដទៃផង ។

បើមនុស្សលោកកាន់ សីល បាណា បានគ្រប់ៗគ្នា នោះមិនត្រឹមតែមនុស្សលោក
បានសេចក្តីសុខ ដោយគ្មានសង្គ្រាមប៉ុណ្ណោះទេ តែសត្វទាំងពួង ដូចជា សត្វស្វាប
ចាប ក្អែក សារិកាកែវ ជាដើម ក៏គ្នាបានសេចក្តីសុខដែរ ។

# ជីវិតរស់នៅក្នុងលោកយើងនេះ
# គួរឲ្យសង្វេគណាស់។

# ៥

## ហេតុអ្វី បានជា ជីវិតរស់នៅសព្វថ្ងៃ ជាទុក្ខ
## តាមព្រះពុទ្ធសាសនា

*មានអ្នកក្រខ្លះ និយាយថា មកពីក្របានជាខ្លួនមានទុក្ខលំបាកបែបនេះ តែដល់ឃើញអ្នកខ្លះមានទ្រព្យសម្បត្តិក៏មានទុក្ខដែរ រហូតដល់ទៅសម្លាប់ខ្លួនក៏មាន ហើយអ្នកខ្លះធ្លាប់មាន បែរទៅជាក្រក៏មាន។ អ្នកខ្លះមានលុយ ហើយចាយមិនដាច់ ពីព្រោះមានជម្ងឺដើរទៅណាពុំរួច ។ ហេតុនេះហើយបានជា ក្នុងធម៌ព្រះពុទ្ធមានចែង ថា ជីវិតជាទុក្ខ ហើយទុក្ខមាន១២កង ដូចជា ការព្រាត់ប្រាសពីសត្វលោកដែលយើងស្រឡាញ់ជាទុក្ខ។ ការរួមរស់នៅជាមួយសត្វលោកដែលយើងស្អប់ជាទុក្ខ។ ការមិនបានសម្រេចដូចសេចក្តីប្រាថ្នាជាទុក្ខ។ ចុះបើទុក្ខតែយ៉ាងនេះ ម្តេចក៏នៅតែមានឃើញមនុស្សដែលសប្បាយរីករាយដែរ នៅតែមានមនុស្សឈឺ ខំមើលខ្លួនឲ្យជាដើម្បីនឹងរស់តទៅទៀត ដោយមិនចង់ស្លាប់? ចម្លើយគឺថា អ្វីៗក្នុងលោកនេះសុទ្ធតែមិនទៀង សុទ្ធតែមានគូនឹងគ្នាជានិច្ច គឺថា បើមានពេលមានទុក្ខ ក៏មានពេលមានសេចក្តីសុខសប្បាយដែរ។ បើមានរដូវត្រជាក់ ក៏មានរដូវក្តៅដែរ ។ បើពេលខ្លះមានចិត្តបុណ្យ ក៏មានពេលខ្លះមានចិត្តបាបដែរ ។ ល ។ ធម៌ មិនទៀងនេះ ជាច្បាប់ធម្មជាតិ។ យើងមិនអាចកែច្បាប់ធម្មជាតិឲ្យមកតាមចិត្តយើងបានឡើយ។ ដើម្បីបានសេចក្តីសុខ ទាល់តែយើងរៀនរស់នៅ*

ឲ្យស្របតាមច្បាប់ធម្មជាតិ  ក៏ដូចសព្វថ្ងៃនេះ យើងត្រូវរស់នៅឲ្យស្របតាមច្បាប់រដ្ឋនោះដែរ ។ ប្រសិនបើជាយើងពុំអាចកែច្បាប់ធម្មជាតិបាន តែយើងក៏ត្រូវរកមធ្យោបាយដើម្បីការពារខ្លួនយើងដែរ  ដូចជា ភ្លៀងខ្យល់ជាបាតុភូតនៃច្បាប់ធម្មជាតិ យើងមិនអាចទប់ទល់នឹងបាតុភូតនោះបានទេ តែយើងអាចការពារខ្លួនយើងដោយបង្កើតសំលៀកបំពាក់ដូចជាអាវភ្លៀង  ឆ័ត្រ សង់ផ្ទះមានដំបូល ដើម្បីកុំឲ្យទទឹកនៅពេលភ្លៀង។

រួមសេចក្ដីទៅ  ដើម្បីបានសេចក្ដីសុខ យើងត្រូវស្គាល់ច្បាប់ធម្មជាតិ ដើម្បីនឹងរស់នៅទៅតាមច្បាប់នោះ ។ ធម៌ព្រះពុទ្ធ  មានប្រយោជន៍ដល់យើងពីព្រោះធម៌ព្រះអង្គ ស្របនឹងច្បាប់ធម្មជាតិ ។ ព្រះអង្គដោះស្រាយបញ្ហាទាំងពួងដោយទុកច្បាប់ធម្មជាតិជាល័ក្ខខ័ណ្ឌ។ ក្នុងធម៌ព្រះអង្គ មានពាក្យ បាលី **អនិច្ចំ**   ប្រែថា « មិនទៀង  »   ហើយធម៌ទាំងអស់របស់ព្រះអង្គ គឺចេញពីធម៌ អនិច្ចំ នេះ ។  ដូចយើងដឹងស្រាប់ហើយ  ធម៌ត្រៃលក្ខណ៍ គឺ **អនិច្ចំ  ទុក្ខំ   អនត្តា ៖** [ធម៌ទាំងឡាយមិនទៀង] [ធម៌ណាមិនទៀងជាទុក្ខ]  ហើយ [ ធម៌ណាមិនទៀង និងជាទុក្ខ  មិនមែនជាយើង  មិនមែនជារបស់យើងទេ ] ។ ព្រះអង្គត្រាស់ដឹង មិនមែនដោយសារធម៌  **អនិច្ចំ** នេះប៉ុណ្ណោះទេ  ពីព្រោះធម៌នេះគ្រាន់តែជា **ហេតុ** ដែលនាំឲ្យកើត **ទុក្ខ** ។ ធម៌ដែលសំខាន់ គឺ ធម៌ដែលនាំទៅរកការ**រំលត់ទុក្ខ** ។ ដូចជាគ្រូពេទ្យ មើលជម្ងឺ  បើគ្រាន់តែប្រាប់ហេតុដែលនាំឲ្យឈឺពោះហើយមិនឲ្យថ្នាំសម្រាប់បំបាត់ជម្ងឺនោះទេ  ក៏មិនគ្រប់គ្រាន់ដែរ ។  ការពិចារណារបស់ព្រះអង្គ គឺ នៅលើភពយើងនេះ មានច្បាប់ធម្មជាតិ  **អនិច្ចំ**   ហើយ អនិច្ចំ ជាទុក្ខ។ ដោយយើងកែច្បាប់ធម្មជាតិមិនបាន ដូច្នេះ ដើម្បីផុតទុក្ខ ទាល់តែយើងកុំកើតនៅលើភពទាំងបី (កាមភព រូបភព  និង អរូបភព) ។ នៅ កាមភព មាន មនុស្ស ទេវតា និង (តិរច្ឆាន

អសុរកាយ ប្រេត នរក )។ ដូច្នេះ ធម៌ដែលព្រះអង្គរក គឺ ធម៌ដែលនាំទៅរកការ **មិនកើត តនៅទៀត** ។ ខ្ញុំរៀបរាប់ខាងលើនេះបាន ដោយសារខ្ញុំឃើញ លទ្ធផល គឺធម៌ដែលព្រះពុទ្ធបានរកឃើញរួចហើយ តែបើពុំទាន់បានឃើញធម៌ព្រះពុទ្ធរកឃើញទេនោះ ខ្ញុំក៏ពុំហ៊ានរ៉ាយរ៉ាប់ពីការពិចារណាជាដំបូង របស់ព្រះអង្គដែរ ។ ពីព្រោះក្នុងការស្រាវជ្រាវ (recherche) មុនដំបូង គេដាក់ជា សម្មតិកម្ម (hypothèse) សិន ហើយបន្ទាប់មក បាន គេខំរាវរកទៅតាមលំនាំ នៃសម្មតិកម្មនោះ ។ ដូចជាក្នុងការស្រាវជ្រាវនេះ សម្មតិកម្ម គឺ « បើមានធម៌ដែលនាំទៅរកការ **កើត** ក៏ត្រូវមានធម៌ដែលនាំទៅរកការ **មិនកើត** ដែរ »។ ដោយ សម័យកាលព្រះពុទ្ធ **គោតម** ពុំទាន់មានអ្នកសិក្សាខាងសាសនាណាមួយនឹកឃើញនូវសម្មតិកម្ម (hypothèse) ខាងលើនេះនៅឡើយ ហេតុនេះហើយបានជាថាព្រះអង្គបានរកឃើញធម៌ **និព្វាន** នេះ ដោយព្រះអង្គឯង ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។ ឧបមាថា មានលោកអ្នកខ្លះដែលកំពុងតែអានអត្ថបទនេះ សួរខ្ញុំថា ៖ ឥឡូវខ្ញុំយល់ហើយថា ការកើតនៅលើពិភពលោកយើងនេះជាទុក្ខ ហើយមានតែបានសម្រេចព្រះនិព្វានទេ ទើបរួចចាកទុក្ខបាន។ តើត្រូវធ្វើរបៀបណា ទើបបានសម្រេច ព្រះនិព្វានបាន ?

ខ្ញុំសូមស្វាគមន៍នូវសំណួរនេះ ពីព្រោះដោយហេតុសំណួរនេះ និងដើម្បីនឹងរកចម្លើយនៃសំណួរនេះហើយ បានជាព្រះពុទ្ធនៃយើងទ្រង់ចេញទៅបួស ។ ធម៌របស់ព្រះអង្គទាំងឡាយ ទៅរកទិសដៅតែមួយ គឺ៖ **សម្រេច ព្រះនិព្វាន** គឺ ផុតចាកទុក្ខ ។ យើងថាព្រះអង្គត្រាស់ដឹង គឺត្រង់ព្រះអង្គរកឃើញនូវ « ធម៌នាំទៅនិព្វាន » ព្រោះពាក្យនិព្វានមានន័យ លុះត្រាតែមានធម៌ដែលនាំយើងទៅដល់និព្វាននោះ បើមិនដូច្នោះទេ គឺគ្រាន់តែជាពាក្យធម្មតាប៉ុណ្ណោះ មិនមានអ្វីជាអស្ចារ្យទេ ។

« ធម៌ នាំទៅនិព្វាន » ដែលព្រះពុទ្ធបានត្រាស់គឺ **ចតុរារិយសច្ច** (អរិយសច្ច៤)

ដែលនៅក្នុងនោះ មាន **អដ្ឋង្គិកមគ្គ** ជា **គោល**នៃផ្លូវសម្រាប់ **បដិបត្តិតាម** ដើម្បីនឹងបានសម្រេចព្រះនិព្វាន ។

ព្រះពុទ្ធ បន្ទាប់ពីបានត្រាស់ដឹងធម៌នេះហើយ ព្រះអង្គមិនលាក់ទុកធម៌នេះសម្រាប់តែមួយព្រះអង្គឯង ឬ សម្រាប់ តែព្រះញាតិវង្សទេ ។ ព្រះអង្គខំរកមធ្យោបាយយ៉ាងណា ដើម្បីផ្សព្វផ្សាយធម៌នេះដល់សត្វលោកទាំងមូល ដើម្បីឲ្យបានរួចចាកទុក្ខដូចព្រះអង្គដែរ ។ ដោយសត្វលោកមានបញ្ញាមិនដូចគ្នា មានឧបនិស្ស័យមិនដូចគ្នា ដើម្បីឲ្យបានយល់គ្រប់គ្នា កុំឲ្យមានការយល់ច្រឡំក្នុងការ **បដិបត្តិ** ព្រះអង្គបានវែកញែក លំអិត ធម៌ព្រះអង្គ **ជាហេតុ ជាផល** សម្រាប់យើងយកទៅពិចារណា ។

នៅក្នុងព្រះពុទ្ធសាសនាការពិចារណា សំខាន់ណាស់ ព្រះអង្គមិនចង់ឲ្យយើងជឿនូវធម៌ព្រះអង្គដោយលិ្ងតលង់នោះទេ ព្រះអង្គចង់ឲ្យយើងជឿដោយបានប្រើបញ្ញា ពីព្រោះធម៌ព្រះអង្គសុទ្ធតែពឹងផ្អែកទៅលើហេតុផលទាំងអស់ ហេតុនេះហើយបានជា មានពាក្យថា **ធម៌** គឺ **ធម្មជាតិ** ។ ច្បាប់ធម្មជាតិ សុទ្ធតែមានហេតុផល តែជួនកាលគេរកហេតុពិតនោះពុំទាន់ឃើញ ដូចជាជម្ងឺអាលសៃម៉ើរ (Alzheimer) ជាដើម ។ តែបើមេឃភ្លៀងវិញ គេអាចថា មេឃភ្លៀង មកពីពពក ហើយ ពពក មកពីចំហាយទឹក ហើយ ចំហាយទឹក មកពីធាតុអាកាសក្តៅ ...។ល។

ដោយហេតុចង់ឲ្យបានយល់គ្រប់គ្នានេះហើយ បានជាធម៌របស់ព្រះអង្គមានទៅដល់ ៨៤០០០ ធម្មខន្ធ ។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងការ បដិបត្តិ ព្រះអង្គបានចែកធម៌ជាថ្នាក់ៗ ដូចជា នៅក្នុង **អដ្ឋង្គិកមគ្គ** មានចែកជាបីថ្នាក់ គឺ **សីល សមាធិ បញ្ញា** ។ ធម៌ទាំងបីនេះជួយគ្នាទៅវិញទៅមក ដូច្នេះសុទ្ធតែមានប្រយោជន៍ទាំងអស់ពីព្រោះមនុស្សយើងម្នាក់ៗ មាន កាយ និង ចិត្ត ឬ ខន្ធ៥ ហើយ កាយនិងចិត្ត ត្រូវការគ្នាទៅវិញទៅមកជានិច្ច ។ បើដើងឈឺ ហើយចិត្តចង់ទៅវត្ត តើទៅវត្តកើតទេ ? ឆ្លើយថាទៅមិន

កើតទេ ។ ដូចអ្នកដក់បារីខ្លះ ដោយបញ្ញា បានយល់ច្បាស់ហើយថា ដក់បារីនាំឲ្យមានជម្ងឺមហារីកសួត តែនៅតែដក់បារី ផឹកស្រាដដែល ។ ឧទាហរណ៍នេះបង្ហាញថាគ្រាន់តែយល់ដោយបញ្ញាមិនទាន់គ្រប់គ្រាន់ទេ ត្រូវមានការបដិបត្តិ ដោយអប់រំចិត្តថែមទៀត ដូចជាការកាន់សីល ធ្វើសមាធិជាដើម ។ មុននឹងបញ្ចប់ ខ្ញុំសូមជូនអត្ថន័យពាក្យខ្លះ តាមដែលខ្ញុំ បានឮ បានយល់ ៖

**ទុក្ខ** : ភាព (ភាវៈ) ដែលទ្រាំពុំបាន ដោយកាយ ឬ ដោយចិត្ត ឧបមា អ្នកខ្លះទ្រាំបានតែត្រឹម ជាតុអាកាស -5° (ក្រោម ៥ អង្សា) ហើយ អ្នកខ្លះទ្រាំបានដល់ -10° (ក្រោម ១០ អង្សា) ។ ទុក្ខដោយ កាយត្រជាក់ ចិត្តខំទ្រាំមិនត្អូញត្អែរ ។

ចំពោះពាក្យ នរក ស្ថគ៌ ឬ និព្វាន ដោយយើងមិនទាន់ទៅដល់ យើងស្គាល់តែឋាន **កណ្តាល** ដូច្នេះមានតែការប្រៀបធៀបនឹងស្ថានដែលយើងរស់នៅសព្វថ្ងៃនេះប៉ុណ្ណោះ ។

**និព្វាន** : ភាព (ភាវៈ) សុខ ឥតមានទុក្ខ (សុខក្នុងន័យ នត្ថិ សន្តិ បរំ សុខំ )

**នរក** : ភាព (ភាវៈ) ទុក្ខ ឥតមានសុខ

**ឋានសួគ៌** : ឋានដែល មានសុខ ច្រើនជាងទុក្ខ

**ឋានកណ្តាល** យើង គឺ មានសុខ និង ទុក្ខ ប្រហាក់ប្រហែលគ្នា ។

# ធម៌ ទាំងឡាយ កើតមកអំពីហេតុ ។

ដូច្នេះ

បើហេតុ រលត់ ធម៌នោះក៏រលត់

បើហេតុ ដូរ ធម៌នោះក៏ដូរ ។

## ៦

## ធម៌ទាំងឡាយ កើតមកអំពីហេតុ

*ខ្ញុំសូមលើកធម៌ព្រះពុទ្ធដូចខាងក្រោមនេះមកអធិប្បាយ៖*

**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ អាហ**

**តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោ ។**

*ប្រែថា ៖* ធម៌ទាំងឡាយឯណាដែលចេញពីហេតុ, ព្រះតថាគតតែងពោលនូវហេតុនៃធម៌នោះ ម្យ៉ាងទៀតសេចក្តីរលត់និងឧបាយឯណាជាគ្រឿងរលត់នៃធម៌នោះ តថាគតបានពោលហើយនូវសេចក្តីរលត់នោះ, ព្រះមហាសមណៈមានប្រក្រតីពោលពាក្យ យ៉ាងនេះឯង ។

*ធម៌នេះមានប្រយោជន៍ណាស់ចំពោះការរស់នៅនៃយើងសព្វថ្ងៃនេះ ដូច្នេះគប្បីយកធម៌នេះមកពិចារណាឲ្យបានយល់ច្បាស់ ដើម្បីសេចក្តីសុខចំរុងចម្រើននៃយើងគ្រប់ៗគ្នា ។ ជាដំបូង យើងពិចារណា នូវន័យរបស់ពាក្យដែលប្រើក្នុងធម៌នេះ ដូចជា ពាក្យថា* «ធម៌ទាំងឡាយ» *ម្តេចមិនប្រើពាក្យ « ធម៌ទាំងអស់ » ។ នេះមកពីមានធម៌ខ្លះដែលមិនចេញមកពីហេតុ ដូចជានិព្វានជាដើម ។ ពីព្រោះនិព្វាន មិនកើត* (non-né) *ជា អមតៈ បើកើត ត្រូវតែស្លាប់ ។ ក្រៅពីនិព្វាន ធម៌ទាំងអស់សុទ្ធតែចេញពីហេតុ ពីព្រោះជាធម៌*

កើតមកពីគ្រឿងផ្សំ គឺថាបានមកដោយការផ្សំធម៌ដទៃឯទៀត ។ ក្នុងឃ្លាទីពីរ ឃ្លាទីបី « ព្រះតថាគតតែងពោលនូវហេតុនៃធម៌នោះ ម្យ៉ាងទៀតសេចក្តីរលត់និងឧបាយឯណាជាគ្រឿងរលត់នៃធម៌នោះ តថាគតបានពោលហើយនូវសេចក្តីរលត់នោះ» ចំពោះធម៌ដែលកើតដោយហេតុ ព្រះពុទ្ធតែងសម្តែងពីហេតុនៃធម៌នោះ និង វិធីដើម្បីនឹងរំលត់ហេតុនោះ ក៏ព្រះអង្គបានពោលរួចហើយដែរ ដូចមាននៅក្នុងធម៌ អរិយសច្ចៈ ឬ បដិច្ចសមុប្បាទ ជាដើម ។

តាមធម្មតា ធម៌មិនមែនកើតឡើងឯងៗដោយចៃដន្យ ឬ ដោយគ្មានហេតុនោះទេ នេះតាមធម៌ព្រះពុទ្ធ ។ ធម៌ព្រះពុទ្ធនេះយើងប្រើរាល់ថ្ងៃ មិនថាចាស់ ឬ ក្មេងទេ ។ ដូចកូនក្មេងពីរនាក់ទាស់គ្នា អាធំវាយ អាតូចៗ ដល់អាតូចយំ វាសួរទៅអាធំថា « **ហេតុ**អ្វីបានមកវាយអញ » អាធំឆ្លើយថា « **មកពី** ឯងវាយប្អូនអញ » ។ ក្នុងឧទាហរណ៍នេះ ធម៌គឺ « អាធំវាយអាតូច » ហេតុគឺ « អាតូចបានវាយប្អូនអាធំ » ហើយន័យតាមធម៌ព្រះពុទ្ធ គឺ ៖ **មិនដែលនៅសុខៗ ស្រាប់តែមានគេមកវាយនោះទេ វាសុទ្ធតែមានហេតុ** ។ ក្នុងជីវិតរស់នៅសព្វថ្ងៃ បើយើងប្រើធម៌នេះជានិច្ច សម្រាប់ដោះស្រាយនូវបញ្ហាផ្សេងៗ នោះយើងនឹងចំណេញពេលវេលាផង ហើយថែមទាំងអាចដោះស្រាយបញ្ហាបានដោយឆាប់រហ័សផង ។ ពីព្រោះកាលណាយើងរកហេតុឃើញ នោះយើងអាចដោះស្រាយបញ្ហាបាន ដោយគ្រាន់តែយកហេតុនោះមកដោះស្រាយ ។

កាលខ្ញុំនៅប្រកបការងារនៅឡើយ ដោយខ្ញុំធ្វើការខាងព័ត៌មានវិជ្ជា (informatique) កាលណាប្រូក្រាម([3]) (programme) មិនដើរ ឬ ក៏ដើរមិនត្រូវនោះដើម្បីរក ហេតុ ដែល

[3] នៅ ព័ត៌មានវិជ្ជា (Informatique) ឬ បច្ចេកវិទ្យា (IT), ប្រូក្រាម (programme) គឺជា អត្ថបទ ដែល

ធ្វើឲ្យប្រូក្រាមដើរខុស អ្នកប្រូក្រាម៉េ គេសរសេរថែមក្នុងប្រូក្រាម ត្រង់បន្ទាត់ខ្លះ ដាក់ជាពាក្យចំណាំ ដូចជាថា « ចំណុចទី១ » ដល់ឆ្ងាយបន្តិចក្នុងប្រូក្រាមដដែល គេសរសេរ « ចំណុចទី ២ » ...។ល។ ហើយត្រង់ចំណុច នីមួយៗ គេឲ្យ ប្រូក្រាមបញ្ចេញលទ្ធផលដែល ម៉ាស៊ីនឲ្យ ។

ដោយធ្វើរបៀបនេះ ប្រូក្រាម៉េអាចដឹងថាតើចាប់ពីចំណុចណាទៅ ម៉ាស៊ីនឲ្យលទ្ធផលខុស ។ ឧបមា នៅ « ចំណុចទី៣ » ម៉ាស៊ីនឲ្យលទ្ធផលត្រូវ ហើយដល់ « ចំណុចទី៤ » ម៉ាស៊ីនឲ្យលទ្ធផលខុស នោះគេអាចសន្និដ្ឋានថា ហេតុដែលនាំឲ្យ ម៉ាស៊ីនឲ្យលទ្ធផលខុស នោះគឺផ្នែក ប្រូក្រាមដែលនៅក្នុង ចន្លោះ « ចំណុចទី៣ » និង « ចំណុចទី៤ » ។

ប្រយោជន៍មួយទៀត របស់ធម៌នេះ គឺ ធ្វើកុំឲ្យយើងអស់សង្ឃឹម ក្នុងការរកហេតុ ពីព្រោះចំពោះព្រឹត្តិការណ៍ខ្លះ ហេតុអាចមានច្រើន ហើយដើម្បីរកហេតុ ដែលជាហេតុពិតនៃព្រឹត្តិការណ៍នោះ ត្រូវប្រើពេលច្រើន តែបើយើងជឿជាក់ថាហេតុត្រូវតែមានជានិច្ច នោះយើងនឹងខំរកហេតុពិតនោះទាល់តែឃើញ ។

ឧបមា ដូចយើងមានទោចក្រយាន (រទេះកង់) ថ្ងៃមួយស្រាប់តែកៅស៊ូកង់វាធូរស្បៀត ។ ព្រឹត្តិការណ៍ គឺ កៅស៊ូកង់វាធូរស្បៀត តើហេតុមកពីអ្វី? ដោយយើងពុំបានឃើញនៅពេលដែលកៅស៊ូនោះវាធូរ ដូច្នេះដើម្បីដោះស្រាយយើងត្រូវ សាកល្បងនូវហេតុដូចជា (មុតបន្លា ឬ ដែកគោល) (ខ្យល់ចេញតាមក្បាលវ៉ាល់) (មានគេលួចបន្ធូរ) ជាដើម ។ ការពិបាកមួយទៀតគឺរកហេតុដើម ឬ មូលហេតុ ។ បើយើងឃើញតែហេតុជិតៗទេ ចំ

---

មនុស្ស សរសេរ ដោយប្រើភាសាពិសេស ដែលម៉ាស៊ីនកុមព្យូទ័រ (computeur) អាចយល់បាន ។ នេះជារបៀបមួយ ដែល មនុស្ស និង ម៉ាស៊ីន អាចនិយាយគ្នាទៅវិញទៅមក ។ មនុស្ស ដែលសរសេរ អត្ថបទនោះ គេហៅថា ប្រូក្រាម៉េ (programmeur) ។

ណោទនោះដោះស្រាយបានតែមួយពេលប៉ុណ្ណោះ តែកាលណាមូលហេតុវាផ្តល់ផលមកម្តងទៀត ចំណោទដដែលនោះក៏លេចឡើងជាថ្មី ។ ដូចជម្ងឺដែលមើលមិនជា ជាដើម។ ចំពោះថ្នាំខ្លះ មេរោគវាគ្រាន់តែខ្សោយកម្លាំង តែវាមិនងាប់ ដូច្នេះដល់វាមានកម្លាំង វាក៏ងើបឡើងម្តងទៀត។ បើនិយាយពីកិលេស តណ្ហា ក៏ដូចគ្នាដែរ បើយើងធ្វើត្រឹមតែ សីល សមាធិ កិលេសគ្រាន់តែទ្រោមៗ ទាល់តែធ្វើ **បញ្ញា** (វិបស្សនា)ទើបផេះដល់ឫស ។ ដូចដើមឈើ បើយើងគ្រាន់តែអារមែកវាចេញ នោះយើងបានស្រឡះមុខផ្ទះតែពេលកាត់មែកនោះទេ តែក្រោយមកមែកនោះនឹងដុះឡើងជាថ្មីម្តងទៀត ។ ដើម្បីកុំឲ្យវាដុះបាន ទាល់តែកាត់គល់កាត់ឫសវាឲ្យដាច់ត្និលតែម្តង ។

ឧទាហរណ៍មួយទៀតដែលបង្ហាញថាការរកមូលហេតុជាការពិបាក ដូចជា ហេតុដែលនាំឲ្យ ប្រជាជនគ្មានការធ្វើ (problème de chômage) អំពើពុករលួយ នៅប្រទេសក្រីក្រ (la corruption dans des pays pauvres) ជាដើម ។

ដោយ « ធម៌ទាំងឡាយ កើតមកអំពី ហេតុ » យើងអាចទាញយកអនុសាធ្យ (corollaire) ដូចជា ៖

១- បើហេតុមិនផ្លាស់ប្តូរ ផលក៏មិនផ្លាស់ប្តូរ ដូចជា បើមិនដូសដុលកៅស៊ូកង់ដែលធូរស៊្បែតនោះទេ កុំសង្ឃឹមថាកៅស៊ូកង់ត្រឡប់មកតឹងវិញឡើយ ។

២- ដើម្បី ផលដូរ លុះត្រាតែហេតុដូរ ដូចជា អ្នកធាត់ ចង់ស្គម ទាល់តែដូរហេតុដែលនាំឲ្យធាត់ ដូចជាបន្ថយចំណីអាហារជាដើម ។

៣- បើចង់ឲ្យផលរលត់ ទាល់តែហេតុរលត់ ដូចជា ទុក្ខ កើតមកអំពី **លោភ** ដូច្នេះដើម្បីទុក្ខរលត់ ទាល់តែលោភរលត់ ។ បើនិយាយពីការរត់គ្រឿងញៀនវិញ ការរត់គ្រឿងញៀនរលត់ កាលណាការដាំគ្រឿងញៀនរលត់ ពីព្រោះថាបើអត់មានអ្នកដាំ ក៏អត់មានអ្នកលក់ដែរ ពីព្រោះអត់មានរបស់លក់ ។ មុននឹងបញ្ចប់ខ្ញុំសូមធ្វើការសង្កេតខ្លះ

ក្នុងការអនុវត្ត « ធម៌ទាំងឡាយកើតមកអំពីហេតុ »។ ដោយក្នុងការនិយាយយើងច្រើនតែប្រើពេលបច្ចុប្បន្នជានិច្ច ថ្វីបើ អំពើបានធ្វើរួចទៅហើយ ឬ ក៏នឹងធ្វើនៅពេលខាងមុខ ។ ដូចនៅក្នុងឃ្លា « ធម៌ទាំងឡាយកើតមកអំពីហេតុ » បានន័យថា ធម៌ នោះកើតក្រោយហេតុ ។ ពោល គឺ ធម៌កើតក្រោយ តែ ហេតុកើតមុន ។ ហើយធម៌ នីមួយៗ ដែល កើតលេចចេញមក អាចមានហេតុដើមដំបូង ដែលខុសពីហេតុចុងក្រោយ ។ មកដល់ត្រង់នេះ លោកអ្នក អាចនឹកថា « វាច្បាស់តែយ៉ាងនេះហើយ មិនចាំបាច់និយាយ ក៏ដឹងដែរ »។ លោកអ្នកនឹងឃើញផលប្រយោជន៍ នៃការសង្កេតនេះ ។ ដោយខ្ញុំធ្លាប់ឮក្នុងធម៌អភិធម្មមានពាក្យថា «ហេតុជិត» គឺហេតុអមហេតុចុងក្រោយនៃធម៌ ខ្ញុំក៏នឹកថា បើមានហេតុជិត ក៏ត្រូវមានហេតុឆ្ងាយដែរ គឺហេតុដំបូងគេ ហើយ ហេតុដើមដំបូងនេះឲ្យផល តៗមក រហូតដល់ចុងបញ្ចប់ ធម៌ ក៏កើតឡើង ។ ឧបមាដូចជាយើងកំពុងតែដើរៗ ស្រាប់តែភ្លៀងធ្លាក់ខ្លោកៗ ធ្វើឲ្យទទឹកខោអាវអស់ ។ យើងច្រើននិយាយថា ទទឹកខោអាវមកពីភ្លៀង ។ និយាយនេះត្រូវ មួយរយភាគរយ (100 %) ពីព្រោះហេតុដែលនាំឲ្យទទឹកខោអាវ គឺ មេឃភ្លៀង ។ តែចំពោះយើងដែលមិនចង់ ឲ្យទទឹកភ្លៀងទៅថ្ងៃមុខ តើគ្រាន់តែ **យល់ថា** មកពីភ្លៀងបានជាខោអាវទទឹក **តើគ្រប់គ្រាន់សម្រាប់ថ្ងៃមុខទេ**? បើលោកអ្នកយល់ដូចខ្ញុំដែរ គឺថា « មិនទាន់គ្រប់គ្រាន់ ទេ» នោះយើងត្រូវស្រាវជ្រាវ រកឫសគល់ហេតុការណ៍នេះ តទៅទៀតៗ ដូចនៅក្នុងឧទាហរណ៍ទទឹកភ្លៀងនេះ យើងសួរថា ហេតុអ្វីបានជាភ្លៀង? បើយើងថាមកពី ខ្យល់ក្តៅ ប៉ះនឹងខ្យល់ត្រជាក់ក្នុងពពក នោះថ្វីបើយើងពុំអាចកែរច្បាប់ធម្មជាតិកុំឲ្យមេឃភ្លៀងបានក៏ដោយ តែយើងអាចរកមធ្យោបាយកុំឲ្យទទឹកជោកតទៅទៀតបានដែរ ។ មធ្យោបាយគឺ ពេលណាមេឃមានពពកខ្មៅហើយ យើងទៅណាមកណាត្រូវមានឆ័ត្រ ឬ អាវភ្លៀង បើយើងខ្លាចទទឹកភ្លៀង។

ខ្ញុំសូមជូនឧទាហរណ៍មួយទៀត ដែលជាប់ទាក់ទងនឹងការប្រតិបត្តិ ធម៌ព្រះពុទ្ធ ។ ក្នុងការបង្រៀនធម៌ព្រះពុទ្ធ  មានលោកគ្រូខ្លះពន្យល់ថា ចំពោះធម៌នាំឲ្យបានសម្រេចព្រះនិព្វាន ឲ្យតែយល់ច្បាស់ត្រឹមត្រូវ នូវធម៌នោះទៅ  នឹងបានសម្រេចហើយ <u>មិនចាំបាច់មានការបដិបត្តិទេ  ពីព្រោះការបដិបត្តិនៅក្នុងការយល់នោះហើយ</u> ។ ត្រង់ឃ្លានេះ ខ្ញុំពុំយល់ស្របទេ  ពីព្រោះនៅក្នុងគម្ពីរ មានដំណាលថា  មានព្រះសង្ឃមួយអង្គជាគ្រូ   បានបង្រៀនសិស្សជាច្រើន ។ ដល់ក្រោយមក សិស្សបានសម្រេចជាព្រះអរហន្តតែចំពោះលោកគ្រូនោះវិញ អត់បានសម្រេចអ្វីទាំងអស់ ។  បើថាមកពីព្រះសង្ឃគ្រូអង្គនោះ មិនយល់ធម៌ព្រះពុទ្ធក៏មិនសម ពីព្រោះមុននឹងពន្យល់ធម៌ដល់សិស្សទាល់តែលោកគ្រូយល់ធម៌នោះជាមុនដែរ ។

ដល់ក្រោយមក ដោយប្រតិបត្តិតាមការណែនាំរបស់សាមណេរអរហន្តមួយអង្គ ដែលធ្លាប់ជាកូនសិស្សលោកគ្រូនោះដែរ  ទើបបានសម្រេចជាព្រះអរហន្ត ។ នេះបង្ហាញឲ្យឃើញថា បើត្រឹមតែយល់ធម៌ព្រះពុទ្ធអាចមិនទាន់គ្រប់គ្រាន់ទេ  ចំពោះមនុស្សទូទៅត្រូវបដិបត្តិនិងអប់រំចិត្តថែមទៀតទើបបានសម្រេចមគ្គផល ។

ម្យ៉ាងទៀត ជនគ្រប់រូបមានឧបនិស្ស័យមិនដូចព្រះសារីបុត្តទេ  ដែលគ្រាន់តែស្តាប់ធម៌ព្រះ អស្សជិ តែប៉ុន្មានម៉ាត់ ក៏បានសម្រេចជាសោតាបន្នបុគ្គល ។ នៅក្នុងអរិយសច្ច៤ កាលណាយើងកំណត់ដឹងនូវទុក្ខ យើងនឹងយល់ថា កិលេស តណ្ហា  ជាហេតុនាំឲ្យកើតទុក្ខ ។  ដោយផ្លូវទៅនិព្វាន គឺ **លះ**កិលេស  តើគ្រាន់តែយល់ អរិយសច្ច៤ ប៉ុណ្ណឹងអាចលះកិលេសអស់ទេ ?

<u>ប្រសិនបើជាលះមិនអស់  តើធ្វើដូចម្តេច ?</u>

ចម្លើយ គឺត្រូវរកហេតុដើមដំបូង នៃលោក ដូចគ្នានឹងរកហេតុដែលធ្វើឲ្យមេឃភ្លៀង ។ តើរកហេតុដើមនោះដោយរបៀបណា ?  អត់ពិបាកទេ ព្រះពុទ្ធទ្រង់បានទុកធម៌ព្រះ

អង្គ ឲ្យដល់យើងគ្រប់គ្រាន់ហើយ មិនចាំបាច់ទៅបង្កើតថ្មី ឬ ទៅរកឯណាឆ្ងាយទេ ។
ខ្ញុំសូមដកស្រង់ ធម៌បដិច្ចសមុប្បាទ មកជូនដូចតទៅ ៖
នាមរូប ជាបច្ច័យឲ្យកើត សឡាយតនៈ ។ ដើម្បីខ្ញីខ្ញុំសរសេរជា នាមរូប => សឡាយតនៈ ។
[នាមរូប => សឡាយតនៈ => ផស្សៈ =>វេទនា ] => [ **តណ្ហា** => ឧបាទាន ] គឺ កិលេស។
[ សីល - សមាធិ - សតិបដ្ឋាន ៤ - វិបស្សនា ] **=>** អស់ [តណ្ហា ] => អស់ [ឧបាទាន ] ។
ខ្ញុំសូមពន្យល់ និង អធិប្បាយ ប្រយោគ ទាំងពីរនេះ ដូចតទៅ ៖
កិលេស គឺគ្រឿងសៅហ្មងចិត្ត ដូចជា លោភៈ ទោសៈ មោហៈ ជាដើម ។
នាមរូប តាមភាសាអ្នកស្រុក គឺ មនុស្សយើងគ្រប់រូប ។ បើតាមភាសាធម៌ គឺ ខន្ធ ៥ មាន រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ដើម្បីលះ តណ្ហា យើងប្រើ រូប ដូចជា ភ្នែក ត្រចៀក ច្រមុះ ជាដើម ។ ហើយយើងប្រើនាម គឺចិត្ត ដូចជា វេទនា សតិ ជាដើម ឲ្យទៅឃាំង កិលេស កុំឲ្យវាកើតបាន ។ ពោលគឺ យើង <u>យកចិត្តអលោភ ទៅ ឃាំង រារាំង ចិត្តលោភ</u> ។ ពីព្រោះចិត្ត មានចិត្តកុសលក៏មាន ចិត្តអកុសល ក៏មាន ។ បើយើងចេះ ប្រើចិត្ត យើងយកចិត្តកុសល ទៅ កំចាត់ចិត្ត អកុសល ។
ដើម្បីប្រើចិត្តបាន ទាល់តែយើងចេះអប់រំវា ថ្វីបើវាមិនមែនជារបស់យើងក៏ដោយ ។ ដូច យើងឃើញស្រាប់ហើយ ដំរី មិនមែនជារបស់យើងទេ[4] ហើយវាខ្លាំងជាងយើងទៀតផង តែដោយការអប់រំរបស់ ហ្ម ដំរីក៏ស្លូតទៅជាមានប្រយោជន៍ដល់ម្ចាស់វាទៅវិញ ។
វិធីអប់រំចិត្ត ព្រះអង្គមានចែងទុករួចមកហើយ នៅតែយើងចេះយកមកប្រើទេ ។

[4] ពីព្រោះតាមធម៌ គ្មានអ្វីជារបស់យើងទេ សូម្បីតែខ្លួនយើងសព្វថ្ងៃនេះ ក៏មិនមែនជារបស់យើងដែរ សូមអាន កថាខ័ណ្ឌ បន្ត ស្តីពី អត្តា ជាបន្ទាប់នេះ ។

*សឡាយតនៈ គឺ ទ្វារទាំង ៦ខាងក្នុងខ្លួនយើង មាន ៖ ទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ ទ្វារចិត្ត ។ ហើយរបស់នៅ ខាងក្រៅ ខ្លួនយើង ដូចជា រូប សំឡេង ក្លិន រសជាតិ ផោដ្ឋព្វ (របស់ដែលកាយប៉ះ) និង ធម្មារម្មណ៍ ។ របស់ ខាងក្រៅ ទាំង ៦នេះ អាចចូលមកក្នុងខ្លួនយើងបាន តាមទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយ ទ្វារចិត្ត ។ យើងដឹងវាចូលមកនៅក្នុងខ្លួនយើងដោយ វេទនា ដូចជា មានការ សុខស្រួល (ហៅថាសុខវេទនា) ឬ មានការឈឺចុកចាប់ (ហៅថាទុក្ខវេទនា) ជាដើម ។ ឧបមា មាន រូបល្អចូលតាមទ្វារភ្នែក បើយើងពេញចិត្ត ក៏ស្រឡាញ់ចង់បាន កើតជាតណ្ហា។ ដល់ជាប់ជំពាក់ខ្លាំងចិត្តក៏ក្លាយទៅជាឧបាទាន (ការប្រកាន់មាំ) ។ ក៏ដូចគ្នា ចំពោះសំឡេង ឬ ក្លិន ។ បើសំឡេងពិរោះក៏ស្រឡាញ់ បើមិនពិរោះក៏ស្អប់ ។ ក្នុងឧទាហរណ៍នេះ យើងឃើញថា តណ្ហា អាចចូលតាមទ្វារទាំង ៦ ដូចជាទ្វារភ្នែក ជាដើម ។ ដូច្នេះ ដើម្បី កុំឲ្យ តណ្ហាចូលតាមទ្វារភ្នែកបាន តើត្រូវធ្វើដូចម្តេច ? នេះហើយជាសំណួរនៃការប្រតិបត្តិ មិនមែនគ្រាន់តែ* **យល់** *ថាតណ្ហា ចូលតាមភ្នែក ហើយក៏ អស់តណ្ហានោះទេ ។ របៀបប្រតិបត្តិមានគ្រប់គ្រាន់ តាំងពីសម័យព្រះពុទ្ធមក មិនពិបាករកទេ ។ គឺ សមាធិ សតិបដ្ឋាន ៤ វិបស្សនា*[5]*។ ការបដិបត្តិ គឺ ដើម្បីឲ្យ មាន* **សតិដឹងទាន់** *កាលណាចិត្តមានរាគៈ ។*

*បើនិយាយតាមភាសាអ្នកស្រុក បើកាលណាចោរវាចូលតាមទ្វារភ្នែក យើងដឹងថាចោរចូលតាមទ្វារភ្នែកហើយ គឺ គ្រាន់តែដឹងបានហើយ មិនចាំបាច់ទៅដេញវាទេ ។ ដូចចោរចូលលួច កាលណាវាដឹងថាយើងឃើញវាហើយ វារត់ទៅឯង។ បើមិនមានចោរ ទេ ក៏ដឹងថា មិនមានចោរ ។ សំខាន់គឺ យើងមិនធ្វេសប្រហែស ដោយមានសតិ គឺការ*

[5] *ខ្ញុំ គ្រាន់តែជំរាបថាមាន ប៉ុណ្ណោះទេ បើលោកអ្នកចង់ស្គាល់ របៀបប្រតិបត្តិទាំងនោះ សូមអញ្ជើញអានសៀវភៅស្តីពី សមាធិ ឬ បញ្ញា (វិបស្សនា) តាមបំណង។*

ប្រុងប្រយ័ត្ន គ្រប់ពេលវេលា ។ បើនិយាយជាភាសាធម៌វិញ ដែលថា មិនមានយើង មិនមានចោរ នោះយើងអាចថា ចោរជាតណ្ហា (ចិត្តអកុសល) ហើយយើងជាអ្នកយាមខ្វាចចោរចូលផ្ទះ គឺ សតិ (ចិត្តកុសល) ដែលតាំងនៅចាំត្រង់ទ្វារភ្នែក ។ កាលណា ភ្នែកឃើញរូបល្អ សុខវេទនាក៏កើតឡើង នៅពេលនោះ បើសតិដឹងទាន់ ពោលគឺសតិមិនបានដេកលក់ នោះសេចក្តីស្រឡាញ់រូបល្អក៏ចូលតាមទ្វារភ្នែកមិនបាន ពីព្រោះមានសតិនៅទីនោះរួចទៅហើយ ។ នេះជាច្បាប់ធម្មជាតិរបស់ចិត្ត ដូចជាមនុស្សល្អ និង មនុស្សអាក្រក់ រស់នៅជាមួយគ្នាមិនកើតទេ[6] យ៉ាងណាមិញ ចិត្តកុសល និង ចិត្តអកុសលក៏នៅជាមួយគ្នាមិនបានដែរ គឺថា ៖ បើមួយមាន មួយគ្មាន ។

នៅក្នុង **ចិត្តានុបស្សនាសតិបដ្ឋាន** មានចែងថា ៖

***នែភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយ រាគៈ ដឹងច្បាស់ថា « ចិត្តប្រកបដោយ រាគៈ » ទោះចិត្តប្រាសចាករាគៈ ដឹងច្បាស់ថា « ចិត្តប្រាសចាករាគៈ »*** ។

*នេះគ្រាន់តែចង់បង្ហាញថា បើលោកអ្នកត្រូវការបដិបត្តិ របៀបបដិបត្តិមាន។*

---

[6] *កាលសម័យព្រះ មានរឿងមួយតំណាលថា មានកូនស្រីសេដ្ឋីម្នាក់ ទៅស្រឡាញ់ចោរ ហើយសុំឪពុកម្តាយ យកចោរនោះមកធ្វើជាប្តី ។ លុះបានគ្នាជាប្តីប្រពន្ធហើយ ដល់គ្រាក្រោយមកប្តីនោះមិនចេះរស់នៅជាមួយនឹងភរិយាខ្លួន ក៏បបួលនាងទៅលាបំណន់គ្រូនៅលើកំពូលភ្នំ លុះដើរទៅដល់ជ្រោះភ្នំ ក៏បង្គាប់ទៅនាងកូនសេដ្ឋី ឲ្យដោះគ្រឿងអលង្ការមកឲ្យខ្លួនមុននឹងគេប្រានាងឲ្យធ្លាក់ស្លាប់ក្នុងជ្រោះភ្នំនៅពេលនេះ។ នាងនោះក៏សុខចិត្តធ្វើតាមបង្គាប់ចោរ លុះបានដោះគ្រឿងអលង្ការអស់ហើយ នាងក៏និយាយទៅប្តីថា មុននឹងយើងបែកគ្នា ខ្ញុំសូមរាំជូនលោកប្តីសិន។ ចោរក៏សុខចិត្តឲ្យនាងនោះរាំ ដល់ចោរមើលកាន់តែជក់ចិត្ត ភ្លេចខ្លួន នាងកូនសេដ្ឋីក៏រុញប្រានចោរនោះធ្លាក់ក្នុងជ្រោះស្លាប់ទៅ ។ រឿងក្បោះក្បាយជាងនេះ តែខ្ញុំយកតែកន្ទែងដែលបញ្ជាក់ថា មនុស្សល្អ និង មនុស្សអាក្រក់ មិនចេះរស់នៅជាមួយគ្នាទេ ។*

មុននឹងបញ្ចប់ ខ្ញុំសូម ធ្វើការអធិប្បាយ អំពីពាក្យ យល់ ជឿ និង ជឿដោយប្រើបញ្ញា ពីព្រោះពាក្យទាំងបីនេះ ទាក់ទងនឹងពាក្យ ហេតុ ។

យល់ ដូចជា យល់ធម៌ ជាដើម

បានន័យថា យើងយល់នូវហេតុដែលបណ្ដាលឲ្យធម៌នោះកើត ។ សុរា ធ្វើឲ្យមនុស្ស ស្រវឹង វង្វេងស្មារតី ។ យើងយល់ដោយធ្លាប់បានឃើញ មនុស្សស្រវឹងស្រា និយាយផ្ដេសផ្ដាស ដើររកជល់គេជល់ឯង ។ តែចំពោះអ្នកវិទ្យាសាស្ត្រគេយល់ដោយ ឃើញជាតិសុរាចូលតាមឈាមទៅដល់ខួរក្បាល រួចហើយក៏ធ្វើឲ្យមនុស្សវង្វេងសប្រហែស ។

ជឿ ដូចជា ជឿធម៌ ជាដើម

ជឿធម៌ គឺជឿថាធម៌នោះត្រូវ ដោយមិនរវល់រកហេតុផល ពីព្រោះទុកចិត្ត លើអ្នកដែលយកធម៌នោះមកផ្សាយ ដូចជា ព្រះសង្ឃ ឬ លោកជម្មាចារ្យជាដើម។

ជឿដោយប្រើបញ្ញា គឺមុននឹងជឿ គេពិចារណារកហេតុផលសិន ពីព្រោះធម៌ទាំងឡាយកើតមកអំពីហេតុ ។ ហើយចំពោះ ធម៌ខ្លះដែលពិបាកនឹងយល់ គេយកធម៌នោះទៅធ្វើការពិសោធន៍ដោយខ្លួនឯងជាមុនសិន មុននឹងថា ជឿ ឬមិនជឿ គឺ មុននឹងថា ធម៌នោះត្រូវ (ឲ្យបុណ្យ ឲ្យសុខ) ឬ មិនត្រូវ (ឲ្យបាប ឲ្យទុក្ខ) ។

នេះក៏ជាពាក្យប្រៀនប្រដៅមួយដែរ របស់ព្រះយើង ។ ពីព្រោះការពិសោធន៍ ជា **ការប្រតិបត្តិ** ដែលអាចជួយយើងឲ្យឆាប់យល់ ។ ដូចជានៅសាលា ក្នុងការសិក្សាគណិតសាស្ត្រ (Mathématiques) ឬ រូបសាស្ត្រ-គីមី (Physique-Chimie) ក៏មានធ្វើលំហាត់ធ្វើការពិសោធន៍ ដែរ ។

យកពាក្យថា « ធម្មទាំងឡាយ កើតមក អំពីហេតុ » មកអនុវត្ត ក្នុងជីវិតរស់នៅសព្វថ្ងៃនេះ នាំឲ្យយើងបានសេចក្ដីសុខច្រើន អាចបន្ថយការខឹងនឹងអ្នកដទៃ បានខ្លះ ដូចជា ខឹងនឹងអ្នកដឹកនាំប្រទេសជាតិជាដើម ។

ឧទាហរណ៍ ខ្ញុំធ្លាប់ខឹងនឹងអ្នកដែលមិនគោរពម៉ោងពេលដែលបានណាត់គ្នារួចហើយដែរ ។ មានពេលខ្លះខ្ញុំចាំគេរាប់ម៉ោង ទម្រាំគេមកដល់ ហើយដល់ពេលគេប្រាប់ខ្ញុំនូវហេតុពិតដែលធ្វើឲ្យគេមកយឺតនោះ ខ្ញុំក៏ឈប់ខឹងនឹងគេទៅ ។ ដូចជាយើងក៏ធ្លាប់ខឹងនឹងអ្នកដឹកនាំប្រទេសជាតិ ថាម្ដេចក៏មិនធ្វើបែបនេះទៅ ដើម្បីនឹងបន្ថយចំនួន អ្នកអត់ការងារធ្វើ ។ ការពិតការដឹកនាំប្រទេស ក៏មិនសូវជាខុសនឹងការដឹកនាំគ្រួសារដែរ ។ ក្នុងគ្រួសារនីមួយៗ អ្នកណាមិនចង់មានបានដូចគេឯង ហើយម្ដេចក៏នៅតែមានគ្រួសារអ្នកក្រដែរ ។ តើហេតុពិត មកពីអ្វី ? ដូច្នេះ យើងគប្បី ដឹករក ហេតុពិតជាមុនសិន មុននឹងខឹង មុននឹងបន្ទោស អ្នកដទៃ ។

# តើអ្វីទៅ ធម៌

*តាម ព្រះពុទ្ធសាសនា ពាក្យថា ធម៌ នេះ មានន័យទូលំទូលាយណាស់ ។ ធម៌ គឺ ច្បាប់ធម្មជាតិ ។ ចំពោះអ្នកកាន់ព្រះពុទ្ធសាសនា ធម៌ គឺ ពាក្យប្រៀនប្រដៅរបស់ព្រះ ពុទ្ធ ។ យើងរស់នៅសព្វថ្ងៃនេះ គឺនៅក្រោមច្បាប់ ធម្មជាតិយើងគេចពីច្បាប់ធម្មជាតិមិនបានទេ ។ ច្បាប់ធម្មជាតិមួយ ដែលយើងគេចមិនរួច គឺ « តែមានការកើត ត្រូវតែមានការស្លាប់ » ។ ដើម្បីយើងបានសុខ ទាល់តែយើង រស់នៅឲ្យស្របនឹង ច្បាប់ ធម្មជាតិ ។ ដូចជាច្បាប់ មួយ ដែល គេច្រើនតែភ្លេច គឺ ៖*

*« សត្វលោកទាំងអស់ (មិនថា មនុស្ស ឬ សត្វតិរច្ឆាន)សុទ្ធតែ ចង់បានសេចក្តីសុខទាំងអស់គ្នា ហើយក៏មិនចង់ជួបនឹង ការទុក្ខលំបាកដែរ » ។ បើដូច្នេះ យើងគប្បីកុំធ្វើបាប អ្នកដទៃ ដោយប្រការណាមួយឡើយ ។*

## ៧

## ធម៌

*យើងច្រើនឮ គេនិយាយពាក្យ ធម៌ កាលណាគេនិយាយពីសាសនា ។ ដូចជាធម៌ នៅក្នុង គ្រឹស្តសាសនា នៅក្នុង សាសនាអ៊ីស្លាម នៅក្នុង ព្រហ្មញ្ញសាសនា នៅក្នុង ពុទ្ធសាសនា ជាដើម ។ នៅពេលនេះ ខ្ញុំសូមលើកតែ ធម៌ បីពួក មកអធិប្បាយ គឺ ១-ធម៌ពិត* (la Vérité) *២-ធម៌នៃសាសនាដទៃពីពុទ្ធសាសនា ៣-ធម៌នៅក្នុងពុទ្ធសាសនា ។*

*ធម៌ពិត* (la Vérité)

*ធម៌ពិត គឺធម៌ដែលត្រូវតែមាន ទោះបីអ្នកនោះ ជឿ ឬ មិនជឿ សាសនាណាមួយ*

ក៏ដោយ។ ឧបមា ដូចយើង ឈរហាលភ្លៀង ដោយអត់មានឆ័ត្របាំងក្បាល នោះមុខជាទទឹកភ្លៀងហើយ ទោះបី យើងកាន់ ឬ មិនកាន់សាសនាក៏ដោយ ។ មកដល់ត្រង់នេះ សូមជំរាបពីខ្លួនខ្ញុំ ដែលជាអ្នកកាន់ពុទ្ធសាសនា ។ កាលខ្ញុំនៅក្មេង ចាស់ៗ អ្នកកាន់សីល ក្នុងព្រះពុទ្ធសាសនា គាត់ប្រាប់ខ្ញុំថា « លោកយាយនេះ គាត់មានរូបរាងស្អាត មកពីជាតិមុនគាត់កាន់សីល ហើយជាតិនេះគាត់ក្រ មកពីជាតិមុនគាត់មិនសូវបានធ្វើបុណ្យ ដាក់ទាន » ។ គាត់មានប្រសាសន៍ បែបនេះ ខ្ញុំអត់មានភ្ញាក់ផ្អើលអ្វីទេ ពីព្រោះនៅស្រុកខ្មែរមនុស្សកាន់ពុទ្ធសាសនា ស្ទើរតែទាំងអស់គ្នាទៅ ហើយ ។ តែដល់ខ្ញុំមករស់នៅស្រុកបារាំង ដែល អ្នកកាន់ពុទ្ធសាសនាស្ទើរតែគ្មាន ហើយក៏មានមនុស្សរូបរាងស្អាតៗច្រើនដែរនោះ ធ្វើឲ្យខ្ញុំសួរថា ហេតុអ្វី ក៏អ្នកដែលមិនកាន់ព្រះពុទ្ធសាសនា ក៏គេមានរូបល្អដែរ ។ ចម្លើយរបស់ខ្ញុំគឺថា គេមិនកាន់ព្រះពុទ្ធសាសនាមែន តែអំពើដែលគេធ្វើ ត្រូវនឹងសីល៥ ក្នុងព្រះពុទ្ធសាសនា ដូចជា មិននិយាយពាក្យអាក្រក់ ជេរប្រទេចគេ ឬ ក៏និយាយពាក្យរោយរាយឥតប្រយោជន៍ជាដើម ។

នេះបញ្ជាក់ថា <u>ធម៌ពិត នៅតែជាធម៌ពិត ដដែល</u> ទោះបីយើងចង់ឬ មិនចង់ក៏ដោយ ។ យើងត្រូវហ៊ាន មើលការពិត សាសនា មិនអាចជួយយើងបានទេ បើសម្លាប់គេ មុខជាបាបហើយ ! ព្រោះហេតុអ្វី ព្រោះថា តើយើងសុខចិត្តឲ្យគេមកសម្លាប់យើងទេ ? យើងមិនសុខចិត្ត ពីព្រោះយើងខ្លាចសេចក្តីស្លាប់ ។ បើយើងខ្លាចស្លាប់ គេក៏ខ្លាចស្លាប់ដែរ ។ ធម៌ពិត (la Vérité) មិនមែនជាធម៌របស់សាសនាណាមួយទេ ។ សាសនាកើតក្រោយ ធម៌ពិត ទេ ។ ចូរកុំទាស់គ្នាពីព្រោះតែការប្រកាន់សាសនារៀងៗខ្លួន។

<u>ធម៌ក្រៅពុទ្ធសាសនា</u>

គឺធម៌ ដែលមិនមែនជាធម៌ព្រះពុទ្ធ ដូចជាថា ៖ មនុស្សយើងម្នាក់ៗ មាន អាត្ម័ន មាន ព្រលឹង អមតៈ(មិនស្លាប់) បន្តពីជាតិមួយទៅជាតិមួយជានិច្ច ជាដើម ។

*ធម៌នៅក្នុងពុទ្ធសាសនា*

*ខ្ញុំ មិននិយាយថាធម៌ **របស់** ពុទ្ធសាសនាទេ ពីព្រោះធម៌ទាំងអស់មានរួចមកហើយ ព្រះពុទ្ធ **មិនបានបង្កើត** ធម៌ដែលព្រះអង្គបានសម្តែងនោះទេ យើងសួរថាបើព្រះអង្គមិនបង្កើត ហើយដោយមុនព្រះអង្គត្រាស់ដឹង ធម៌ខ្លះមិនដែលមានផង ដូចជា អរិយសច្ច ជាដើម តើអ្នកណាបង្កើតធម៌នោះ? មុននឹងឆ្លើយខ្ញុំសូមធ្វើការវែកញែក រវាងពាក្យ « បង្កើត » និងពាក្យ « រកឃើញ » ។ បង្កើត បានន័យថា បង្កើតអ្វីៗ ដែលមិនទាន់មានហើយធ្វើឲ្យមានឡើង ដូចជាម្តាយបង្កើតកូន។ ចំពោះពាក្យ « រកឃើញ » គឺ រកឃើញនូវរបស់អ្វីដែលបាត់បង់ ពោលគឺរបស់នោះមាន តែមិនដឹងនូវឯណា ដូចជា រកឃើញនូវកំណប់ ឬ ដូចជាអ្នកវិទ្យាសាស្រ្ត រកឃើញ រូបមន្ត នៃច្បាប់ធម្មជាតិ ឬ ព្រះពុទ្ធរកឃើញធម៌នាំទៅនិព្វាន ជាដើម ។ បានន័យថា* **និព្វាន** *មាន តែមុនព្រះពុទ្ធត្រាស់ដឹង នៅលើលោកយើងសព្វថ្ងៃនេះ មិនទាន់មានអ្នកណាមួយរកឃើញនៅឡើយ ។ តែព្រះពុទ្ធទាំងឡាយ ដែលបានត្រាស់ដឹង សុទ្ធតែបានរកឃើញនូវធម៌នាំទៅនិព្វាននេះជានិច្ច ។ យើងសួរថាតើសំអាងលើអ្វីថា និព្វានមាន? ដោយ ទាំងលោកអ្នកខ្លះ ទាំងខ្ញុំ សុទ្ធតែមិនដែលឃើញនិព្វានដូចតែគ្នា នេះស្រេចតែទៅលើ ជំនឿ ឬ ការទុកចិត្តលើការត្រាស់ដឹងនៃព្រះពុទ្ធ រៀងៗខ្លួន ។ ចំពោះអ្នក ទុកចិត្តលើការត្រាស់ដឹងនៃព្រះពុទ្ធ គឺ គេសំអាងថា មុនព្រះសម្មាសម្ពុទ្ធគោតម ក៏មានព្រះពុទ្ធច្រើនព្រះអង្គបានសម្រេចនិព្វានរួចទៅហើយ លុះដល់សម័យព្រះពុទ្ធគោតម ព្រះអង្គ ព្រមទាំងសាវកជាច្រើន ក៏បានសម្រេចនិព្វានដែរ ។ ដូច្នេះ និព្វាន[7]មាន ។*

[7] *នេះជាយោបល់ខ្ញុំផ្ទាល់ទេ ចំពោះ**និព្វាន** ៖ ចំពោះនិព្វាន ដោយមិនមានសភាពដូចអ្វីៗដែលមាននៅក្នុងលោកយើងសព្វថ្ងៃនេះទេ តើមានពាក្យឯណា មកពន្យល់ មកឲ្យនិយមន័យនិព្វានបាន ។ ឧបមាដូចរថយន្តយើងជិះសព្វថ្ងៃនេះ យើងអាចរកពាក្យមកពិព៌ណនាអំពីរថយន្តបាន តែបើសម័យ*

*យើងសួរថា ធម៌កើតនៅពេលណា  អ្នកណាបង្កើតធម៌នោះ ? នេះចូលមកដល់សំណួរសត្វលោក កើតនៅពេលណា  អ្នកណាជាអ្នកបង្កើត   សំណួរទាំងនេះ មិនងាយឆ្លើយឲ្យត្រូវចិត្តគ្រប់ៗគ្នាបានទេ យើងមើលរហូតមកដល់សព្វថ្ងៃនេះ ចំពោះសំណួរ ថាតើ* « **ព្រះ មាន ឬ មិនមាន** » ( Est-ce Dieu existe ?) *ក៏គ្មានចម្លើយត្រូវគ្នាដែរ ។ ម៉្យាងទៀត ទោះបីជាមានចម្លើយក៏ដោយ  ក៏ចម្លើយទាំងនោះពុំអាចដោះស្រាយនូវបញ្ហា ទុក្ខនៃមនុស្សលោកបានដែរ ។ ដូច្នេះនាំតែខាតពេល  នាំតែបង្កើតសង្គ្រាមសាសនាពីព្រោះតែសំណួរគ្មានចម្លើយនោះ ។  ដោយយើងរស់នៅក្នុងធម្មជាតិ ដូច្នេះយើងត្រូវស្គាល់ច្បាប់ធម្មជាតិដើម្បីបានសុខ  ហេតុនេះហើយ បានជាធម៌ដែលព្រះពុទ្ធរកឃើញ  ហៅថាច្បាប់ធម្មជាតិ ។  ធម៌របស់ព្រះអង្គ យកច្បាប់ធម្មជាតិជាគោល ។*

*ពាក្យថា* **ធម៌**  *ក្នុងព្រះពុទ្ធសាសនាមានន័យច្រើនណាស់ គឺសភាវៈ ទ្រទ្រង់សត្វលោក ដូចជា បុណ្យ  បាប កុសល អកុសល និព្វាន  ហេតុ ធម្មតា ប្រក្រតី  ធម្មជាតិ ប្រាជ្ញាញាណ កិរិយាមារយាទ ជាដើម។  បន្ទាប់មក  មានពាក្យ  សង្ខារធម៌  គឺ  ធម៌ដែលកើតឡើង ដោយគ្រឿងប្រកប តាក់តែង  ប្រមូលផ្សំ  ដែលហៅថាសង្ខារ ។*

---

*ព្រះពុទ្ធ ដែលមិនទាន់មានរថយន្តផង តើឲ្យអ្នកសម័យនោះពិព៌ណនាអំពីរថយន្ត ដូចម្តេចកើត។ ហេតុនេះហើយបានជាមកដល់សព្វថ្ងៃនេះ ក្នុងគម្ពីរ បើថ្លែងអំពីនិព្វាន គេច្រើនតែនិយាយនូវអ្វីដែល* ***<u>មិនមែនជានិព្វានទៅវិញ</u>*** *។ ដូចជានិព្វាន មិនមែនជាសង្ខារធម្ម មិនមានកើត  មិនមានស្លាប់ជាដើម ។ ហើយអ្នកខ្លះ ដល់ថាមិនមានកើត ក៏បកស្រាយថានិព្វាន គឺ សូន្យ ហើយក៏មិនចង់ទៅនិព្វានទេ ពីព្រោះមិនចង់សូន្យ ។ នេះហើយការបកស្រាយ នូវអ្វីៗ ដែលយើងមិនទាន់ស្គាល់  មិនទាន់ឃើញ មិនទាន់ទៅដល់ ។  ចំពោះខ្ញុំវិញ ជាអ្នកបដិបត្តិធម៌ព្រះ ដោយខ្ញុំយល់ដោយខ្លួនខ្ញុំថា មគ្គប្រកបដោយអង្គ៨ នឹងផ្តល់ឲ្យខ្ញុំនូវសេចក្តីសុខដោយ <u>ពិតប្រាកដ</u> នោះខ្ញុំគ្រប់គ្រាន់ហើយ ខ្ញុំមិនចំណាយពេលសួរដេញដោលរកចម្លើយដែលយើងមិនដឹងដូចតែគ្នានោះទេ ។ ទោះបីព្រះសង្ឃក៏លោកឆ្លើយតែតាមគម្ពីរដែរ ប្រសិនបើសព្វថ្ងៃនេះ មានព្រះអរហន្ត ដូចកាលសម័យព្រះពុទ្ធ នោះលោកអាចពន្យល់យើងបានខ្លះ ។*

ឧបមាដូច សម្ងកកូរ ជា សង្ខារធម៌ ពីព្រោះកើតឡើង ដោយផ្សំគ្រឿងជាច្រើន ដូចជា អង្ករលីញ ល្ហុងខ្ចី សាច់ត្រី ទឹកត្រី ទឹក ជាដើម ។ ហើយ ទឹកត្រី ក៏ជាសង្ខារធម៌ដែរ ពីព្រោះ ផ្សំដោយស្ងោជាមួយគ្នា កូនត្រី អំបិល ទឹក ជាដើម ។ ហើយទឹក ក៏ជាសង្ខារធម៌ទៀត ពីព្រោះតាមអ្នកវិទ្យាសាស្រ្តខាងគីមី ថាទឹកផ្សំដោយ ខ្យល់ អុកស៊ីសែន និង អ៊ីដ្រូសែន ។ ក្នុងឧទាហរណ៍ទឹកត្រីនេះ យើងឃើញថា សង្ខារធម៌ នីមួយៗសុទ្ធតែផ្សំដោយសង្ខារធម៌ឯទៀត ដែលផ្សំដោយសង្ខារធម៌ ឯទៀតៗ បេះតែតៗទៅ តូចៗទៅ ល្អិតៗទៅ ដូចយើងធ្លាប់ឮហើយថា កិលេស ក៏មានកិលេសតូចសុខុម ហៅថា អនុស្ស័យកិលេសដែរ ។ ដូច្នេះសង្ខារធម៌ ត្រូវតែប្រែប្រួល កាលណាគ្រឿងផ្សំណាមួយ ប្រែប្រួល ដូចជាសម្ងកកូរ ត្រូវប្តូរគុណភាព ដូចជាផ្អូមជាដើម កាលណាគ្រឿងផ្សំណាមួយវាប្តូរគុណភាព។ នេះជាភាព ចំណុះគ្នា ប្រទាក់ប្រទងគ្នាទៅវិញទៅមកនៃសង្ខារធម៌ ។ ដូចជា វិបត្តិសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក ធ្វើឲ្យសេដ្ឋកិច្ចទ្វីបអឺរុប ចុះថយដែរ ។ ដោយ<u>តាមច្បាប់ធម្មជាតិ</u> អ្វីៗក្នុងលោកនេះ សុទ្ធតែមិនទៀង ដូច្នេះ សង្ខារធម៌ ក៏មិនទៀងដែរ ។ <u>មានច្បាប់ធម្មជាតិមួយទៀត</u> គឺ **កើត រលត់**

កាលណាមានការកើត ត្រូវតែមានការរលត់ ។ យើងថាច្បាប់ធម្មជាតិ ពីព្រោះតាមការសង្កេតមកពុំដែលមានទេ មនុស្សមិនស្លាប់ គឺ **អមតៈ**។ អ្នកអាយុវែង បានយ៉ាងច្រើនលើសពី ១០០ឆ្នាំ ហើយហួសពី ១០០ឆ្នាំទៅ បើនៅរស់ក៏មិនសប្បាយណាស់ណាដែរ ពីព្រោះរាងកាយទាំងមូល កាន់តែចាស់ទ្រុឌទ្រោម ភ្នែកក៏ស្រវាំង ត្រចៀកក៏ធ្ងន់ ។ បើនិយាយអំពី សង្ខារធម៌វិញ ធម៌ទាំងឡាយតែងតែ កើត តាំងនៅ រលត់ ។ អ្វីៗទាំងពួងក្នុងលោកសុទ្ធជា សង្ខារធម៌ គឺ ធម៌ដែលកើតឡើង ដោយ គ្រឿងប្រកបតាក់តែងដោយប្រមូលផ្សំ ។ មនុស្សយើងក៏ជាសង្ខារធម៌ ភ្លើងទៀនដែលកំពុងតែឆេះក៏ជាសង្ខារធម៌ ។ ភ្លើងទៀន ដែលឆេះរលត់ ឆេះរលត់ តៗគ្នា មើលទៅហាក់ដូចជាភ្លើងតែមួយ

ដែលឆេះរហូតហើយរលត់ទាល់តែអស់ទៀន ឬ ក៏យើងពន្លត់ ។ តាមពិត ភ្លើងទៀនឆេះរលត់ ឆេះរលត់ ជាបន្តគ្នា ជាប់រហូត ។ គ្រាន់តែ មុននឹងរលត់ ភ្លើងនោះជាហេតុឲ្យមានភ្លើងឆេះបន្ត ដូចជា មនុស្សយើង នៅពេលមុនស្លាប់ ចុតិចិត្ត (ចិត្តនៅពេលដង្ហើមចុងក្រោយមុនដាច់ខ្យល់) នៅភពបច្ចុប្បន្ន រលត់ បណ្តាលឲ្យ បដិសន្ធិចិត្តនៅភពថ្មី កើតបន្តភ្លាម រួចហើយទើបចិត្តនោះចូលភវង្គ គឺ ធ្វើកិច្ចរក្សាភព ជាបន្តក្នុងកំណើតថ្មី ។ ដូច្នេះ យើងឃើញថា ស្លាប់ហើយកើត (បដិសន្ធិ)ភ្លាមៗ តែត្រូវទៅកើតនៅឋានណា ឬ កន្លែងណា នោះយើងមិនដឹងទេ ទាល់តែព្រះពុទ្ធដោយការត្រាស់ដឹងរបស់ព្រះអង្គទើបដឹងដោយទ្រង់ញាណ។

ឥឡូវខ្ញុំសូមលើកយកមកពិភាក្សា អំពីការត្រាស់ដឹងនៃព្រះពុទ្ធ តើព្រះពុទ្ធត្រាស់ដឹង ពិតមែន ឬមិនពិត ? យើងមានអំណាចសួរ ពីព្រោះយើងពុំបានឃើញ ។ ដោយយើងពុំបានឃើញ ដូច្នេះដើម្បីនឹងជឿបាន លុះត្រាតែមានអ្វីជាភស្តុតាងហើយសមហេតុសមផល ។ ការត្រាស់ដឹងព្រះពុទ្ធមានបីផ្នែក គឺ ១-ចតុរារិយសច្ច ២-ចំពោះសត្វលោកណាក៏ដោយព្រះអង្គអាចប្រមើលមើលឃើញថាសត្វលោកនោះ ធ្លាប់មានកំណើតជាអ្វី ៣- ចំពោះសត្វដែលស្លាប់ ព្រះអង្គ ដឹងនូវភពដែលសត្វនោះបានអន្ទោលទៅកើត ។ យើងសួរថាតើការត្រាស់ដឹងធម៌ទាំង បីនេះ សមហេតុសមផលទេ? ឧបមា ថាព្រះអង្គមិនបានត្រាស់ដឹងធម៌ទី ១ ។ <u>ចុះធម៌ទី១</u> នេះដែលមានរហូតដល់សព្វថ្ងៃនេះចេញមកពីណា? ហើយប្រសិនបើជាធម៌របស់សាសនាផ្សេង ម្តេចក៏ម្ចាស់ សាសនានោះ ឬ អ្នកកាន់សាសនានោះមិនឃើញតវ៉ានៅពេលដែលព្រះពុទ្ធផ្សាយធម៌ទីមួយនេះដល់ បញ្ចវគ្គីយ៍ នៅពារាណសី ?

<u>ចំពោះធម៌ទី២</u> ព្រះអង្គមិនត្រឹមតែដឹងអតីតជាតិនៃសត្វលោកប៉ុណ្ណោះទេ ព្រះអង្គត្រាស់ដឹងជាតិកំណើតព្រះអង្គទាំងអស់ ។ ដូចជាមុនជាតិចុងក្រោយ ព្រះអង្គជាព្រះវេស្សន្តរ ហើយព្រះអង្គត្រាស់ដឹងថា មុនព្រះអង្គ ក៏មានព្រះពុទ្ធរាប់រយកោដិ ដែលបានត្រាស់ដឹង

ដូចព្រះអង្គដែរ ដោយទាំងមានព្រះនាមព្រះពុទ្ធនោះផង ។ នៅជាតិខ្លះព្រះអង្គធ្លាប់កើតជាសត្វតិរច្ឆានក៏មាន ព្រះអង្គឥតមានលាក់បាំងអ្វីទាំងអស់។ ភស្តុតាងសមហេតុផលមួយទៀតគឺ ទាំងរឿងប្រវត្តិ ទាំងធម៌ដែលព្រះអង្គបានសំដែង សុទ្ធតែស្របគ្នាទាំងអស់ គឺមិនប្រឆាំងនឹងគ្នា ពីព្រោះខ្ញុំច្រើនសង្កេតឃើញចំពោះសំដីមនុស្សកុហក ច្រើនតែជាន់កែងឯង ។ ដូចកាលព្រះអង្គស្វែងរកធម៌ ធ្វើទុក្ករកិរិយា ព្រះមាតាព្រះអង្គដែលទៅកើតនៅឋានតុសិត បានចុះមកមើលព្រះអង្គ នៅឋានកណ្ដាលយើងនេះ ។ ដល់ព្រះអង្គបានត្រាស់ដឹង ព្រះអង្គបានយាងទៅប្រោសពុទ្ធមាតា នៅឋាន តាវតឹង្សៗ មកដល់ត្រង់នេះ បើព្រះអង្គមិនបានត្រាស់នូវ ធម៌ទី៣ ទេ នោះយើងអាចសួរថាតើ ព្រះអង្គដឹងថា ពុទ្ធមាតា កើតនៅឋានតុសិត ដោយរបៀបណា ? ដូច្នេះមានតែព្រះអង្គត្រាស់ដឹងធម៌ទី៣នេះ ទើបព្រះអង្គទ្រង់យាងទៅដល់ ហើយទើបមានធម៌អភិធម្ម ទុកឲ្យយើងរហូតដល់សព្វថ្ងៃនេះ។

ទាំងនេះជាហេតុផល សម្រាប់លោកអ្នកយកទៅពិចារណា ក្នុងសំណួរថា ព្រះពុទ្ធបានត្រាស់ដឹងមែន ឬ មិនមែន ។ បើលោកអ្នកជឿថាមែន នោះសំណួរ ថា **តើស្លាប់ហើយកើតទៀត** មិនពិបាកឆ្លើយទេ ពីព្រោះធម៌ត្រាស់ដឹងទី២ និងទី៣ បង្ហាញថា ស្លាប់ហើយកើតទៀត រួចទៅហើយ ដូចជា ព្រះវេស្សន្តរ ឬ ព្រះពុទ្ធមាតាជាឧទាហរណ៍ស្រាប់។

# ធម៌ **អនត្តា**

ធម៌ អនត្តា នេះមានតែនៅក្នុងព្រះពុទ្ធសាសនា

យើងទេ ។ មានន័យថា ៖

*ខ្លួនយើង  មិនមែនជារបស់ យើង។*

*លោកអ្នក អាចសួរថា*

*បើខ្លួនយើង មិនមែនជារបស់យើង   តើវា ជារបស់*

*អ្នក ណា ?*

*លោកអ្នក នឹងរកឃើញ នូវចម្លើយនៃសំណួរនេះ  ដោយ ខ្លួនឯង បន្ទាប់ពីបានអាន អត្ថបទ ដូច តទៅនេះ .....។*

**៨**

## ធម៌អនត្តា

*ជាដំបូងខ្ញុំសូមធ្វើការវែកញែក រវាង ភាសាអ្នកស្រុក និង ភាសាធម៌ ។ ភាសាអ្នកស្រុក គឺជាភាសាដែលមនុស្សទូទៅបាន សន្មតប្រើ ដើម្បីប្រាស្រ័យទាក់ទងគ្នាក្នុងការរស់ នៅក្នុងសង្គមមនុស្ស មិនថា ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬ អ្នកនៅក្រៅព្រះពុទ្ធសាសនា ឡើយ។ ចំពោះ ភាសាធម៌ វិញ គឺ ភាសាដែលជាប់ទាក់ទងនឹងធម៌ព្រះពុទ្ធ ។  ដូចជា ភាសាអ្នកស្រុកថា « វានេះជាកូនរបស់ខ្ញុំ »  ដល់ភាសាធម៌វិញថា  « កូនរបស់ខ្ញុំឯណា បើខ្ញុំ មិនមែនជារបស់ខ្ញុំផង » ។ ការខុសគ្នានេះ ខ្ញុំសូមពន្យល់ដូចតទៅនេះ ។*

នៅសម័យមុនពុទ្ធសាសនា មានសាសនាដទៃខ្លះមានរួចមកហើយ ដូចជា ព្រហ្មញ្ញសាសនាជាដើម។ ដោយទ្រឹស្តីខ្លះក្នុងព្រះពុទ្ធសាសនា ខុសពីសាសនាដទៃ ហេតុនេះហើយបានជា មានពាក្យខ្លះសរសេរអក្សរដូចគ្នា តែមានន័យខុសគ្នា។ ដូចជាពាក្យថា « យើង ឬ ខ្ញុំ » ជាដើម ។ តាមលទ្ធិ ក្រៅពីព្រះពុទ្ធខ្លះ គេថា មនុស្ស យើងម្នាក់ៗ ដល់ស្លាប់ទៅមាន អាត្មន ឬ ព្រលឹង[8] អមតៈ ជាប់តាមជានិច្ច ជាអចិន្ត្រៃយ៍ ពីជាតិមួយទៅជាតិមួយ ដូច្នេះ ពាក្យថា

| « យើង ឬ ខ្ញុំ » គឺសំដៅ អាត្មន ឬ ព្រលឹង |
|---|

(ក១) ។

ចំពោះទ្រឹស្តីព្រះពុទ្ធសាសនាវិញ មនុស្សយើងម្នាក់ៗ មានតែ **កាយ** និង **ចិត្ត** ឬ **ខន្ធ៥** ហើយក៏គ្មានអ្វី ក្រៅពីខន្ធ៥ នេះដែរ ។ ខន្ធ៥ មាន « **រូប វេទនា សញ្ញា សង្ខារ** និង **វិញ្ញាណ** » ។

ដូច្នេះចំពោះពាក្យអ្នកស្រុក ថា ***យើងម្នាក់ៗ មាន កាយ និងចិត្ត*** នោះ ត្រូវនឹងធម៌ព្រះពុទ្ធហើយ ដោយគ្រាន់តែសន្មតថា [ កាយ គឺ រូប ] និង [ ចិត្ត គឺ វេទនា សញ្ញា សង្ខារ និង វិញ្ញាណ ] ។ ហើយពាក្យថា

| « យើង ឬ ខ្ញុំ » គឺសំដៅ កាយ និង ចិត្ត |
|---|

(ក២) ។

តទៅនេះ ខ្ញុំសន្មត យក និយមន័យ (ក២) មកប្រើ រហូត បើខ្ញុំមិនបានបញ្ជាក់ ។ ដោយ ធម៌ព្រះពុទ្ធ ៖

**អនិច្ចំ ទុក្ខំ អនត្តា** និងធម៌

[8] សូមអាន [1] L'enseignement du Bouddha Walpola Rahula , page75 នៅក្នុង « **ផ្នែកសៀវភៅ និង ឯកសារពិគ្រោះ** »

**សព្វេ សង្ខារា អនិច្ចា**

**សព្វេ សង្ខារា ទុក្ខា**

និង **សព្វេ ធម្មា អនត្តា**

*យើងបាន ៖*

***ជ១-*** *សង្ខារធម៌ទាំងឡាយ មិនទៀង* (សព្វេ សង្ខារា អនិច្ចា)

***ជ២-*** *ធម៌ណា មិនទៀង ធម៌នោះជាទុក្ខ* (អនិច្ចំ ទុក្ខំ)

***ជ៣-*** *ធម៌ណា មិនទៀង ធម៌នោះ មិនមែនយើង មិនមែនខ្លួនយើង មិនមែនរបស់យើង*

(សព្វេ ធម្មា អនត្តា ) *ហើយជា ទុក្ខ ។*

- *ដោយ ខន្ធ៥ ជាសង្ខារធម៌*[9] *ដូច្នេះ ខន្ធ៥ មិនទៀង (ដោយ ជ១) ហើយ*

« *យើង ឬ ខ្ញុំ* » *ក៏ មិនទៀង (ដោយ ក២) ។*

- ***ដោយ ធម៌ណាមិនទៀង*** **ធម៌នោះ មិនមែនយើង មិនមែនខ្លួនយើង មិនមែនរបស់**

***យើង ហើយជា ទុក្ខ*** (*ដោយ ជ៣*) *។*

*<u>សង្កេត</u>*

*១- យើងឃើញថា និយមន័យ (ក១) និង និយមន័យ (ក២) ខុសគ្នាស្រឡះ ។*

*នេះគួរឲ្យឆ្ងល់ដែរ មនុស្សនៅតែមនុស្សដដែល ម្ដេចក៏មាននិយមន័យពីរខុសគ្នា ?*

*ការឲ្យនិយមន័យពីរខុសគ្នា អំពីមនុស្សនេះ មិនមែនមកពីមនុស្សដូរទេ គឺមកពីទ្រឹស្ដីពីរ ខុសគ្នា ។ ទ្រឹស្ដីទី១ ខាងព្រហ្មញ្ញសាសនា គេថា មនុស្សមានព្រលឹងទៀងនៅដដែលមិនផ្លាស់ប្រែប្រួល ។ ចំពោះទ្រឹស្ដីទី២ ដោយធម៌* **អនិច្ចំ** និង **កើតរលត់***គ្រប់តែសង្ខារធម៌ទាំងអស់ ដូច្នេះមនុស្សដូរគ្រប់ពេលវេលា ។*

---

[9] *ធម៌កើតឡើង ដោយគ្រឿងផ្សំ គឺដោយយកធម៌ដទៃមកផ្សំជាមួយគ្នា ដូចជាសម្ល កកូរ បានមក ដោយយកគ្រឿងជាច្រើនមកផ្សំបញ្ចូលលាយជាមួយគ្នា ។*

២- ដោយន័យ មនុស្សដូរគ្រប់ពេលវេលា នេះហើយ បានជាមានធម៌ព្រះចៃថា ៖

- នេះ[10] មិនមែន របស់អញ [Ceci ne m'appartient pas,] (1)

- អញ មិនមែន នេះ [je ne suis pas ceci,] (2)

- នេះ មិនមែន ខ្លួនអញ ។ [ceci n'est pas mon égo.] (3)

តទៅនេះ ជាការបកស្រាយតាមខ្ញុំយល់ ចំពោះ (1) (2) (3) ៖

(1) ក្នុងន័យថា ដូចរូបកាយ យើង កាលណាវាឈឺ វាក៏ឈឺទៅ ទុកជាយើងមិនចង់ឲ្យវាឈឺក៏ដោយ ។ បានន័យថាយើងបង្គាប់វាមិនបានដូចចិត្តយើងទេ ។ ដូច្នេះ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនជារបស់យើងទេ ។

(2) ក្នុងន័យថា យើង ឬ ខ្ញុំ ឬ អញ មិនមែន រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ទេ ។ យើងអាចសួរថា ចុះបើ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែន យើង ឬ ខ្ញុំ ឬ អញ តើ យើង ឬ ខ្ញុំ ឬ អញ ជាអ្វីទៅ? ឆ្លើយថា គឺ**ទទេ** អត់មានអ្វីទាំងអស់ គឺគ្រាន់តែជាពាក្យ សន្មត ក្នុងការប្រាស្រ័យ ទាក់ទងគ្នាតែប៉ុណ្ណោះ ។

(3) ក្នុងន័យថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែន ខ្លួនយើង ឬ ខ្លួនខ្ញុំ ឬ ខ្លួនអញទេ ។ ដែលយើងថា « អញៗ » នោះ អត់មានអ្វីនៅក្នុងនោះទេ ដូចពពុះទឹកអញ្ចឹង។

រួមសេចក្តីទៅ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ គឺ ខន្ធ៥ នេះ គេអត់ស្គាល់យើងថាជាម្ចាស់របស់គេទេ ។ គឺយើងទេតើ ដែលឃើញគេចេះប្រាស្រ័យទាក់ទងគ្នា គឺថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ចេះសហការជាមួយគ្នា យើងក៏**<u>តាំងខ្លួន</u>**ជាម្ចាស់នៃគេទៅ ហើយស្រឡាញ់គេ ជាប់ចិត្តនឹងគេ ហើយដល់ខន្ធ៥គេមិនស្តាប់បង្គាប់ យើង

[10] ពាក្យថា « នេះ » នៅទីនេះសំដៅសង្ខារធម៌ទាំងអស់ ដូចជា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាដើម ទោះបី ជាសង្ខារធម៌ ពី អតីត បច្ចុប្បន្ន ឬ អនាគត ផ្ទាល់ខ្លួន ឬ អ្នកដទៃ ក៏ដោយ ។

ក៏តាំងកើតទុក្ខតែខ្លួនឯង ។ ចំណែក រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ គេអត់ដឹងពួ
រើរវល់នឹងការឈឺចាប់យើងទេ ។ នេះជាការពិត ខំគិតនិងសង្កេតបន្តិចទៅ នឹងឃើញហើយ។ លោកអ្នកអាចសួរថា តើត្រូវធ្វើដូចម្ដេច បើបានជាជ្រុលស្រឡាញ់គេទៅហើយ ? តើរកអ្នកណាជួយបានទេ ? ខ្ញុំឆ្លើយថាបាន បើសុខចិត្តពិចារណាតាមដែលខ្ញុំបានធ្លើរួចមកហើយ ។

ខ្ញុំថា **ពិចារណា** តាមខ្ញុំ ។ តែខ្ញុំមិនបានថា **ឲ្យធ្វើតាមខ្ញុំ** នោះទេ ។ ពីព្រោះខ្ញុំមិនមានបំណងបង្ខំលោកអ្នកឲ្យធ្វើតាមខ្ញុំទេ តែបើបន្ទាប់ពីពិចារណាទៅ លោកអ្នកយល់ដូចខ្ញុំដែរ នោះលោកអ្នកក៏ធ្វើតាមការយល់របស់លោកអ្នកទៅ ។ នេះហើយដែលហៅថា ជឿ ឬ យល់ដោយប្រើបញ្ញា ។ បើថ្ងៃមុខស្រាប់តែឃើញខុសទៅវិញ កុំមកបន្ទោសខ្ញុំ ត្រូវបន្ទោសខ្លួនយើង កុំបន្ទោសអ្នកដែលប្រាប់យើង ។ ឥឡូវនេះខ្ញុំសូមជំរាបរបៀបដែលខ្ញុំបានពិចារណា។

ខ្ញុំគិតថា ឥឡូវនេះ បានជាជ្រុលតាំងខ្លួនជាម្ចាស់នៃ ខន្ធ៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណនេះទៅហើយ « អាត្មាអញ នៅតែតាំងតទៅទៀតចុះ » ។ **តែត្រូវប្រយ័ត្ន មិនឲ្យចិត្ត[11] នេះ មកទាញអញឲ្យទៅរក សេចក្ដីទុក្ខដែលអញមិនចង់ជួបនោះឡើយ** ។ លោកអ្នកអាចសួរថា បើចិត្តមិនស្ដាប់បង្គាប់យើងផង មិនមែនជារបស់យើងផង តើឲ្យយើងប្រយ័ត្ន របៀបណា ? ដើម្បីនឹងឆ្លើយ សូមលោកអ្នកសង្កេតមើល ដើមឈើ វានៅក្រៅពីខ្លួនយើង ហើយមិនចេះស្ដាប់ភាសាខ្មែរផង ម្ដេចយើងពត់វាឲ្យត្រង់បាន ហើយសត្វដំរី ខ្លាំងជាងយើងផង ម្ដេចក៏ហ្មដំរី ប្រើវាឲ្យទាញឈើហ៊ុបបាន ? ចំពោះចិត្តយើងក៏ដូច្នោះដែរ យើងអាចអប់រំចិត្តយើងបាន ។ យើងដឹងហើយថាចិត្តមានពីរពួកធំៗ

[11] តាមភាសាអ្នកស្រុក ចិត្ត នៅទីនេះ គឺសំដៅយក វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ វិញ្ញាណខន្ធ ហើយរូបរាងកាយ គឺ រូបខន្ធ ។ ដូច្នេះ មនុស្សយើងម្នាក់ៗ តាមភាសាអ្នកស្រុក មាន កាយ និង ចិត្ត ។

គឺចិត្តកុសល និងចិត្តអកុសល ។ ចិត្តអកុសលនាំយើងទៅរក «ទុក្ខ» ហើយចិត្តកុសលនាំយើងទៅរកសេចក្តីសុខ ទាំងបច្ចុប្បន្ន ទាំងអនាគត ។ ដូច្នេះដើម្បីជៀសទុក្ខ ត្រូវអប់រំចិត្តឲ្យធ្វើតែអំពើជាកុសល និង កុំឲ្យធ្វើអំពើអកុសល ។ បើនិយាយតាមភាសាអ្នកស្រុក គឺយើងសន្សំបុណ្យឲ្យបានច្រើន ហើយកុំធ្វើបាប ។ ដូច្នេះ ចិត្ត ពិតមែនតែមិនមែនជារបស់យើងក៏ដោយ តែយើងអាចអប់រំវាបាន ដោយយើងប្រើ **ចិត្តកុសល** ឲ្យទៅវាយប្រហារ **ចិត្តអកុសល** ហើយតែកាលណាចិត្តកុសលវាយឈ្នះចិត្តអកុសលហើយ នោះយើងដែលមិនមែនជាម្ចាស់នៃចិត្តទាំងពីរ នឹងបានសុខហើយ ។

រួមសេចក្តីទៅ បើយើងសុខចិត្ត ថា យើង ហើយនិង ខន្ធ៥ គឺដូចតែគ្នា[12] សុខចិត្តរួមសុខទុក្ខជាមួយគ្នា គឺថា បើចិត្ត នៃខន្ធ៥ បានសុខ យើងក៏បានសុខដែរ បើចិត្តនៃខន្ធ៥ មានទុក្ខ យើងក៏មានទុក្ខដែរ ។ ដោយយើងសុទ្ធតែចង់បានសុខគ្រប់ៗគ្នា យើងខំអប់រំ ចិត្តនៃខន្ធ៥ នោះទៅ ពោលគឺយើងកុំធ្វើបាប ដែលជាប្រភពនៃទុក្ខ ។ ធ្វើរបៀបនេះ ត្រូវនឹងច្បាប់ធម្មជាតិ ហើយ ច្បាប់ធម្មជាតិនេះក៏ជាធម៌ព្រះពុទ្ធដែរ។ បន្ទាប់ពី បានអប់រំចិត្ត ដូចខ្ញុំបានជំរាបខាងលើនេះហើយ លោកអ្នកខំពិចារណាតទៅទៀត។ <u>ពិចារណាលើអ្វីទៅ?</u> គឺពិចារណាថា ខន្ធ៥នេះ ជាទុក្ខ នេះតាមធម៌ព្រះពុទ្ធ ។ ដោយធម៌ព្រះពុទ្ធ ជាធម្មជាតិ ដូច្នេះយើងសង្កេតមើលអ្នកនៅ ជុំវិញខ្លួនយើង តាំងពីប្រពន្ធកូនយើង រហូតដល់អ្នកដទៃ <u>**តើខន្ធ៥ជាទុក្ខ ដូចពុទ្ធដីកាទេ?**</u> នេះហើយការពិចារណា ដែលខ្ញុំបាននិយាយរហូតមកទល់ពេលនេះ ។ **គឺពិចារណានូវធម៌ព្រះពុទ្ធ ថាត្រូវ ឬ មិនត្រូវ ដោយពឹងផ្អែក ទៅលើការសង្កេតនូវអ្វីៗទាំងអស់ដែលនៅជុំវិញខ្លួនយើង ។**

---

[12] ដូចតែគ្នា ជៀតែក្នុច ឬ ក៏ថា « មួយដំប និង បួន » ។

*ធម៌មួយទៀតដែលគួរយកមក**ពិចារណាដែរ** គឺ ថា **តណ្ហា** ការស្រឡាញ់ ប្រកាន់ថា ខ្លួន (រូបខន្ធ)យើង ជារបស់យើង ជាហេតុមួយនាំឲ្យកើតទុក្ខដែរ កាលណាខ្លួនយើង ចាស់ ស្បែកជ្រីវជ្រួញ ធ្មេញបាក់ ជាដើម ។ នេះមកពីអ្វី? គឺមកពី ធម៌មិនទៀង ។ ឧបមាដូចយើងទៅពឹងលើបង្គោលមួយ ដោយស្មានថាបង្គោលនោះមាំ តែដល់ថ្ងៃ មួយបង្គោលនោះបាក់ទៅ យើងក៏លិចលង់ទៅជាមួយនឹងបង្គោលនោះដែរ យ៉ាង ណាមិញ ដោយនឹកថាខន្ធ៥ទៀង មិនចេះស្លាប់ ដល់ថ្ងៃណាមួយស្លាប់មកដល់ ក៏ទុក្ខសោក ជាមួយនឹងខន្ធ៥នោះទៅ ។ នេះមកពីយើង យល់ថា ខន្ធ៥ ថាទៀង ថាជារបស់យើង ។ ដូចមានគាថាទី៦២ ក្នុងធម្មបទ ដូចតទៅនេះ ៖*

**បុត្តាមត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**

**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។**

ជនពាល តែងក្តៅក្រហល់ក្រហាយថា បុត្រទាំងឡាយរបស់អញមាន ទ្រព្យសម្បត្តិរបស់ អញមាន តាមការពិត **ខ្លួនមិនមែនជារបស់ខ្លួន** បុត្រទាំងឡាយនឹងមានមកពីណា ទ្រព្យនឹងមានមកពីណា ។

*សំណួរមួយទៀត មុននឹងបញ្ចប់ តើយើងខឹងនឹងបង្គោលដែលបាក់ ព្រោះតែពឹង មិនបាន? ឬ មួយក៏អាណិតបង្គោលដែលបាក់នោះ ។ ខ្ញុំយល់ថា គួរតែអាណិតអាសូរ ដល់បង្គោលដែលបាក់នោះ ពីព្រោះគ្នាក៏នៅក្រោមច្បាប់ អនិច្ចំ ដែរ ។ ប្រកចេញ មានតែ ពួតដៃគ្នា[13]កម្ចាត់ចិត្តអកុសល ដើម្បីបានសុខ សម្រេចនិព្វាន ។*

[13] *គឺយើងពួតដៃជាមួយនឹង ខន្ធ៥ ។*

# ៩

# ប្រយោជន៍ នៃ ធម៌ អនត្តា

**សព្វេ ធម្មា អនត្តា**  *មានន័យថា  ធម៌ទាំងឡាយ ទាំងពួង មិនមែន ជា របស់យើង*

*ក្នុងន័យនេះ ដោយ ខន្ធ៥ ក៏ជាធម៌ដែរ ដូច្នេះ ខន្ធ៥  ក៏មិនមែនជារបស់យើងគ្រប់គ្នាដែរ។ ហេតុអ្វីក៏ថាមិនមែនជារបស់យើង  ពីព្រោះ ព្រះពុទ្ធសាសនាដែលយកច្បាប់ធម្មជាតិ ជាគោល  សង្កេតឃើញថាធម្មជាតិ មានលក្ខណៈបី គឺ ៖* **អនិច្ចំ  ទុក្ខំ  អនត្តា** *។*

**អនិច្ចំ** *មានន័យថា មិនទៀង ។ ដូច្នេះ ខន្ធ៥  នៅក្នុងធម្មជាតិ ក៏មិនទៀងដែរ  ហើយបើ ខន្ធ៥ មិនទៀង  តើយើងអាចទុកខន្ធ៥  ថាជារបស់យើងបានទេ បើមិនដឹងជាថ្ងៃណាផង វានឹងបែកធ្លាយទៅវិញនោះ។ តើលក្ខណៈ* **អនិច្ចំ** *ចេញមកពីណា ? ចម្លើយ គឺចេញ មកពី ភាវៈ [***កើត-រលត់ កើត-រលត់***] ជានិច្ច  នៃសង្ខារធម៌ទាំងពួង ។  សព្វថ្ងៃនេះ អ្នកវិទ្យាសាស្ត្រក៏គេយល់ស្របនូវ ភាវៈនេះដែរ ។ ខ្ញុំសូមជូនឧទាហរណ៍ខ្លះនូវ  លក្ខណៈ មិនទៀង និង លក្ខណៈ កើត-រលត់ ដូចតទៅះ*

***លក្ខណៈមិនទៀង*** *ដូចជា ជាតុអាកាស  ម្តងក្តៅ ម្តងត្រជាក់   អ្នកខ្លះធ្លាប់មានទ្រព្យ សម្បត្តិ បុណ្យសក្តិធំ ស្រាប់តែធ្លាក់ខ្លួនមកក្រវិញក៏មាន ។ បើមិនទៀងរបៀបនេះ តើមានការកក់ក្តៅ ទុកចិត្តម្តេចនឹងកើត ។ ម្យ៉ាងទៀតដោយនឹកថា ខ្លួន ជារបស់អញ ម្នាក់ៗទៅជាមានការ លោភលន់ ចង់បានមិនចេះឆ្អែតឆ្អន់ ហើយជាប់ជំពាក់នឹង ទ្រព្យសម្បត្តិ បុណ្យសក្តិ  លាភ  យស  សេចក្តីសុខ ។ ចង់ឲ្យគេ  គោរព សរសើរ ខ្លួន តែ រំលោភលើច្បាប់ លើសុជីវធម៌  កំហែងអ្នកទន់ខ្សោយ  ខ្វះធម៌មេត្តា ។ នេះមកតែ ពី គិតថា ខ្លួនជារបស់ខ្លួន  កូនប្រពន្ធជារបស់ខ្លួន ហើយដោយអ្នកដទៃ មិនមែនជា*

កូនចៅ ជាមិត្តសម្លាញ់ខ្លួន ក៏ធ្វើបាបរំលោភគេទៅ ។

តែការពិត មាន កូនចៅ មិត្តសម្លាញ់របស់ខ្លួនឯណា បើខ្លួនឯងមិនមែនជារបស់ខ្លួនឯងផង មិនដឹងជាស្លាប់[14]ថ្ងៃណាផង។ ប្រសិនបើជាមនុស្សលោកទាំងអស់គ្នាយកធម៌មិនទៀងនេះ ដាក់ក្នុងចិត្ត នោះពិភពលោកយើងនេះ បានសេចក្តីសុខសប្បាយ ឥតមានសង្គ្រាមរវាង ប្រទេសនិងប្រទេស ឬ ការវិវាទរវាង បុគ្គល និង បុគ្គលសោះឡើយ ។ ម្យ៉ាងទៀតដោយថាជីវិតមិនទៀង បើយើងជឿនូវកម្មផល នោះយើងខំធ្វើអំពើល្អ ខំសន្សំកុសលទុកឲ្យបានច្រើនសម្រាប់ជាតិខាងមុខ ទាន់យើងនៅរស់ ហើយអាចធ្វើដោយខ្លួនឯងបាន ដោយមិនចាំបាច់ពឹង កូនចៅឲ្យធ្វើបញ្ជូនកុសលទៅតាមក្រោយ ។

<u>**លក្ខណៈកើត-រលត់**</u> ដូចជា [ វេទនាក៏កើតរលត់ ] [ដង្ហើមចូល និងដង្ហើមចេញ ] [ ចិត្ត ] [ ចិត្តចុតិរលត់ ចិត្តបដិសន្ធិក៏កើត ] ជាដើម ។

មនុស្សយើងម្នាក់ៗ មាន កាយនិងចិត្ត ៖ កាយក៏កើតរលត់ ចិត្តក៏កើតរលត់ ។

កាយកើតរលត់ ដូចជា កាលណាយើងដកដង្ហើម ខ្យល់ចូលគឺកើត ខ្យល់ចេញគឺរលត់។ ដែលយើងហៅថាជីវិត គឺការផ្សំគ្នារវាងថាមពលកាយនិងថាមពលចិត្ត។ ថាមពលនោះផ្លាស់ប្តូរជានិច្ច វាមិនដូចគ្នាពីពេលមួយ ទៅពេលបន្ទាប់នោះទេ។ គឺវាកើត ហើយវារលត់ទៅវិញភ្លាម មុននឹងកើតជាថ្មី និងរលត់ជាថ្មីម្តងទៀត ហើយចេះតែតៗ ជារៀងដរាបទៅ រហូតដល់ដង្ហើមចុងក្រោយ ហៅថា ចុតិចិត្ត។ តែបន្ទាប់ពីចុតិចិត្តរលត់ទៅ បដិសន្ធិចិត្តក៏

---

[14] ដល់ពេលស្លាប់ គឺខ្លួនទីពឹងខ្លួនហើយ មិត្តភក្តិ ប្រពន្ធកូនជួយមិនបានទេ ទ្រព្យសម្បត្តិលុយកាក់ តែមួយកាក់យកទៅមិនបានផង ដូចជំនាន់ដើម គេដាក់ក្នុងមាត់មនុស្សស្លាប់ប្រាក់មួយកាក់ ហើយដល់ពេលគេបូជាសពរួចហើយ ប្រាក់កាក់នោះនៅដដែល ។ នេះសម្រាប់ឲ្យយើងពិចារណា ថា ស្លាប់ទៅទ្រព្យសម្បត្តិយកទៅមិនរួចទេ ដូច្នេះត្រូវរកស៊ីដោយសម្មាអាជីវោ ។

កើតជាបន្តគ្នាភ្ជាមមិនបានឃើតយូរឡើយ ។ ហេតុនេះចិត្ត កើតរលត់ កើតរលត់ តៗគ្នា ពីជាតិមួយទៅជាតិមួយ មិនដែលដាច់ទេ ទាល់តែឈប់កើត គឺទាល់តែសម្រេចនិព្វាន ទើបចប់ការកើតការរលត់នៃចិត្ត ។ បើតាមន័យនេះ ដោយ ខន្ធ៥ កើតរលត់ កើត រលត់ ដូច្នេះការរស់នៅនៃយើងសព្វថ្ងៃនេះ ក៏ដូចជា ស្លាប់កើត ស្លាប់កើតដែរ ហើយ បើនិយាយឲ្យអស់សេចក្តី គឺ **កើត តាំងនៅ ហើយរលត់ទៅ** ចេះតែ តៗ រហូតដល់ សេចក្តីស្លាប់ចុងក្រោយ ។ ការកើតនៅភពថ្មី ខុសពីការរស់នៅសព្វថ្ងៃនេះ ត្រង់កាយ ស្លាប់ តែចិត្តកើតបន្តពីចិត្តចុតិ ។ ដូច្នេះ កុសលកម្ម និង អកុសលកម្ម ដែលយើងបាន សន្សំទុកពីមុនមក អត់បាត់ទៅណាទេ ច្បាប់កម្មផល ទុកឲ្យយើងទាំងអស់ យើងយកទៅ តាមពីមួយជាតិទៅមួយជាតិ ។ ដូចជាព្រះពុទ្ធមិនមែនទើបតែសាងមួយ ជាតិចុងក្រោយ នេះ ហើយក៏បានត្រាស់ជាព្រះពុទ្ធនោះទេ ។ តាមជាតក ព្រះអង្គបានសន្សំកុសល ជាច្រើនជាតិ រាប់មិនអស់ មុននឹងបានសម្រេចមគ្គផលនិព្វាន ។

បើយើងជឿតាមទ្រឹស្តីនេះ យើងត្រូវខំសន្សំកុសល គ្រប់ៗជាតិ ជាមួយគ្នានេះ យើងខំ បន្ថយអំពើអកុសលទាំងឡាយ ដែលហាមដោយច្បាប់រដ្ឋ ឬដោយ ច្បាប់សាសនា។ ជាទូទៅ ក្នុងមុខវិជ្ជានីមួយៗ មានពីរផ្នែក គឺផ្នែកទ្រឹស្តី និងផ្នែក ការអនុវត្តន៍ ពីព្រោះថា ដើម្បីទាញយកផលប្រយោជន៍ ពីទ្រឹស្តីនោះបាន ទាល់តែយើងយកទ្រឹស្តីនោះមកប្រើ មកធ្វើការពិសោធន៍ ។ ដូចនៅក្នុងគណិតសាស្ត្រ កាលនៅពីក្មេង យើងខំទន្ទេញ មេលេខឲ្យរត់មាត់ ដូចជា ៖ ពីរ ពីរដង បួន (២ x ២ = ៤) និង ពីរ បីដង ប្រាំមួយ ជាដើម ។ ហើយដល់ការអនុវត្តន៍ គឺការគិតលេខ ក្នុងចំណោទ្យ ដូចជា ៖ ខ្មៅ ដៃមួយ ថ្ងៃ ២ រៀល តើខ្មៅដៃ ៣ ថ្ងៃប៉ុន្មាន ? នៅក្នុងធម៌ព្រះពុទ្ធ បើយើងគ្រាន់តែយល់ ទ្រឹស្តី ហើយយើងមិនខំអប់រំចិត្តទៅតាមទ្រឹស្តីនោះទេ យើងក៏ មិនអាចទទួលផលពីទ្រឹស្តី ព្រះអង្គបានដែរ ។ ដូចនៅក្នុងសីល ៥ មានវៀរ ការសម្លាប់សត្វ ការសេពសុរា ។តែលោក

*អ្នកខ្លះ នៅតែ សម្លាប់សត្វ នៅតែផឹកស្រា ដដែល ថ្វីបើយល់ថា សត្វក៏គ្នាចង់មានជីវិត ស្រឡាញ់ជីវិតដូចតែយើងដែរ ។ រួមសេចក្តីទៅ យើងត្រូវ ខំអប់រំចិត្ត តទៅទៀត ដោយ យកធម៌ព្រះពុទ្ធជាគោល ដើម្បីនឹងបានផលប្រយោជន៍ដល់យើង ទៅអនាគត ។*

# ១០

# ប្រយោជន៍ នៃ សមាធិ និង បញ្ញា ( *វិបស្សនា* )

*សមាធិ និង បញ្ញា (វិបស្សនា) ជាផ្លូវ បដិបត្តិ ដែលព្រះពុទ្ធរកឃើញ ជាមួយនឹងធម៌ជាទ្រឹស្តី ដូចជា អរិយសច្ច៤ អដ្ឋង្គិកមគ្គ ឬ បដិច្ចសមុប្បាទ ។ ពីព្រោះព្រះអង្គយល់ថា ការចេះ ការយល់ទ្រឹស្តី ពុំទាន់គ្រប់គ្រាន់នៅឡើយទេ ដើម្បីទៅដល់ត្រើយ គឺនិព្វាន។ មានរឿងនិទានកាលសម័យព្រះពុទ្ធ មានព្រះសង្ឃមួយអង្គ ជាគ្រូនៃសិស្សជាច្រើន ហើយសិស្សបានសម្រេចជាព្រះអរហន្ត រហូតដល់សិស្សមួយ ត្រឹមតែជាសាមណេរ ប៉ុណ្ណោះក៏បានសម្រេចជា ព្រះអរហន្តដែរ ។ តែចំពោះលោកគ្រូនោះវិញ មិនបានសម្រេចអ្វីទាំងអស់ ។ លុះដល់ពេលក្រោយមក លោកគ្រូនោះសុខចិត្តធ្វើតាមការណែនាំរបស់សិស្សសាមណេរ ដែលជាព្រះអរហន្ត ទើបលោកគ្រូបានសម្រេច ជាព្រះអរហន្ត ។ នេះជាកស្តុតាងមួយឲ្យឃើញថាការគ្រាន់តែយល់ធម៌ មិនទាន់គ្រប់គ្រាន់ទេ។ បើនិយាយថាមកពីលោកគ្រូនោះ ពុំទាន់យល់ធម៌នោះច្បាស់ ក៏មិនសូវសមដែរ ពីព្រោះតាមធម្មតា ដើម្បីពន្យល់ធម៌ណាមួយដល់សិស្សបាន ទាល់តែលោកគ្រូយល់ធម៌នោះជាមុនសិន នេះតាមដែលខ្ញុំដឹង ពីព្រោះខ្ញុំក៏ធ្លាប់ធ្វើគ្រូផ្នែកគណិតសាស្ត្រដែរ ។ ម្យ៉ាងទៀត ចំពោះលោកគ្រូខ្លះដែលនៅតែគាំទ្រគំនិតថា គ្រាន់តែយល់ធម៌នោះគ្រប់គ្រាន់ហើយ មិនចាំបាច់បដិបត្តិដូចជាសមាធិជាដើមនោះទេ នាំតែខាតពេល នោះខ្ញុំសូមលោកគ្រូមេត្តាឆ្លើយទៅសំណួរខ្ញុំថា*

« ***តើ សព្វថ្ងៃនេះលោកគ្រូបានសម្រេចមគ្គផល ដល់កម្រឹតណាហើយ?*** »

ពីព្រោះកាលសម័យព្រះពុទ្ធ ក៏មានសាវកខ្លះ បានសម្តែងឫទ្ធិ ដើម្បីជាកស្តុតាង ឲ្យពួកនិគ្រន្ថឃើញដែរ ។ ប្រយោជន៍នៃ ការបដិបត្តិ សមាធិ គឺធ្វើឲ្យយើងមានការប្រុងប្រយ័ត្ន គ្រប់ពេលវេលាដោយស្វ័យប្រវត្តិ ហាក់បីដូចមានលេខាធិការម្នាក់តាមចាំឃ្លាំប្រាប់យើងថាត្រូវប្រយ័ត្នកុំភ្លេចស្មារតី ។ ដោយជាលេខាធិការ មិនបាច់ជួលអស់លុយ នោះអ្នកណាក៏ចង់បានដែរ ។ តើសមាធិអាចផ្តល់មកឲ្យយើងនូវ លេខាធិការនោះ ដោយរបៀបណា ។ ខ្ញុំសូមជំរាបដូចតទៅ ៖

ថ្វីបើការធ្វើសមាធិ មានឥរិយាបថ ៤ គឺ ដើរ ឈរ អង្គុយ ដេក តែនៅពេលធ្វើសមាធិ ដែលមានមនុស្សច្រើននៅក្នុងបន្ទប់ធំតែមួយ គេយកឥរិយាបថអង្គុយ ។ កាលណាយើងអង្គុយ ចំពោះអ្នកធ្វើដំបូង ច្រើនតែចុកចាប់ចង្កេះ ពោយខ្នង ឈឺក្បាលជង្គង់ ជាដើម ។ ការឈឺបែបនេះពាក្យធម៌ ហៅថា វេទនា ។ ចំពោះវេទនា មានវេទនា ផ្លូវកាយ (ដូចពោយខ្នងជាដើម) និង វេទនាផ្លូវចិត្ត ហើយចែកជា សុខវេទនា ទុក្ខវេទនា និង អទុក្ខមសុខវេទនា (ឧបេក្ខាវេទនា )។ ឧបេក្ខាវេទនា គឺ វេទនា ជាកណ្តាលៗ មិនសុខ មិនទុក្ខ ទាំងផ្លូវកាយ និងទាំងផ្លូវចិត្ត ។ ហើយចំពោះវេទនា ពីរទៀត ដោយចែកតាមផ្លូវកាយ និង តាមផ្លូវចិត្ត នោះមាន ៖

- សុខវេទនា និង ទុក្ខវេទនា ជា វេទនា <u>ខាងកាយ</u>
- សោមនស្សវេទនា និង ទោមនស្សវេទនា ជា វេទនា <u>ខាងចិត្ត</u> ។

ដូច្នេះតាមនិយមន័យនេះ កាលណាយើង <u>កំពុងតែអង្គុយ</u> ធ្វើសមាធិ ស្រាប់តែមានឈឺឆ្អឹងខ្នង ការឈឺនោះហៅថា ទុក្ខវេទនា ។ បើ <u>កំពុងតែអង្គុយ</u> ស្រាប់តែមានភាពសុខស្រួលដូចមានគេមកអង្អែលគក់ច្របាច់ឲ្យ (massage) សេចក្តីសុខនោះហៅថា សុខវេទនា ។ ចំពោះវេទនាខាងផ្លូវចិត្តវិញ កាលណាយើងសប្បាយចិត្ត សេចក្តីសុខនោះហៅថា សោមនស្សវេទនា កាលណាយើងមានចិត្តមួរម៉ៅ មានការថ្នាំងថ្នាក់ចិត្ត

នោះ ហៅថា ទោមនស្សវេទនា។ ចំពោះយើងម្នាក់ៗ ដែលមានកាយនិងចិត្ត លេខាធិការ ដែលចាំដាស់យើង កុំឲ្យភ្លេចការប្រុងប្រយ័ត្ន គឺ **សតិ** ។

តើធ្វើយ៉ាងណា ដើម្បីឲ្យមានសតិ? គឺយើងយកវេទនាជាឧបករណ៍ សម្រាប់បណ្ដុះសតិ និងសម្រាប់អប់រំចិត្តឲ្យនៅជា ឧបេក្ខា ។ សតិសម្រាប់ទប់ចិត្តកុំឲ្យស្អប់ទុក្ខវេទនា កុំឲ្យស្រឡាញ់សុខវេទនា ។ **ដោយសតិដឹងទាន់នូវវេទនា អ្នកធ្វើសមាធិ ក៏តាំងចិត្តជាឧបេក្ខា** ។ ពីព្រោះវេទនា ជាសុខក្ដី ជាទុក្ខក្ដី សុទ្ធតែមិនទៀង ។ ហើយរបស់ណាមិនទៀង របស់នោះជាទុក្ខ ដូច្នេះយើងគប្បីលះបង់ចោល វេទនាទាំងនោះ កុំប្រកាន់មាំ កុំជាប់ជំពាក់ ។ ឥឡូវនេះយើងឃើញប្រយោជន៍ របស់សមាធិហើយ តើការបដិបត្តិសមាធិ ត្រូវធ្វើរបៀបណា។

**<u>សមាធិ - អានាបានស្សតិ</u>**

បើយើងយកឥរិយាបថអង្គុយ នោះយើងអង្គុយពែនភ្នែន ជើងស្ដាំដាក់លើជើងឆ្វេង ដៃស្ដាំដាក់លើដៃឆ្វេង ដងខ្លួនត្រង់ធម្មតាដោយអត់ប្រឹង ក ត្រង់ មុខអោនចុះបន្តិច អត់ពាក់វ៉ែនតា ហើយបិទភ្នែក ។ បន្ទាប់មកគេ <u>សង្កេត</u> ដង្ហើមចេញចូល ។ គឺការដកដង្ហើម<u>**ធម្មតា**</u> គ្រាន់តែសង្កេត មើលដង្ហើម ។ កាលណាដកដង្ហើមចូល <u>**សតិដឹង**</u> ថាអាត្មាអញ ដកដង្ហើមចូល ។ កាលណាដកដង្ហើមចេញ សតិដឹងថា អាត្មាអញ ដកដង្ហើមចេញ ។

កាលណាដង្ហើមចូលវែង សតិដឹងថាដង្ហើមចូលវែង កាលណាដង្ហើមចូលខ្លី សតិដឹងថាដង្ហើមចូលខ្លី ។ កាលណាដង្ហើមចេញវែង សតិដឹងថាដង្ហើមចេញវែង កាលណាដង្ហើមចេញខ្លី សតិដឹងថាដង្ហើមចេញខ្លី ។ ដោយខ្យល់ដង្ហើមចេញចូល តាមរន្ធច្រមុះ នោះគេយក <u>សតិមកតាំងនៅត្រង់បបូរមាត់ខាងលើ ក្រោមរន្ធច្រមុះទាំងពីរ</u> ។ បើកំពុងតែអង្គុយធ្វើសមាធិ យើងឈឺនៅកន្លែងណាមួយ ដូចជាឈឺ

*ចង្កេះជាដើម នៅពេលនោះ សតិយើងរត់មករកកន្លែងឈឺនោះ ជួនកាលយើងភ្លេចខ្លួន ចិត្តនៅជាប់តែត្រង់កន្លែងដែលឈឺនោះ ដោយនឹកថា កាយឈឺ ឬ ចង្កេះឈឺ។ តាមធម្មតា <u>ចិត្តទេ ដែលដឹងឈឺ</u> ហើយកាយ <u>មិនដឹងអ្វីទាំងអស់</u> យើងមើលមនុស្សស្លាប់ ដោយអត់មានចិត្តនៅក្នុងកាយ ចង់យើងយកមនុស្សស្លាប់នោះទៅដុតក៏ឥតមានស្រែកថាក្តៅ ដូចមនុស្សរស់ដែរ ។ នៅមន្ទីរពេទ្យ អ្នករបួសខ្លះកំពុងតែស្រែកថ្ងូរ ដល់គ្រូពេទ្យចាក់ថ្នាំ មួយម្ជុលទៅ បាត់ថ្ងូរភ្លាម ហើយកន្លែងរបួសមានទាន់សះជាឯណា នេះសរឲ្យឃើញថា យើងម្នាក់ៗដឹងថាឈឺ ក្នុងខ្លួនដោយសារចិត្ត។ បើចិត្តមិនរវល់ នឹងកន្លែងឈឺនោះទេ យើងមិនដឹងថាឈឺទេ  យើងធ្លាប់ឃើញអ្នកលេងអុក លេងភ្លេចបាយភ្លេចទឹក ភ្លេចឈឺចង្កេះ នេះមកពីពេលកំពុងតែលេងនោះ សតិគាត់ជាប់តែនឹងកូនអុកយ៉ាងស្អុង ភ្លេចអ្វីៗនៅជុំវិញខ្លួនទាំងអស់ ។ ឧទាហរណ៍ទាំងនេះ ធ្វើឲ្យយើងយល់ថាហេតុអ្វីបានជា អ្នកធ្វើសមាធិខ្លះ អាចអង្គុយ ៥ ម៉ោងនៅតែមួយកន្លែងឥតមានប្តូរជើងម្តងសោះ ។ យើងសួរថា ប្រសិនបើជាអង្គុយនោះវាឈឺចុកចាប់ ដូចអ្នកដែលមិនធ្លាប់ធ្វើ តើទ្រាំបានទេ ចំនួន៥ម៉ោងនោះ ថែមទាំងគ្មានការបង្ខំពីអ្នកដទៃទៀតផង។ ហេតុនេះហើយ បានជាក្នុងពិធីអង្គុយធ្វើសមាធិ កាលណាខ្លួនយើងឈឺនៅកន្លែងណាមួយ កាលណាសតិរត់មកមើលកន្លែងឈឺនោះ គេឲ្យយើងទាញសតិយកមកដាក់នៅកន្លែងដែលបាន<u>កំណត់រួចមកហើយ</u> គឺ បបូរមាត់លើនៅក្រោមរន្ធច្រមុះ* ***ដោយចិត្តឧបេក្ខា*** *គឺ មិនខឹងនឹងការឈឺនោះ ដោយនឹកថា ការឈឺក្តី ការសុខស្រួលក្តីសុទ្ធតែមិនទៀង រួចហើយក៏ បន្តការសង្កេត ដង្ហើមចេញចូល តទៅទៀត ។*

*<u>មកដល់ត្រឹមនេះ ខ្ញុំសូមធ្វើការសង្កេតខ្លះ មុននឹងបន្តទៅមុខទៀត</u> ៖*

*១- ពាក្យថា* ***<u>សង្កេត</u>*** *មានន័យថាយើងជាអ្នក* ***<u>អាជ្ញាកណ្តាល</u>*** *យើងគ្រាន់តែមើលឲ្យដឹងតែឥតមានជាប់ជំពាក់ចិត្ត ស្អប់ ឬ ស្រឡាញ់ របស់ដែលយើងសង្កេតនោះទេ ។*

២- កាលណា យើងអង្គុយធ្វើសមាធិ ចំពោះអ្នកថ្មី ច្រើនតែ ឈឺចុកចាប់លើរាងកាយ ត្រង់កន្លែងណាមួយ ដែលភាសាធម៌ហៅថា ទុក្ខវេទនា ហើយយើងឃើញថា <u>**វេទនានេះវាកើតឡើងខ្លួនវា មិនមែនយើងជាអ្នកបង្កើតទេ**</u> ប្រសិនបើជាយើងអាចបង្កើតវេទនានោះបាន ម៉្លេះយើងបង្កើតតែសុខវេទនាហើយ អ្នកណាមិនចង់សុខ មិនដែលចង់ឈឺ ដូចជាឈឺចង្កេះជាដើមនោះទេ ។ ហេតុនេះហើយ បានជាគេឲ្យយើង <u>គ្រាន់តែដឹង</u>ថាមានវេទនា តែកុំខឹងនឹងទុក្ខវេទនា ហើយក៏កុំចង់បានឬជាប់ជំពាក់នឹង សុខវេទនានោះដែរ ។ ដោយសតិដឹងទាន់ យើងតាំងចិត្ត ជាកណ្តាលៗ គឺចិត្តជា <u>ឧបេក្ខា</u> ។

៣- យើងអាចសួរដែរ ថា តើវេទនានេះ មានប្រយោជន៍អ្វីដែរ ក្នុងការបដិបត្តិសមាធិ? ខ្ញុំសូមឆ្លើយថា វេទនា ជាទុក្ខក្តី ជាសុខក្តី មានប្រយោជន៍ក្នុងការធ្វើសមាធិ ។ ប្រយោជន៍ត្រង់ពង្រឹងសតិយើងឲ្យធាប់ដឹងទាន់ ដើម្បីអប់រំចិត្តឲ្យនៅជា ឧបេក្ខាដដែល កុំឲ្យភ្លេចខ្លួនទៅជាប់ជំពាក់នឹងសុខវេទនា ហើយមានទោសៈនឹងទុក្ខវេទនា ។ បើបែរមកខាងការរៀនវះកាត់ ក្នុងមុខវិជ្ជាពេទ្យវិញ វេទនាទុកដូចជាខ្មោច សម្រាប់សិស្សរៀនវះកាត់ឲ្យស្ទាត់ជំនាញ មុននឹងមកវះកាត់មនុស្សរស់ ។ ពីព្រោះចេះតែទ្រឹស្តី បើខ្វះការហ្វឹកហាត់នោះពុំទាន់អប់រំចិត្តបានដូចបំណងទេ[15] ។

ប្រយោជន៍ នៃសតិ មួយទៀតគឺ ក្នុងជីវិតរស់នៅសព្វថ្ងៃ បើយើងប្រកបកិច្ចការអ្វីមួយ ដោយមានសតិជាប់ស្អិតតែនឹងកិច្ចការនោះ ភ្លេចអ្វីៗទាំងអស់ អ្នកដទៃក៏ភ្លេច ខ្លួនឯងក៏ភ្លេច នៅពេលនោះយើងសង្កេតឃើញថា កិច្ចការដែលកំពុងតែធ្វើនោះប្រើពេលខ្លីហើយល្អទៀត ។ ចំពោះចិត្តឧបេក្ខាវិញ បើយើងធ្លាប់ មានចិត្តឧបេក្ខាចំពោះអារម្មណ៍ខាងក្នុងខ្លួនយើងហើយ នៅពេលដែលមានអារម្មណ៍មកពីក្រៅ

---

[15] គេថាចិត្តដូចសត្វស្វា ដែលចេះតែលោតពីមែកឈើមួយទៅមែកឈើមួយ មិនចេះឈប់ឈរ។

ទោះជាទីគាប់ចិត្តក្តី ឬ មិនគាប់ចិត្តក្តី  ក៏ចិត្តយើងនៅតែឧបេក្ខាដដែល។ អារម្មណ៍មកពីក្រៅ ដូចជាគេជេរយើង  ឬ  គេសរសើរយើង  ក៏យើង មិនខឹង ឬ មិនត្រេកអរហួសហេតុ   ហាក់បីដូចជាយើងមានអាវក្រោះ ពាក់ការពារមិនឲ្យគ្រាប់កាំភ្លើងបាញ់ធ្លុះរបួសយើងបាន ។

**<u>ប្រយោជន៍ នៃ វិបស្សនា</u>** ៖

បំណងក្នុងការចម្រើន **វិបស្សនា** គឺ បន្ថយ **តណ្ហា** ដោយពិចារណា នូវធម៌ត្រៃលក្ខណ៍ គឺ  **អនិច្ចំ  ទុក្ខំ  អនត្តា** ។ យើងសួរថាហេតុអ្វីត្រូវបន្ថយ តណ្ហា ?  ពីព្រោះតាមធម៌ព្រះពុទ្ធ អរិយសច្ចបួន( **ចតុរារិយសច្ចៈ**) ទុក្ខទាំងឡាយ  កើតមកពីតណ្ហា ។ ដូច្នេះ ដើម្បី រំលត់ ទុក្ខ ទាល់តែ រំលត់តណ្ហា ហើយ ដើម្បី រំលត់តណ្ហា យើងត្រូវដើរតាមផ្លូវ **អដ្ឋង្គិកមគ្គ** ដោយចម្រើន  វិបស្សនា។

វិបស្សនា ត្រូវការពិចារណាច្រើន ពិចារណាឲ្យឃើញសេចក្តីពិត ដោយមិនខ្លាចសេចក្តីពិតនោះ ។ អ្នកខ្លះដឹងស្គាល់សេចក្តីពិតដែរ  តែមិនហ៊ានប្រឈមមុខតទល់នឹងសេចក្តីពិត សុខចិត្តរស់នៅក្នុងការស្រមៃ ។ តែកុំភ្លេចថា ធម៌ទាំងឡាយកើតមកពីហេតុ បើមិនដោះស្រាយហេតុនោះទេ កុំសង្ឃឹមថាដោះស្រាយបញ្ហានោះបានដូចបំណង។

<u>យើងអាចសួរថាតើ សមាធិ និង  បញ្ញា (វិបស្សនា) ខុសគ្នាត្រង់ណា ហើយ មានទំនាក់ទំនងគ្នាទេ ?</u>

តាមការពន្យល់ខាងលើ វិបស្សនា គឺវិធីអប់រំចិត្ត ដោយធ្វើការពិចារណា រកហេតុផល ដូចជា យើងសួរថា <u>តើទុក្ខ កើតមកពីណា</u> កើតនៅពេលណា ជាដើម ។ តើសំណួរនេះមានប្រយោជន៍អ្វី ម្តេចក៏ចាំបាច់សួរ ? ។  ចម្លើយ មានច្រើន ។ ខ្ញុំសូមជូនតែចម្លើយមួយ គឺថា ទុក្ខ  មិនខុសពីមេរោគដែលមកបៀតបៀនយើងទេ អ្នកណាក៏មិនចង់ឲ្យមេរោគមកបៀតបៀនដែរ ។ ដូច្នេះ អ្នកណាក៏មិនចង់បានទុក្ខដែរ  គឺយើងចង់តែបំបាត់

*ទុក្ខ ចង់តែជៀសវាងទុក្ខ ។ ដើម្បីជៀសវាងវា យើងត្រូវស្គាល់កន្លែងវានៅ ស្គាល់កន្លែងវាកើត ស្គាល់ហេតុដែលនាំឲ្យវាកើត ។ បើកាលណាយើងស្គាល់ហេតុដែលនាំឲ្យវាកើតហើយ នោះយើងនឹងដោះស្រាយចំណោទនោះបាន ។ គឺ* ***យើងគ្រាន់តែឈប់ធ្វើឲ្យហេតុនោះ មានកំណើតតទៅទៀត*** *។ ដូចជាយើងឈឺពោះ បើកាលណាយើងដឹងថាហេតុមកពីផឹកទឹកមិនស្អាត នោះយើងផឹកទឹកដាំពុះទៅ នោះយើងឈប់ឈឺពោះទៀតហើយ ។ យើងសួរតទៅទៀតថា ហេតុដែលនាំឲ្យកើតទុក្ខព្រះពុទ្ធព្រះអង្គបានរកឃើញរួចទៅហើយ ចាំបាច់ទៅពិចារណាខំរកធ្វើអ្វីទៀត ? ខ្ញុំសូមឆ្លើយថា ព្រះអង្គលោករកឃើញពិតមែន គឺ* ***លោភ*** *ដែលជាហេតុនាំឲ្យកើតទុក្ខ ។ តើយើងជឿជាក់ច្បាស់ថាពិតជាយ៉ាងនោះមែនដូចព្រះពុទ្ធដីកានោះទេ ? ពោលគឺជឿដោយគ្មានបង្ខំចិត្ត ឬ ដោយតាម អ្នកដទៃ ។ ពីព្រោះថាទាល់តែយើងជឿដោយខ្លួនឯង ទើបយើងខំប្រឹងជៀសនូវទុក្ខនោះ ។ ធ្វើអ្វីក៏ដោយ បើយើងធ្វើតាមគេ មិនសូវជាបានផល ដូចយើងធ្វើដោយចិត្តយើងយល់នោះទេ ដូចជាយើងធ្វើបុណ្យ ឬធ្វើអំពើជាកុសល បើយើងធ្វើដោយប្រាជ្ញា ដោយចិត្តយើងសទ្ធាជ្រះថ្លា នោះយើងបានបុណ្យកុសលច្រើនជាងយើងធ្វើដោយគេបបួល ។*

*ដើម្បីការពិចារណារបស់យើងមានប្រសិទ្ធភាព ទាល់តែចិត្តយើងស្ងប់ មូលទៅលើអារម្មណ៍តែមួយ ដោយមានសតិដឹងទាន់កាលណាចិត្តយើងបែរទៅរកអារម្មណ៍ណាមួយផ្សេងទៀត ។ នេះហើយទំនាក់ទំនង រវាង សមាធិ និង បញ្ញា (វិបស្សនា) ។ គួរយល់ដែរ ចំពោះ ពាក្យ នៅក្នុង ចិត្តានុបស្សនាសតិបដ្ឋានដែលចែងថា ៖*

« នែភិក្ខុទាំងឡាយ ភិក្ខុនៅក្នុងសាសនានេះ ទោះចិត្តប្រកបដោយ រាគៈ[16] ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ »។

[16] *អាចជំនួស ពាក្យរាគៈ ដោយពាក្យផ្សេងទៀត ដូចជា ទោសៈ មោហៈ ..... ជាដើម ។*

ពាក្យថា « ដឹងច្បាស់ » គឺ គ្រាន់តែ ដឹងដោយ សតិ ប៉ុណ្ណោះ ។ មិនត្រូវមានគំនិត ចង់បាន ឬ ស្អប់ ឬ ខ្លាច រាគៈ ឬ មួយខ្លាចបាបព្រោះតែចិត្តមានរាគៈ នោះឡើយ ។ ពីព្រោះបំណងរបស់សមាធិ គឺគ្រាន់ត្រឹមតែដឹងទាន់តែប៉ុណ្ណោះ ។ ដូចជាអ្នកយាមទ្វារ បើមានចោរចូលមកលួច គ្រាន់តែដឹងថាមានចោរចូលមកលួច តែមិនមានមុខងារ ទៅចាប់ចោរនោះទេ ។ បើចាប់ចោរ គឺ ទុកឲ្យភ្នាក់ងារនគរបាលវិញ ។

ចំពោះអ្នកកាសែត នៅពេលខ្លះគេមិនខ្លាចនឹងសួរទៅភ្ញៀវដែលគេសម្ភាស នូវសំណួរ ដែលជារអាចកំប៉ាំងនោះទេ ។ ហើយភ្ញៀវខ្លះដោយទ្រាំទប់ចិត្តមិនបាន ក៏ខឹងនឹងអ្នកកាសែតនោះ ។

នៅពេលនោះ បើយើងជាភ្ញៀវវិញ តើត្រូវធ្វើដូចម្តេចដើម្បីកុំឲ្យច្រឡោតនៅមុខភ្ញៀវពន្លឺឯទៀត ?

មកដល់ត្រង់នេះខ្ញុំនឹកដល់ពេលដែលខ្ញុំធ្លាប់ខឹង។ អ្នកណាក៏មិនចង់ខឹងដែរ តែមកពីទប់មិនបាន។ របៀបមួយដើម្បីទប់ស្កាត់កុំឲ្យកំហឹងមកគ្របសង្កត់យើងបាន គឺ យើងកុំគិតទៅហេតុដែលអ្នកដទៃគេធ្វើឲ្យយើងខឹង តែផ្ទុយទៅវិញ យើងត្រូវដឹងឲ្យទាន់ ថា « អឺយ៉ា! ចោរមកហើយ » (ដោយយើងទុកកំហឹងនោះ ដូចជាចោរ ដែលវាមកញោះឲ្យយើង ខឹង) ។ គ្រាន់តែ ដឹងទាន់ប៉ុណ្ណឹង ចោររត់បាត់ទៅហើយ។ ដូច្នេះយើងឃើញថា **សតិ** មានប្រយោជន៍ធំណាស់ ។ កំហឹងជាចោរ វាលួចសេចក្តីសុខ សេចក្តីស្ងប់របស់យើង ហើយវាថាជាមិត្តនៃយើង វាកាន់ជើងយើង តែតាមពិតវាធ្វើឲ្យយើង មានទុក្ខ ពិបាកចិត្ត មានការថ្នាំងថ្នាក់ ។

## បន្ថែម

អានាបានស្សតិ មានប្រយោជន៍ឲ្យកើតពលៈ (កម្លាំង)៥ គឺ **សទ្ធាពលៈ១ សតិពលៈ១ វីរិយពលៈ១ សមាធិពលៈ១ បញ្ញាពលៈ១** ។ ពលៈទាំង ៥ បានមកពីការហាត់ចម្រើន

នូវអានាបានស្សតិនេះឯង។ ក្នុងការចម្រើននេះ មានវត្ថុ ១៦យ៉ាងដែលចែកជា៤ ពួក គឺ ៖

**ពួកទី ១** (បឋម ចតុក្កៈ)

១- កាលដកដង្ហើម ចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើម ចេញវែង

កាលដកដង្ហើម ចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើម ចូល វែង ។

២- កាលដកដង្ហើម ចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើម ចេញខ្លី

កាលដកដង្ហើម ចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើម ចូលខ្លី ។

៣- អាត្មាអញជាអ្នក **ដឹងច្បាស់នូវកាយ**[17] គឺខ្យល់ដកដង្ហើម ចេញទាំងអស់ឲ្យប្រាកដ ទើបដក ដង្ហើមចេញ - អាត្មាអញជាអ្នក **ដឹងច្បាស់នូវកាយ** គឺខ្យល់ដកដង្ហើម ចូលទាំងអស់ឲ្យប្រាកដ ទើបដក ដង្ហើមចូល ។

៤- អាត្មាអញជាអ្នក រម្ងាប់នូវកាយសង្ខារ[18] ទើបដក ដង្ហើមចេញ -

អាត្មាអញជាអ្នក រម្ងាប់នូវកាយសង្ខារ ទើបដក ដង្ហើមចូល ។

**ពួកទី ២** (ទុតិយ ចតុក្កៈ)

១- អាត្មាអញជាអ្នក **ដឹងច្បាស់នូវបីតិ** ទើបដក ដង្ហើមចេញ -

អាត្មាអញជាអ្នក **ដឹងច្បាស់នូវបីតិ** ទើបដក ដង្ហើមចូល ។

២- អាត្មាអញជាអ្នក **ដឹងច្បាស់នូវសុខ** ទើបដក ដង្ហើមចេញ -

អាត្មាអញជាអ្នក **ដឹងច្បាស់នូវសុខ** ទើបដក ដង្ហើមចូល ។

៣- អាត្មាអញជាអ្នក **ដឹងច្បាស់នូវចិត្តសង្ខារ**(គឺ វេទនា និង សញ្ញា) ទើបដក ដង្ហើមចេញ -

អាត្មាអញជាអ្នក **ដឹងច្បាស់នូវចិត្តសង្ខារ** ទើបដក ដង្ហើមចូល ។

៤- អាត្មាអញជាអ្នក **រម្ងាប់នូវចិត្តសង្ខារ** ទើបដក ដង្ហើមចេញ -

---

[17] អដ្ឋកថាពន្យល់ថា [ធ្វើខាងដើម ធ្វើកណ្តាល ធ្វើទីបំផុត] នៃកាយ គឺ ដង្ហើមចេញទាំងអស់ឲ្យប្រាកដ។

[18] កាយសង្ខារ គឺ អស្សាសៈ និង បស្សាសៈ ។

*អាត្មាអញជាអ្នក **រម្ងាប់នូវចិត្តសង្ខារ** ទើបដក <u>ដង្ហើមចូល</u> ។*

*ត្រកូលខ្យល់ ទាំង៤គូ (ចេញ-ចូល) នេះ ឈ្មោះថា បណីត ខ្យល់ល្អិតចុះស្រួល ចាត់ទុកជា ទុតិយជ្ឈាន (ឈានទី២) ។*

**<u>ពួកទី ៣ (*តតិយ ចតុក្កៈ*)</u>**

*១- អាត្មាអញជាអ្នក **ដឹងច្បាស់នូវចិត្ត** ទើបដក <u>ដង្ហើមចេញ</u> -*

*អាត្មាអញជាអ្នក **ដឹងច្បាស់នូវចិត្ត** ទើបដក <u>ដង្ហើមចូល</u> ។*

*២- អាត្មាអញ **ធ្វើចិត្តឲ្យរីករាយ** ទើបដក <u>ដង្ហើមចេញ</u> -*

*អាត្មាអញ **ធ្វើចិត្តឲ្យរីករាយ** ទើបដក <u>ដង្ហើមចូល</u> ។*

*៣- អាត្មាអញ **តម្កល់ចិត្តឲ្យស្មើក្នុងអារម្មណ៍** ទើបដក <u>ដង្ហើមចេញ</u> -*

*អាត្មាអញ **តម្កល់ចិត្តឲ្យស្មើក្នុងអារម្មណ៍** ទើបដក <u>ដង្ហើមចូល</u> ។*

*៤- អាត្មាអញ **នឹងដោះចិត្តឲ្យរួចចាកនីវរណធម៌**[19] ជាដើម ទើបដក <u>ដង្ហើមចេញ</u> -*

*អាត្មាអញ **នឹងដោះចិត្តឲ្យរួចចាកនីវរណធម៌** ជាដើម ទើបដក <u>ដង្ហើមចូល</u> ។*

---

[19] *អដ្ឋកថាពន្យល់ថា ៖ ភិក្ខុដោះចិត្តឲ្យរួចចាក នីវរណធម៌ដោយ* **បឋមជ្ឈាន** - *ឲ្យរួចចាក វិតក្កៈ និង វិចារៈ ដោយ* **ទុតិយជ្ឈាន** - *ឲ្យរួចចាក បីតិ ដោយ* **តតិយជ្ឈាន** - *ឲ្យរួចចាក សុខៈ និង ទុក្ខ ដោយ* **ចតុត្ថជ្ឈាន** - *ឲ្យរួចចាក និច្ចសញ្ញា ដោយ* **អនិច្ចានុបស្សនា** - *ឲ្យរួចចាក សុខសញ្ញា ដោយ* **ទុក្ខានុបស្សនា** - *ឲ្យរួចចាក អត្តសញ្ញា ដោយ* **អនត្តានុបស្សនា** - *ឲ្យរួចចាក នន្ទិ ដោយ* **និព្វិទានុបស្សនា** - *ឲ្យរួចចាក រាគៈ ដោយ* **វិរាគានុបស្សនា** *(ល)* - *ឲ្យរួចចាក តណ្ហា ដោយ* **និរោធានុបស្សនា** *។*

ត្រកូលខ្យល់ ទាំង៤គូ (ចេញ-ចូល) នេះ ឈ្មោះថា និច្ចលាសុខុម
ខ្យល់ល្អិតជាសុខ ព្រះយោគីជិតបានឈាន ចាត់ជា តតិយជ្ឈាន (ឈានទី៣) ។

**<u>ពួកទី ៤</u>** <u>(ចតុត្ថ ចតុក្កៈ)</u>

១- អាត្មាអញជាអ្នក **ឃើញរឿយៗនូវបញ្ចក្ខន្ធថាមិនទៀង** ទើបដក <u>ដង្ហើមចេញ</u> - អាត្មាអញជាអ្នក **ឃើញរឿយៗនូវបញ្ចក្ខន្ធថាមិនទៀង** ទើបដក <u>ដង្ហើមចូល</u> ។

២- អាត្មាអញជាអ្នក **ឃើញរឿយៗនូវធម៌ដែលប្រាសចាករាគៈ** ទើបដក <u>ដង្ហើមចេញ</u> - អាត្មាអញជាអ្នក **ឃើញរឿយៗនូវធម៌ដែលប្រាសចាករាគៈ**
ទើបដក <u>ដង្ហើមចូល</u> ។

៣- អាត្មាអញជាអ្នក **ឃើញរឿយៗនូវធម៌ដែលរលត់បង់នូវកងទុក្ខ** ទើបដក <u>ដង្ហើមចេញ</u> - អាត្មាអញជាអ្នក **ឃើញរឿយៗនូវធម៌ដែលរលត់បង់នូវកងទុក្ខ**
ទើបដក <u>ដង្ហើមចូល</u> ។

៤- អាត្មាអញជាអ្នក **ឃើញរឿយៗនូវធម៌ដែលជាគ្រឿងលះចោលនូវកិលេស** ទើបដក <u>ដង្ហើមចេញ</u> - អាត្មាអញជាអ្នក **ឃើញរឿយៗនូវធម៌ដែលជាគ្រឿងលះចោលនូវកិលេស** ទើបដក <u>ដង្ហើមចូល</u> ។

ត្រកូលខ្យល់ ទាំង៤គូ (ចេញ-ចូល) នេះ ឈ្មោះថា អតិនិច្ចលាតិសុខុម
ខ្យល់ល្អិតក្រៃពេក ព្រះយោគីបានសម្រេចឈានហើយ គ្មានដង្ហើមដូចស្លាប់
ចាត់ជា ចតុត្ថជ្ឈាន (ឈានទី៤) ហៅថា អប្បនាឈាន ។

មុននឹងបញ្ចប់ ខ្ញុំសូមជំរាបនូវពាក្យថា **ឃើញរឿយៗ** ។ ឃើញ គឺយល់ ហើយដើម្បីយល់ ត្រូវពិចារណា ។ ដើម្បីយល់ត្រូវ ទាល់តែពិចារណាដោយប្រើបញ្ញា ដែលផ្នែកមួយនៃ វិបស្សនា ។ តើយើងពិចារណា ទៅលើធម៌ អ្វីខ្លះ ។ ធម៌ដែលគួរពិចារណាមានៈ

**សង្ខារធម៌ទាំងអស់ជារបស់មិនទៀង** យើងឃើញថា មិនទៀងដោយប្រើបញ្ញា។ បញ្ញាដែលដឹងពិត ឃើញពិត ក្នុងសភាវៈ **កើតឯង** របស់សង្ខារ ។ របស់ណាដែល កើតឯង គឺកើតដោយខ្លួនវា របស់នោះ ក៏រលត់បាត់បង់ទៅវិញដោយខ្លួនវាដែរ ។ ដូច្នេះយើងមិនដឹងថាវារលត់នៅពេលណាទេ បានន័យថាជារបស់មិនទៀង។ របស់ណាមិនទៀង របស់នោះជា **ទុក្ខ** ហើយក៏មិនមែនជារបស់យើងដែរ មិនមែនជា ខ្លួន-ប្រាណ យើងដែរ ដែលបាលីហៅថា **អនត្តា** ។ របស់នោះមិនគួរបើនឹងប្រកៀក ប្រកាន់ ថាជារបស់យើង ថាជាខ្លួនយើង ដោយអំណាច **តណ្ហា ឧបាទាន មានៈ** និង **ទិដ្ឋិ** ឡើយ ។ ព្រោះថា ខ្លួនប្រាណ យើង គេ មិនមានទេ ។ បញ្ញាដែលពិចារណា ឃើញជាក់ច្បាស់យ៉ាងនេះ ដរាបដល់កើត **និព្វិទា** (សេចក្តីនឿយណាយ) មិនស្អាតខ្ពើម សង្ខារ កើត **វិរាគ** ប្រាសចាកសេចក្តីត្រេកអរក្នុងសង្ខារ ។ **វិមុត្តិ** រួចផុតចាក **កិលេស អាសវៈ** ទាំងអស់ នេះជាតួ **វិបស្សនា** ទាំងអស់ដូចគ្នា ។

យើងអាចសួរថា សង្ខារធម៌កើតឡើងឯង នោះវាមិនទៀង ខ្ញុំសុខចិត្តទទួលហើយ តែ ដូចជាផ្ទះខ្ញុំ ដែលខ្ញុំសាងសង់ដោយដៃខ្ញុំ មិនមែនកើតឡើងឯងឯណា គឺខ្ញុំជាអ្នកបង្កើត វា ហេតុអ្វីក៏មិនទៀងដែរ? ចម្លើយ គឺ មកពី គ្រឿងប្រដាប់ដែលយើងយកមកសង់ផ្ទះ នោះ សុទ្ធតែជាសង្ខារធម៌ ដែលកើតឡើងឯង ដូចជាឈើសសរផ្ទះ យើងបានមកពីដើម ឈើនៅក្នុងព្រៃ ដែលដុះឯង ជាដើម ។ ឧទាហរណ៍មួយទៀត ដែលថា វាកើតខ្លួនវា ដូចអ្នកខ្លះ ចង់បានកូន ទៅជាមិនបានទៅវិញ ទាល់តែទៅសុំកូនគេមកចិញ្ចឹម ហើយ អ្នកខ្លះមិនចង់បានកូនទៀតទេ (ពីព្រោះមានកូនច្រើនហើយ) ត្រឡប់ជាមានទៅវិញ ។ នេះមកអំពីតាមច្បាប់ធម្មជាតិ « ធម៌ទាំងឡាយកើតមកពីហេតុ » គឺមិនមែនយើងជា អ្នកបង្កើតទេ គឺហេតុទេដែលបង្កើតធម៌នោះ ។ តែក្នុងការប្រាស្រ័យទាក់ទងគ្នា យើង និយាយថា ឪពុកម្តាយជាអ្នកបង្កើតកូន ។ យើងអាចសួរតទៅទៀតថា « ធម៌ទាំងឡាយ

កើតមកពីហេតុ» ជាការពិតហើយ ។ តែកូនបើឪពុកម្ដាយមិនបានរួមដំណេកជាមួយគ្នា ក៏មិនមានកូនដែរ។ ដើម្បីនឹងឆ្លើយទៅសំណួរនេះ គឺ ឪពុកម្ដាយរួមដំណេកជាមួយគ្នាក៏ជាហេតុមួយដែរ ។ តាមធម៌ព្រះ ហេតុមានបី ដែលចូលរួមតៗគ្នា គឺ ដើម្បីមានកំណើត ត្រូវ នៅពេលដែលឪពុកម្ដាយរួមសង្វាសជាមួយគ្នានោះ ម្ដាយមានរដូវដែលចំពេលមានកូន ហើយកូនដែលមកចាប់កំណើតនោះក៏ត្រូវពេលវេលាមកចាប់ជាតិជាថ្មីម្ដងទៀតដែរ ទៅតាមកម្មផលពីអតីតជាតិរបស់ខ្លួន។ ដូច្នេះបើយើងថាឪពុកម្ដាយជាអ្នកបង្កើតកូនក៏ជាមិនខុសអ្វីដែរ ពីព្រោះនេះជាហេតុមួយក្នុងហេតុទាំងបី។ ឧទាហរណ៍នេះ ធ្វើឲ្យយើងកាន់តែយល់ធម៌បដិច្ចសមុប្បាទ ដែលមានហេតុតៗគ្នារហូតដល់១២កង។ មានឧទាហរណ៍មួយទៀត ដែលខ្ញុំធ្លាប់ជួបដោយខ្លួនខ្ញុំផ្ទាល់ គឺ ថ្ងៃមួយ ប្រហែលម៉ោង ៩ ព្រឹក ខ្ញុំបានបរ រថយន្ត ជូនព្រះសង្ឃទៅផ្ទះអ្នកធ្វើបុណ្យប្រគេនចង្ហាន់ដល់ព្រះសង្ឃ ។ រថយន្តកំពុងតែបើកតាមផ្លូវធំ (autoroute) ល្បឿនប្រហែល ១០០ គីឡូម៉ែត្រ ក្នុង ១ ម៉ោង ក៏ស្រាប់តែមានសត្វស្លាបមិនដឹងជាហើរមកពីណាទេ មកជុះអាចម៍ ចំមុខកញ្ចក់ឡានខ្ញុំដែលកំពុងបើក ។ យើងមើល តើហេតុដែលធ្វើឲ្យកញ្ចក់ឡានប្រឡាក់របៀបនេះមានប៉ុន្មាន មានមួយឬក៏មានច្រើន ។ យើងឆ្លើយថាមានច្រើន ហើយហេតុទាំងនោះវាមកដល់ជាប់ៗគ្នា ហាក់បីដូចជាមកទាំងអស់តែមួយពេល ។ តាមពិត បើសត្វនោះវាមិនបានចេញដំណើរ កាលពីមុន ឡានខ្ញុំមកដល់ទីនោះទេ ក៏គ្មានសត្វ មកជុះដាក់កញ្ចក់ឡានខ្ញុំដែរ ហើយដើម្បីនឹងធ្លាក់ឲ្យចំកញ្ចក់ឡានដែលកំពុងតែបើកនោះទៀត ត្រូវល្បឿនឡាននៅពេលនោះ វាត្រូវពេល នឹងលាមកដែលកំពុងតែធ្លាក់ពីលើមេឃមក ។ នេះសរឲ្យឃើញថាហេតុមានច្រើន។ ដូច្នេះយើងថាកូនកើតមកពីម៉ែឪ ក៏មិនខុសដែរ ត្រូវមានចិត្តឲ្យទូលាយ។ ដូចគេថា មនុស្សខ្វាក់ ស្ទាបចំត្រចៀកដំរី ក៏ថាដំរី មានរាងដូចផ្ចិត ហើយម្នាក់ទៀតស្ទាបចំជើងដំរី ក៏ប្រកែកថា ដំរី មានរាងដូចសសរផ្ទះ ជាដើម ។

បើតាមធម៌បដិច្ចសមុប្បាទ ហេតុដែលនាំឲ្យកើតមិនមានត្រឹមតែបីនោះទេ គឺមានច្រើនរាប់មិនអស់ ។ ដូចព្រះពុទ្ធនៃយើង ដែលបានត្រាស់ជាព្រះពុទ្ធមិនមែនដោយការកសាងរបស់ព្រះអង្គតែមួយជាតិចុងក្រោយនោះទេ ។ បើរាប់ចាប់ពី ព្រះពុទ្ធទីបង្ករ មកព្រះអង្គបានកសាងចំនួន បួនអសង្ខេយ្យនិងមួយសែនកប្បរួចទៅហើយ។ តើព្រះអង្គកសាងអ្វី ក្នុងកំឡុង បួនអសង្ខេយ្យនិងមួយសែនកប្បនោះ ? តាមខ្ញុំយល់ គឺព្រះអង្គកសាងដោយធ្វើនូវអំពើដែលជាកុសល ហើយជៀសវាងនូវបាបកម្មទាំងពួង ។

# ១១

## អំពី សិស្ស ពូកែ ជាងគ្រូ

*សិស្សពូកែជាងគ្រូ មិនមានអ្វីប្លែកទេ បើគ្រូជាមនុស្សសាមញ្ញធម្មតា តែបើគ្រូជាព្រះពុទ្ធ* **គោតម** *សូមមើលឲ្យគ្រប់ជ្រុងជ្រោយផង មើលឲ្យអស់ ៨៤០០០ ធម្មក្ខន្ធ ជាមុនសិន មុននឹងនិយាយថា ធម៌ព្រះពុទ្ធ ខ្វះត្រង់នេះ ឬ ខ្វះត្រង់នោះ ។ មានពេលមួយ ព្រះពុទ្ធ ព្រមទាំងបរិវារ បានមកដល់ព្រៃឈើ ហើយសម្រាកក្រោមដើមឈើមួយដើម ។ ព្រះអង្គបានយកស្លឹកឈើមួយក្តាប់ មកសួរភិក្ខុទាំងឡាយថា « ម្នាលភិក្ខុទាំងឡាយ ស្លឹកឈើនៅក្នុងបាតដៃតថាគត និង ស្លឹកឈើនៅក្នុងព្រៃនេះ តើស្លឹកឈើណាច្រើនជាង »។ ព្រះភិក្ខុឆ្លើយថា គឺ ស្លឹកឈើនៅក្នុងព្រៃ ។ ព្រះអង្គមានព្រះបន្ទូលតទៅទៀតថា « ធម៌ដែលតថាគតត្រាស់ដឹង ប្រៀបដូចស្លឹកឈើនៅក្នុងព្រៃនេះ តែធម៌ដែលតថាគតយកមកផ្សព្វផ្សាយប្រៀបដូចស្លឹកឈើនៅក្នុងបាតដៃតថាគត ពីព្រោះតថាគតយកតែធម៌ណាដែលមានប្រយោជន៍ដល់សព្វសត្វ » ។*

*បើយោងទៅតាមពុទ្ធដីកានេះ ធម៌ដែលព្រះអង្គយកមកបង្ហាត់បង្រៀនទាំងប៉ុន្មានសុទ្ធតែមានប្រយោជន៍ដល់យើងទាំងអស់ ដូចជា ការធ្វើសមាធិ ជាដើម ។ ចុះហេតុអ្វី បានជាមានលោកគ្រូ* **អភិធម្ម** *មួយក្រុមបានពន្យល់សិស្សថា ៖ « ឲ្យតែយល់ធម៌អភិធម្ម ទៅមិនចាំបាច់ ធ្វើការបដិបត្តិអ្វីទៀតទេ ពីព្រោះការបដិបត្តិនៅនឹងការយល់នេះហើយ » ។ ហើយលោកបានបញ្ជាក់ថែមទៀតថា ៖*

*« ធ្វើសមាធិ នាំតែឲ្យខាតពេល » ។*

*ចំពោះការអះអាង របស់លោកគ្រូអភិធម្មទាំងនោះ ខ្ញុំសូមលើកយករឿង ដែលមានក្នុង*

គម្ពីរ ជាកស្តុតាង បន្ទាប់មកខ្ញុំសូមលើកជាសំណួរ ជូនទៅឲ្យលោកគ្រូទាំងនោះ[20] ៖

មានថ្ងៃមួយ នៅតាមផ្លូវ ដល់វេលាយប់ ព្រះពុទ្ធទ្រង់សំណាក់នៅរោងហាលមុខផ្ទះអ្នកស្មូនឆ្នាំងម្នាក់។ នៅមុនពេលនោះ ក៏មានយុវជន ជាអ្នកបួសម្នាក់ ឈ្មោះ បុក្កុសាតិ បានមកសុំសំណាក់នៅទីនោះដែរ ។ ព្រះពុទ្ធដោយឃើញយុវជននោះមានឫកពាសមរម្យ ក៏សួរទៅយុវជននោះថា តើអ្នកចេញចាកគ្រួសារ មកបួស តាមគ្រូណា ? តាមទ្រឹស្តីណា ? បុក្កុសាតិ ឆ្លើយថា ខ្ញុំបួសតាម ព្រះគោតម ដែលមានឈ្មោះល្បីថាជាព្រះអរហន្ត បានត្រាស់ដឹងដ៏បរិបូរ ។

- ព្រះអង្គសួរតទៅទៀតថា : តើព្រះអរហន្តនោះ គង់នៅឯណា ?
- ព្រះអង្គគង់នៅក្រុងសាវត្ថី ភាគប្រទេសខាងជើង
- តើអ្នកឯង ដែលបានឃើញទេ ហើយស្គាល់ទេ ប្រសិនបើជាបានជួប
- ខ្ញុំពុំដែលបានឃើញទេ ហើយក៏ពុំស្គាល់ដែរ ប្រសិនបើជាខ្ញុំបានជួបព្រះអង្គ ។

ព្រះពុទ្ធ ទ្រង់ជ្រាបថា គឺក្នុងនាមព្រះអង្គហើយ ដែលអ្នកបួសនេះចេញចាកគ្រួសារ ហើយក៏ទ្រង់មានព្រះបន្ទូលតទៅទៀតថា ៖ ម្នាលភិក្ខុ ចូរអ្នកប្រុងស្តាប់ទ្រឹស្តីដូចតទៅនេះ យើងនឹងសម្តែង ៖

- ប្រសើរណាស់ អាវុសោ (ភិក្ខុនោះឆ្លើយ) ។

ព្រះអង្គក៏ចាប់សម្តែងដោយពិស្តារអំពី និរោធសច្ចៈ (ព្រះនិព្វាន) ។ លុះបានស្តាប់ចប់ហើយ ភិក្ខុនោះក៏ដឹងថា អ្នកដែលសម្តែងនេះ គឺជាព្រះពុទ្ធ ហើយក៏ងើបឈរឡើងអោនថ្វាយបង្គំព្រះអង្គចំពីមុខ ហើយសុំខមាទោសពីព្រះអង្គ ដោយបានទុកព្រះអង្គ

[20] បើលោកគ្រូចង់ឆ្លើយ សូមប្រើ អាស័យដ្ឋាន របស់ពេជពុម្ពសៀវភៅនេះ។

ស្មើនឹងខ្លួន ដោយប្រើពាក្យអាវុសោ (មានន័យថា មិត្ត) ។ ហើយក៏សុំឲ្យព្រះអង្គបំបួស ។ ព្រះអង្គទ្រង់មានបន្ទូលថា ដើម្បីនឹងបួស អ្នកត្រូវមាន ត្រៃចីវរ និង បាត្រ ដូច្នេះចូរអ្នកទៅរករបស់នោះមក ។ បុក្កុសាតិ ក៏ចេញទៅរក ត្រៃចីវរ និង បាត្រ តែត្រូវ គោញីរ៉ែស្លាប់ ។ ដល់ពេលក្រោយមក លុះដំណឹងដ៏កំសត់នេះបានទៅដល់ព្រះពុទ្ធ ព្រះអង្គទ្រង់មានបន្ទូលថា បុក្កុសាតិ ជាអ្នកមានបញ្ញា បានយល់អរិយសច្ចៈ នេះជាជាតិចុងក្រោយ របស់គេហើយ។ គេបានសម្រេចអនាគាមី គេមិនត្រឡប់មកកើតទៀតឡើយ ។ ចាប់ពីនេះទៅខ្ញុំសូមលើកជា សំណួរ ដូចតទៅ ៖

១- នៅក្នុង រឿងនេះ បុក្កុសាតិ បានសម្រេច អនាគាមី ដោយគ្រាន់តែយល់ធម៌ អរិយសច្ចៈ មិនចាំបាច់រេះធម៌ អភិធម្ម ផង។

២- ព្រះពុទ្ធ បន្ទាប់ពីបានត្រាស់ដឹង ព្រះអង្គបានយាងទៅប្រោសពុទ្ធមាតា នៅឋាន តុសិតា ដោយសម្តែង ធម៌អភិធម្ម ធម៌ដែលលោកគ្រូអភិធម្ម យកមកបង្រៀនសព្វថ្ងៃនេះ ។ ហើយតាមដែលយើងបានដឹងថា ពុទ្ធមាតា បន្ទាប់ពីបានយល់ធម៌អភិធម្មសម្តែង ដោយព្រះពុទ្ធផ្ទាល់ផង បានសម្រេចត្រឹមតែ សោតាប៉ុណ្ណោះ។ ដូច្នេះមិនទាន់សម្រេចនិព្វានឯណា ។ បើបានតែត្រឹមសោតា នោះត្រូវកើត ៧ជាតិទៀតយ៉ាងតិចមុននឹងសម្រេចព្រះនិព្វាន ។ ចុះក្នុង ៧ ជាតិចុងក្រោយនេះ មួយថ្ងៃៗ ពុទ្ធមាតាធ្វើអ្វីខ្លះទៅ បើមិនចម្រើន សីល សមាធិ បញ្ញា ដែលជាការបដិបត្តិ ។ ទុកជាព្រះពុទ្ធក៏ព្រះអង្គ ចម្រើន អានាបានស្សតិ រឿយៗខ្លះៗដែរ មុននឹងបរិនិព្វាន ហើយ សាវកព្រះអង្គ ក៏ចំរើនការនោះដែរ មុននឹងបរិនិព្វាន ។

៣- ប្រសិនបើជាសមាធិ ឥតប្រយោជន៍ ម្តេចក៏ព្រះអង្គ មិនលុបសមាធិ នោះចោលទៅទុកតែធម៌អភិធម្ម ឲ្យយើងរៀនពាល់គ្នាទៅ នោះគ្រប់គ្រាន់ហើយ ។

៤- តាមធម្មតាគ្រូ មុននឹងពន្យល់សិស្ស នូវធម៌អ្វីមួយ ទាល់តែខ្លួនឯងយល់ធម៌នោះ

ជាមុនសិន ទើបសិស្សអាចយល់បាន។ ដោយយោងទៅតាមពាក្យសំដីលោកគ្រូអភិធម្ម ដែលថា « ឲ្យតែយល់ នោះបានសម្រេច មគ្គផលហើយ » តើលោកបានសម្រេចដល់ណាហើយដែរ សព្វថ្ងៃនេះ? អាចប្រាប់ខ្ញុំផងបានទេ ដើម្បី ជាភស្តុតាង។ ភស្តុតាងសំខាន់ណាស់ សម្រាប់ធ្វើឲ្យគេជឿ ដូចព្រះពុទ្ធ ប្រសិនបើជាមានតែព្រះអង្គមួយអង្គឯង ដែលបានសម្រេចនិព្វាននោះ ប្រហែលជាមានគេមិនជឿច្រើនជាងសព្វថ្ងៃនេះទៅទៀត តែភស្តុតាង គឺមានសាវកព្រះអង្គជាច្រើនបានសម្រេចនិព្វានដូចព្រះអង្គដែរ ។

# ១២

## តើយើងស្លាប់ទៅ សូន្យ ឬ កើតទៀត

*ខ្ញុំ លើកពាក្យ កើត ស្លាប់ មកពេលនេះ ពីព្រោះមាន ចម្លើយមិនដូចគ្នា ចំពោះសំណួរថា តើ* **ស្លាប់ហើយ កើតទៀត ឬ ក៏មិនកើតទៀត** *?*

*ខ្ញុំ គ្រាន់តែចង់រកហេតុផល នៃចម្លើយនីមួយៗនោះទេ ដោយពុំមានបំណងចង់ឲ្យលោកអ្នកអាន មកយល់តាមខ្ញុំនោះទេ ពីព្រោះការយល់ខុសគ្នានេះ មានតាំងពីសម័យមុនព្រះយើងម្ល៉េះ ។ មតិធំៗមានបី ៖*

*១- ស្លាប់ ហើយកើតទៀត ធ្លាប់កើតយ៉ាងណា កើតលើកក្រោយយ៉ាងនោះទៀត*

*២- ស្លាប់ ហើយ មិនកើតទៀតទេ គឺសូន្យតែម្តង*

*៣- ស្លាប់ហើយ អាចកើតទៀត ឬ មិនកើតទៀត ទៅតាមហេតុផ្សេងៗ ។*

*<u>មតិទី១-</u> សស្សតទិដ្ឋិ ជឿថាមានអត្តា <u>នៅរហូត</u> <u>មិនទាក់ទងនឹង</u> ការរីកចំរើន នៃកាយនឹងចិត្ត ទោះក្នុងជាតិនេះក្តី ឬជាតិខាងមុខក្តី ។ បានន័យថា បើជាតិនេះ កើតមកក្នុងពូជ ព្រាហ្មណ៍ ពីព្រោះកាលពី ជាតិមុនក៏ធ្លាប់ជា ព្រាហ្មណ៍ ហើយទៅជាតិខាងមុខ ក៏កើតជាព្រាហ្មណ៍តទៅទៀត ។ ដូច្នេះចំពោះ អ្នកកើត ក្នុងត្រកូលអ្នកក្រ ត្រកូលផ្សេងទៀតៗ គេមិនរាប់រកទេ ។*

*<u>មតិទី២</u>- ឧច្ឆេទទិដ្ឋិ ជឿថាមានអត្តា មានការរីកចំរើន នៃកាយនឹងចិត្ត ប្រហាក់ប្រហែលនឹងមតិទី១ ដែរ តែទាំងអស់នេះនឹងរលាយសោះសូន្យ ជាមួយនឹងសេចក្តីស្លាប់ ។ ត្រង់មតិនេះខ្ញុំមានសំណួរ តែខ្ញុំមិនចេះឆ្លើយ ។ សំណួរថា ៖ បើស្លាប់ទៅសូន្យ មិនកើតទៀត ចុះអ្នកដែលកើតមកដល់ថ្ងៃនេះ ចេញមកពីទីណា ពីមជ្ឈដ្ឋានណា ឬ ក៏*

ធ្លាក់មកពីលើមេឃ ដោយចៃដន្យ ដូចទឹកភ្លៀង ។

ប្រសិនបើជាចេញពីមជ្ឈដ្ឋានណាមួយ

ហើយប្រសិនបើជា អ្នកដែលស្លាប់នោះមិនត្រឡប់ទៅកើតនៅ មជ្ឈដ្ឋាននោះវិញទេ មជ្ឈដ្ឋាននោះ មានអ្វីផ្តល់មកឲ្យកើតទៀត ពីព្រោះមានតែរបស់ចេញ ឥតមានរបស់ចូល ។ ចំពោះមេឃភ្លៀង គឺផ្តល់ដោយពពក ។ សំណួរមួយទៀត គឺមានកូនក្មេងដែល កើតមកហើយ ចាំជាតិ ។ ហេតុការណ៍នេះ មានទាំងនៅក្នុងស្រុកខ្មែរផង ទាំងនៅបរទេសទៀត ។ អំពីការចាំជាតិនេះ លោកបណ្ឌិត ម៉ែម ទីន មន សាស្ត្រាចារ្យ ជាតិភូមា បានប្រមូលភស្តុតាងជាច្រើន ដែលនៅសហរដ្ឋអាមេរិកក៏មាន នៅប្រទេសរបស់លោកក៏មាន ។ ចំពោះយើង ដែលជាអ្នកជឿព្រះពុទ្ធសាសនា និង ជឿធម៌ កម្មផល ពុំមានអ្វីប្លែកទេ ។ ពីព្រោះរឿង ក្នុងគម្ពីរទាំងប៉ុន្មាន ដែលទាក់ទងនឹង ការកសាងរបស់ព្រះពុទ្ធ សុទ្ធតែស្តីពី អតីតជាតិដ៏ច្រើន របស់ព្រះអង្គ មុននឹងដល់ជាតិចុងក្រោយ ដែលជាជាតិព្រះអង្គត្រាស់ដឹង ។ ដូចជាព្រះអង្គ ចាប់ជាតិជា ព្រះវេស្សន្តរ ជាដើម ។

ខ្ញុំសូមដកស្រង់រឿងមួយ ដែលមានក្នុងសៀវភៅ « កម្ម អ្នកសាងលោកពិត » របស់លោកបណ្ឌិត ម៉ែម ទីន មន ដូចតទៅនេះ ៖

នៅ មីយ៉ាម៉ា (ភូមា) ភាគកណ្តាលក្នុងភូមិមួយឈ្មោះ អ៊ិន ពីន ហ្វាក់ នៅសង្កាត់ ទាហ្គូន មានកូនក្មេងស្រីម្នាក់ កើតមកមានដុំសាច់ពកពីរ នៅលើក្បាលរបស់ខ្លួន ដូចជាស្នែងក្របី ។ នាងឈ្មោះ **ម៉ា ហ្តៃ** (Ma Htay) នៅពេលនាងអាចនិយាយបានច្បាស់ នាងបាននិយាយអំពី អតីតជាតិ ២ ដងរបស់នាង ។

ក្នុងអតីតជាតិទី ១ របស់នាង នាងឈ្មោះ **ឆ័រ ម៉្វាក់** នៅភូមិ **ញ៉ោងប៊ីន ជី** ។ **ឆ័រ ម៉្វាក់ បានជួល ម៉ា តេងទីន** ព្រមទាំងម្តាយនាង ឲ្យធ្វើការក្នុងស្រែរបស់ខ្លួន ។ **ម៉ា តេងទីន** ទើបតែមានអាយុ ១៣ ឆ្នាំ ប៉ុន្តែនាងមានរាងខ្ពស់មាំ ។ ដូច្នេះម្តាយរបស់នាង បណ្តោយ

ឲ្យនាង ធ្វើការដូចមនុស្សពេញវ័យដែរ ។ ប៉ុន្តែនៅពេល **ឌ័រ ម៉្វាក់** ឲ្យប្រាក់ថ្លៃឈ្នួលដល់ពួកគេ នាងឲ្យ **ម៉ា តេង់ទីន** តែថ្ងៃពាក់កណ្តាលនៃតម្លៃមនុស្សពេញវ័យ ដោយនិយាយថា **ម៉ា តេង់ទីន** ជាកូនក្មេង ។ ម្តាយរបស់ **ម៉ា តេង់ទីន** បាននិយាយអង្វរថា យើងជាអ្នកក្រីក្រ ដូច្នេះហើយ ទើបខ្ញុំបណ្តោយឲ្យកូនខ្ញុំ ធ្វើការដូចមនុស្សពេញវ័យ ដើម្បីទទួលបានប្រាក់ឈ្នួលដូចមនុស្សពេញវ័យ ដូច្នេះសូមមេត្តាផ្តល់ឲ្យនាងនូវប្រាក់ឈ្នួលដូចមនុស្សពេញវ័យផង ។ **ឌ័រ ម៉្វាក់** បដិសេធ មិនព្រមឲ្យថ្លៃឈ្នួលនោះទេ ។ នេះជាការបោកប្រាស់ថ្លៃឈ្នួលពាក់កណ្តាល របស់ **ម៉ា តេង់ទីន** ។ ដូច្នេះនៅពេល **ឌ័រ ម៉្វាក់** បានស្លាប់ទៅ នាងបានទៅចាប់កំណើត នៅក្នុងផ្ទៃនៃក្របីរបស់ **ម៉ា តេង់ទីន** ។ នាងកើតជាក្របីញី កើតកូនបានបី ក៏ស្លាប់ទៅ ។ នៅពេលយប់មុនពេលស្លាប់ **ម៉ាតេង់ទីន** សុបិនថា ក្របីញីនោះ មករកនាង ហើយឲ្យសាច់ដល់នាង ។ **ម៉ា តេង់ទីន មានគភ៌ ហើយសម្រាលកូនបាន ម៉ា ហ្លៃ** ដែលមានសាច់ពកដុះឡើងពីរដូចស្នែងនៅលើក្បាល ដើម្បីចង្អុលបង្ហាញថា អតីតជាតិរបស់នាងគឺ ជាក្របី ។ **ម៉ា ហ្លៃ** បានចាំកូនក្របីឈ្មោលទាំង ៣ របស់នាងក្នុងអតីតជាតិ ហើយទួញយំស្រក់ទឹកភ្នែក ចំពោះកូនទាំង ៣នោះ ។ បណ្ឌិត **អៀន ស្តេវិនសិន** បានមកប្រទេសមីយ៉ាម៉ា ដើម្បីពិនិត្យសង្កេតលើករណីនេះ[21]។

<u>យើងគួរវិភាគ រឿងនេះដែរ</u> ៖

តើយើងជឿថា ស្លាប់ ហើយកើតទៀតទេ ? ចំពោះខ្ញុំ សំណួរមិននៅត្រង់ ជឿ ឬ មិនជឿទេ ។ ពីព្រោះថា កាលណាយើងឃើញអ្វីមួយ ច្បាស់ដោយភ្នែកហើយ អត់មានអ្វីថា ជឿ ឬ មិនជឿនោះទេ ។ ឧបមាដូច ខ្ញុំក្តាប់បាតដៃខ្ញុំជិត ខ្ញុំសួរទៅលោកអ្នកថា

[21] Dr. Mehm Tim Mom, « Two Paths for Future Existence », published in Myanmar Langage. Third Printing, p.195

« តើជឿថាខ្ញុំ បានក្លាប់លុយ ឬទេ ? » នោះលោកអ្នកខ្លះថាជឿថាមានលុយ លោកអ្នកខ្លះថាជឿថា អត់មានលុយ គឺបាតដៃទទេ។ យើងឆ្លើយបែបនេះ មកពីយើងពុំទាន់បានឃើញដោយភ្នែករបស់យើង ។ តែដល់ខ្ញុំលាបាតដៃហើយ នោះលោកអ្នកឃើញច្បាស់ដោយភ្នែកថា មាន ឬមិនមាន ស្រេចទៅហើយ ។

តែសំណួរដែល លោកអ្នកគួរសួរនៅពេលនេះ គឺថា **តើរឿងនោះ ពិត ឬ មិនពិត។** នៅពេលនេះខ្ញុំឆ្លើយថា គួរប្រើបញ្ញារៀងៗខ្លួន ។ ចំពោះខ្ញុំ ដោយរឿងរបៀបនេះ ក៏ស្របនឹងធម៌ព្រះដែរ ហើយអ្នកសរសេររឿងនេះទៀត បានទៅឃើញផ្ទាល់ជាមួយលោក បណ្ឌិត **អៀន ស្តេរិនសិន** ខ្ញុំថាជារឿងពិត ។

លោកអ្នកអាចសួរថា តើហេតុអ្វី ក៏មនុស្សមិនចាំជាតិគ្រប់ៗគ្នាទៅ ? ខ្ញុំសូមឆ្លើយតាមការយល់ ការសង្កេតរបស់ខ្ញុំ ៖ មនុស្សយើងសព្វថ្ងៃនេះ មានការចាំមិនដូចគ្នាទេ អ្នកខ្លះគេមើលមេរៀនតែពីរបីចប់ គេចាំសូត្រគ្មានខុសមួយមាត់ ហើយអ្នកខ្លះរៀនមេរៀនដដែលមួយព្រឹកធំមិនទាន់ចាំផង ។ ដូច្នេះបើគ្រាន់តែក្នុងជាតិបច្ចុប្បន្ន នេះភ្លេចទៅហើយ ទំរាំតែស្លាប់ហើយកើតម្តងទៀតឲ្យចាំ នោះមិនងាយទេ ។ ត្រូវខំធ្វើធម្មទានសន្សំបុណ្យកុសល តទៅទៀត ។ ម្យ៉ាងទៀត យើងឃើញក្នុងរឿងនេះ នាង **ឌ័រ ម៉្វាក់** បដិសេធមិនព្រម ឲ្យប្រាក់ឈ្នួលទៅនាង **ម៉ា តេងទីន** ដូចជាមនុស្សពេញវ័យទេ ទុកជាម្តាយនាងនេះអង្វរយ៉ាងណាក៏ដោយ ។ ត្រង់នេះ យើងឃើញថានាង **ឌ័រ ម៉្វាក់** យកអំណាចមក កេងប្រវ័ញ្ចអ្នកក្រីក្រ ហើយថែមគ្មានធម៌មេត្តាទៀតផង។ ដល់នាងនេះមកកើតជាក្របីញី ត្រូវបាន នាង **ម៉ា តេងទីន** ជាម្ចាស់ក្របី (នេះមកពីជំពាក់ប្រាក់ឈ្នួលនាង**ម៉ា តេងទីន** កាលពីអតីតជាតិ) ។ ហើយក្របីញីនោះ មានកូនដល់ទៅ ៣ សុទ្ធតែជាក្របីឈ្មោល មុននឹងខ្លួនស្លាប់ ហើយ មកចាប់ជាតិជា កូនរបស់នាង **ម៉ា តេងទីន** ទៀត ដោយមានឈ្មោះថា នាង **ម៉ា ហ្កៃ**។ នាង **ម៉ា ហ្កៃ** ដោយចាំជាតិ

ឃើញក្របី ឈ្មោលទាំង៣ ដែលជារបស់ម្ដាយនាង ហើយ ដែលជា កូនរបស់នាងកាលពីជាតិមុន  ក៏ទួញយំស្រក់ទឹកភ្នែក ចំពោះកូនទាំង៣នោះ ។ នេះគ្រាន់តែឃើញកូនប៉ុណ្ណឹងស្រក់ទឹកភ្នែកទៅហើយ  ចុះដល់ថ្ងៃមុខបើគេយកក្របីទាំងនោះ ទៅប្រើដោយគ្មានធម៌មេត្តា ដូចកាលនាង ប្រើនាង **ម៉ា តេងទីន** ដោយគ្មានធម៌មេត្តាដែរនោះ តើនាងមានទឹកឃើញទេថា "តើម្ដាយនាង **ម៉ា តេងទីន** កាលអតីតជាតិនោះ អាណិតកូនគាត់យ៉ាងណាដែរ?" (នេះហើយ កម្មពៀរ វាច្នងមិនចេះចប់ក្នុងវដ្តសង្សារ) ។

<u>មតិទី៣</u>- គឺពន្យល់តាមព្រះពុទ្ធសាសនា ដោយយកធម៌ **កម្ម ផល** ជាគោល ហើយ ធម៌នេះ អ្នកវិទ្យាសាស្ត្រ គេអាចយល់បាន ពីព្រោះស្របនឹងច្បាប់ធម្មជាតិ។ ធម៌ព្រះពុទ្ធមួយទៀតគឺ **ធម៌ទាំងឡាយ កើតមកអំពីហេតុ** (ដូច្នេះគ្មានអ្វី កើតដោយចៃដន្យទេ)។ តាមធម៌ព្រះពុទ្ធ មិនពិបាកយល់ទេ ៖

មនុស្សយើងម្នាក់ៗរស់នៅសព្វថ្ងៃតែងតែធ្វើអំពើណាមួយ ដោយ កាយ វាចា ឬចិត្ត ។ អំពើ តាមភាសាធម៌ ហៅថា កម្ម ។ កម្ម មានបួនប្រភេទ គឺ **កម្មស** (កុសល) **កម្មខ្មៅ** (អកុសល) **កម្មសខ្លះខ្មៅខ្លះ និង កម្មមិនស មិនខ្មៅ** (មិនកុសល មិនអកុសល) ដែលគេហៅថា **កិរិយា ប្រព្រឹត្តទៅដើម្បីអស់កម្ម** ។

តាមព្រះពុទ្ធសាសនា ចេតនាកម្ម[22]តែងតែឲ្យផល ជា កុសល ឬ ជា អកុសល ។ ចំពោះ កម្ម ដែលជា កិរិយា មានព្រះអរិយបុគ្គល ដូចជាព្រះសោតាបន្នបុគ្គលជាដើម លោកធ្វើដើម្បី រំលត់ទុក្ខ ហើយកម្មព្រះអរហន្ត គឺ កម្មប្រព្រឹត្តទៅដើម្បីអស់កម្ម ពីព្រោះលោកដល់ត្រើយហើយ ដូច្នេះលោកមិនត្រូវការកុសលអ្វីទៀតទេ ។ កុសលទុកដូចជាក្បូនសម្រាប់តែចម្លងលោក ពីត្រើយម្ខាង ទៅត្រើយម្ខាង។ ហេតុនេះហើយបានជាអំពើ

---

[22] ចេតនា គឺ ជា កម្ម ដែលធ្វើដោយមានបំណងជាក់ច្បាស់ ដោយគំនិតខ្លួនឯង ។

ដែលលោកធ្វើទាំងប៉ុន្មាន គឺសម្រាប់តែជួយសត្វលោកដែលត្រូវការសន្សំកុសល នៅឡើយ និង លះ អកុសល ។ ដោយយើងម្នាក់ៗ សុទ្ធតែនៅមានកុសល និង អកុសល ពីអតីតជាតិ និង បច្ចុប្បន្នជាតិ ដូច្នេះយើងត្រូវតែកើតទៀត ដើម្បី ទទួលផល នៃអំពើដែលយើងបានធ្វើ ។ នេះហើយ ការពន្យល់តាម ព្រះពុទ្ធសាសនា ដែលថា « ស្លាប់ហើយ កើតទៀត » ។ យើងអាចសួរថា ចំពោះព្រះអរហន្ត លោកធ្វើកិរិយា ក្នុងជាតិបច្ចុប្បន្ននេះពិតមែនហើយ តែដោយមានកម្មពីអតីតជាតិដែរ ហេតុអ្វី បានជាលោកមិនកើតទៀត ?

ចម្លើយគឺ ៖ ចំពោះព្រះ អរហន្ត លោកអស់កិលេសហើយ បន្ទាប់ពីចុតិទៅ លោកសម្រេច និព្វាន ដូច្នេះ តាមព្រះពុទ្ធសាសនាលោកមិនត្រឡប់កើតទៀតឡើយ ។ ក្រៅពីព្រះ អរហន្ត បន្ទាប់ពីចុតិទៅ សុទ្ធកើតទៀតទាំងអស់ ដូចជាព្រះអរិយខ្លះ កើត៧ដងទៀត ខ្លះកើតម្តងទៀត ខ្លះបរិនិព្វាននៅជាតិចុងក្រោយនោះតែម្តង ។

មតិទី៣ នេះ មិនដូចមតិទី១ទេ ពីព្រោះ មតិទី១ បើអ្នកនោះធ្លាប់កើតជា មនុស្សអ្នកក្រ នៅតែកើតជាមនុស្សអ្នកក្រដដែល ចំពោះមតិទី៣ កើតម្តងៗ ទៅតាមកម្មណាដែលឲ្យ ផល នៅពេលបដិសន្ធិ ។ ហើយ មតិទី៣ នេះ ក៏មិនដូចមតិទី២ ដែលថាស្លាប់ ហើយ មិនកើតទៀតទេ គឺសូន្យ ។ ពីព្រោះតាមព្រះពុទ្ធសាសនា ស្លាប់ហើយ មិនកើតទៀត លុះត្រាតែជាព្រះអរហន្ត ។ ទុកជាយើងយល់ថាមិនកើតទៀតក៏ដោយ ក៏នៅតែកើតជាថ្មីម្តងទៀតដែរ បើយើងជឿទៅលើច្បាប់ហេតុបច្ច័យ ឬ កម្មផល តែចិត្តនៅមានកិលេស គឺចិត្តមិនទាន់បរិសុទ្ធ នោះយើងនៅមាន លោភៈ ទោសៈ មោហៈ នៅឡើយ ដូច្នេះកម្មដែលយើងធ្វើ នៅជាកម្មស ឬ ជាកម្មខ្មៅនៅឡើយ ពុំទាន់ បាន ជាកម្មមិនស មិនខ្មៅនៅឡើយទេ ដូច្នេះត្រូវតែកើតទៀត ចង់ ឬមិនចង់ក៏ដោយ ។ ហើយឋានដែលនឹងទៅកើតទៀត ក៏មិនទៅតាមចំណង់យើងដែរ ។

*តើគួរខ្លាចពេលមុនដាច់ខ្យល់ស្លាប់ទេ ?*

តាមធម្មតា អ្វីដែលយើងមិនដែលស្គាល់ យើងខ្លាច ដូចជាពេលមុនស្លាប់ជាដើម ។ ខ្ញុំធ្លាប់ឮគេនិយាយថា មានជនជាតិខ្មែរអ៊ីស្លាមម្នាក់ របររកទទួលទានគឺ កាប់គោ ។ ដល់ពេលគាត់ជិតដាច់ខ្យល់ គេឮគាត់ស្រែកដូចសម្លេងគោ ។ ខ្ញុំក៏ធ្លាប់មានសំណួរអំពីរឿងស្លាប់នេះដែរ ។ សំណួរខ្ញុំគឺ « ដោយយើងម្នាក់ៗ សុទ្ធតែបានធ្វើបុណ្យផង ហើយក៏បានធ្វើបាបខ្លះដែរ ចុះបើមុននឹងដាច់ខ្យល់ ចិត្តយើងមានអារម្មណ៍ទៅលើអំពើអកុសលណាមួយដែលបានធ្វើ តើយើងទៅកើតនៅឯណា ? » ។

ចម្លើយគឺ តាមធម៌អភិធម្ម គឺចិត្តចុងក្រោយនេះ ដែលផ្តល់ឲ្យចិត្តបដិសន្ធិ បន្តភពថ្មីតទៅទៀត បើចិត្តចុងក្រោយសោយអារម្មណ៍អកុសល នោះយើងទៅកើតនៅអបាយភូមិភ្លាម តែបើចិត្តចុងក្រោយ (ចុតិចិត្ត) សោយអារម្មណ៍កុសល នោះយើងកើតនៅ ឋានមនុស្ស ឬ ឋានទេវតា ។

ដូច្នេះចិត្តចុងក្រោយនេះសំខាន់ណាស់ ។ ពីព្រោះមនុស្សម្នាក់ៗថាឲ្យអស់បាបនោះ មិនងាយអស់ទេ យើងមើលអង្គុលីមាល បើកុំតែសម្រេចនិព្វានទាន់ នោះមិនដឹងជាអំពើអកុសល ចេញមកឲ្យផលនៅជាតិណាខ្លះទៀតទេ។ តែដល់អង្គុលីមាល បានសម្រេចព្រះនិព្វានហើយ នោះអកុសលកម្មទាំងនោះ ក៏គ្មានឱកាសនឹងឲ្យផលតទៅទៀត។ ដើម្បីមនុស្ស ជិតស្លាប់មានអារម្មណ៍ តែជាកុសល កូនចៅរបស់អ្នកជិតស្លាប់នោះ បានយកព្រះបដ មកដាក់តាមជញ្ជាំង និងតាំងនៅតាមពិតានផ្ទះ ហើយគេចាក់ស៊ីឌីធម៌ជូនគាត់ស្តាប់ ដែលជាជំនួយឲ្យគាត់ នឹកតែទៅអំពើល្អ ដែលគាត់ធ្លាប់បានធ្វើ ។ ចំពោះយើង បើខ្លាចអំពើអាក្រក់វាមកលង ដូចខ្មោច ត្រូវខំធ្វើអំពើល្អរាល់ៗថ្ងៃ កុំចាំជិតស្លាប់បាននឹកធ្វើ ។

*សង្ខេប*

ខ្ញុំយល់ថា ក្នុងមតិទាំង៣ មតិទី៣ មានប្រយោជន៍ជាង មតិទី២ និង មតិទី១ ទុកជាយើងមានជំនឿយ៉ាងណាក៏ដោយ។ ពីព្រោះអ្វី?

ពីព្រោះ មតិទី១ ធ្វើឲ្យមនុស្ស ខ្ជិល អស់សង្ឃឹមលើអនាគត មិនខំប្រឹងប្រែងធ្វើការងារ ពីព្រោះថា បើខំ ក៏នៅតែប៉ុណ្ណឹង មិនខំក៏នៅតែប៉ុណ្ណឹង ។ ដូច្នេះ ខំរៀនសូត្រ ឬបដិបត្តិធម៌ ធ្វើអំពើល្អ បានប្រយោជន៍អ្វី ។

ចំពោះ មតិទី២ ដោយថាស្លាប់ទៅសូន្យ ឥតមាននរក ឥតមានឋានសួគ៌ ដូច្នេះ សប្បាយ ឲ្យអស់ដៃទៅ ទាន់ខ្លួននៅរស់ ។ ចុះប្រសិនបើជាមាននរកវិញ អ្នកដែលមានមតិយ៉ាងនេះ មិនខាតធំទៅហើយ ។ ពីព្រោះថា ការពិតយ៉ាងណា វានៅតែយ៉ាងនោះ ដូច្នេះហើយបានជាខ្ញុំថា បើយើងអាចយល់ខុសដែរ នោះខ្ញុំយល់ថា ជ្រើសយក មតិទី៣ នាំឲ្យយើងមានអនាគតប្រសើរជាងយើងជ្រើសយក មតិទី១ ឬ មតិទី២ ។ ពីព្រោះមតិទី៣ នាំឲ្យយើងរស់នៅបានសេចក្ដីសុខសប្បាយទាំងក្នុងបច្ចុប្បន្ន ទាំងទៅអនាគត ដោយយើងប្រព្រឹត្តតែអំពើល្អ ចំពោះខ្លួនយើង និង ចំពោះអ្នកដទៃ ។

ព្រឹត្តិការណ៍ « ក្មេងរលឹកជាតិ » ជាកស្តុតាងមួយដែរ ចំពោះជំនឿថាស្លាប់ហើយកើតទៀត ហើយ ព្រឹត្តិការណ៍នោះ អាចពន្យល់តាមធម៌អភិធម្ម (ជាធម៌ព្រះពុទ្ធ)បាន ពីព្រោះក្នុង ធម៌អភិធម្ម <u>ចិត្ត កើតឡើង និង រលត់ទៅវិញ ជាងមួយកោដិដង បន្តបន្ទាប់គ្នាពល់**វិនាទី**</u> ដូច្នេះនៅពេលស្លាប់ បន្ទាប់ពី**ចុតិចិត្ត រលត់**ទៅភ្លាម នៅក្នុងបច្ចុប្បន្នភព **បដិសន្ធិចិត្ត ក៏កើត** ឡើងភ្លាមនៅក្នុងភពបន្ទាប់ (អនាគតភព) <u>ដោយគ្មានចន្លោះពេល</u> រវាង វិថីចិត្តក្នុងបច្ចុប្បន្នភព និង វិថីចិត្តនៃជីវិតបន្ទាប់ ។ ដូច្នេះ អ្វីៗដែលយើងបានរៀនសូត្រ ឬ បានពិសោធទាំងប៉ុន្មានក្នុងជីវិតនេះ ត្រូវបានកើតបន្តនៅវិថីចិត្តនៃជីវិតបន្ទាប់ ដែលជាហេតុ នាំឲ្យមានក្មេងជាច្រើននៅលើសកលលោក អាចចាំនូវអតីតជាតិរបស់ពួកគេបានយ៉ាងត្រឹមត្រូវ ហើយបានជាមានក្មេងមាន

*ទេពកោសល្យអាចចាំ និងសូត្រនូវអ្វីៗដែលពួកគេបានរៀនសូត្រក្នុងអតីតជាតិយ៉ាង អស្ចារ្យ ។ មកដល់ត្រង់នេះយើងឃើញថា ព្រលឹង និង វិថីចិត្ត ហាក់បីដូចជាមិនខុសគ្នា ។ តែបើយើងពិនិត្យ យើងឃើញខុសគ្នាត្រង់ ព្រលឹង គឺ រស់ជានិច្ច តែ វិថីចិត្ត គឺ កើតរលត់- រលត់កើត បន្តគ្នាមិនដែលដាច់សោះឡើយ ។*

*ជាចុងក្រោយ បើយើងជឿនូវការត្រាស់ដឹងនៃព្រះពុទ្ធ នៅក្នុងគម្ពីរព្រះសូត្រមានរឿង និទានជាច្រើន ស្តីពីព្រះពុទ្ធកាលដែលនៅជាព្រះពោធិសត្វនៅឡើយ ។ ព្រះអង្គបានចាប់ កំណើត ជា មនុស្ស ជាទេវតា ជាសត្វតិរច្ឆានក៏មាន។ ទាំងនេះសរឲ្យឃើញថាស្លាប់ ហើយកើតទៀត។ បើលោកអ្នកខ្លះថា រឿងទាំងនោះសុទ្ធតែប្រឌិត នោះស្រេចតែទៅ លើការយល់រៀងៗខ្លួនចុះ ។*

# ១៣

## ការបកស្រាយ ធម៌ព្រះពុទ្ធ ខុសរបៀប ខុសពេលវេលា

*ត ទៅនេះជា យោបល់ផ្ទាល់របស់ខ្ញុំ បើលោកអ្នកមិនយល់ដូចខ្ញុំ សូមកុំទៅរករឿង គ្រូរបស់ខ្ញុំ ណាមួយលោកក៏ចាស់ទៀតផង។ ថ្វីបើព្រះអង្គគ្រូខ្ញុំ លោកជួយពិនិត្យក៏ដោយ លោកពិនិត្យតែធម៌ព្រះពុទ្ធ ចំពោះការយល់របស់ខ្ញុំ គឺ ខ្ញុំជាអ្នកទទួលខុសត្រូវ ។*

**13-1** *ដោយមានពាក្យ* ***អនត្តា*** *ក្នុងធម៌ព្រះ ក៏បកស្រាយថា មិនមែនយើង មិនមែនខ្លួនយើង មិនមែនរបស់យើង*

*តាមខ្ញុំយល់ អនត្តា គឺចង់សំដៅថា អ្វីៗក្នុងលោកនេះសុទ្ធតែមិនទៀង ខ្លួនយើងក៏មិនទៀង ខ្លួនកូនយើងក៏មិនទៀង ដូច្នេះ ដើម្បីកុំឲ្យកើតទុក្ខ នៅពេលណាដែលរបស់នោះបាត់ទៅវិញ យើងកុំជាប់ជំពាក់នឹងរបស់ទាំងនោះ ។ ដូច្នេះ* **ធម៌ដែលប្រតិបត្តិ ចំពោះ អនត្តា គឺ មិនត្រូវមានចិត្តជាប់ជំពាក់**។ *មិនមែន គ្រាន់តែនិយាយថា ឥតមានខ្លួន ឥតមានយើង នោះក៏អស់ទុក្ខនោះទេ ។ ក្នុងការប្រាស្រ័យទាក់ទងគ្នាត្រូវតែនិយាយ ថាខ្ញុំ ថាគេ ថាលោក ទើបស្របនឹង អ្វីៗដែលភ្នែកយើងឃើញ ។ យើងថាឥតមានគេដូចម្តេចកើត បើភ្នែកខ្ញុំមើលទៅឃើញរូបគេនៅនឹងមុខខ្ញុំ មានតែខ្វះភ្នែកខ្ញុំចោល ។ បើធ្វើយ៉ាងនេះខុសពីច្បាប់ធម្មជាតិ ដែលមនុស្សតែងតែមានភ្នែក ។ ដោយធម៌ព្រះស្របតាមច្បាប់ធម្មជាតិ ការបកស្រាយណាមិនស្របនឹងច្បាប់ធម្មជាតិ ជាការបកស្រាយធម៌ព្រះមិនត្រឹមត្រូវ ។ ត្រូវ ពន្យល់ថា យើងគ្រប់រូប ទាំងខ្ញុំ ទាំងលោកអ្នក បើមិនចង់មានទុក្ខ ត្រូវអប់រំចិត្ត* ***កុំឲ្យជាប់ជំពាក់នឹង ខ្លួនយើង នឹងកូនប្រពន្ធយើង*** *នឹងអ្វីៗទាំងអស់ក្នុងលោកនេះ ពីព្រោះទាំងយើង ទាំងគេ សុទ្ធតែមិនទៀង ។*

ក្នុងការប្រាស្រ័យទាក់ទង ត្រូវតែប្រើពាក្យសន្មត ពីព្រោះថាទុកជាយើងជុំនួស ពាក្យ « យើង ខ្ញុំ គេ ឯង » ដោយពាក្យបរមត្ថ « ខន្ធ៥ » ក៏ដោយ ក៏នៅសល់ពាក្យសន្មតដូចជា « ឡាន ឬ រថយន្ត » តើយើងរកពាក្យបរមត្ថ មកជុំនួសបានទេ? ពីព្រោះពាក្យថា « ឡាន » ក៏ជាពាក្យសន្មតដែរ ដោយយើងពុំអាចចង្អុលប្រាប់គេបានថា **តើកន្លែងណាទៅដែលហៅថាឡាននោះ?** បើយើងមើលទៅឃើញតែ កង់ ដែចង្កូត ឬ ទ្វារឡាន ជាដើម តែប៉ុណ្ណោះ។

ពាក្យថាឡាននេះ ជាពាក្យអរូបី សំដៅ **សំនុំ** មួយដែលនៅក្នុងនោះមានធាតុ ជាច្រើន ដូចជា កង់ ដែចង្កូត ទ្វារ ចង្កៀង ជាដើម ។ ដូច្នេះពាក្យថា **ឡាន** នេះ គឺទទេស្អាត ដូចជាពាក្យថា **ខ្ញុំ** ឬ **គេ ឯង** ជាដើមដែរ ។

ដោយធម៌ អនត្តា ដដែលនេះ ក៏បកស្រាយថាអត់មាន អ្នកគិតទេ មានតែគំនិត ក៏ដូចអត់មានអ្នកធ្វើទេ មានតែអំពើ អត់មានអ្នកទទួលផលនៃអំពើទេ មានតែ អំពើ និង ផលនៃអំពើ ដែលកើតតៗគ្នា ទៅតាមច្បាប់ « **ហេតុ-ផល**» ក៏ដូច គ្រាប់ពូជ និង ដើមឈើ ដែលផ្លាស់ប្តូរគ្នាម្តងម្នាក់ ។

ទាំងនេះជាពាក្យដែល លោកគ្រូជំនាន់ដើម បានបកស្រាយរហូតមកដល់ពេលនេះ។ ខ្ញុំសូមយកតែឃ្លាចុងក្រោយមកអធិប្បាយ គឺឃ្លា គ្រាប់ពូជ និង ដើមឈើ ដែលផ្លាស់ប្តូរគ្នាម្តងម្នាក់ បានន័យថា៖

គ្រាប់ពូជ ជាហេតុឲ្យដុះ ដើមឈើ យើងសរសេរ ៖ គ្រាប់ពូជ => ដើមឈើ ។ ហើយដោយប្តូរគ្នាម្តងម្នាក់គឺ ដើមឈើ ឲ្យគ្រាប់បានជា ពូជ យើងសរសេរ ៖ ដើមឈើ => គ្រាប់ពូជ ។ ដូច្នេះ ៖ គ្រាប់ពូជ => ដើមឈើ => គ្រាប់ពូជ => …… ។ សំណួររបស់ខ្ញុំគឺ បើមនុស្ស មិនយកគ្រាប់ទៅបណ្តុះ តើដើមឈើដុះឬទេ?ដូចជា ពូជស្រូវ បើនៅតែក្នុងជង្រុក តើចេញជាសំណាប បានជាដើមស្រូវទេ? នេះសរឲ្យ

ឃើញថា គ្រាប់ពូជ គ្រាន់តែជាហេតុមួយ ក្នុងចំណោមហេតុដទៃ ដែលនាំឲ្យមាន ដើមស្រូវ ហើយហេតុដទៃនោះគឺ មនុស្សដែលយកពូជស្រូវទៅត្រាំទឹក ។

13-2 ដោយមានពាក្យ **លោភ** ក្នុងធម៌ព្រះ ក៏ពន្យល់ថា កុំឲ្យលោភលន់ ។

ដល់បកស្រាយឲ្យល្អិតពេកទៅ ក៏ដល់ថ្នាក់ថា ការធ្វើបុណ្យកុសលក៏ជាការលោភលន់ដែរ ពីព្រោះមានចេតនាចង់បាននេះ ចង់បាននោះ ដូចជាចង់បាន ទៅកើតឋានសួគ៌ ឬ ក៏សម្រេចនិព្វានជាដើម ។ តាមធម្មតា (ធម្មជាតិ) មនុស្សតែងតែចង់បានរបស់ដែលពេញចិត្ត នឹងស្អប់របស់ដែលមិនពេញចិត្ត ។ ហើយមនុស្សមានកម្លាំងពុះពារឧបសគ្គគ្រប់បែបយ៉ាង កាលណាមានចិត្តចង់បាន ដូចជាចង់ជាប់សញ្ញាប័ត្រក៏ខំរៀនទាំងយប់ទាំងថ្ងៃ ។ ប្រសិនបើជាគ្មានចេតនាចង់ទៅ កើតឋានសួគ៌ទេ មនុស្សធ្វើម្តេចនឹងចង់ធ្វើបុណ្យធ្វើកុសល ធ្វើចង្ហាន់យកទៅប្រគេនព្រះសង្ឃ។ គ្រោះថ្នាក់នៃលោភ គឺ មកពី លោភ ជាហេតុនៃ ទុក្ខ ហើយ លោភ ជាហេតុឲ្យកើតតណ្ហា ហើយតណ្ហា ជាហេតុឲ្យកើត **ការជាប់ជំពាក់ (ឧបាទាន)**។ ដូច្នេះ ធម៌ដែលត្រូវភ័យខ្លាចជាងគេ គឺ **ឧបាទាន** ។ នៅក្នុងធម៌បដិច្ចសមុប្បាទ តែហួស ឧបាទានហើយនោះវិខ្ចនលែងរួចហើយ ពីព្រោះត្រូវតែ <u>កើតស្លាប់-ស្លាប់កើត</u> តទៅទៀត វិលដូចកង់រទេះរកចប់មិនឃើញទេ។

ចំពោះលោកអ្នកដែលពុំទាន់ស្គាល់ធម៌បដិច្ចសមុប្បាទ ខ្ញុំសូមអធិប្បាយដោយត្រួសៗដូចតទៅនេះ ។ បដិច្ចសមុប្បាទ ជាធម៌ដែលព្រះសង្ឃសូត្រនៅពេលធ្វើបុណ្យម្តងៗ ជាធម៌បង្ហាញ នូវ ហេតុនិងផល ដែលមានជាបន្តៗគ្នា ដោយ [ហេតុ => ផល ] ហើយផលនោះក៏ទៅជាហេតុដែលឲ្យផលបន្តទៅទៀត ទាំងអស់មាន ១២ អង្គ ដែលឲ្យ [ហេតុ-ផល ]ៗ របៀបនេះ គឺ ថា ៖ (**តារាង-1**)

| |
|---|
| អវិជ្ជា (1) => សង្ខារ (2) => វិញ្ញាណ (3) => នាមរូប (4) => សឡាយតនៈ(5) => ផស្សៈ (6) => **វេទនា (7)** => តណ្ហា (8) => **ឧបាទាន (9)** => **ភព** (10) => ជាតិ (11) => ជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ (12) ។ |

ក្នុង តារាង-1 ខាងលើនេះ គប្បីមើលថា អវិជ្ជា ជាហេតុ[23] សង្ខារ ជាផល ។ បន្ទាប់មក សង្ខារ ជាហេតុ ហើយ វិញ្ញាណ ជាផល ។ បន្ទាប់មក វិញ្ញាណ ជាហេតុ ហើយ នាមរូប ជាផល ។ ចេះតែ តៗគ្នា រហូតដល់ ជាតិ ជាហេតុ ហើយ ជរាមរណៈ សោកៈ ...ជាផល ។ ក្នុង តារាង-1 នេះដដែល ទុក្ខ (12) ជាផលនៃ ជាតិ(11) គឺការកើត ។ បានន័យថា កាលណាមាន ការកើត មាន ទុក្ខហើយ ។ នេះតាមធម៌ បដិច្ចសមុប្បាទ។ ដូច្នេះដើម្បីកុំឲ្យមាន ទុក្ខ ទាល់តែ កុំមានកំណើត ។ បើនិយាយពី ច្បាប់ ហេតុផល គឺ ហេតុ ឲ្យ ផល ហើយ ដើម្បី ផលរលត់ (រលត់ទុក្ខ) ទាល់តែ ហេតុរលត់ (រលត់ការកើត) ។

| | |
|---|---|
| ហេតុ => ផល (1) | **(តារាង-2)** |
| ហេតុ រលត់ => ផល រលត់ (2) | |

ដោយយើងរាល់រូប សុទ្ធតែមិនចង់ជួបទុក្ខ ដូច្នេះ ដើម្បីកុំឲ្យមានទុក្ខ យើងត្រូវរំលត់ហេតុរបស់វា ។ ហេតុ មានហេតុជិត និង ហេតុឆ្ងាយ ។ តាមធម្មតាហេតុជិត ស្រួលរកជាងហេតុឆ្ងាយ ពីព្រោះហេតុជិតយើងអាចមើលឃើញភ្លាមៗ តែហេតុឆ្ងាយដែលជាឫសគល់ នៃផលខាងចុងនោះ ពិបាកនឹងរកខ្លាំងណាស់ ។ តែចំពោះយើង ដោយសារធម៌បដិច្ចសមុប្បាទរបស់ព្រះពុទ្ធ នោះហេតុជិតនិងហេតុឆ្ងាយ យើងមានទាំងអស់។ ផលខាងចុងគឺ ជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ (12) ហើយ

[23] ខ្ញុំ ដាក់ថា ហេតុ នេះ ជាការបកស្រាយរបស់ខ្ញុំដើម្បី ស្រួលយល់ខ្លះៗនោះទេ តែមិនអស់សេចក្តី ដូចធម៌ព្រះពុទ្ធទេ ។ ព្រះពុទ្ធទ្រង់ថែងថា ៖ **អវិជ្ជា បច្ចយា សង្ខារា** បកមកជាខ្មែរថា « ព្រោះមានអវិជ្ជា ជាបច្ច័យ ទើបមាន សង្ខារ » ។ ហើយដល់ខ្ញុំបកស្រាយ ខ្ញុំជំនួសពាក្យ ជាបច្ច័យ ដោយពាក្យ **ហេតុ** ហើយពាក្យ ទើបមាន ដោយពាក្យ **ផល** ។ តែពាក្យ ហេតុ នេះគ្រាន់តែន័យមួយ នៅក្នុងពាក្យ បច្ច័យ ។ ពីព្រោះបច្ច័យទាំងអស់ មាន២៤ ហើយហេតុនៅក្នុងពួក២៤នោះ ។

ហេតុឆ្ងាយបំផុត គឺ អវិជ្ជា (1) (មើល (**តារាង-1**)) ។

ដោយ (**តារាង-2**) ដើម្បី (12)[24] រលត់ ត្រូវ (1)[25] រលត់ ។ ពីព្រោះថាបើ (1) រលត់ នោះ(2) ក៏រលត់ ហើយ (2)រលត់ (3)ក៏រលត់ ដូច្នេះ ចេះតែរលត់តៗគ្នា រហូតដល់លេខ 12 ។ តែដោយគោរពច្បាប់ធម្មជាតិ មានហេតុខ្លះយើងមិនអាចធ្វើឲ្យរលត់បានដោយស្របនិងច្បាប់ធម្មជាតិនោះទេ ។ ឧបមា ដូចវេទនា(7) ជាដើម ដែលកើតកាលណាភ្នែកឃើញរូប ឬ ត្រចៀកឮសំឡេង ដូច្នេះដើម្បីឲ្យវេទនារលត់ ទាល់តែភ្នែកកុំឃើញរូប ឬ ត្រចៀកកុំឮ ។ តែមនុស្សតែងតែមានភ្នែកសម្រាប់មើល មានត្រចៀកសម្រាប់ឮ ហេតុនេះ

<u>តើត្រូវរករបៀបយ៉ាងណាដើម្បីរំលត់ វេទនានេះ ?</u>

ចម្លើយគឺនៅក្នុងច្បាប់ ហេតុ-ផល ដដែល ។ ដើម្បីឲ្យ វេទនា រលត់ ទាល់តែហេតុដែលនាំឲ្យកើតវេទនា នោះរលត់ ឬមួយ ហេតុទាំងឡាយដែលកើតមុនហេតុនោះ រលត់ជាមុនសិន ។ តាមធម៌ បដិច្ចសមុប្បាទ ហេតុមុនគេគឺ អវិជ្ជា (ហេតុទី១) ហើយហេតុក្រោយគេមុនដល់វេទនា គឺ ផស្ស: (ហេតុទី៦) នេះតាម (**តារាង-1**) ។ តាមតារាងនេះដែរ បើមាន « នាមរូប » ត្រូវតែមាន «វេទនា » ។ តែដើម្បី កុំឲ្យមាន នាមរូប ត្រូវកុំកើត ហើយដើម្បី កុំកើត ទាល់តែសម្រេច ព្រះនិព្វាន ដោយ រំលត់ អវិជ្ជា ។ ដោយព្រះនិព្វាននៅឆ្ងាយណាស់មិនងាយនឹងទៅដល់ទេ ពីព្រោះត្រូវការកសាងរាប់សែនកប្ប ដូច្នេះត្រូវរកហេតុផ្សេងទៀត ដែលយើងអាចរំលត់បានដោយងាយជាង។ នៅក្នុង (**តារាង-1**) ដដែលនេះមានហេតុ តណ្ហា (8) និង ឧបាទាន (9) ដែលយើងអាចបន្ថយ កម្លាំងវា បណ្ដើរៗ ចាប់ពីជាតិនេះទៅ រហូតដល់បានសម្រេចព្រះនិព្វាន ជាទីអវសាន ។

---

[24] (12) គឺ លេខរៀងទី 12 ក្នុងតារាង-1 គឺ ជំនួសពាក្យ ជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ

[25] (1) គឺ លេខរៀងទី 1 ក្នុងតារាង-1 គឺ ជំនួសពាក្យ អវិជ្ជា ។ តទៅនេះខ្ញុំអាចប្រើ លេខ ជំនួសពាក្យក៏មាន ប្រសិនបើជាមិននាំឲ្យមានការច្រឡំ ។

ខ្ញុំសូមជូនអត្ថន័យរបស់អង្គ តណ្ហា ឧបាទាន និង ភព[26] តាមគម្ពីរ ៖

<u>ម្នាល ភិក្ខុទាំងឡាយ ចុះតណ្ហា(8) តើដូចម្ដេច</u> ?

ម្នាលភិក្ខុទាំងឡាយ ពួកតណ្ហានេះមាន ៦ គឺ រូបតណ្ហា១ សទ្ទតណ្ហា១ (សំឡេង) គន្ធតណ្ហា១ (ក្លិន) រសតណ្ហា១ (រសជាតិ) ផោដ្ឋព្វតណ្ហា១ (ការប៉ះកាយទៅនឹង របស់ខាងក្រៅខ្លួន) ធម្មតណ្ហា១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា តណ្ហា ។

<u>ម្នាល ភិក្ខុទាំងឡាយ ចុះឧបាទាន (9) តើដូចម្ដេច</u> ?

ម្នាលភិក្ខុទាំងឡាយ ឧបាទាននេះ មាន ៤ គឺ កាមុបាទាន១ (ជាប់និងកាម) ទិដ្ឋុបាទាន១ (ប្រកាន់មាំការយល់ខុះ) សីលព្វត្តុបាទាន១ (ប្រកាន់មាំលើពិធី) អត្តវាទុបាទាន១ (ប្រកាន់ថាមានអត្តា) ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧបាទាន ។

---

[26] ដើម្បី យល់ភព និងយល់ធម៌ បដិច្ចសមុប្បាទ ឲ្យបានជ្រៅបន្ដិច ខ្ញុំសូមដកស្រង់ អត្ថបទខ្លះនៅក្នុងសៀវភៅបដិច្ចសមុប្បាទ ដោយ ភិក្ខុ ងិន គេន [សៀវភៅយោង លេខ 4 ] ដែលមានដូចតទៅនេះ ៖ « សភាវធម៌ ដែលជាហេតុជាផល អាស្រ័យគ្នាកើតឡើងដូចច្រវាក់ជាប់គ្នាជារង្វង់មូល វិលទៅក្នុងវដ្ដសង្សារមិនមានទីបំផុត ប្រព្រឹត្តទៅតាមហេតុបច្ច័យ ប្រាសចាកសត្វបុគ្គល (អនត្តា) ដោយមិនមាននរណាជាអ្នកសាង នេះហៅថា **បដិច្ចសមុប្បាទ** »។ ក្នុង ១២អង្គនោះ មានចែកជា ៤ ក្រុម ដូចតទៅ ៖

1- អតីតហេតុ : អវិជ្ជា សង្ខារ

2- បច្ចុប្បន្នផល : វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា

3- បច្ចុប្បន្នហេតុ : តណ្ហា ឧបាទាន ភព

4- អនាគតផល : ជាតិ ជរា មរណៈ (សោក ។ល។ ) ។

<u>សង្កេត</u> ដោយបដិច្ចសមុប្បាទ ជាធម៌វិលក្នុងវដ្ដសង្សារ នៃសត្វលោក ហេតុដែលនាំវិលនេះ មាន អតីតហេតុ (មាន២) និង បច្ចុប្បន្នហេតុ (មាន៣) ។ អតីតហេតុ និង បច្ចុប្បន្នហេតុ ឲ្យផលជា អនាគតផល ។ [ **អតីតហេតុ និង បច្ចុប្បន្នហេតុ** ] => [ **អនាគតផល** ]

ដូច្នេះត្រូវ តែហេតុណាមួយរលត់ ទើបផលរលត់ គឺ ទើបចេញពីវដ្ដសង្សារនេះរួច ។

ម្នាល ភិក្ខុទាំងឡាយ ចុះភព (10) តើដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ ភពនេះ មាន ៣ គឺ កាមភព១ (ភពមានកាម គឺ អបាយភូមិ៤ មនុស្សភូមិ១ និង ទេវភូមិ៦) រូបភព១ (ភូមិព្រហ្មមានរូប១៦) អរូបភព ១ (ភូមិព្រហ្មឥតមានរូប៤) ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភព ។

ខ្ញុំរំលឹកធម៌ បដិច្ចសមុប្បាទ តែប៉ុណ្ណេះ សូមអញ្ជើញមើលសៀវភៅ បន្ថែមទៀតចុះ ពីព្រោះធម៌ បដិច្ចសមុប្បាទនេះ ព្រះមានព្រះភាគ ទ្រង់មនសិការ (ពិចារណា) ជាអនុលោម (នាំឲ្យកើត) ជាបដិលោម (នាំឲ្យរលត់) មិនមែនតែអស់បឋមយាមនៃរាត្រីប៉ុណ្ណោះទេ អស់មជ្ឈិមយាមនៃរាត្រីផង អស់បច្ឆិមយាមនៃរាត្រីផង គឺ អស់រាត្រីទាំងមូលតែម្តង [27]។ ព្រោះអ្វី? ព្រោះធម៌ដែលព្រះអង្គបានត្រាស់ដឹងហើយ ជាធម៌ជ្រាលជ្រៅ (គម្ភីរោ) ជាធម៌ឃើញដោយកម្រ (ទុទ្ទសោ) ជាធម៌ដឹងតាមបានដោយកម្រ (ទុរនុពោធោ) ជាធម៌ស្ងប់ (សន្តោ) ជាធម៌ប្រណីត (បណីតោ) ជាធម៌ល្អិត (និបុណោ) ជាធម៌ ជាវិស័យដែលបណ្ឌិតគប្បីដឹង (បណ្ឌិតវេទនិយោ)។

ដូច្នេះ ក្នុងការពន្យល់ **ធម៌លោក** កុំចាំបាច់ហាមថា កុំឲ្យមានលោភ ពីព្រោះនាំឲ្យគេយល់ច្រឡំ គេទៅជាខ្ជិលស៊ីដេកៗ ឲ្យម៉ែឪចិញ្ចឹម ធ្វើយដាក់ថាមកពីធម៌ព្រះពុទ្ធថាកុំលោភ ។ ត្រូវនិយាយថា ព្រះលោកឲ្យយើងខំធ្វើការងារដោយសម្មាអាជីវៈ ដើម្បីមានទ្រព្យសម្បត្តិ ។ ត្រូវចេះសន្សំទ្រព្យទុកដាក់សម្រាប់ថ្ងៃមុខ ពីព្រោះអ្វីៗក្នុងលោកនេះសុទ្ធតែមិនទៀង ជីវិតក៏មិនទៀង ទ្រព្យសម្បត្តិក៏មិនទៀង ថ្ងៃនេះរកបាន ថ្ងៃស្អែកអាចរកមិនបាន យើងមានលុយកាក់ត្រូវចេះសន្សំទុកគ្រាន់ដោះទ័លពេលមានអាសន្ន ។ ម្យ៉ាងទៀតយើងកុំជាប់ជំពាក់នឹងទ្រព្យសម្បត្តិនេះពេក ដើម្បីកុំឲ្យយើង

---

[27] **បដិច្ចសមុប្បាទ និង ឥទប្បច្ចយតា** រៀបរៀងដោយ ភិក្ខុ ជិន គេន វត្តពោធិវង្ស ប្រទេសបារាំង។

*ខកចិត្ត កាលណាវារត់ចោលយើង មកពីធម៌មិនទៀងនេះ ។ ត្រូវរំលែកទ្រព្យខ្លះយកទៅ ធ្វើបុណ្យ ជួយអ្នកដទៃ ដើម្បីសន្សំកុសលទៅជាតិមុខ ដូចជាធ្វើបុណ្យដាក់ទានជាដើម ។ ធ្វើយ៉ាងនេះអ្នកនឹងបានសេចក្ដីសុខក្នុងជាតិនេះផងនិងទៅជាតិខាងមុខផង។ ខ្ញុំយល់ ថា លោភ ឬ មិនលោភ នៅលើចិត្ត យើងគប្បីអប់រំចិត្តកុំឲ្យជាប់ជំពាក់នឹង អ្វីៗទាំងអស់ សូម្បីតែឋានសួគ៌ ដែលអាចទៅកើតបានដោយ កុសល ក៏កុំជាប់ជំពាក់ដែរ ពីព្រោះយើង អាចធ្លាក់ពីឋានទេវតា ទៅកើតអបាយភូមិក៏បានដែរ ។*

*ខ្ញុំ មិនខ្វាចនិយាយថា ខ្ញុំមាន អត្តា ឬ មាន លោភ ទេ បើខ្ញុំស្គាល់ អត្តា ឬ លោភ ច្បាស់ហើយ ដូចជាអ្នកដែលស្គាល់ ពស់ច្បាស់ហើយ គេមិនខ្វាចកាន់ក្បាលពស់ទេ ។ ដូចអ្នកខ្លះ ខឹងនឹងរដ្ឋាភិបាល អនុញ្ញាតឲ្យបើកកន្លែងលេងល្បែង កាស៊ីណូ* (casino) *។ តាមខ្ញុំយល់ បើយើងមិនចូលចិត្ត កាស៊ីណូ យើងកុំទៅជិតវាទៅ ។ កាស៊ីណូវាមានមក ចាប់ដៃយើង ឬ បង្ខំយើងឲ្យចូលទៅរកវាឯណា ។ យើងទេដែលថា ស្អប់វា តែទៅជាប់ជំ ពាក់ចិត្តនឹងវា នេះដូចយើងស្រែកថា « ខ្ញុំស្អប់ឯងណាស់ » តែនៅតែទៅអោបរបស់ ដែលស្អប់នោះ ឲ្យស្អិតមើលតែស្ករតាំងម៉ែ*[28]*។ បើត្រឡប់មក* **អនត្តា** *វិញ យើងមិន ហ៊ាននិយាយថាមាន អត្តាទេ តែត្រូវនិយាយថាមានតែខន្ធ៥ ដើម្បីឲ្យត្រូវតាមធម៌ព្រះ ។ តែតាមការពិតទុកជាថា « មានតែខន្ធ៥ » ក៏ដោយ បើចិត្តនៅតែជាប់ជំពាក់នឹងខន្ធ៥ អោបខន្ធ៥ ឲ្យស្អិត មិនព្រមស្រាយចំណង ដែលយើងចងដោយខ្លួនឯងចេញនោះទេ ទុក្ខនៅតែមានតទៅទៀតដដែល ។ សំខាន់នៅលើយើង តើយើងចង់ស្រាយចំណង ដែលយើងចងជាប់នឹងខន្ធ៥ ឬ ចងជាប់នឹងលោភនោះទេ ? ពីព្រោះសព្វថ្ងៃនេះយើង នៅស្រឡាញ់ ខន្ធ៥ ឬ លោភនៅឡើយ ។* ***ស្រឡាញ់ដោយរបៀបណា ?***

---

[28] *ខ្ញុំនិយាយនេះ មិនមែនខ្ញុំមានចិត្តលំអៀងទៅខាងរដ្ឋាភិបាលទេ តែខ្ញុំចង់ឲ្យលោកអ្នកដែលប្រព្រឹត្ត ល្បែងស៊ីសងពិចារណាទៅលើរឿងនេះផង ដើម្បីសេចក្ដីសុខសប្បាយរួចចាកទុក្ខរបស់យើង ។*

ដូចជា ស្រឡាញ់ អំណាច បុណ្យសក្តិ ចង់ឲ្យគេសរសើរគោរពបូជា (ដូចស្តេចដំនាន់ដើម ហ៊ានធ្វើអ្វីឲ្យប្រសើរជាងព្រះចេស្តា អ្នកឯងនឹងត្រូវវិនាសមិនខាន) ចង់មានមាសពេជ្រមកពាក់បង្អួតគេ ឲ្យគេសរសើរ ។ល។ ចាស់ហើយ ចង់កែកុន មុខមាត់លាបសក់ ឲ្យគេឃើញថានៅក្មេង ។ រួមសេចក្តីទៅ ការអប់រំចិត្តសំខាន់ ជាងការប្រើពាក្យបរមត្ថ ឬ ពាក្យសន្មត ឬ ការយល់ដោយបញ្ញា។ តាមការពិសោធន៍របស់ខ្ញុំ ការអប់រំចិត្ត គឺការបដិបត្តិ[29] តាមពាក្យទូន្មានរបស់ព្រះពុទ្ធ។

13-3 ដោយមានពាក្យ ចិត្ត កើតខ្លួនវា រលត់ខ្លួនវា ដូច្នេះយើងមិនអាចធ្វើអ្វីវាកើតទេ ។

បើថាយើង មិនអាចធ្វើអ្វីវាកើតទេ នោះបានសេចក្តីថា យើងទុកឲ្យចិត្តវាក្រឡុកយើងគ្មានឈប់ឈរទៅហើយ ៖ បើចិត្តចង់ផឹកស្រា យើងក៏បណ្តោយឲ្យវាផឹក បើចិត្តចង់ចាប់រំលោបប្រពន្ធកូនគេ យើងក៏បណ្តោយឲ្យវាចាប់រំលោបប្រពន្ធកូនគេ ។ ហើយដល់ក្រុមនគរបាលមកចាប់ យើងឆ្លើយថា មិនមែនខ្ញុំទេដែលចាប់ប្រពន្ធកូនគេនោះគឺចិត្តទេតើ ។ នេះហើយការយល់ធម៌ ការបកស្រាយធម៌ខុសទំនង ។ តាមពិត ចិត្តអាចអប់រំបាន ដោយយកចិត្ត ទៅអប់រំចិត្ត។ ឧទាហរណ៍ មានគរគោក នៅក្នុងធម៌ព្រះពុទ្ធ ដូចជា យកចិត្តមេត្តា ទៅអប់រំចិត្តទោសៈចិត្តកំណាញ់ យកសតិទៅអប់រំចិត្តវាយមាយចិត្តមិនស្ងប់ ជាដើម ។ ឧទាហរណ៍មួយទៀត គឺ សត្វដំរី ដែលធ្លាប់តែមានចិត្តសាហាវ ហ្មដំរីចេះ អប់រំចិត្តវា ឲ្យស្លូតរហូតដល់ប្រើឲ្យទាញឈើហ៊ុបបាន ។ ភស្តុតាងមួយទៀត ប្រសិនបើជាយើងមិនអាចអប់រំចិត្តបាន ម្តេចក៏ព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ឲ្យដំបូន្មានដល់យើងគ្រប់រូបថា៖

[29] មានតែចំណេះដែលយើងប្រើទេ ដែលនៅជាប់នឹងខ្លួនយើង ដោយយើងចាំមិនភ្លេច។

១- កុំធ្វើ អំពើអាក្រក់ ២- ធ្វើ អំពើល្អ ៣- ធ្វើចិត្ត ឲ្យបរិសុទ្ធ ។

13-4 និយាយពីការដោះស្បែកជើង

ការដោះស្បែកជើងនេះ មាននៅក្នុងព្រះពុទ្ធសាសនា ក៏ដូចមាននៅក្នុងសាសនាដទៃដូចជា សាសនាអ៊ីស្លាមជាដើម គឺត្រូវដោះស្បែកជើងមុននឹងចូលក្នុងព្រះវិហារ។

ខ្ញុំលើកយកការដោះស្បែកជើងក្នុងវត្ត មកនិយាយពេលនេះ ដោយខ្ញុំមានយោបល់មិនស្របនៅកន្លែងខ្លះ នៅពេលខ្លះ ។ ដូចជា ព្រះសង្ឃនិមន្តបិណ្ឌបាត ដើងទទេ ហើយលុយទឹកទៀត ពេលភ្លៀងលិចក្រុងភ្នំពេញម្តងៗ ។

ខ្ញុំសួរថា តើមានប្រយោជន៍អ្វី ក្នុងការគោរពបដិបត្តិធម៌ព្រះ ដោយមិនឲ្យព្រះសង្ឃពាក់ស្បែកជើង ពេលនិមន្តបិណ្ឌបាត? ពីព្រោះព្រះពុទ្ធមិនបានឲ្យយើងគោរពធម៌ព្រះអង្គរហូតដល់ធ្វើបាបខ្លួន ដូចជាដេកហាលថ្ងៃនោះឡើយ ។ ដូច្នេះ ខ្ញុំយល់ថា ការដែលព្រះសង្ឃមិនពាក់ស្បែកជើង នៅពេលនិមន្តបិណ្ឌបាត ជាពលិកម្ម អត់ប្រយោជន៍ ហើយថែមទាំងនាំឲ្យមានរបួស ដូចជាមុតបន្លា ឬ មុតអំបែងកែវ នៅពេលលុយទឹកភ្លៀង។ មុននឹងឡើងជណ្តើរចូល ក្នុងកុដិ ឬ ក្នុងព្រះវិហារ យើងត្រូវតែដោះស្បែកជើង ពីព្រោះជាកន្លែងស្អាត ។ តែបើកន្លែងមិនស្អាត ដូចជាពេលហែ កឋិនទាន នៅជុំវិញព្រះវិហារ មានប្អូនស្រីជីដូនមួយខ្ញុំម្នាក់ គេថាឲ្យខ្ញុំដោះស្បែកជើង ហើយចាំគេកាន់ស្បែកជើងឲ្យខ្ញុំ ។ ខ្ញុំឆ្លើយថា បើខ្ញុំដោះស្បែកជើង ដើរជើងទទេជាន់ដី នោះជើងខ្ញុំនឹងប្រឡាក់ដី ហើយដល់ខ្ញុំដើរចូលក្នុងព្រះវិហារ នោះធ្វើឲ្យប្រឡាក់កន្ទេលដែលគេអង្គុយ តើសមទេ? ប្រសិនបើជាមានទឹកលាងជើង មានក្រដាស ឬក្រណាត់ជូតជើង មុននឹងចូលក្នុងព្រះវិហារនោះខ្ញុំមិនប្រកែកទេ ។ ហេតុនេះខ្ញុំសុំពាក់ស្បែកជើងសិន នៅពេលហែអង្គកឋិន ហើយខ្ញុំនឹងដោះស្បែកជើងមុនឡើងជណ្តើរចូលក្នុងព្រះវិហារ ។

*សង្កេត*

*ចំពោះចម្លើយនៃសំណួរថា «តើស្លាប់ហើយ កើតទៀត ឬ មិនកើតទៀត » គឺមាននៅក្នុងធម៌ បដិច្ចសមុប្បាទ នេះហើយ តាមព្រះពុទ្ធសាសនា។ សត្វទាំងឡាយឯណា គឺ មនុស្ស ឬ ទេវតា ឬ ព្រហ្ម បើមុននឹងស្លាប់ ចិត្ត នៅមាន តណ្ហានៅឡើយ សត្វទាំងឡាយនោះត្រូវតែកើតម្តងទៀត ហើយបើចិត្តនៃសត្វទាំងឡាយនោះ អស់តណ្ហាហើយ សត្វទាំងឡាយនោះ ឈប់កើតទៀតហើយ ។ ពីព្រោះ តាមទំព័រ ៩១* (*តារាង*-1) ៖

តណ្ហា (8) => ***ឧបាទាន* (9)** => *ភព* (10) => ជាតិ(11) ។

*ដូច្នេះ* តណ្ហា *រលត់* => ជាតិ *រលត់* ។

# ១៤

## អតីត  អនាគត  និង បច្ចុប្បន្ន

ពាក្យ  អតីត  អនាគត និងបច្ចុប្បន្ន  យើងសុទ្ធតែដឹងន័យទាំងអស់គ្នា ។ ការយល់ពាក្យបច្ចុប្បន្ន ក្នុងធម៌ព្រះពុទ្ធ គួរតែរែកញែកឲ្យច្បាស់ដែរ ។ ដូចជាពាក្យថា « យើងត្រូវរស់នៅក្នុងបច្ចុប្បន្ន » (Il faut vivre dans le présent) តើមានន័យយ៉ាងណាដែរ ? មុនដំបូង ខ្ញុំសូមបញ្ជាក់នូវពាក្យដែលយើងប្រើ ដើម្បីប្រាប់កាលទាំងបី  គឺ៖

- ចំពោះ អតីតកាល យើងប្រើពាក្យ  « **បាន** »  ឧទាហរណ៍ ធម៌ ដែលខ្ញុំបាន រៀន (ហើយ)។
- ចំពោះ អនាគតកាល  យើងប្រើពាក្យ  « **នឹង** »  ឧទាហរណ៍ ធម៌ ដែលខ្ញុំនឹង រៀន (នៅថ្ងៃមុខ)។
- ចំពោះ បច្ចុប្បន្នកាល  យើងប្រើពាក្យ  « **កំពុងតែ** »  ឧទាហរណ៍ ធម៌ ដែលខ្ញុំកំពុងតែ រៀន (នៅសព្វថ្ងៃនេះ ឬ នៅពេលនេះ) ។

ចុះពាក្យថា « យើងត្រូវរស់នៅក្នុងបច្ចុប្បន្ន » មានន័យដូចម្តេច ?

មានន័យថា បើយើងកំពុងតែ ហូបបាយ  សតិរបស់យើង ត្រូវនៅជាប់តែនឹងការហូបបាយ  កុំគិតទៅអ្វីផ្សេងទៀត  ដូចជា ហូបបាយផង  ឆ្លៀតមើលសារពត៌មានផង ឬ មួយហូបបាយផង ហើយនឹកគិតទៅកិច្ចការដែលនឹងធ្វើនៅថ្ងៃស្អែកផង។  ពាក្យបារាំងថា កិច្ចការនីមួយៗ មានពេលសម្រាប់តែកិច្ចការនោះ  (chaque chose en son temps) ។ ឧទាហរណ៍  កាលខ្ញុំនៅធ្វើការនៅឡើយ  មានពេលមួយនោះកិច្ចការដែលខ្ញុំធ្វើ ខ្ញុំ ត្រូវ

ធ្វើឲ្យហើយមុនថ្ងៃកំណត់ ដោយខ្ញុំដក់ទៅក្នុងកិច្ចការនោះខ្លាំងពេក ខ្ញុំចង់ភ្លេចហូបបាយ ទឹក ហើយដល់ទៅហូបបាយ នៅពេលកំពុងតែហូប ចិត្តខ្ញុំនៅតែគិតទៅកិច្ចការនោះ ទៀត ដល់ហុតទឹកសម្លមិនបានប្រយ័ត្ន ក៏ហៀរប្រឡាក់ខោអាវ ។ ក្នុងឧទាហរណ៍នេះ ពេលបច្ចុប្បន្ន គឺ ពេលកំពុងហូបបាយ ក្រៅពីនោះគឺ ពេលអតីត ឬ ពេលអនាគត ។ ឧទាហរណ៍មួយទៀត បើនិយាយពីម៉ោង បើម៉ោង 12H05 ជាពេលបច្ចុប្បន្ន នោះម៉ោង 12H04 ជាពេលអតីត ហើយ ម៉ោង 12H06 ជាពេលអនាគត ។តាមការពិសោធន៍ បើកាលណាចិត្តយើងនៅមូលជាប់តែនឹងកិច្ចការដែលយើង **កំពុងតែ**ធ្វើ នោះលទ្ធផល បានមក ល្អហើយចំណាយពេលខ្លីទៀត តែបើចិត្តមិនមូលទេ លទ្ធផល មិនបានល្អ ហើយថែមទាំងចំណាយពេលច្រើនទៀតផង។ អ្នកខ្លះគេថា ៖ មួយថ្ងៃ ស្មើនឹងបីថ្ងៃ បើយើងធ្វើការអ្វីមួយ យើងធ្វើតែការនោះ ឬ គិតតែទៅលើការនោះ។ មានលោក គ្រូខ្លះ ពន្យល់ថា ដោយយើងត្រូវតែរស់នៅក្នុងពេលបច្ចុប្បន្ន ដូច្នេះយើងមិនត្រូវគិត អនាគតទេ ពីព្រោះអនាគតមិនទៀង ហើយក៏ពុំទាន់មកដល់ផង ។ ខ្ញុំសួរថា ***បើដូច្នេះ តើអ្វីៗដែលយើងនឹងធ្វើនៅពេលខាងមុខ នោះយើងអាចគិតទុកជាមុនបានទេ ដូចជាគំរោងការជាដើម ?***

តាមខ្ញុំយល់ យើងត្រូវមាន សតិដោតជាប់ទៅនឹងកិច្ចការដែលយើង **កំពុងតែធ្វើ** ទោះជាកិច្ចការនោះមានប្រភេទបែបណាក៏ដោយ ឬជាកិច្ចការដែល**នឹងធ្វើនៅ**ថ្ងៃខាង មុខក៏ដោយ ។ ឧបមាថា មានកិច្ចការពីរ កិច្ចការទី១ គឺសរសេរសំបុត្រតបទៅនឹងសំបុត្រ ដែលទើបនឹងបានទទួល កិច្ចការទី២ គឺគិតអំពីការរៀបចំតុទទួលភ្ញៀវ ដោយត្រូវដាក់ ភ្ញៀវដែលស្គាល់គ្នាឲ្យអង្គុយជិតគ្នា នៅពេលជប់លៀងនៅខែខាងមុខ ។ ក្នុងឧទាហរណ៍ នេះ ថ្វីបើ ពេលជប់លៀងនៅមួយខែទៀតក៏ដោយ ខ្ញុំត្រូវតែគិតកិច្ចការទី២ មុនថ្ងៃជប់ លៀង បើមិនដូច្នោះទេ ចាំដល់ពេលភ្ញៀវមកដល់បានគិត នោះគិតមិនទាន់ទេភ្ញៀវមុខ

ជាឈរចាំរួយដើងស្លាប់ហើយ ។ ដូច្នេះត្រូវតែគិតទុកជាមុន គ្រាន់តែនៅពេលដែលខ្ញុំ
កំពុងតែ សរសេរសំបុត្រ(ធ្វើកិច្ចការទី១) ខ្ញុំមិនត្រូវ នឹកគិតទៅកិច្ចការទី២នោះទេ។
មានថ្ងៃមួយនោះ តាមទូរទស្សន៍ មានកីឡាករម្នាក់ដែលទើបនឹងបានជ័យជម្នះ
ក្នុងការប្រកួតប្រជែង បានឆ្លើយទៅនឹងសំណួរអ្នកកាសែតថា « ឥឡូវខ្ញុំមិនគិតទៅ
ថ្ងៃមុខទេ ខ្ញុំសូមសប្បាយនឹងជ័យជម្នះនេះសិនហើយ » ។ នេះ ដូចជាគេច្រើននិយាយថា
រស់នៅក្នុងបច្ចុប្បន្ន មិនឲ្យខាតបង់ពេលនេះទេ ។ ពីព្រោះថាអ្វីៗ
សុទ្ធតែមិនទៀង ៖ រស់នៅក្នុងបច្ចុប្បន្ន ទាន់អាសន្នមិនទាន់មក ។

# ១៥

# ត្រូវចេះធ្វើបុណ្យទើបបានបុណ្យច្រើន

*ការធ្វើបុណ្យ អាចចែកជាបីពេល គឺ ខណៈពេលមុនធ្វើ ខណៈពេលកំពុងធ្វើ និង ខណៈពេលធ្វើរួចហើយ ។ ដើម្បីបានបុណ្យច្រើន ត្រូវរបស់ទ្រព្យដែលយកមកធ្វើបុណ្យ នោះបានមកប្រកបដោយធម៌ ព្រះសង្ឃ ឬ លោកអ្នកដែលទទួលចតុបច្ច័យពីអ្នកធ្វើ បុណ្យនោះ ជាអ្នកមានសីល ហើយអ្នកធ្វើបុណ្យនោះទៀតគប្បីមានចិត្ត សទ្ធា ជ្រះថ្លា សប្បាយរីករាយ ទាំងបីខណៈ ។ តាមធម្មតា យើងច្រើនមានចិត្ត សទ្ធាជ្រះថ្លា សប្បាយរីករាយតែនៅពេលមុនធ្វើបុណ្យ ហើយដល់ពេលធ្វើបុណ្យ ក៏ជួបនឹងឧបសគ្គ ផ្សេងៗដែលពុំបានគ្រោងទុកជាមុន ដោយភ្លេចខ្លួនក៏ទៅជាខឹងនឹងភ្ញៀវក៏មាន ហើយ ដល់ធ្វើបុណ្យចប់ហើយ ជួនកាលអស់ប្រាក់កាសច្រើន ក៏មានបញ្ហាក្នុងគ្រួសារ ។*

*ខ្ញុំលើកតែការមិនស្រុះស្រួលនេះ មិនមែនបានន័យថា មានតែរបៀបនេះគ្រប់តែអ្នកដើម បុណ្យនោះទេ។ ខ្ញុំគ្រាន់តែចង់រំលឹកលោកអ្នកកុំឲ្យភ្លេចខ្លួន ខ្ចាចកំពប់បុណ្យ ។*

*ម្យ៉ាងទៀត កាលណាយើងធ្វើអំពើជាកុសលណាមួយ យើងគង់តែនឹងបានផលពីអំ ពើនោះជាមិនខាន ដូច្នេះមិនចាំបាច់ ប្រាថ្នាថា សុំឲ្យបានសម្បត្តិព្រះរាជា ឬ សម្បត្តិសួគ៌ នោះឡើយ។ ព្រោះការប្រាថ្នានូវសម្បត្តិទាំងឡាយនេះ នាំចិត្តយើងឲ្យកើតលោភ ដែល ជា* ***អកុសលចិត្ត*** *។*

*បើនិយាយតាមភាសាធម៌ <u>មុនពេលធ្វើបុណ្យ</u> បុគ្គល ត្រូវតែយល់ឲ្យច្បាស់អំពី អានិសង្ស នៃបុណ្យនោះ ហើយគួរត្រេកអរជ្រះថ្លា និងមានឆន្ទៈប្រកបដោយសទ្ធា ក្នុងការបំពេញ បុណ្យនោះ។ ចេតនា (អំពើ) នេះហៅថា* បុព្វ ចេតនា ។

ខណៈពេលកំពុងធ្វើបុណ្យ យើងត្រូវតែសប្បាយចិត្តជ្រះថ្លា ចំពោះអំពើល្អដែលយើងកំពុងតែធ្វើនេះ ដោយដឹងថាអំពើល្អនឹងនាំមកនូវសេចក្តីសុខ ។ ចេតនានេះឈ្មោះថា មុញ្ចន ចេតនា ។

បន្ទាប់ពីបានបំពេញកុសលហើយ យើងត្រូវតែរីករាយជ្រះថ្លា ចំពោះអំពើល្អដែលយើងបានសាងហើយនោះ គឺ រាល់ពេលដែលយើងនឹកដល់អំពើល្អនោះ យើងតែងតែរីករាយសប្បាយចិត្ត ។ ចេតនានេះឈ្មោះថា អបរាបរ ចេតនា ។

បុណ្យ ដែលប្រកបដោយចេតនាទាំងបីយ៉ាងនេះហើយ ហៅថា បណីត ទាន និងទង្វើនេះ ហៅថា បណីត កុសលកម្ម។ បុណ្យកុសល ដែលប្រាសចាកចេតនាទាំងបីនេះ ហៅថា ហីន ទាន និងទង្វើ ហៅថា ហីន កុសលកម្ម ។

បណីត កុសលកម្ម ឲ្យផលប្រសើរជាង ហីន កុសលកម្ម ។ ដូច្នេះ ទោះបុគ្គលពីររូបបរិច្ចាគ ទានដូចគ្នាក៏ពិតមែន តែផលដែលពួកគេទទួលបាន គឺមិនដូចគ្នានោះទេ ។ អ្នកដែលបរិច្ចាគដោយសទ្ធាជ្រះថ្លា ប្រកបដោយចេតនាជាកុសល រមែងទទួលបានបណីតកុសលកម្ម គឺបានផលប្រសើរជាងអ្នកឯទៀត ៗ។

ដូច្នេះ បុគ្គលគួរបំពេញអំពើល្អប្រកបដោយ **បញ្ញា** យល់ច្បាស់ពីកម្ម និងផលរបស់កម្ម និងប្រកបដោយ កុសលចេតនាទាំងបីយ៉ាង ដូចបានរៀបរាប់មកខាងលើនេះស្រាប់ ។

# ១៦

## អារម្មណ៍ ដែលត្រូវមាន មុនពេលស្លាប់[30]

តាមព្រះពុទ្ធសាសនា កម្មអាចចែកជា ៤ប្រភេទ គឺ: ១- គរុកកម្ម (កម្មធ្ងន់)
២- អាសន្នកម្ម (កម្មជិតស្លាប់) ៣- អាចិណ្ណកម្ម (កម្មអចិន្ត្រៃយ៍ - ទម្លាប់)
៤- កដត្តាកម្ម (កម្មមិនជាក់លាក់) ។

**១- គរុកកម្ម** កម្មដែលមានទម្ងន់ធ្ងន់

ក/ ខាងកុសល គឺមានទម្ងន់ខ្លាំងក្លា ដែលមិនមានកម្មឯណានីមួយមកកាត់ផ្តាច់ ឬជំនួសក្នុងការសម្រេច នៃជាតិបន្ទាប់។ ម្យ៉ាងវិញទៀត គរុកកម្មនេះ ច្បាស់ណាស់ថានឹងឲ្យផលតាក់តែងកំណើតថ្មីនៃជាតិខាងមុខ ។

ខ/ ខាងអកុសល គឺបាបកម្មដ៏ធ្ងន់ ៥ យ៉ាង (បញ្ចានន្តរិយកម្ម) ហើយនិងការយល់ខុសជាប្រចាំ (និយតមិច្ឆាទិដ្ឋិ)។

**-អនន្តរិយកម្ម៥** មាន: 1- សម្លាប់បិតា 2- សម្លាប់មាតា 3- សម្លាប់ព្រះអរហន្ត
4- បង្ករបួសចំពោះព្រះពុទ្ធ 5- ញុះញង់បំបែកបំបាក់សង្ឃ ។

**-និយតមិច្ឆាទិដ្ឋិ** គឺបុគ្គលដែលបដិសេធនូវកម្ម និងផលនៃកម្ម (បាបកម្មធ្ងន់) ។
គរុកកម្ម ជាកម្ម មានទម្ងន់ ទាំងខាងអកុសល និងខាងកុសល ៖

- បុគ្គលណា ប្រព្រឹត្តធ្វើទោសណាមួយ ក្នុងចំណោមទោសទាំង ៥ នៃអនន្តរិយកម្មនេះ ពេលស្លាប់ទៅ នឹងទៅកាន់ទុគតិភព ។ បុគ្គលដែលជានិយតមិច្ឆាទិដ្ឋិ គឺបុគ្គលដែលបដិសេធនូវ កម្ម និងផលនៃកម្ម នោះក៏រាប់បញ្ចូលក្នុង អកុសលគរុកកម្មដែរ (បាបកម្មធ្ងន់) ។ នៅពេលដែលបុគ្គលនោះស្លាប់ទៅ នឹងទៅចាប់កំណើតក្នុងលោកន្តរិក

[30] ដកស្រង់ពីសៀវភៅ «**កម្ម អ្នកសាងលោកពិត** » បណ្ឌិត ម៉ែន ទីន មន សាស្ត្រាចារ្យមហាសទ្ធម្មជោតិកធជ (ប្រទេសមីយ៉ាន់ម៉ា) ។

នរក ដែលងងឹតសូន្យជានិច្ច ។
- ចំណែកខាងកុសលកម្មវិញ មានអំពើជាកុសលដែលប្រព្រឹត្តទៅ ក្នុង រូបភព៥ (រូបាវចរកុសលកម្ម) និង អំពើជាកុសលដែលប្រព្រឹត្តទៅ ក្នុង អរូបភព៤ (អរូបាវចរកុសលកម្ម) ដែលជាកុសលគរុកកម្ម (អំពើល្អដ៏មានទម្ងន់) ។
បុគ្គលដែលបានសម្រេចឈានរហូតដល់ថ្ងៃស្លាប់ នឹងបានទៅកើតក្នុងព្រហ្មលោក ។
បុគ្គលដែលបានចាក់ធ្លុះក្នុង មគ្គនិងផល ដោយការចម្រើនទូវវិបស្សនាកម្មដ្ឋាន ហើយញុំាងកុសលកម្មក្នុងលោកុត្តរ (លោកុត្តរកុសលកម្ម) ឲ្យកើតឡើងជាគរុកកម្ម នឹងបិទនូវទ្វារ នៃអបាយទាំង៤ ជារៀងរហូត ។ ដូច្នេះបុគ្គលនោះក្រោយពេលស្លាប់ពីលោកនេះទៅ នឹងទៅកើតក្នុងសុគតិភពតែម្យ៉ាង ។
- ប្រសិនបើ បុគ្គលបានចម្រើនឈានឲ្យកើតឡើងហើយ ប៉ុន្តែក្រោយមកបានប្រព្រឹត្តនូវអនន្តរិយកម្មណាមួយ ក្នុងចំណោម៥ នោះ អកុសលកម្មនឹងបិទបាំងនូវកុសលកម្ម ហើយក្រោយមកញុំាងកំណើត ក្នុងអបាយឲ្យកើតឡើងបាន។ ឧទាហរណ៍ជាក់ស្តែងគឺ ភិក្ខុទេវទត្ត ដែលត្រូវជាសាច់ញាតិជីដូនមួយ នៃព្រះសម្មាសម្ពុទ្ធ បានបាត់បង់នូវឫទ្ធានុភាព ហើយទៅកើតក្នុងអវចីនរក ដោយសារតែខ្លួនបានធ្វើឲ្យមានរបួសដល់ម្រាមព្រះបាទនៃព្រះសម្ពុទ្ធ និងការដែលខ្លួនបានញុំាងគណៈសង្ឃឲ្យបែកបាក់ ។
ជាងនេះទៅទៀត ប្រសិនបើបុគ្គលណាមួយប្រព្រឹត្តនូវកម្មណាមួយក្នុងចំណោមអនន្តរិយកម្មទាំង៥ <u>បុគ្គលនោះ**នឹងមិនចាក់**ធ្លុះក្នុងលោកុត្តរធម៌ឡើយ</u> ពីព្រោះថា អកុសលកម្មនោះមានទម្ងន់ធ្ងន់ពេក។ ហេតុដូច្នេះហើយបានជាព្រះបាទ អជាតសត្តុ ខណៈពេលកំពុងតែស្តាប់នូវសាមញ្ញផលសូត្រ ដែលប្រទានដោយព្រះសម្មាសម្ពុទ្ធ ទ្រង់មានល័ក្ខណ្ឌគ្រប់គ្រាន់ដើម្បីសម្រេចសោតាបត្តិមគ្គ ប៉ុន្តែព្រះអង្គមិនបានចាក់ធ្លុះក្នុងមគ្គនិងផលឡើយ នេះក៏ព្រោះតែទ្រង់បានធ្វើឃាតព្រះបិតារបស់ទ្រង់ គឺព្រះបាទពិម្ពិសារ ។
ក្រោយមកទៀត ថ្វីបើព្រះបាទអជាតសត្តុ បានបំពេញកុសលកម្មយ៉ាងច្រើន ដូចជាទ្រង់បានរាជូបត្ថម្ភ ក្នុងការប្រារព្ធធ្វើសង្គាយនា លើកទីមួយ និងទ្រង់បានសាង

ព្រះចេតិយដ៏ធំអស្ចារ្យ ដើម្បីតម្កល់ព្រះសារីរិកធាតុព្រះសាស្ដាក៏ដោយ ក៏ទ្រង់នៅ
តែមិនអាចគេចផុត ពីកំណើតក្នុងនរកឡើយ។ នេះគឺព្រោះតែទ្រង់បានប្រព្រឹត្ត
អនន្តរិយកម្ម គឺធ្វើឃាតបិតានោះឯង ។

**២- អាសន្នកម្ម កម្មជិតពេលស្លាប់**

កម្មនៅពេលជិតស្លាប់ គឺជាកម្លាំងនៃកម្ម ទាំងជាកុសលនិងអកុសលដែលបុគ្គល បានធ្វើទុកមក ឬក៏ចងចាំក្នុងរយៈពេលដ៏ខ្លីមុនពេលស្លាប់ ។ ប្រសិនបើពុំមាន គរុកកម្មទេ អាសន្នកម្មនេះនឹងដើរតួនាទីរបស់ខ្លួន តាក់តែងកំណើត ដោយហេតុ ថាកម្មនេះមានកម្លាំងខ្លាំងក្លា ព្រោះកើតនៅពេលរៀបនឹងស្លាប់ ។

ប្រសិនបើបុគ្គលម្នាក់ដែលធ្លាប់សាងបាបកម្មច្រើន ធ្វើអំពើល្អមុនពេលខ្លួនស្លាប់ ឬ ក៏ចងចាំនូវអំពើល្អដែលខ្លួនបានធ្វើមុនពេលស្លាប់នោះ បុគ្គលនោះនឹងបានទៅកើត ក្នុងសុគតិភព។ ផ្ទុយទៅវិញ ប្រសិនបើបុគ្គលម្នាក់ធ្លាប់បានសាងកុសលកម្មច្រើន តែចងចាំនូវអំពើអាក្រក់ណាមួយ ដែលខ្លួនធ្លាប់បានសាងក្នុងពេលមុន ឬក៏បានធ្វើអំពើ អាក្រក់មុនពេលស្លាប់ បុគ្គលនោះនឹងទៅកើតក្នុងទុគ្គតិភព ។

ព្រោះហេតុនេះហើយ បានជាការចាំបាច់ណាស់ ចំពោះមាតាបិតា ឬមនុស្សជាទី ស្រឡាញ់របស់យើង មុនពេលជិតនឹងស្លាប់ យើងធ្វើបុណ្យកុសលជូនគាត់ ឬ ក៏ជួយក្រើនរំលឹកពួកគាត់ ឲ្យនឹកឃើញអំពើល្អគ្រប់យ៉ាងដែលពួកគាត់បានសាង ។

ទោះបីបុគ្គលដែលបានសាងអំពើបាបច្រើន បានទៅកើតក្នុងសុគតិភព ដោយអំណាច នៃអំពើល្អដែលខ្លួនបានធ្វើមុនពេលស្លាប់ក៏ដោយ មិនមែនមានន័យថាបុគ្គលនោះ អាច គេចផុតពីអកុសលកម្ម ដែលខ្លួនបានសាងកាលនៅរស់នោះឡើយ។ នៅពេលដែល បុគ្គលនោះបានសុខចម្រើន បាបកម្មទាំងនោះក៏អាចឲ្យផល ទៅតាមការសមស្របរបស់ វាដែរ ។ វៀរលែងតែបុគ្គលនោះ រក្សានូវត្រៃសិក្ខា (សីល សមាធិ បញ្ញា) ឲ្យបានខ្ជាប់ ខ្ជួន ហើយបានចាក់ធ្លុះក្នុងមគ្គ និងផល ដូចនេះអកុសលកម្មទាំងឡាយនឹងមានកម្លាំង ខ្សោយ ហើយមិនអាចអូសទាញបុគ្គលនោះ ទៅកាន់អបាយបានឡើយ ។

**៣- អាចិណ្ណកម្ម កម្មជាទម្លាប់**

អាចិណ្ណកម្ម គឺជា អំពើល្អ ឬអាក្រក់ ដែលបុគ្គលទម្លាប់ធ្វើជាប្រចាំ ឬក៏អ្វីមួយដែលបុគ្គលបានធ្វើតែម្តង ហើយចងចាំនឹករលឹករឿយៗ ។

ប្រសិនបើគ្រូបង្រៀនតែងតែពន្យល់ណែនាំសិស្សរបស់ខ្លួនដោយបំណងល្អ ដើម្បីឲ្យពួកគេមានចំណេះដឹង ការបង្រៀនជាប្រចាំនេះ គឺជាកុសល អាចិណ្ណកម្ម គឺអំពើល្អជាប្រចាំ ឬ ទម្លាប់ ។ ប្រសិនបើស្រីម្នាក់តែងចំអិនអាហារ ហើយដាក់បាត្រលោកជារៀងរាល់ថ្ងៃ ទង្វើនេះជាកុសលកម្មអចិន្ត្រៃយ៍ ។

ប្រសិនបើ បុគ្គលម្នាក់ មានប្រក្រតីរក្សានូវសីល ហើយតែងតែពិចារណាត្រេកអរ ចំពោះសេចក្តីបរិសុទ្ធ ក្នុងសីលនោះជាប្រចាំ ការរក្សានូវសីលនេះ ហៅថា កុសលអាចិណ្ណកម្ម ។ សម្រាប់បុគ្គលអ្នកចម្រើននូវកម្មដ្ឋាន ការចម្រើននូវកម្មដ្ឋាននេះ ហៅថាអាចិណ្ណកម្ម ។ សម្រាប់បុគ្គលអ្នកនេសាទត្រី បរបាញ់សត្វ លួចឆក់ប្លន់ ។ល។ ដើម្បីការចិញ្ចឹមជីវិតជាប្រចាំ ។ ទង្វើបាបទាំងនេះ ជាអកុសលអាចិណ្ណកម្ម គឺអំពើអាក្រក់ជាប្រចាំ ឬទម្លាប់ ។

ប្រសិនបើ មិនមានវត្តមានគរុកកម្ម និងអាសន្នកម្មទេ អាចិណ្ណកម្មនឹងដើរតួនាទីរបស់វាជាអ្នកសម្រេចតាក់តែងជាតិកំណើតថ្មី ។

**៤- កដត្តាកម្ម កម្មមិនជាក់លាក់**

កដត្តាកម្មនេះ គឺជាកម្មទីទៃអំពីកម្មទាំងឡាយដែលបានរៀបរាប់មកខាងលើ គឺជាកម្មដែលបុគ្គលបានសាងពីមុនមក ហើយមិនបានចងចាំទេ ប៉ុន្តែវាអាចមានកម្លាំងគ្រប់គ្រាន់ ដើម្បីតាក់តែងជាតិកំណើតថ្មីបានដែរ ។ កម្មមិនជាក់លាក់នេះ វានឹងមានឱកាសតាក់តែងកំណើតថ្មីបាន ប្រសិនបើមិនមានវត្តមាននៃកម្មទាំងបីខាងលើនោះ មកបំពេញតួនាទីទេ ។

មាន កុសលកម្ម និង អកុសលកម្ម រាប់មិនអស់នៅក្នុងសន្តានដែលបានសន្សំទុកមក ហើយទាំងអស់នេះសុទ្ធតែអាចដើរតួជា កដត្តាកម្មបានទាំងអស់។ ប្រសិនបើកុសល

កជត្តាកម្ម (អំពើល្អមិនច្បាស់លាស់) មានឱកាសឲ្យផល បុគ្គលនោះនឹងមានសំណាង ល្អ ។ តែបើ អកុសលកជត្តាកម្មឲ្យផលមុននោះ នឹងមានដំណើរឆ្ពោះទៅកាន់ទុគ្គតិភព ហើយបើទៅកើតក្នុងទីនោះហើយ ពិបាកនឹងចេញមកវិញណាស់ ព្រោះទីនោះមិនមែន ជាកន្លែង កសាងធ្វើបុណ្យទាន ។ យើងមិនគួរអនុញ្ញាតឲ្យ អកុសលកជត្តាកម្ម សម្រេច ជោគវាសនាឲ្យយើងទេ ព្រោះថា យើងជាម្ចាស់ជោគវាសនារបស់ខ្លួនយើង ។ ដូច្នេះយើងគួរណាស់តែព្យាយាមទម្លាប់ធ្វើអំពើល្អឲ្យបានច្រើន ដើម្បីឲ្យអំពើល្អនេះ តាក់តែងកំណើតថ្មី ក្នុងសុគតិភពឲ្យយើង ។

<u>សេចក្តីបន្ថែម</u>

**មរណៈ** គឺសេចក្តីស្លាប់ មានបួនយ៉ាង គឺ

១- មរណៈដោយអស់អាយុ គឺស្លាប់ដោយជំងឺ ដោយជរា។ កាលពីសម័យព្រះពុទ្ធ មនុស្សអាយុ ១០០ឆ្នាំ ។ ព្រះពុទ្ធនៃយើងព្រះអង្គបានព្រះជន្មតែ ៨០ ឆ្នាំក៏បរិនិព្វានទៅ ។ មកដល់យើងសព្វថ្ងៃនេះ គឺ ជាង ២៥០០ ឆ្នាំហើយ ដែលព្រះពុទ្ធបរិនិព្វាន ដូច្នេះអាយុ យើងត្រូវថយអស់ ២៥ ឆ្នាំ[31] គឺ មនុស្ស អាយុច្រើនជាង (១០០ - ២៥) = ៧៥ ឆ្នាំ មានមិនច្រើនទេ ។ ចំពោះមនុស្សដែលមានអាយុលើសពី ៧៥ឆ្នាំទៅ គឺ បានដោយសារ បុណ្យ ។

២- មរណៈដោយអស់បុណ្យ។ ដូចទេវតា ដែលអស់បុណ្យ ក៏ស្លាប់ ហើយមកចាប់ជាតិ ជាមនុស្ស ឬ ទៅ អបាយ ក៏មាន ។

៣- មរណៈដោយអស់អាយុ និង អស់បុណ្យ ទាំង២ ចុះព្រមគ្នា ។ ឧបមា ដូចចង្កៀង ប្រេងកាត ដែលរលត់ ដោយអស់ទាំងប្រេង អស់ទាំងប្រឆេះ ដោយព្រមគ្នា។

---

[31] ពីព្រោះតាមជំនឿ ខាងព្រះពុទ្ធសាសនា ក្នុង ១០០ឆ្នាំ អាយុមនុស្សត្រូវថយអស់ ១ ឆ្នាំ ដូច្នេះ ក្នុង រយៈពេល ២៥០០ ឆ្នាំ (នៅព.ស ២៥៦១ នេះ) អាយុមនុស្សយើងត្រូវថយអស់ ២៥ ឆ្នាំ ។

៤- មរណៈដោយកម្មចាស់ចូលទៅកាត់បង់ ។ គឺស្លាប់ដោយ កម្មដែលបានធ្វើពីកាលមុន មកកាត់ផ្តាច់ជីវិត ។

មនុស្ស ជិតនឹងស្លាប់ ជួនកាលមានអារម្មណ៍ ៖

១- **កម្ម** គឺកុសល ឬអកុសល ដែលនឹងឲ្យបដិសន្ធិ ក្នុងភពខាងមុខ មកប្រាកដ ជាអារម្មណ៍។ កម្មជាកុសលនោះ ដូចជាខ្លួនធ្លាប់ ឲ្យទាន រក្សាសីល ស្តាប់ធម៌ ឬ ចំរើនភាវនា ធ្លាប់ធ្វើយ៉ាងណា ក៏មកប្រាកដដូចកំពុងធ្វើយ៉ាងនោះ ។ ចំណែកខាង អកុសលវិញ ដូចជា ខ្លួនធ្លាប់សម្លាប់សត្វ លួចទ្រព្យ ឆបោក បំបាត់ ឬវាយដំ សំពង ចងសត្វទាំងពួងយ៉ាងណា ក៏មកប្រាកដដូចកំពុងធ្វើយ៉ាងនោះ ។

២- **កម្មនិមិត្ត** គឺ វត្ថុដែលជាគ្រឿងធ្វើកុសល ឬអកុសល ។ មានរូបជាដើមដែលខ្លួនធ្លាប់ បាន កាលវេលាធ្វើកម្មជាកុសល ឬ អកុសលនោះ ។ គ្រឿងដែលមកប្រាកដក្នុង អារម្មណ៍ ដូចជា គ្រឿងដែលធ្វើកុសលក្នុងបច្ចុប្បន្នជាតិនេះមាន សម្ពត់ និងគ្រឿង សក្ការៈផ្សេងៗជាដើម ។ កម្មនិមិត្ត ចំណែកអកុសល គឺនឹងឃើញគ្រឿងដែលបៀតបៀន សត្វផ្សេងៗ ដែលខ្លួនធ្លាប់យកទៅធ្វើក្នុងជាតិនេះ មាន ដាវ លំពែង មង ជាដើម ។

៣- **គតិនិមិត្ត** គឺ គ្រឿងបរិភោគដែលខ្លួននឹងគប្បីបានក្នុងភពដែលនឹងទៅកើតជា លំដាប់ មកប្រាកដជាអារម្មណ៍ ។ គតិនិមិត្ត មាន ២ យ៉ាង គឺ សុគតិ ១ ទុគ្គតិ១ ។

**សុគតិ** គឺ ដំណើរដែលនឹងទៅល្អនោះ គឺនឹងឃើញ វិមានប្រាសាទ ទិព្វសម្បត្តិ និង នាងទេពអប្សរជាដើម។ សុទ្ធតែជាចំណែកដែលល្អ ។

**ទុគ្គតិ** គឺដំណើរដែលនឹងទៅសោយទុក្ខនោះ គឺ នឹងឃើញអណ្តាតភ្លើងនាយនិរយបាល ឆ្កែ ឬ ត្មាត ជាដើម ដែលនឹងមកបៀតបៀនខ្លួន ។

កម្មដែលនឹងមកប្រាកដនោះ គឺមកប្រាកដក្នុងមនោទ្វារ ។ កម្មនោះប្រាថ្នាយក កម្ម ជា អតីត ដែលខ្លួនបានធ្វើហើយយ៉ាងណា ក៏ឃើញដូចកំពុងធ្វើយ៉ាងនោះ ។

*អារម្មណ៍មួយដែលខ្ញុំយល់ថាគួរនឹកដែរ គឺ* **គុណព្រះពុទ្ធ** *ពីព្រោះយើងបានយក* **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ** *ជាទីពឹង ទីរលឹក។*

*ព្រះពុទ្ធមុននឹងបរិនិព្វាន បានគិតមកទុក្ខនៃសត្វលោក ហើយបណ្តាំចុងក្រោយរបស់ព្រះអង្គនៅក្នុងគម្ពីរព្រះត្រៃបិដកខ្មែរ ភាគទី ១៦  ទំព័រ ២៥៧* មានដូចតទៅនេះ ៖

ម្នាលភិក្ខុទាំងឡាយ  អ្នកទាំងឡាយកុំប្រមាទ  ត្រូវមានស្មារតី  មានសីលល្អ មានតម្រិះតម្កល់នឹងល្អ  ចូររក្សាចិត្តរបស់ខ្លួន ឲ្យរឿយៗចុះ ។

ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ  (ភិក្ខុនោះ) នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ បានមិនខាន ។

# ១៧

## ធម៌ព្រះពុទ្ធ តាមការយល់ និង ការពិសោធន៍ខ្លះ របស់ខ្ញុំ

*ជាបឋម ខ្ញុំសូម បញ្ជាក់ថា គំនិតយោបល់ ដែលខ្ញុំសូមជូនលោកអ្នកអានដូចតទៅនេះ ជាគំនិត និងយោបល់ផ្ទាល់ខ្លួនខ្ញុំ ដែលខ្ញុំបានយល់តាមប្រាជ្ញាខ្ញុំ នូវធម៌ព្រះពុទ្ធ ។ ដោយខ្ញុំជា បុថុជ្ជននៅឡើយ ការបកស្រាយនេះ អាចខុសពីធម៌ព្រះពុទ្ធដែលព្រះអង្គបានចែងទុកមក។ ខ្ញុំសរសេរនេះ គ្រាន់តែជាគំនិតមួយ សម្រាប់លោកអ្នកយកទៅពិចារណា ថាត្រូវ ឬ ខុស ប៉ុណ្ណោះទេ។ ទុកជាអាហារមួយខាងផ្លូវចិត្ត ដែលខ្ញុំសូមជូនលោកអ្នក។*

*១-និព្វានតាមខ្ញុំយល់*

*ដោយនិព្វាន យើងមិនទាន់ទៅដល់ អ្នកខ្លះបកថាសូន្យ ជាពិសេសជនជាតិបរទេស ហើយខ្មែរយើងបកថា អមតៈមហានិព្វាន ជាស្ថានក្សេមផុតចាកទុក្ខ។ តែខ្ញុំសួរខ្លួនឯង ថាហេតុអ្វីបានជាថា និព្វាន គឺ ផុតចាកទុក្ខ? ហើយកាលណាមិនទាន់សម្រេចនិព្វាន នោះនៅមានទុក្ខ? បើធម៌ព្រះពុទ្ធ ជាធម្មជាតិ យើងត្រូវយល់បានដោយការសមហេតុសមផល ពោលគឺមិនមែនដោយជំនឿទាំងស្រុងនោះទេ ។*

*តាមព្រះពុទ្ធសាសនា មនុស្សយើងម្នាក់ៗ មានកាយនិងចិត្ត។ ដើម្បីថា យើងបានសុខទាល់ តែកាយក៏សុខ និង ចិត្តក៏សុខ។ កាយមិនសុខ កាលណាយើងមានរោគមកបៀតបៀនគឺថាមានមេរោគផ្សេងៗនៅក្នុងកាយយើង។ ដើម្បីកុំឲ្យមេរោគមកបៀតបៀនកាយបានទាល់តែយើងអត់មានកាយ ។ ហេតុនេះហើយបានជា មានព្រហ្មអត់រូប (អរូបព្រហ្ម) ដែលទៅអំពីព្រហ្មមានរូប ដោយខំធ្វើឈានតទៅទៀត ។ តែទុកជាព្រហ្មអត់រូបក៏ដោយក៏នៅតែដោះស្រាយ ជម្ងឺខាងផ្លូវចិត្តមិនទាន់បាន ពីព្រោះនៅមានមេរោគខាងផ្លូវចិត្ត នៅឡើយ ដែលមកបៀតបៀនចិត្តនោះ។ មេរោគនោះ តាមព្រះពុទ្ធ គឺ តណ្ហា។ ដូច្នេះ*

ដើម្បី ចិត្តបានសុខ ទាល់តែចិត្តអស់តណ្ហារលីង គឺស្អាតបរិសុទ្ធ ។ និព្វាន នៅលើភពមនុស្សយើងនេះមាន គឺនិព្វានខាងផ្លូវចិត្ត បានដោយចិត្តអស់តណ្ហា។ តែនិព្វានខាងផ្លូវកាយ មិនទាន់សម្រេចទេ ពីព្រោះនៅមានកាយដែលជាសំបុកនៃរោគ នៅក្រោមច្បាប់ អនិច្ចំនៅឡើយ។ និព្វានខាងផ្លូវចិត្តយើងនឹងស្គាល់ កាលណាចិត្តយើងស្អាតបរិសុទ្ធ សក្បុសដូចក្រណាត់សំពត់ថ្មីដែលទើបនឹងចេញពីកីតម្បាញ។ កាលណាចិត្តមិនទាន់បានស្អាតទេ បើជាអរិយបុគ្គល ក៏នៅជាអរិយបុគ្គលថ្នាក់ដំបូង មិនទាន់ទៅដល់ថ្នាក់ព្រះអរហន្តនៅឡើយ ។ តែថ្វីបើមិនទាន់បានជាព្រះអរហន្តក៏ដោយ យើងអាចភ្លក់រសនិព្វានម្តងៗបានដែរ កាលណាចិត្តយើងស្ងប់ បរិសុទ្ធ ឥតមាន លោភៈ ទោសៈ មោហៈ មកលាយឡំ ។ យើងដែលខុសពីព្រះអរហន្តត្រង់ចិត្តយើងមិនបានបរិសុទ្ធរហូត ដូចជាយើងស្ងួតតែមិនទាន់មានគេធ្វើឲ្យចិត្តថ្លាំងថ្នាក់ទេ ដូចទឹកក្នុងពាងដែលថ្លាតែខាងលើ ហើយនៅមានកករនៅបាតពាង តែគេធ្វើឲ្យពាងរង្គើនោះកករក៏ឡើងមកលាយឡំធ្វើឲ្យទឹកទៅជាល្អក់មួយរំពេច។ ខ្ញុំនិយាយនេះដោយសំអាងលើពាក្យថា **នត្ថិ សន្តិ បរំ សុខំ** គ្មានសុខអ្វី ស្មើនឹងសេចក្តីស្ងប់ ដូច្នេះក្នុងរសនិព្វាន មានសេចក្តីស្ងប់មួយដែរ ។ ដូចគេថាស្ករផ្អែម ផ្អែមរបស់ស្ករត្នោត ក៏ជារសផ្អែមមួយដែរ ហើយរសស្ករអំពៅ ជារសផ្អែមមួយទៀត ដូច្នេះ សេចក្តីស្ងប់ ក៏ជារសមួយនៃនិព្វានដែរ ។ មានសំណួរមួយដែលសួរថា និព្វាន ជា វិសង្ខារធម៌ (នេះតាមធម៌ព្រះ) ចុះព្រះអរហន្តបានសម្រេចនិព្វានម្តេចនឹងកើត បើលោកនៅមាន ខន្ធ៥ ( រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ដូចយើងដែរ ហើយខន្ធ៥ក៏ជាសង្ខារធម៌ដែរ ។ ជាការពិតហើយដែលថាព្រះអរហន្តនៅមានខន្ធ៥នៅឡើយ តែចិត្តព្រះអរហន្តខុសពីចិត្តយើងដែលជាបុថុជ្ជន ត្រង់ចិត្តលោកបរិសុទ្ធ អស់កិលេស ទាំងកិលេសគ្រោតគ្រាត ទាំងកិលេសល្អិតសុខុម ។ ដោយហេតុព្រះអរហន្តនៅមាន សង្ខារធម៌ជាប់មកពីកំណើតនេះហើយ បានមានពាក្យ

**បរិនិព្វាន** គឺ និព្វានទៅម្ខាង ពីនិព្វានដែលមានសង្ខារធម៌នៅឡើយ គឺ ជានិព្វាន មិនមានការកើតទៀត។ពីព្រោះតែមានការកើតហើយ ក្នុងកំណើតនោះ ត្រូវតែ មានសង្ខារធម៌មកជាប់ជាមួយម្តងទៀត ។ដូច្នេះដើម្បីបានសម្រេចនិព្វានជា វិសង្ខារធម៌ នោះទាល់តែព្រះអរហន្តបានរំលាយខន្ធពីភពទាំងបីនេះទៅ គឺ កាមភព រូបភព និង អរូបភព ។

២- ត្រូវរស់នៅឲ្យស្រុបទៅតាមច្បាប់ធម្មជាតិ

យើងពុំអាចកែច្បាប់ធម្មជាតិ ឲ្យស្រុបមកតាមចិត្តយើងបានទេ ។ ឧបមា ថាយើងមិនចង់ ឲ្យមេឃភ្លៀងទេថ្ងៃនេះ ពីព្រោះយើងធ្វើបុណ្យមានភ្ញៀវច្រើន។ តែមេឃមិនបានស្តាប់ យើងទេ ។ ដូច្នេះ យើងទេដែលត្រូវ សម្រុបទៅតាមច្បាប់ធម្មជាតិ ។ បើយើងស្គាល់ច្បាប់ ធម្មជាតិច្បាស់ យើងអាចទាញយកផលប្រយោជន៍ពីច្បាប់នេះ ឬក៏អាចចៀសនូវគ្រោះ ថ្នាក់បណ្តាលមកពីច្បាប់នេះដែរ ។ តែឲ្យច្បាប់នេះ កែមកតាមយើងគឺមិនបានឡើយ ។ អាចទាញយកប្រយោជន៍ ដូចជា យើងត្រូវការទឹកភ្លៀង ដើម្បីដាំស្រូវ ។ ចៀសនូវគ្រោះ ថ្នាក់ដូចជា យន្តហោះបើដឹងថាតំបន់ដែលនឹងត្រូវហោះកាត់មានខ្យល់ព្យុះខ្លាំង នោះ អ្នកបើកយន្តហោះ មានពេលនឹងគេចពីតំបន់នោះ ។

ច្បាប់ធម្មជាតិមួយ ដែលយើងត្រូវស្រុបតាម គឺច្បាប់ អនិច្ចំ ដែលថា មិនទៀង ដូចជា ជីវិត មិនទៀងជាដើម ។ ន័យមួយទៀតគឺ ផ្លាស់ប្តូរ ប្រែប្រួល ដូចជា សំលៀកបំពាក់ត្រូវ ផ្លាស់ប្តូរទៅតាមរដូវ រងារ ឬ ក្តៅ ឬ ទៅតាមម៉ូត ទៅតាមសម័យ ។ នេះមកពីចិត្តមនុស្ស ផ្លាស់ប្តូរ របស់នៅជុំវិញយើង ផ្លាស់ប្តូរ ប្រទេសជិតខាងគេផ្លាស់ប្តូរ ដូច្នេះយើងត្រូវតែ ផ្លាស់ប្តូរ ទៅរកវឌ្ឍនភាព ដូចគេឯងដែរ ។ មានសុភាសិត ចិនមួយថា « ដែលភ័យ គឺ ភ័យមិនទៅមុខ តែបើទៅមុខហើយ ទោះបីជាយឺតក៏មិនអីដែរ » ហើយសុភាសិតបារាំង មួយថា « កាលណាមិនទៅមុខ នោះថយក្រោយហើយ » (ពីព្រោះនៅពេលជាមួយ

គ្នានោះ មានគេឯទៀតគេទៅមុខ) ។

មកដល់ត្រង់នេះ ខ្ញុំនឹកឃើញសំណួរមួយ ដែលខ្ញុំកាលពីក្មេងបាន សួរទៅឪពុកខ្ញុំថា « លោកតា បានគិម កាលពីដើម គាត់ជាអ្នកមានទ្រព្យសម្បត្តិ មួយនៅឃុំបាក់ខែង យើង ហេតុអ្វីបានជា សព្វថ្ងៃនេះ គាត់គ្រាន់តែជាអ្នកធម្មតា ? » ។ ឪពុកខ្ញុំឆ្លើយ មកខ្ញុំថា « មកពីមុខរបរ ដែលគាត់រកកាលពីមុននោះ ឥឡូវនេះគេប្រើសុទ្ធតែម៉ាស៊ីនដូច ជាគេប្រើកាណូត ហើយគាត់នៅប្រើទូកចែវ ជាដើម ពោលគឺគាត់ធ្វើការវិវឌ្ឍន៍មិន ទាន់ពេលវេលា » ។ នេះជាឧទាហរណ៍មួយ ដែលអ្នកដឹកនាំគួរយកមកពិចារណា ។

<u>៣- រឿង កើតពីហេតុ</u>

មនុស្សយើងគ្រប់រូប សុទ្ធតែចង់បានសុខ មិនចង់ជួបប្រទះ នឹងរឿងរ៉ាវផ្សេងៗនោះទេ ។ ដោយរឿងរ៉ាវខ្លះកើតមកពីក្រៅ មិនមែនយើងជាអ្នកបង្កើត តើត្រូវធ្វើដូចម្តេច ដើម្បីកុំឲ្យ រឿងទាំងនោះមករំខានយើង ។ របៀបម្យ៉ាងដើម្បីជៀសវាង គឺត្រូវដោះស្រាយកុំបង្អែ បង្អង់ ទុកឲ្យរឿងនោះកាន់តែធំឡើងៗ ដោយឆាប់រកហេតុវាឲ្យឃើញ ។ ពីព្រោះរឿង មិនងាយរលត់ទៅវិញឯងៗទេ លុះត្រាតែហេតុរលត់ ទើបរឿងនោះរលត់ ។ យើងអាចយកក្បួននេះ មកអនុវត្តលើការងារដែលយើងត្រូវធ្វើ ក្នុងជីវិតរស់នៅសព្វ ថ្ងៃនេះ ។ ការងារដែលត្រូវធ្វើ គួរតែធ្វើឲ្យហើយកុំបង្អង់ ។ ពីព្រោះបើយើងមិនធ្វើ នៅពេលនេះ ក៏គេចមិនរួចនៅពេលខាងមុខដែរ ។ ដោយធ្វើរបៀបនេះ យើងជៀសវាង ការកើតទុក្ខ ព្រោះតែកិច្ចការដែលកកកុញនោះ ដល់ច្រើនទៅវាមកគ្របសង្កត់លើយើង។ ដូចពាក្យលោកថា « កុំទុកទៅថ្ងៃស្អែក កិច្ចការអ្វីដែលអាចធ្វើនៅថ្ងៃនេះបាន »។ យើង អាចទុកកិច្ចការដូចជា ទម្ងន់មួយ ហើយបើយើងមិនយកទម្ងន់នោះចេញទេ ទម្ងន់ថ្មី មកថែមពីលើវា ហើយដល់យូរៗទៅ យើងកាន់តែធ្ងន់ ងើបលែងរួច ត្រូវហៅគេមកជួយ ។

<u>៤- តើត្រូវធ្វើដូចម្តេច ដើម្បីអ្នកដទៃ គេស្រឡាញ់ គោរព រាប់អានយើង</u>

មនុស្សយើងធ្វើអំពើទាំងពួងដោយ  កាយ វាចា និង ចិត្ត ។ ចំពោះសុខនិងទុក្ខ ទាំង យើងទាំងគេ សុទ្ធតែចង់បានសុខ ហើយ មិនចង់ជួបនឹងទុក្ខ ។

ដូច្នេះមុននឹងធ្វើអំពើអ្វីមួយ យើងត្រូវគិតថា បើគេធ្វើអំពើបែបនេះមកលើយើង តើយើង សប្បាយចិត្ត ឬ កើតទុក្ខ ?

បើយើងឆ្លើយថា យើងនឹងសប្បាយចិត្ត នោះយើងធ្វើទៅលើគេ  គេនឹងសប្បាយចិត្តដូច យើងដែរ ។ដូច្នេះបើយើងធ្វើអំពើនោះទៅ  អ្នកផងទាំងពួងគេនឹង  គោរព ស្រឡាញ់ រាប់អានយើងហើយ ។  តែបើយើងឆ្លើយថា យើងក៏មិនចង់ឲ្យគេធ្វើមកលើយើងរបៀប នេះដែរ   នោះយើងកុំធ្វើអំពើនោះទៅលើគេ ។ ប្រសិនបើជាយើងធ្វើវិញ នោះគេនឹង មួម៉ៅពីព្រោះគេខាតប្រយោជន៍ រងទុក្ខវេទនាដោយ ព្រោះតែអំពើរបស់យើង។

ខ្ញុំលើកយករឿងនេះមកនិយាយពេលនេះ  ដោយខ្ញុំសង្កេតឃើញអ្នកខ្លះចង់ឲ្យគេគោរព ស្រឡាញ់រាប់អាន  តែអ្នកនោះ ធ្វើតែអំពើអ្វី ដែលមិនគួរឲ្យគេស្រឡាញ់រាប់អានបាន ដូចជា គិតតែប្រយោជន៍ផ្ទាល់ខ្លួន ចង់អ្នកណាស្លាប់ក៏ស្លាប់ទៅ  ឲ្យតែអាត្មាអញ គ្រួសារ អញ  មិត្តភក្តិអញ បានចម្រើន សុខសប្បាយ ។ ដូចអ្នកដឹកនាំប្រទេសខ្លះ មករំលោភ ឈ្លានពានប្រទេសទន់ខ្សោយជាងខ្លួន ដើម្បីប្រមូលទ្រព្យសម្បត្តិប្រទេសគេ យកទៅ ឲ្យប្រជារាស្ត្រខ្លួន ។  ចុះម្តេចក៏មិនគិតថា ប្រជារាស្ត្រយើងចង់សុខ ចម្រុងចម្រើន  ប្រជា រាស្ត្រគេ  ក៏ចង់សុខចម្រុងចម្រើនដែរ ។ បើគិតរបៀបនេះ   នោះយើងនិងគេ នឹងបាន សុខសប្បាយទាំងអស់គ្នា ។ ពីព្រោះថា បើយើងបានសុខ ហើយគេមិនបានសុខ  នោះមិន យូរ មិនឆាប់ យើងក៏នឹងមិនបានសុខដែរ ។

៥- ត្រូវស្គាល់ ហេតុ ផល

ធម៌ « ហេតុផល »  មានប្រយោជន៍ច្រើនក្នុងការដោះស្រាយចំណោទផ្សេងៗ ។

ដូចជាម៉ាស៊ីនរថយន្តខូច ដាងដើម្បីធ្វើម៉ាស៊ីនរថយន្តនោះឲ្យដើរឡើងវិញ ត្រូវស្គាល់

ហេតុ ដែលនាំឲ្យ ម៉ាស៊ីននោះមិនដើរ ។ ដោយម៉ាស៊ីនមិនចេះនិយាយ[32]ជាងត្រូវរកហេតុនោះឲ្យឃើញជាមុនសិនទើបអាចជួសជុលម៉ាស៊ីននោះបាន ។ ការរកហេតុនេះដោយពឹងផ្អែកទៅលើ ការសមហេតុ សមផល (ឬ ហេតុ បច្ច័យ) គឺ បើ « ក » => « ខ » => « គ » => « ឃ » នោះគេរកហេតុដើមដំបូង ដោយដេញមករកមូលហេតុ ដូចតទៅ ៖ គេសួរថាតើ « ឃ » (ម៉ាស៊ីនរថយន្តមិនឆេះ) មកពីហេតុអ្វី? ដល់រកទៅគេឃើញថា មកពី « គ »។ រួចហើយ គេសួរដេញតទៅទៀតថា តើ « គ » មានមកពីហេតុអ្វី? ដល់រកទៅគេឃើញថា មកពី « ខ »។ ហើយដល់សួរ ថា « ខ »ចេញមកពីណា? នោះគេឃើញថា មកពី « ក » ។ ដូច្នេះហេតុដែលធំ ដែលដំបូងគេ គឺ « ក » ។ បើកាលណាជាងនោះជួសជុល « ក » ទៅ ចំណោទនោះក៏ដោះស្រាយបានដូចបំណង ។ ការរកហេតុដើមនៃចំណោទខ្លះ មិនជាស្រួលទេ ។ ដូចសព្វថ្ងៃនេះ ចំណោទយុវជនអត់ការងារធ្វើ តើដោយហេតុអ្វី ជាដើម ។ តែក៏មានចំណោទជាច្រើនដែលអាចរកហេតុឃើញដោយមិនពិបាក ប្រសិនបើជាគេចង់ដោះស្រាយចំណោទនោះដោយចិត្តស្មោះត្រង់ពិតមែន។ ដូចជាចំណោទ អំពើពុករលួយ ជាដើម ។ យើងច្រើនសង្កេតឃើញនៅក្នុងប្រទេសក្រីក្រដែលប្រជាជនមិនសូវចេះដឹង មានអំពើពុករលួយ ច្រើនជាងប្រទេសជឿនលឿន។ បើអ្នកដឹកនាំប្រទេសក្រីក្រ ចង់ដោះស្រាយបញ្ហានោះដោយពិតប្រាកដ នោះគប្បីរកហេតុ ដែលនាំឲ្យមានអំពើពុករលួយតិច នៅក្នុងប្រទេសជឿនលឿន នឹងហេតុដែលនាំឲ្យមានអំពើពុករលួយច្រើន នៅប្រទេសក្រីក្រ ។
បន្ទាប់មក យើងយកហេតុទាំងពីរមកប្រៀបធៀបនឹងគ្នា តើហេតុទាំងពីរនោះ ខុសគ្នា

[32] មិនដូចគ្រូពេទ្យ ដែលសួរអ្នកជម្ងឺ ដែលចេះនិយាយ ។យ៉ាងនេះហើយក៏នៅធ្វើ រ៉ាឌីយោ (radio) ឬ ស្កានណែ (Scanner)ថែមទៀត ។

ត្រង់ណាខ្លះ ហើយយើងកែហេតុដែលនាំឲ្យមានអំពើពុករលួយទៅតាមនោះទៅ ។ ធ្វើរបៀបនេះ ត្រូវនឹងធម៌ព្រះពុទ្ធ ដែលថែងថា **ធម៌ទាំងឡាយកើតមកអំពីហេតុ កាលណាហេតុរលត់ ធម៌នោះក៏រលត់** ។ មុននឹងបញ្ចប់ អត្ថបទនេះ ខ្ញុំសូមដំណាលរឿងមួយដែលជារឿងពិត នៅភូមិខ្ញុំ ។ កាលនោះខ្ញុំនៅក្មេងនៅឡើយ មានប្ដីប្រពន្ធពីរនាក់ ប្ដីអាយុប្រហែល ២២ ឆ្នាំ ហើយប្រពន្ធ ប្រហែល ១៨ឆ្នាំ មានរូបរាង ស្អាតល្អទាំងពីរនាក់ ហើយរស់នៅជាមួយគ្នាដោយសុខសាន្ត ។ កាលដើមឡើយប្ដីធ្វើការនៅសហគ្រាសរដ្ឋ ឈ្មោះ SKD (Société Khmer de Distillerie) ដល់ក្រោយមក មកដើរកាណូតដឹកជញ្ជូនអីវ៉ាន់ មកលក់នៅភ្នំពេញ ។ ថ្ងៃមួយ ប្ដីនៅពេលបញ្ឆេះម៉ាស៊ីនកាណូតមិនឆេះ ក៏ខឹងហើយយកជើងទៅធាក់ម៉ាស៊ីនមួយជើងយ៉ាងខ្លាំង ក៏ធ្វើឲ្យរបួសជើង ។ ដល់ក្រោយមករបួសនោះក្លាយទៅជាដំបៅ រហូតដល់ទៅសុំឲ្យគ្រូពេទ្យកាត់ជើងនោះចេញ ។ ប្ដីនោះក្លាយទៅជាអ្នកពិការ រកទទួលទានដោយប៉ះកង់។ ប្រពន្ធគេក៏ឈប់ស្រឡាញ់លែងលះគ្នា ហើយគេក៏ទៅរៀបការជាមួយនឹងកម្លោះមួយនៅក្នុងភូមិដដែល ។ ខ្ញុំលើករឿងនេះមកនិទាន មកពីខ្ញុំពីក្មេង នៅរៀននៅសាលាមធ្យមសិក្សានៅឡើយ មានថ្ងៃមួយនោះខ្ញុំងើបពីព្រលឹម ដើម្បីមើលមេរៀនឡើងវិញ មុននឹងទៅសាលា ។ ដោយនៅស្រុកចំការ ត្រូវអុជចង្កៀងប្រេងកាត ដើម្បីមើលមេរៀន ដល់ខ្ញុំកេះ ដែកកេះចេះតែមិនឆេះ ខ្ញុំក៏បោកដែកកេះចោល។ ឪពុកខ្ញុំឮ ក៏ពោលថា « ទៅខឹងអីនឹងដែកកេះ ដែលជារបស់ឥតវិញ្ញាណ »។ នេះហើយដូចពាក្យចាស់លោកថា « ខឹងគោ វាយរទេះ » អត់ចំណេញបានតែខាត ដូចអ្នកពិការនោះ អស់ទាំងជើង អស់ទាំងប្រពន្ធក្មេង។

ដោយប្រើច្បាប់ **ធម៌ទាំងឡាយកើតមកអំពីហេតុ** ខ្ញុំចេះជួសជុលរបស់ដែលខូចបានច្រើន ដោយមិនចាំបាច់ហៅជាងមកធ្វើ ។ នេះកាលណាខ្ញុំអាចដោះបើកគំរប របស់នោះបាន ខ្ញុំមើលកន្លែងដែលវាខូច ហើយរកហេតុដែលនាំឲ្យខូច ។បើកាលណាខ្ញុំឃើញ

ហេតុហើយ នោះខ្ញុំអាចជួសជុលបាន ដោយមិនចាំបាច់ទៅទិញរបស់ថ្មីមកផ្លាស់ក៏មាន។ ដើម្បីបំបាត់អំពើពុករលួយបានដោយប្រសិទ្ធិភាព ទាល់តែបំបាត់ហេតុដើមដែលធ្វើឲ្យមនុស្សទូទៅច្រើនតែពុករលួយ ។ តាមខ្ញុំយល់មិនមែនយកច្បាប់ខាងផ្លូវលោកមកប្រើ ដូចជាពិន័យ ឬចាប់ដាក់គុកជាដើមនោះទេ តែត្រូវយកច្បាប់ខាងផ្លូវធម៌មកពន្យល់វិញ គឺធ្វើឲ្យអ្នកទាំងនោះយល់ដោយខ្លួនឯងថា ទ្រព្យសម្បត្តិលុយកាក់មាសពេជ្រ មិនផ្តល់ឲ្យមានសុភមង្គលរហូតទេ តែសុភមង្គលដែលពិតនោះ គឺកាលណាចិត្តយើងស្ងប់ មិនព្រួយបារម្ភ មិនដូចចិត្តពួកចោរ ឬពួករត់គ្រឿងញៀនជាដើម ។

<u>៦- ខ្លួនទីពឹងខ្លួន</u>

ដើម្បីកុំឲ្យខកចិត្ត មុននឹងធ្វើការអ្វីមួយ ត្រូវមើលកម្លាំងរបស់ខ្លួនជាមុនសិន កុំអាលសង្ឃឹមទៅលើកម្លាំងអ្នកដទៃ ។ ពោលគឺថា បើគេមិនជួយ ក៏ការរបស់យើងនៅតែដើរ គ្រាន់តែមិនបានលឿនដូចគេជួយ ។ ម្យ៉ាងទៀតទុកជាគេជួយ ក៏គេជួយបានតែមួយគ្រា ឬ ពីរគ្រាតែប៉ុណ្ណោះ គេមិនអាចជួយយើងរហូតទេ ។

<u>៧- ត្រូវដើរផ្លូវកណ្តាល</u>

ដើរផ្លូវកណ្តាល មិនមែនព្រោះតែ មិនច្បាស់ខ្លួនឯង ដូចជាការបោះឆ្នោតស (អត់យោបល់) នោះទេ ។ ពាក្យថា កណ្តាល គឺកុំឲ្យហួសជ្រុលពីម្ខាងទៅម្ខាង ដូចជាកុំឲ្យតឹងពេក កុំឲ្យធូរពេក ។ ព្រះពុទ្ធ មុននឹងបានត្រាស់ដឹង ព្រះអង្គកាន់តឹងពេក ធ្វើទុក្ខកិរិយា នោះទៅជារកធម៌សម្រេចនិព្វានមិនឃើញទៅវិញ ដល់ព្រះអង្គទ្រង់កាន់ផ្លូវកណ្តាលទើបរកធម៌នោះឃើញ។ ក្នុងជីវិតយើងរស់នៅសព្វថ្ងៃនេះ ក៏គប្បីដើរផ្លូវកណ្តាលនេះដែរ ។ មានអ្នកខ្លះខំធ្វើការងារខ្លាំងពេក ដល់ពេលចូលនិវត្ត ទៅជាមានជម្ងឺដោយបាក់កម្លាំង ។ អ្នកខ្លះដោយខ្លួនឯងខ្ជិលធ្វើការ ខ្វះការព្យាយាម និយាយថាធម៌ព្រះ មិនឲ្យលោភ ។ ពាក្យប្រៀនប្រដៅ ជា ក្បួនមួយទូទៅ ដើម្បីយកទៅអនុវត្ត

យើងត្រូវចេះយកមកតម្រូវតាមកម្លាំងយើងម្នាក់ៗ ។ ដូចអ្នកខ្លះគេលីបាវអង្ករទម្ងន់ ៥០ kg បាន ហើយបើយើងលីបានតែត្រឹម២៥ kg នោះទៅលីបាវទម្ងន់ ៥០ kg ដូចគេ ទៅជាមានគ្រោះថ្នាក់ដល់ខ្លួនយើងទៅវិញ ។

<u>៨- ត្រូវទទួលស្គាល់កំហុសរបស់ខ្លួន - សម្មប្បធាន៤</u>

មនុស្សយើង តែងតែមានកំហុស ។ មនុស្សដែលគ្មានកំហុសសោះពិបាកនឹងរកណាស់ ។ ដូច្នេះបើយើងធ្វើខុស មិនមានអ្វីប្លែកទេ ត្រូវហ៊ាន ទទួលស្គាល់កំហុសនោះ ដើម្បីនឹងកែទៅថ្ងៃមុខ ។ ធ្វើបែបនេះត្រូវនឹង ពាក្យទូន្មានរបស់ព្រះពុទ្ធក្នុងធម៌ សម្មប្បធាន៤ ដែលចែងថា ៖

១- ព្យាយាម កុំធ្វើតទៅទៀតនូវ អំពើអកុសល ដែលបានធ្វើហើយ ។

២- ព្យាយាម កុំធ្វើ អំពើអកុសលដែល មិនទាន់បានធ្វើ ។

៣- ព្យាយាម រក្សាអំពើកុសល ដែលបានធ្វើហើយ និង ខំធ្វើអំពើកុសលនោះតទៅទៀតឲ្យកាន់តែច្រើន។

៤- ព្យាយាម ខំធ្វើអំពើកុសលដែល មិនទាន់បានធ្វើ ។

<u>៩- គប្បីទទួលយកធម៌ព្រះពុទ្ធមកដាក់ក្នុងខ្លួនកុំបង្អែបង្អង់</u>

មានអ្នកខ្លះធ្វើបុណ្យប្រាថ្នាឲ្យបានជួបព្រះពុទ្ធអនាគត ព្រះនាម **មេត្រី** ។ ខ្ញុំសួរថា ចង់ជួបដើម្បី ប្រយោជន៍អ្វី ? បើថា « ចង់ជួបដើម្បីស្គាល់ធម៌ព្រះមេត្រី ឬ ដើម្បីទៅ អនាគតបានត្រាស់ជាព្រះពុទ្ធមួយអង្គ ឬ មួយដើម្បីបានសម្រេចជាព្រះអរហន្ត » នោះខ្ញុំសូមជូនយោបល់ដូចតទៅ ៖

1- <u>ចង់ស្គាល់ធម៌ព្រះ មេត្រី</u> សព្វថ្ងៃនេះយើងមានធម៌ព្រះពុទ្ធស្រាប់ហើយ ម្ដេចក៏ មិនខំរៀន មិនខំបដិបត្តិទៅ ? ម្ដេចក៏ទៅចាំរបស់ដែលមិនទាន់មកដល់ទៅវិញ ? ក្រែង

ដល់ពេលនោះមិនបានកើតជាមនុស្ស ហើយជួនកាលកើតជាមនុស្សហើយ ក៏អាចមិនជួបនឹងព្រះក៏មានដែរ ពីព្រោះប្រទេសឥណ្ឌាធំ ។ នៅជំនាន់ព្រះគោតម ក៏មានអ្នកខ្លះមិនបានជួបព្រះអង្គដែរ ពីព្រោះ រស់នៅឆ្ងាយពីកន្លែងដែលព្រះអង្គគង់នៅ ឬមួយមិនបានស្គាល់ធម៌ព្រះអង្គក៏មានដែរ ពីព្រោះមានមិច្ឆាទិដ្ឋិ ។

2- <u>ចង់បានត្រាស់ជាព្រះពុទ្ធ</u> បំណងនេះល្អបំផុត តែគប្បីចាប់ជួយប្រោសសត្វលោកចាប់ពីពេលនេះទៅ ពីព្រោះព្រះពុទ្ធគោតម ព្រះអង្គខំកសាងក៏ដើម្បីបានត្រាស់ដឹងនូវធម៌សម្រាប់ប្រោសសត្វលោកឲ្យរួចចាកទុក្ខដែរ ។ ឥឡូវនេះធម៌ប្រោសសត្វលោកឲ្យរួចចាកទុក្ខនោះមានហើយ ដូច្នេះគ្រាន់តែយកធម៌នោះទៅផ្សព្វផ្សាយពន្យល់ទៅក៏ដូចជាបានត្រាស់ជាព្រះពុទ្ធដែរ ។ ម្តេចចាំទាល់តែធម៌របស់យើងបានពូកែ ? គំនិតរបៀបនេះខ្ញុំធ្លាប់ជួបហើយនៅកន្លែងធ្វើការ ចំពោះមេៗខ្លះ ទាល់តែគំនិតរបស់គេដែលជាមេ បានគេយក បើគំនិតមកពីកូនចៅ គេមិនយកទេ ទុកជាល្អជាងគំនិតខ្លួនក៏ដោយ នេះហើយហៅថាអញ្ញនិយម ។

3- <u>ចង់បានសម្រេចជាព្រះអរហន្ត</u> សូមជំរាបថា កាលជំនាន់ព្រះពុទ្ធគោតម ក៏មានអ្នកដែលមិនបានសម្រេចជាព្រះអរហន្តដែរ ។ យើងឃើញសាវកព្រះខ្លះបានសម្រេចជាព្រះអរហន្តពិតមែន តែយើងដឹងទេ ការកសាងកាលពីអតីតជាតិនៃសាវកទាំងនោះ ? ឆ្លើយថាយើងពុំអាចដឹងទេ ។

រួមសេចក្តីទៅ នៅពេលនេះយើងមានសំណាងបានជួបនឹងធម៌ព្រះហើយ ត្រូវខំបដិបត្តិតាមធម៌ព្រះអង្គឲ្យបានជាប់ជានិច្ច ទាន់កម្លាំងស្មារតីនៅមាន ។

# ១៨

## ពាក្យមុននឹងបញ្ចប់

*មុននឹងបញ្ចប់សៀវភៅនេះ ដែលទាក់ទងនឹងរបៀបរស់នៅសព្វថ្ងៃ ខ្ញុំនឹកទៅកាលដែលខ្ញុំនៅក្មេង ។ ឪពុកខ្ញុំ គាត់បានទូន្មានខ្ញុំជាច្រើន ដូចជា ដាស់តឿនខ្ញុំកុំឲ្យចេះតែធ្វើតាមគេដោយល្ងីតល្ងង់ ជាដើម។ មានពេលមួយនោះ ដើម្បីដោះស្រាយកំហុសខ្ញុំៗ ឆ្លើយទៅឪពុកខ្ញុំថា ៖ « ខ្ញុំធ្វើតាមក្មេងនោះទេ » ឪពុកខ្ញុំក៏សួរមកខ្ញុំវិញថា « <u>បើគេស៊ីអាចម៍តើឯងស៊ីអាចម៍ដែរ ?</u> » ។ ពាក្យនេះថ្វីបើមិនពីរោះ តែមានប្រយោជន៍ដល់ខ្ញុំច្រើនក្នុងការរស់នៅមកដល់សព្វថ្ងៃនេះ ។ ធ្វើឲ្យខ្ញុំចេះគិត មិនចេះតែធ្វើតាមគេ ដោយមិនបានគិតឲ្យបានវែងឆ្ងាយនោះទេ ហើយដល់មានហេតុការគ្រោះថ្នាក់ ក៏ឆ្លើយដាក់គេឯង ។ ដូចក្មេងខ្លះចេះជក់បារីដោយមកពីធ្វើតាមគ្នាជាដើម ។ មកដល់សព្វថ្ងៃនេះ ខ្ញុំនៅតែអនុវត្តតាមសំដីឪពុកខ្ញុំដដែល ។ ខ្ញុំមិនងាយធ្វើតាមមិត្តភក្តិ ឬ អ្នកដទៃណាមួយទេ បើខ្ញុំមិនយល់ស្រប ។ ដូចជាខ្ញុំសុខចិត្ត ខាតលាភ ខាតយស កុំឲ្យតែខុសឧត្តមគតិ ឬសច្ចធម៌ដែលខ្ញុំខំថែរក្សាជាយូរមកហើយ ។ ខ្ញុំមានទម្លាប់ ដឹងគុណ អ្នកដែលគេធ្វើល្អមកលើខ្ញុំ មិនថាអ្នកតូច ឬ អ្នកធំទេ ។ ដូចជា លោកគ្រូបង្រៀន ចាប់ពីថ្នាក់កុមារដ្ឋានឡើងទៅដល់មហាវិទ្យាល័យ ទាំងខ្មែរ ទាំងបរទេសជាដើម ។*

*ដល់ខ្ញុំចូលនិវត្ត ខ្ញុំយកពាក្យ* ***អាចម៍*** *ដែលឪពុកខ្ញុំប្រើនេះ មកពិចារណាតទៅទៀត ពីព្រោះតាមន័យធម្មតា គឺលាមក គឺរបស់ដែលគេខ្ពើមរអើម គេដើរគេច គេមិនចង់ជួប ហើយរហូតដល់ ពីរនាក់ឈ្លោះគ្នា មានពេលខ្លះឲ្យអាចម៍គ្នាក៏មាន ។ មកដល់ត្រង់នេះ ខ្ញុំនឹកថា ពាក្យអាចម៍នេះ អាចមានន័យអាថ៌កំបាំង គឺមានន័យថា ជារបស់ដែលគេស្អប់*

មិនចូលចិត្ត មិនចង់ជួបប្រទះ ហើយបើជួបនាំឲ្យចិត្តគេថ្នាំងថ្នាក់ រួមសេចក្ដីទៅ នាំឲ្យគេមានទុក្ខ ។ បើក្នុងន័យនេះ ពាក្យដែលឪពុកខ្ញុំបានប្រដៅខ្ញុំនៅពេលនោះទៅជា ៖ « <u>បើគេធ្វើអំពើដែលនាំមកនូវសេចក្ដីទុក្ខ តើឯងធ្វើតាមគេដែរទេ ?</u> » ។ ដោយនិយមន័យរបស់ពាក្យ **បាប** គឺអំពើដែលនាំឲ្យមានទុក្ខ ដល់អ្នកដែលធ្វើ ឬ ដល់អ្នកដទៃ ឃ្លាខាងលើនេះទៅជា ៖ « <u>បើគេធ្វើអំពើ បាប តើឯងធ្វើបាបតាមគេដែរទេ ?</u> » ។

បន្ទាប់មក ដោយខ្ញុំស្រឡាញ់ឪពុកខ្ញុំ ខ្ញុំពុំមានឱកាសសងគុណគាត់ពេលគាត់នៅរស់ ខ្ញុំក៏ខំបដិបត្តិតាមឃ្លាទី៣ នេះ។ តើប្រតិបត្តិតាមរបៀបណា ? គឺខ្ញុំប្រតិបត្តិ តាមធម៌ព្រះពុទ្ធដែលមានចែងក្នុងន័យថា « យកទឹក ទៅលត់ភ្លើង » (កុំយកភ្លើង ទៅលត់ភ្លើង) ។ ដូចជាកាលពីប៉ុន្មានឆ្នាំមុននេះមាន លោក «ក» គាត់ស្អប់ខ្ញុំណាស់ ថ្វីបើខ្ញុំពុំដែលបានធ្វើអ្វីទៅលើគាត់ផង។ ដោយរឿងកើតមកពីហេតុដល់ក្រោយមកទើបខ្ញុំដឹងថាមកអំពីគាត់ច្រណែននឹងខ្ញុំ គាត់មិនចង់ឲ្យខ្ញុំមានមុខ មានមាត់ដូចគាត់ ។ ខ្ញុំអត់មានការភ្ញាក់ផ្អើលអ្វីនឹងការច្រណែននោះទេ ពីព្រោះមនុស្សបុថុជ្ជនច្រើនតែមានការច្រណែនជាធម្មតា ។ ចំណោទ គឺខ្ញុំត្រូវរករបៀបណា ដើម្បីបានសុខទាំងខ្ញុំផង បានសុខទាំងលោក «ក» ផង ។ ហេតុអ្វីបានជាខ្ញុំថាយ៉ាងនេះ ? ពីព្រោះកាលណាខ្ញុំច្រណែននឹងគេ ចិត្តខ្ញុំមិនបានសុខស្ងប់ទេ ដូច្នេះខ្ញុំដឹងថាលោក «ក» ក៏មានចិត្តមិនស្ងប់ដែរ ។ ហើយចំពោះខ្ញុំវិញ បើខ្ញុំខឹងនឹងលោក «ក» ក៏ចិត្តខ្ញុំមិនស្ងប់ដែរ ។ ហេតុនេះហើយបានជាខ្ញុំថាធ្វើយ៉ាងណាដើម្បី « បានសុខទាំងខ្ញុំ បានសុខទាំងលោក «ក» »។ មុនដំបូងខ្ញុំយកសុខខ្លួនខ្ញុំជាមុនហើយ ពីព្រោះខ្ញុំអាចប្រដៅខ្លួនខ្ញុំបាន តែអ្នកដទៃខ្ញុំមិនហ៊ានទេ ។ ខ្ញុំប្រដៅខ្លួនខ្ញុំដោយពិចារណាដូចតទៅនេះ ៖

លោក «ក» គាត់ច្រណែនខ្ញុំ គាត់ស្អប់ខ្ញុំ ដូច្នេះគាត់បាបហើយ (ពីព្រោះគាត់កើតទុក្ខនៅក្នុងចិត្តព្រោះតែការច្រណែន) ។ បើខ្ញុំខឹងនឹងគាត់ ស្អប់គាត់ ខ្ញុំនឹងបាបដូចគាត់ដែរ

ពីព្រោះខ្ញុំកើតទុក្ខដោយមួម៉ៅក្នុងចិត្ត ។ ដូច្នេះ ដើម្បីគោរពតាមពាក្យឪពុក ខ្ញុំៗ មិនត្រូវខឹងនឹងគាត់ទេ គឺថា « បើគាត់ធ្វើបាបហើយ ខ្ញុំមិនធ្វើបាបតាមគាត់ទេ » ។ ខ្ញុំត្រូវខំធ្វើយ៉ាងណាឲ្យគាត់ត្រឡប់មកស្រឡាញ់ខ្ញុំវិញ ដូចជាជួយគាត់កាលណាគាត់ត្រូវការពឹងពាក់ ឬ ធ្វើអ្វីដែលជាប្រយោជន៍ដល់គាត់ ហើយមិនខុសច្បាប់ ជាដើម ។

ខ្ញុំកាលនៅពីក្មេង ធ្វើខុសក៏ច្រើន ហើយខ្ញុំឆ្ងល់ក៏ច្រើន តែឪពុកខ្ញុំគាត់មានពេលពន្យល់ខ្ញុំជានិច្ច ។ មានពេលមួយនោះដោយខ្ញុំចេះតែធ្វើខុសច្រើនពេក ផ្នែកនេះខុស ផ្នែកនោះខុស ខ្ញុំក៏សួរទៅឪពុកខ្ញុំថា ចុះហេតុអ្វីបានខ្ញុំធ្វើខុស ច្រើនជាងធ្វើត្រូវ ? ឪពុកខ្ញុំឆ្លើយថា មកពីត្រូវមានតែមួយ ក្រៅពីនោះខុសទាំងអស់ ។ ចម្លើយឪពុកខ្ញុំនេះមើលតែចម្លើយ ក្នុងគណិតសាស្ត្រ ដែលលោកគ្រូឲ្យកូនសិស្សបូកលេខ ( 2 + 2 ) តើត្រូវជាប៉ុន្មាន ? ហើយបើកូនសិស្សឆ្លើយខុសពី ៤ នោះគឺខុសទាំងអស់ ។ ថ្ងៃមួយ ខ្ញុំបាននិយាយពីមិត្តនៅក្នុងថ្នាក់ខ្ញុំម្នាក់ នៅមុខឪពុកខ្ញុំ ថា « សារិក[33] វាចេះតែព្រួយចិត្ត ដោយវាឃើញឪពុកវា ថ្វីបើជាគ្រូបង្រៀនក៏ដោយ គាត់មានបន្ទុកច្រើន » ។ ឪពុកខ្ញុំឆ្លើយថា « សារិក វាគិតយ៉ាងហ្នឹងខុសហើយ ព្រោះទោះបីវាគិតយ៉ាងណា ក៏វាជួយគាត់ មិនបានដែរ ដូច្នេះត្រូវគិតតែខំរៀនទៅ ដល់យើងធ្វើការបានប្រាក់ខែ នៅពេលនោះយើងអាចជួយគាត់បាន » ។ សំដីឪពុកខ្ញុំនេះ មានប្រយោជន៍ច្រើនចំពោះខ្ញុំរហូតមកដល់សព្វថ្ងៃនេះ គឺចំពោះខ្ញុំ អ្វីដែលខ្ញុំមើលទៅ ឈោងមិនដល់ ខ្ញុំឈប់គិត តែខ្ញុំរករបៀបដោះស្រាយផ្សេងទៀត ពីព្រោះការដោះស្រាយនូវចំណោទនីមួយៗ មានរបៀបច្រើន ។ ម្យ៉ាងទៀត ចំពោះការងារ (ឬ នយោបាយ) បើខ្ញុំមើលមិនទាន់ឃើញច្បាស់ថានៅ

[33] ខ្ញុំនិយាយឈ្មោះវាចំ ពីព្រោះវាស្លាប់ដាច់ពូជទាំងឪពុកម្ដាយ បងប្អូន កូនប្រពន្ធ និងក្មួយៗ អត់សល់ទេ នៅពេលប៉ុលពត ហើយវាជាមិត្តរបស់ខ្ញុំដែលកម្ររកបាន។ ធ្វើបុណ្យម្ដងៗ ខ្ញុំ តែងតែបញ្ជូនកុសលទៅវា និង មិត្តខ្ញុំម្នាក់ទៀត ។ ខ្ញុំមិនសូវមានមិត្តទេ។

**ទីបំផុត**នឹងបានលទ្ធផលយ៉ាងនេះឬយ៉ាងនោះទេ នោះខ្ញុំមិនទាន់ចាប់ផ្តើមការងារនោះទេ ខ្ញុំត្រូវគិតតទៅទៀត ឬក៏ប្តូរគំនិតថ្មី ។ ដោយធ្វើរបៀបនេះ ការងារដែលខ្ញុំបានទទួលធ្វើទាំងប៉ុន្មាន មិនដែលត្រូវបោះបង់ចោលកណ្តាលផ្លូវ ឬ ក៏ស្ទះរកច្រកចេញមិនរួចនោះទេ ។ ដូចពាក្យចាស់លោកថា « ចាប់ច្រវា សំដៅត្រើយ » ពោលគឺថា ទាល់តែឃើញត្រើយច្បាស់ បានចាប់ច្រវា យកមករុំទូកឆ្ពោះត្រង់ទៅត្រើយ។

ខ្ញុំសូមបញ្ចប់សំណួរ និងចម្លើយ រវាង ខ្ញុំ និង ឪពុកខ្ញុំតែប៉ុណ្ណេះ ។

សព្វថ្ងៃនេះ នៅពេលខ្លះដែលខ្ញុំបានសុខស្ងប់ ខ្ញុំនឹកទៅគុណព្រះពុទ្ធដោយលើកដៃប្រណម្យពីព្រោះដោយសារពាក្យដំបូន្មានរបស់ព្រះអង្គនេះហើយ បានជាខ្ញុំបានសុខបានស្ងប់ដូច្នេះ។

មានរឿងមួយទៀតដែលខ្ញុំចង់ជម្រាបដែរ គឺកាលខ្ញុំនៅក្មេង ខ្ញុំយល់ថា «ខ្ញុំខំរៀនសូត្រដើម្បីឲ្យឪពុកម្តាយខ្ញុំ សប្បាយចិត្តនឹងខ្ញុំ » ។ ដល់ពេលក្រោយមកបានខ្ញុំដឹងថាការខំរៀនសូត្រក្តី ឬ ការធ្វើកុសលក្តី គឺដើម្បីខ្លួនយើងទេ មិនមែនដើម្បីម៉ែឪ ឬក៏ដើម្បីព្រះពុទ្ធនោះឡើយ។ ពីព្រោះថាអ្នកណាធ្វើ អ្នកនោះជាអ្នកទទួលផល ។

នៅពេលខ្ញុំធ្វើការស៊ីឈ្នួលគេ ខ្ញុំតែងតែមានចិត្តស្មោះត្រង់នឹង ថៅកែ ចៅហ្វាយរបស់ខ្ញុំ ពីព្រោះថា សេចក្តីសុខរបស់ខ្ញុំ តែងតែជាប់ទាក់ទងនឹងសេចក្តីសុខរបស់ថៅកែ ចៅហ្វាយរបស់ខ្ញុំ ។ ខ្ញុំស្រឡាញ់ការងារដែលគេប្រគល់ឲ្យធ្វើ ។ ខ្ញុំធ្វើដោយយកចិត្តទុកដាក់ ដោយមិនគិតចង់បានរង្វាន់ទៅថ្ងៃមុខ ដូចអ្នកធ្វើបុណ្យខ្លះ ដែលគេធ្វើបុណ្យដោយមិនគិតចង់បានឈ្មោះ ឬ ចង់បានទៅកើតនៅស្ថានសួគ៌ជាដើម។ ដោយគ្មានបំណង លោភលន់យ៉ាងនេះ ចិត្តខ្ញុំក៏ស្ងប់ សប្បាយតែនឹងកិច្ចការដែលកំពុងធ្វើ ។ លទ្ធផល គឺ ខ្ញុំធ្វើកិច្ចការបានហើយសព្វគ្រប់មុនពេលកំណត់ ហើយល្អទៀត។ មានពេលមួយនោះខ្ញុំទំនេរគ្មាន

កិច្ចការជំជុំធ្វើ  ខ្ញុំក៏មានពេលគិតទៅលើសេចក្តីត្រូវការទៅថ្ងៃមុខ  ក្នុងតំបន់ពួកខ្ញុំ ។ នេះក៏ជាមេរៀនមួយ ចំពោះអ្នកដឹកនាំ ដែលត្រូវមើលឲ្យបានវែងឆ្ងាយ  ឧបមាដូចជា តើថ្ងៃមុខ ការវិវឌ្ឍន៍នឹងទៅដល់ណា ?  យើងនឹងត្រូវការធ្វើអ្វីថែមទៀត ដើម្បីឲ្យមុខរបរ យើង ដើរទាន់គេ ឬ ក៏ទៅលឿនជាងគេ ..។ល។

ដោយមានគំនិតបែបនេះ ខ្ញុំក៏ឆ្លៀតពេលដែលខ្ញុំទំនេរនោះ ធ្វើការសិក្សាអំពីរបៀប ឲ្យម៉ាស៊ីនជួយកែកំហុសមនុស្ស  នៅពេលមនុស្ស សរសេរ  ចំឡង ឬ កត់ចូលក្នុង ordinateur  នូវពត៌មាននានា (ឬទិន្នន័យ : données) ។ ដល់ខ្ញុំគិតរួចហើយ ខ្ញុំក៏យកគំរោង នោះទៅស្នើដល់ថៅហ្វាយខ្ញុំ ៗ ក៏យល់ព្រម ហើយយកទៅស្នើថ្នាក់លើតទៅទៀត ។ សូមជំរាបថា គម្រោងនោះ គឺចេញមកពីគំនិតខ្ញុំផ្ទាល់ ឥតមានថៅហ្វាយណាប្រើ ឬ នឹក ឃើញធ្វើបែបនោះទេ ។ តែដោយខ្ញុំចូលចិត្តគិតមិនចេះនៅទំនេរ  ខ្ញុំមើលឃើញសេចក្តី ត្រូវការទៅថ្ងៃមុខ  ក៏រករបៀបដោះស្រាយសេចក្តីត្រូវការនោះនៅពេលទំនេរនោះទៅ ។ មកដល់ថ្ងៃនេះ (ឆ្នាំ ២០១៦) របស់ដែលខ្ញុំបានបង្កើតកាលពីឆ្នាំ ១៩៩៣ គេនៅប្រើនៅ ឡើយ ។ ពោលគឺរបស់នោះ មានអាយុជាង ២០ ឆ្នាំ  ហើយសហគ្រាសខ្ញុំនៅតែប្រើ ថ្វីបើខ្ញុំបានចូលនិវត្តជិត១៥ឆ្នាំរួចមកហើយ ។

របស់ដែលខ្ញុំបានបង្កើតនោះឈ្មោះ CX099 ។ គេប្រើវានៅពេលគេត្រូវការបញ្ចូល ទិន្នន័យ (données) ថ្មីៗ ទៅក្នុងកូមព្យូទ័រ ឬ ក៏កែនូវទិន្នន័យចាស់ដែលគេបានបញ្ចូល ហើយ ។ ពីព្រោះពត៌មានទាំងឡាយ ត្រូវបំពេញលក្ខខណ្ឌសមហេតុសមផលផង និងស្របតាមច្បាប់រដ្ឋផង។

-ក្នុងន័យនេះ វាអាច ត្រួតពិនិត្យគ្រប់ទិន្នន័យ  ទោះបីលក្ខខណ្ឌនៃទិន្នន័យ នោះស្មុគស្មាញក៏ដោយ ។  -បើគេបញ្ចូលពត៌មានខុស វាប្រាប់នូវហេតុនៃកំហុសនោះ។ -វាអាចទទួលទិន្នន័យថ្មីបាន។ តែទិន្នន័យថ្មី មិនអាចកែរុះរើ ទិន្នន័យចាស់បានឡើយ។

អ្នកប្រើមើលឃើញតែទិន្នន័យដែលខ្លួនត្រូវការ និងទិន្នន័យខ្លះដែលជាប់ទាក់ទងគ្នា តែប៉ុណ្ណោះ ថ្វីបើនៅក្នុង CX099នោះ មានទិន្នន័យច្រើនរាប់រយក៏ដោយ ។

ឥឡូវនេះ ជាសម័យ internet, iPhone, Apple ដូច្នេះ ដោយអ្វីៗ សុទ្ធតែមិនទៀង នោះ CX099 ក៏ត្រូវកែទម្រង់ទៅតាមសម័យនឹងគេដែរ ។ តែកែតែសំបកក្រៅទេ ចំពោះគ្រឿងខាងក្នុង គឺ គំនិតធំៗ ទ្រឹស្តី និងរបៀបធ្វើ របស់ខ្ញុំ កាលពី ២០ឆ្នាំមុន នៅដដែល។

មកដល់ឆ្នាំ២០១៤ហើយ តាមសេចក្តីរាយការណ៍ គេថា CX099 ជាចម្លើយមួយដ៏ « សព្វគ្រប់ » ចំពោះអ្នកធ្វើការនៅមុខភ្លៀវ ឬ នៅកំបាំងភ្លៀវ (CX099 est une solution « trouve tout » pour le réseau et pour les backs) ។

ខ្ញុំនិយាយនេះដើម្បីឲ្យខ្មែរយើងខ្លះ កុំចេះតែបន្ទាបជាតិយើង ហើយលើកតម្កើងជាតិដទៃ។ រហូតពេលខ្លះ មិនហ៊ានប្រាប់គេថាខ្លួនជាខ្មែរទេ ព្រោះខ្មាចអន់ ។ ខ្ញុំក៏ធ្លាប់មានជនស្បែកសគេធ្វើការជាមួយដែរ មានអ្នកខ្លះ គេមិនមើលងាយយើងទេ តែគេច្រណែននឹងយើង ជាពិសេសយើងមកនៅស្រុកគេ ហើយយើងមានយសស័ក្តិខ្ពស់ជាងគេ ។ តែពួកគេក៏អាចមើលងាយយើងដែរ មិនថាតែខ្មែរ ឬ ជាតិដទៃទេ បើកាលណាយើងមាន ចរិយា មារយាទមិនសមរម្យ បោកបញ្ឆោតគេ ជាដើម ។ សូមកុំភ្លេចពាក្យចាស់លោកថា « ចេះមកពីរៀន មានមកពីរក » ។ ប្រាជ្ញាក៏កើតមកពីរៀនដែរ អ្នកខ្លះកើតមកមានប្រាជ្ញាជាដើមទុន តែបើមិនខំរៀនតទៅទៀតទេ នោះប្រាជ្ញានៅត្រឹមតែត្រឹមហ្នឹងហើយ មិនថាខ្មែរ ឬ បរទេសទេ ។

ខ្ញុំសូមលោកអ្នក អភ័យទោសទុកជាមុន ដោយបន្ទាប់ទៅនេះ ខ្ញុំសូមបង្ហាញ CX099 ជាភាសាបារាំង។ នេះទុកជាស្នាដៃកូនខ្មែរមួយរូប ដែលធ្វើការស៊ីឈ្នួលឲ្យបារាំង នៅ

ក្រុងបារីស នៅពេលនិរាសពីមាតុប្រទេស ដោយបង្ខំចិត្ត។ ពត៌មានពី CX099នេះ គឺមិត្តបារាំងម្នាក់ ជាអតីតសហការីខ្ញុំ គេបានផ្ញើរមកឲ្យខ្ញុំកាលពីឆ្នាំ ២០១៥ នៅពេលដែលខ្ញុំសួរដំណឹង ពី CX099។ មិត្តនោះគេនៅធ្វើការនៅឡើយ មិនទាន់ចូលនិវត្តដូចខ្ញុំទេ ។

ជាទីបញ្ចប់ ខ្ញុំសូមអរគុណ លោកអ្នកដែលខំអានសៀវភៅខ្ញុំនេះរហូតដល់ចប់ ។ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មុននឹងសម្រេចចិត្ត ឬ ធ្វើកិច្ចការអ្វីនីមួយៗ ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី សូមកុំភ្លេចប្រើបញ្ញាលោកអ្នក សូមកុំភ្លេចធ្វើការប្រៀបធៀប ចិត្តលោកអ្នក នឹងចិត្តអ្នកដទៃ ។ ពីព្រោះថា មនុស្សគ្រប់រូប មិនថាយើង មិនថាគេទេ សុទ្ធតែចង់បានសុខចម្រុងចម្រើន ហើយមិនចង់ជួបទុក្ខលំបាកទេ ។ មានពាក្យបារាំងមួយឃ្លាថា ៖ « **ចូរកុំធ្វើទៅលើអ្នកដទៃ នូវអ្វីៗដែលអ្នកមិនចង់ឲ្យគេធ្វើមកលើអ្នក** »។ មកដល់ត្រង់នេះខ្ញុំនឹកទៅដល់អ្នកដឹកនាំប្រទេសខ្លះ នៅពេលប្រទេសខ្លួន ត្រូវប្រទេសមហាអំណាចមកជិះជាន់ ក៏ស្រែកសុំឲ្យប្រទេសដទៃមកជួយ ដូចជាប្រទេសវៀតណាម កាលដែលត្រូវសហរដ្ឋអាមេរិកមកជិះជាន់ធ្វើសង្គ្រាមដោយកម្លាំងអាវុធ ត្រូវបានប្រជារាស្ត្រអាមេរិកកាំងបះបោរប្រឆាំងនឹងអ្នកដឹកនាំខ្លួន ហើយ បង្ខំឲ្យបញ្ឈប់សង្គ្រាមភ្លាម ។ ក្រោយមក ប្រទេសវៀតណាម ក៏បានសុខសន្តិភាពសម្បូរណ៍សប្បាយរហូតដល់សព្វថ្ងៃនេះ (ឆ្នាំ ២០១៧) ។ តែដល់ខ្លួនបានសុខសប្បាយហើយ ក៏ចាប់មកជិះជាន់ប្រទេសជិតខាងដែលមានកម្លាំងខ្សោយជាងខ្លួន ដូចជាប្រទេសខ្មែរយើងជាដើម ។ ម្តេចក៏វៀតណាម មិនគិតដល់កាលដែល ប្រទេសអាមេរិក មកជិះជាន់ប្រទេសខ្លួនផង តើកាលនោះ លោកអ្នកដឹកនាំមានការលំបាកចិត្តយ៉ាងណាដែរ ? ហើយឥឡូវនេះ ម្តេចក៏ឆាប់ភ្លេចម្ល៉េះ? លោកមកជិះជាន់ប្រទេសខ្មែរ តើប្រជារាស្ត្រខ្មែរគ្នាពិបាកចិត្ត ដូចកាលដែលលោកអ្នកត្រូវអាមេរិកាំងមកជិះជាន់នោះទេ ? ខ្ញុំសូមឲ្យ

លោកអ្នកដឹកនាំគ្រប់ប្រទេស យកឧទាហរណ៍នេះមកពិចារណាផង ដើម្បីឲ្យពិភពលោកយើងទាំងមូលបានសេចក្តីសុខសប្បាយទាំងអស់គ្នា ដូចសេចក្តីប្រាថ្នា ។

សូមជំរាបថា បើលោកអ្នកបានសុខ ហើយអ្នកដទៃមិនបានសុខ នោះសេចក្តីសុខលោកអ្នកនឹងមិនបានគង់វង់នៅយូរអង្វែងទេ ។ ប្រសិនបើលោកអ្នកបានសុខនៅពេលនេះ តែកូនចៅលោកអ្នកមិនច្បាស់ជាបានសុខដូចលោកអ្នកទេ ។ ប្រវត្តិសាស្ត្របានបង្ហាញរួចមកហើយ ។ ស្តេច Louis XIV បានសុខសប្បាយ ដល់ស្តេច Louis XVI ត្រូវការបដិវត្តន៍យកទៅកាត់ក ។ ហេតុនេះហើយបានជាថា « **លោកអ្នកជួយឲ្យគេបានសុខដូចលោកអ្នកជួយ ខ្លួន លោកអ្នក ឬ កូនចៅលោកអ្នក ឲ្យបានសុខដែរ** »។

ខ្ញុំសូមជូនគំនិតមួយទៀត ដែលខ្ញុំជឿជាក់ថានឹងនាំយើងទាំងអស់គ្នាទៅរកសេចក្តីសុខ ។ ការស្រឡាញ់ ប្រទេសរបស់ខ្លួន រៀងៗខ្លួន ជាការធម្មតាទេ នេះជាគំនិតស្នេហាជាតិនៃមនុស្សទូទៅ ។ តែដែលខ្ញុំមិនយល់ស្រប គឺការកេងប្រវ័ញ្ច យកទ្រព្យសម្បត្តិប្រទេសដទៃ មកឲ្យប្រទេសខ្លួន ។ ចំពោះមនុស្សយើងក៏ដូចគ្នាដែរ បើខំធ្វើការដើម្បីបានប្រាក់កាសដោយសម្មាអាជីវៈ ជាការធម្មតា តែដែលមិនធម្មតាគឺមានទ្រព្យដោយអំពើលួចប្លន់ ឬ រត់គ្រឿងញៀនជាដើម ។ កាលពីជំនាន់ដើម ប្រទេសធំៗខ្លះ ទៅធ្វើសង្គ្រាមវាតទឹកដី យកប្រទេសតូចតាចជាចំណុះ បង្គាប់ឲ្យលើកសួយសារអាករមកឲ្យខ្លួន ហើយខ្លួនមិនបាច់ខំធ្វើការងារទេ ចាំតែដេកស៊ីរាំច្រៀង ។ ធ្វើបែបនេះមិនខុសពីឯកជនខ្លះ ដែលធ្វើជាចោរដើរប្លន់អ្នកស្រុកដើម្បីធ្វើជាអ្នកមាន ។ តែឥឡូវនេះ អាណានិគមនិយម វាតយកទឹកដីគេឯង វាហួសសម័យហើយ ពីព្រោះមានអង្គការសហប្រជាជាតិជាអ្នករកយុត្តិធម៌ឲ្យ ហើយប្រទេសធំៗក៏គេផ្លាស់គំនិតដែរ[34] ។ តើផ្លាស់គំនិតបែបណា ? គឺគេយល់ថា ដើម្បីឲ្យប្រជារាស្ត្រគេសុខសប្បាយ ចម្រុងចម្រើន គឺមិនមែនធ្វើ

[34] នេះតាមការសង្កេតរបស់ខ្ញុំ តែក៏អាចមានអ្នកដឹកនាំប្រទេសខ្លះដោយ **លោភៈ**ចង់លួចប្លន់ទឹកដីទ្រព្យ

សង្គ្រាមវាតយកទឹកដីគេឯងនោះទេ តែត្រូវធ្វើឲ្យសេដ្ឋកិច្ចពិភពលោកយើងដើរ ដើម្បី ពាស្ត្រគេមានការងារធ្វើ មានឋានៈជីវភាពខ្ពង់ខ្ពស់ ។ ដូចជាប្រទេសចិន ប្រទេសជប៉ុន គេជួយប្រទេសខ្មែរយើងឲ្យចម្រើនលូតលាស់ ដល់រាស្ត្រខ្មែរខំធ្វើការងារមានលុយ នោះ នឹងត្រូវការទិញរបស់ប្រើប្រាស់ដែលប្រទេសគេធ្វើ ។ ដូច្នេះរាស្ត្រគេក៏មានការធ្វើ ដោយ លក់របស់មកឲ្យរាស្ត្រខ្មែរ ។ ដើម្បីឲ្យរបស់គេលក់បានថោក គេខំធ្វើការស្រាវជ្រាវ រក បច្ចេកទេសថ្មី ដើម្បីប្រកួតប្រជែងនឹងរបស់នៃប្រទេសផ្សេងៗទៀតលើឆាកអន្តរជាតិ ។ ដូច្នេះគេឈប់ធ្វើសង្គ្រាមដោយអាវុធហើយ តែគេធ្វើសង្គ្រាមសេដ្ឋកិច្ចវិញ។ កាលពី ដើមប្រទេសបារាំង ទៅគ្រប់គ្រងប្រទេសអាហ្វ្រិក (Afrique) ខ្លះដោយអាវុធ ។ ឥឡូវនេះ ប្រទេសចិនទៅរកផ្សារសម្រាប់លក់របស់គេ ដោយទៅជួយធ្វើថ្នល់ ធ្វើស្ពាន នៅប្រទេស ទាំងនោះទៅវិញ ។ ចិនគេបញ្ជូនទាំងវិស្វករគេឲ្យទៅធ្វើការនៅប្រទេសទាំងនោះ ទៀតផង ។ បើយើងគិតជាបុណ្យបាបវិញ សង្គ្រាមសេដ្ឋកិច្ចនេះ មានប្រយោជន៍ ទាំងសងខាង គឺ ទាំងប្រទេសដែលទន់ខ្សោយនិងទាំងប្រទេសដែលជឿនលឿនដូចជា ប្រទេសចិនឬ ជប៉ុនជាដើម ហើយបានសុខសប្បាយទាំងអស់គ្នាទៀត ដូច្នេះ ជាបុណ្យ ជាកុសលហើយ ។ គំនិតមួយទៀតដែលខ្មែរយើងគួរដូរដែរ គឺការលាក់ការចេះដឹង ដូចជាគ្រូមិនហ៊ានបង្រៀនសិស្សឲ្យអស់ចំណេះរបស់ខ្លួនទេ ដោយខ្លាចសិស្ស ពូកែជាងគ្រូ ហើយមកធ្វើបាបគ្រូវិញ ។ រឿងសិស្សធ្វើបាបគ្រូ ឬ គ្រូធ្វើបាបសិស្សនេះ ប្រសិនបើជាមានក៏មានមិនច្រើនដែរ ។ដូចជារឿង អង្គុលីមាល គឺគ្រូចង់ឲ្យគេសម្លាប់

សម្បត្តិប្រទេសទន់ខ្សោយដែរ ។ តែប្រទេសទាំងនោះគេក៏មិនភ្លេចខ្លួនដែរ ។ ដូចពាក្យស្លោកមួយថា « អ្នក ណាចង់បានសុខសន្តិភាព ត្រូវរៀបចំចម្បាំង » (Qui veut la paix prépare la guerre) ។ ប្រទេសដែល ស្រឡាញ់សន្តិភាព ទាំងអស់ គប្បីរួមកម្លាំងគ្នា ដើម្បីកុំឲ្យ ប្រទេសត្មាតស៊ីមិនចេះឆ្អែតនោះ វាហ៊ានមក ឈ្លានពានធ្វើបាបគេឯង ។

សិស្សអង្គុលីមាល ក៏បង្គាប់ឲ្យអង្គុលីមាលទៅរកម្រាមដៃឲ្យបាន១០០០ មកឲ្យគាត់ ។ តែតាមខ្ញុំយល់ ការលាក់ចំណេះ គឺនាំឲ្យខាតប្រយោជន៍ដល់កូនខ្មែរជំនាន់ក្រោយ ធ្វើឲ្យការចេះដឹងរបស់ដូនតាយើងចេះតែបាត់បង់បន្តិចម្តងៗ ។ ឧបមា គ្រូចេះ១០ មកដល់សិស្សចេះតែ ៩ ហើយ ដល់សិស្ស របស់សិស្ស ចេះតែ ៨ ដូច្នេះដល់យូរៗ ទៅវិជ្ជានោះក៏រលាយសាបសូន្យបាត់អស់គ្មានសល់ ។ តែកុំភ្លេចថា ចំណេះខ្លះមិនមែនតែយើងទេដែលចេះ ។ បើខ្មែរយើងចេះក៏អាចមានប្រទេសដទៃគេមានអ្នកប្រាជ្ញគេ គេរកឃើញដូចយើងដែរ ។ ហើយបើយើងរវល់តែលាក់នឹងគ្នាយើង ហើយគេៗមិនលាក់នឹងកូនចៅគេ នោះយើងទៅជាដើរក្រោយគេវិញហើយ ។ ដូចសព្វថ្ងៃនេះ ប្រទេសខ្លះ គេលក់បច្ចេកទេសដែលគេមានឲ្យទៅប្រទេសដទៃ ហើយគេក៏ចាប់រកបច្ចេកទេសថ្មីតទៅទៀត ។ ធ្វើយ៉ាងនេះគេអាចទាញយកផលពីចំណេះដែលគេមាន ពីព្រោះបើអ្នកដទៃគេរកឃើញដែរនោះ របស់ដែលខំលាក់នោះ អ្នកដទៃគេឈប់ត្រូវការហើយ ។ សព្វថ្ងៃនេះប្រទេសដែលលក់ ទាំងគ្រឿងប្រដាប់ផង ទាំងបច្ចេកទេសផង មានសហរដ្ឋអាមេរិក ប្រទេសអាល្លឺម៉ង់ ប្រទេសបារាំងជាដើម ។

ដោយសៀវភៅនេះ ជាសៀវភៅចុងក្រោយរបស់ខ្ញុំ ខ្ញុំសូមជំរាបមកលោកអ្នកនយោបាយ គ្រប់ជំនាន់ សូមមេត្តាគិតទៅដល់ប្រជារាស្ត្រខ្មែរ ស្លូតត្រង់ ដែលសូមតែសេចក្តីសុខចំរើន ដោយសម្មាអាជីវោ ។ បើលោកមានចិត្ត អាណិតអាសូរដល់បងប្អូនរួមជាតិយើង ដោយស្មោះត្រង់ សូមលោកធ្វើយ៉ាងណា ឲ្យប្រទេសជាតិយើងបានសុខសប្បាយ ចំរុងចម្រើន និងសន្តិភាពផង ។ ខ្ញុំបានស្គាល់ហើយ ការទុក្ខលំបាកមកតែពីការបែកបាក់គ្នារវាងលោកអ្នកដឹកនាំខ្មែរ ដោយមកតែពីមិនស្គាល់អ្នកណាជាមិត្តនឹងយើង អ្នកណាជាសត្រូវរបស់យើងដោយច្បាស់លាស់ ។ច្រើនទុកចិត្តលើបរទេស ជាងទុកចិត្តលើខ្មែរដូចគ្នា ។ តាមពាក្យរបស់អតីតរដ្ឋមន្ត្រីក្រសួងការបរទេស

នៃសហភាពសូវៀត (U.R.S.S.) ក្នុងសៀវភៅដែលលោកបានបោះពុម្ពផ្សាយក្រោយពីលាពីដំណែង មានពាក្យមួយឃ្លាដែលគួរយកមកពិចារណា គឺ « គ្មានអ្នកណាគេស្រឡាញ់ ប្រទេសយើង ជាងប្រទេសរបស់គេនោះទេ »។ បើយើងគិតបន្តិចទៅ យើងឃើញថាមិនមានអ្វីប្លែកទេ ។ ពីព្រោះប្រទេសនីមួយៗ គេធ្វើការដើម្បីប្រយោជន៍ដល់ប្រទេសគេ ដល់ប្រជារាស្ត្រគេ ។
ប្រសិនបើជាគេមកជួយយើង ទាល់តែមានប្រយោជន៍ដល់គេដែរ ទើបគេហ៊ានចំណាយទ្រព្យសម្បត្តិប្រទេសគេ មកជួយប្រទេសយើង ឬមួយកាលណាប្រយោជន៍គេនិងប្រយោជន៍យើងស្របគ្នា។ ដូចពេលសង្គ្រាមលោកលើកទីពីរ ប្រទេសអង់គ្លេស សហរដ្ឋអាមេរិក មកជួយប្រទេសបារាំង ដើម្បីយកជ័យជំនះលើប្រទេស អាឡឺម៉ង់ ជាដើម ។ លោកគ័រប៉ាឆែវ (GORBATCHEV) អតីតអ្នកដឹកនាំសហភាពសូវៀត បានសរសេរថា « ការបែកបាក់គ្នានៃពួកយើង ជាអំណោយមួយដ៏ធំដែលពួកយើងអាចជូនទៅ គូសត្រូវ[35] នៃយើង » ។ Il m’est souvent arrivé de dire aux partisans de la démocratie que leurs divisions étaient le plus grand cadeau qu’ils pouvaient faire aux adversaires des réformes. (Mikhail GORBATCHEV – année 1991).

ការពិចារណា រឿយៗ នូវធម៌ **កើត-រលត់** នាំឲ្យចិត្តយើងបរិសុទ្ធ មិនចង់បានទ្រព្យអ្នកដទៃ ពីព្រោះថា របស់ណាដែល (កើត-រលត់)ៗ របស់នោះ អាច រលត់ហើយ ក៏ ឈប់កើតក៏មាន ហើយបើសិនជាកើតឡើងវិញម្តងទៀត ក៏អាចខុសពីមុនក៏មាន ។ ដូចជាមនុស្សយើងសព្វថ្ងៃនេះ ដល់ស្លាប់ទៅ បើកើតម្តងទៀត អាចមិនចាប់កំណើតជាមនុស្សក៏មាន ។

35 សូមយល់ទៅតាមពេលវេលា បើរវាងខ្មែរនិងខ្មែរ គឺ គូប្រជែង បើរវាងប្រទេសនិងប្រទេសគឺ គូសត្រូវ ។

ដោយខ្ញុំជឿជាក់ថាអំពើល្អដែលខ្ញុំបានធ្វើដោយសរសេរសៀវភៅធម៌នេះ ខ្ញុំនឹងបាន កុសលដ៏ច្រើន ខ្ញុំសូមចែករំលែកកុសលនោះជូនលោកអ្នកអានគ្រប់ៗរូប ចូរលោកអ្នក អនុមោទនាទទួលយកដោយចិត្តសោមនស្សរីករាយរៀងៗខ្លួនចុះ។ ហើយសូមឲ្យលោក អ្នកបានប្រកបដោយពុទ្ធពរទាំង៤ ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** និងមានបញ្ញា ដូចព្រះមហោសថ និងនាងអមរា កុំឲ្យឃ្លៀងឃ្លាតឡើយ ។

## ជីវប្រវត្តិអ្នកនិពន្ធ

| ពុទ្ធំ សរណំ គច្ឆាមិ | ធម្មំ សរណំ គច្ឆាមិ | សង្ឃំ សរណំ គច្ឆាមិ |
|---|---|---|
| *ខ្ញុំព្រះករុណា សូមដល់នូវ*<br>**ព្រះពុទ្ធ**<br>*ជាទីពឹងទីរលឹក* | *ខ្ញុំព្រះករុណា សូមដល់នូវ*<br>**ព្រះធម៌**<br>*ជាទីពឹងទីរលឹក* | *ខ្ញុំព្រះករុណាសូមដល់នូវ*<br>**ព្រះសង្ឃ**<br>*ជាទីពឹងទីរលឹក* |



*អាន តាງគីម កើតនៅថ្ងៃសុក្រ ១កើតខែជេស្ឋ ឆ្នាំមមី ត្រូវនឹងថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៤២ នៅឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា ។ ឪពុកឈ្មោះ អាន ស៊ុនហេង ម្ដាយឈ្មោះ អ៊ា គិមអេង របររកចិញ្ចឹមជីវិត លក់ដូរគ្រឿងឧបភោគ បរិភោគ។ កាលនៅកុមារភាព បានរៀនអក្សរខ្មែរ ចេះមើលសាត្រាស្លឹករឹត ដោយនៅវត្ត មង្គលសត្ថាវ៉ន ភូមិព្រែកតាគង់ ឃុំព្រែកតាសេក ស្រុកមុខកំពូល ខេត្តកណ្ដាល។ ដល់ អាយុ៩ឆ្នាំ មានបង្កើតសាលាបឋមសិក្សា នៅ ឃុំព្រែកលៀប ទើបបានមកសុំចូលរៀន*

នៅថ្នាក់ បរិវិច្ចនដ្ឋាន (cours préparatoire) ។ ដល់អាយុ ១២ឆ្នាំ ពេលវិស្សមកាល បានបួសជាសាមណេរ នៅវត្ត មង្គលសត្ថាវ័នហើយ ចាកសិក្ខា មុនពេលចាប់ផ្តើម ឆ្នាំសិក្សាថ្មី ។ ជាមួយគ្នានោះ បានប្តូរសាលា មករៀននៅសាលាបឋមសិក្សាឫស្សីកែវ សង្កាត់លេខ១ ក្រុងភ្នំពេញ ។ ដល់បានជាប់ សញ្ញាប័ត្រ បឋមសិក្សាហើយ ដោយប្រឡងប្រជែងចូលថ្នាក់ទី៦ នៃវិទ្យាល័យ ស៊ីសុវត្ថិ មិនជាប់ ក៏មករៀន នៅសាលាឯកជនខាងគ្រិស្តសាសនា (école Miche) រហូតដល់ជាប់ សញ្ញាបត្រ័មធ្យមសិក្សា (diplôme de l’enseignement secondaire) ទើបមានច្បាប់សុំចូលរៀននៅថ្នាក់ទី ២ (classe de seconde) នៃវិទ្យាល័យ ស៊ីសុវត្ថិ ដោយមិនចាំបាច់ប្រឡងចូល ។

សូមជំរាបថា កាលខ្ញុំរៀននៅ សាលា Miche លោកគ្រូដែលជាអ្នកបួសក្នុងគ្រិស្តសាសនា នៅឆ្នាំដំបូង គាត់ពន្យល់សាសនា មួយថ្ងៃ មួយម៉ោង ពេញមួយឆ្នាំ។ ដល់ខ្ញុំជាប់ ឌីប្ល៉ូម ខ្ញុំទៅសុំលាមករៀននៅ វិទ្យាល័យ ស៊ីសុវត្ថិវិញ នោះលោកនាយកសាលា ដែលជាអ្នកបួស ជនជាតិកាណាដា (CANADA) បានហៅខ្ញុំទៅជួប ដើម្បីពន្យល់ខ្ញុំថែមទៀត អំពីសាសនារបស់លោក និងការលះបង់របស់លោក ដើម្បី គ្រិស្តសាសនា ។ បំណង របស់លោក គឺចង់បញ្ចុះ បញ្ចូលខ្ញុំ ឲ្យមកកាន់ គ្រិស្តសាសនាវិញ ។ តែដោយការអប់រំរបស់ខ្ញុំតាំងពីកុមារមក ព្រមទាំងគ្រួសារ ខាងឪពុកខ្ញុំ សុទ្ធតែជាអ្នកធម៌អាថ៌ នោះបន្ទាប់ពីខំពន្យល់ខ្ញុំអស់មួយព្រឹកធំមក លោកក៏អស់មធ្យោបាយ អស់សង្ឃឹម ព្រោះស្តាយខ្ញុំដោយឃើញខ្ញុំនៅក្នុងថ្នាក់ រៀនមុខវិជ្ជាខ្លះមិនចាញ់កូនយួន ដូចជាគណិតសាស្ត្រជាដើម ថ្វីបើកូនខ្មែរមានតែបីបួននាក់ក៏ដោយក្រៅពីនោះភាគច្រើនគឺកូនយួន[36] ។ ម្យ៉ាងទៀត ក្នុងចំ

[36] អ្នកខ្លះចង់ឲ្យយើងស្រឡាញ់គេ ចង់ឲ្យយើងគោរពគេ តែគេធ្វើបាបយើង គេមានចិត្តមិនត្រង់នឹងយើង តើឲ្យយើងស្រឡាញ់ គោរពម្តេចនឹងកើត ។ ពីព្រោះតាមធម្មតា គេអាចបង្ខំកាយអ្នកដទៃបាន តែបង្ខំចិត្តមិនបានទេ នេះតាមព្រះពុទ្ធសាសនា ពីព្រោះចិត្ត ជាធំ ជាប្រធាន មានឥទ្ធិ

ណោមសាលាឯកជន សាលានោះយកថ្លៃដាច់គេ  ហើយពិបាកនឹងចូលទៀត ។ ចំពោះកូនខ្មែរ សាលាតម្រូវឲ្យធ្វើការប្រឡងចូលជាមុនសិន ដោយគេទុកកន្លែងសម្រាប់តែកូនយួន នឹង កូនជនជាតិបរទេស ។

ដល់ខ្ញុំមករៀននៅវិទ្យាល័យស៊ីសុវត្ថិ  ខ្ញុំមានចំណោទខាងអក្សរខ្មែរ  ពីព្រោះខ្ញុំរៀនបានតិចនៅសាលា Miche តែចំពោះមុខវិជ្ជាផ្សេងៗទៀត ខ្ញុំរៀនទាន់ រហូតដល់ថ្នាក់ទី១(classe de première) ខ្ញុំបានអាហារូបករណ៍ រស់នៅក្នុងសាលាដល់ជាប់ បាក់ឌុប (Bac. 2ème partie)  ផ្នែកគណិតសាស្ត្រ ។ ខ្ញុំចូលចិត្តរៀនគណិតសាស្ត្រតាំងពីក្មេង  នេះដោយសារឪពុកខ្ញុំ គាត់មានការអំណត់ ខំពន្យល់ខ្ញុំ ទាល់តែខ្ញុំបានយល់។ ហើយខ្ញុំក៏ចាប់ស្រឡាញ់គណិតសាស្ត្រ រហូតមក ។ មករៀននៅមហាវិទ្យាល័យ ខ្ញុំយកគណិតសាស្ត្រទៀត។ ខ្ញុំមានបរិញ្ញាប័ត្រផ្នែកគណិតសាស្ត្រ និងចេញពីសាលាគរុកោសល្យជាន់ខ្ពស់ ក្រុងភ្នំពេញនៅឆ្នាំ ១៩៦៨ ។ បន្ទាប់មកខ្ញុំធ្វើជាសាស្ត្រាចារ្យផ្នែកគណិតសាស្ត្របង្រៀននៅថ្នាក់ទីបញ្ចប់ ផ្នែកគណិតសាស្ត្រ នៃវិទ្យាល័យនានាក្នុងប្រទេស ដូចជា វិទ្យាល័យព្រះសីហនុ នៅកំពង់ចាម ឬ វិទ្យាល័យស៊ីសុវត្ថិជាដើម ។ បន្ទាប់ពីបានបង្រៀនចំនួន ប្រាំឆ្នាំ

---

ពលខ្លាំងណាស់ ។ បើស្រឡាញ់ហើយ ចិត្តហ៊ានប្តូរស្លាប់រស់ ដើម្បីនឹងជួយគ្នាទៅវិញទៅមក ។ ដូច្នេះមិនពិបាកទេ បើចង់លុបពាក្យយួន ហើយដាក់ពាក្យ វៀតណាមជំនួសវិញ ឬ ក៏លុបពាក្យសៀម ហើយដាក់ពាក្យថៃជំនួសវិញនោះ  សូមឲ្យអ្នកដឹកនាំប្រទេសទាំងពីរនេះ គោរពបូរណភាពទឹកដីខ្មែរ ស្រឡាញ់រាប់អានខ្មែរដោយចិត្តស្មោះត្រង់ មិនកេងប្រវ័ញ្ច  ឬប្រើកម្លាំងអាវុធ មកលើប្រជារាស្ត្រខ្មែរ ដែលសុំតែសេចក្តីសុខសន្តិភាព រស់នៅដោយសម្មាអាជីវោ ។  អ្នកណាក៏ចង់បានសេចក្តីសុខ សេចក្តីចំរើនដែរ មិនថាតែ វៀតណាម ថៃ ឬ ខ្មែរ ទេ ។នេះជាច្បាប់ធម្មជាតិ ជាធម្មព្រះពុទ្ធ ហើយប្រទេសយើងទាំង បី  សុទ្ធតែកាន់ធម៌ព្រះពុទ្ធទាំងអស់គ្នា ។

មក ខ្ញុំបានទទួលអាហារូបករណ៍ពីប្រទេសបារាំង មកបន្តវិជ្ជានៅប្រទេសនេះនៅឆ្នាំ ១៩៧៣ ។ ដោយសារគ្រូរបស់ខ្ញុំ លោក តាន់ ប៊ុនសួ (Tan Bun Sor) បានជួយទាក់ទង គ្រូធំរបស់លោក ឈ្មោះ Monsieur Jean LEGRAS (Nancy-France) ដែលលោកគ្រូខ្ញុំបាន ស្គាល់កាលពីពេលលោកធ្វើនិក្ខេបបទ ខ្ញុំក៏បានលោកសាស្ត្រាចារ្យ Jean LEGRAS ជួយនែនាំតមក ។ មកដល់ប្រទេសបារាំង លោក Jean LEGRAS ឲ្យខ្ញុំរៀនខាង ពត៌មាន វិជ្ជា (informatique) បន្ទាប់មក លោកឲ្យខ្ញុំនូវ ប្រធានបទ ជានិក្ខេបបទមួយខាងគណិត សាស្ត្រអនុវត្ត (mathématiques appliquées) ដែលត្រូវការចំណេះខាងពត៌មានវិជ្ជាថែមទៀត ដើម្បីនឹងគណនានូវសមីការផ្សេងៗ ។

នៅ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៧ ខ្ញុំបានគាំទ្រការស្រាវជ្រាវរបស់ខ្ញុំនៅមុខ គណៈកម្មាធិការមេប្រយោគ ដែលមាន លោក Jean LEGRAS ជាប្រធាន ហើយខ្ញុំក៏ បានជាប់ សញ្ញាប័ត្របណ្ឌិត ផ្នែកពត៌មានវិជ្ជាខាងការសម្រេច (Informatique de la décision) នៅពេលនោះ ដោយនិទ្ទេសកិត្តិយសខ្ពស់បំផុត (avec mention très honorable) ។ ដោយកាលនោះ ស្ថានការណ៍នៅ ប្រទេសយើងកំពុងតែមានការ ច្របូកច្របល់នៅឡើយ អត់មានដំណឹងពីឪពុកម្តាយនិងបងប្អូនខ្ញុំក៏សម្រេចចិត្តរកការងារធ្វើសិនជាបណ្តោះ អាសន្ន ដោយមិនសុខចិត្តសុំចូលជាជនភៀសខ្លួនទេ (réfugié politique) ពីព្រោះខ្ញុំបម្រុង នឹងវិលត្រឡប់ទៅស្រុកវិញ ដើម្បីជួបជុំ កូនខ្ញុំ និងឪពុកម្តាយ បងប្អូន ដែលខ្ញុំឃ្លាតឆ្ងាយ ជាងបីឆ្នាំមកហើយ ។ ដោយគ្មានដំណឹងពីក្មួយខ្ញុំ និងមិត្តភក្តិខ្លះដែលបានចូលទៅក្នុង ស្រុក ខ្ញុំក៏ចេះតែរស់នៅស្រុកគេ តៗទៅរហូតមកដល់សព្វថ្ងៃនេះ (ឆ្នាំ ២០១៧)។ ក្នុងការជួយស្រុកទេស ខ្ញុំមានលទ្ធភាពបានត្រឹម សរសេរ គណិតសាស្ត្រ **ជាភាសាខ្មែរ** ចុះផ្សាយជាសាធារណៈ ជាធម្មទាន បណ្តើរៗ តាមប្រព័ន្ធអាំងតែនែត (lien d'internet) របស់ខ្ញុំ ឈ្មោះ www.btkhmer.com ។ គណិតសាស្ត្រនោះសម្រាប់ និស្សិត ឆ្នាំដំបូង នៅ

មហាវិទ្យាល័យ ។ ខ្ញុំបានដំរាបថា ខ្ញុំស្រឡាញ់គណិតសាស្ត្រ ពុំមែនបានន័យថាខ្ញុំពូកែគណិតសាស្ត្រជាងគេឯងនោះទេ ។ គឺខ្ញុំស្រឡាញ់របៀបត្រិះរិះរកហេតុផល ប្រើពាក្យមានន័យច្បាស់លាស់ មិនអាចឲ្យគេយកទៅបកស្រាយបានច្រើនន័យ ។ ដូចកាលខ្ញុំធ្វើនិក្ខេបបទ លោកសាស្ត្រាចារ្យ Jean LEGRAS គាត់មានប្រសាសន៍ថា ការធ្វើនិក្ខេបបទដើម្បីបានសញ្ញាប័ត្រ នេះជាការធម្មតាទេ តែដែលសំខាន់ គឺគាត់ចង់អប់រំខ្ញុំឲ្យមានគំនិតស្រាវជ្រាវ (esprit de recherche) ។ គឺគំនិតបែបនេះហើយ ដែលធ្វើឲ្យយើងរកឃើញនូវទ្រឹស្តីថ្មីៗ ឬ រកឃើញនូវចម្លើយនៃបញ្ហាថ្មីខ្លះដែលយើងជួបប្រទះ ក្នុងការងារ ឬ ក្នុងការរស់នៅរាល់ថ្ងៃ ។

## សៀវភៅយោង

[1] *ព្រះគ្រូ អ៊ុច រស់* **សតិបដ្ឋានកថា** *ការផ្សាយរបស់ព្រះរាជបណ្ណាល័យ* PhnomPenh - 1930

[2] *ភិក្ខុ ងិន គេន ឥន្ទប្បញ្ញោ* **វិបស្សនាភូមិ** *វត្តពោធិវង្ស ប្រទេសបារាំង - ឆ្នាំ ២០០៦*

[3] *ភិក្ខុ ងិន គេន ឥន្ទប្បញ្ញោ* **បាប និង បុណ្យ** *វត្តពោធិវង្ស ប្រទេសបារាំង - ឆ្នាំ ២០០៩*

[4] *ភិក្ខុ ងិន គេន ឥន្ទប្បញ្ញោ* **បដិច្ចសមុប្បាទ** និង **ឥទប្បច្ចយតា** *វត្តពោធិវង្ស ប្រទេសបារាំង - ឆ្នាំ ២០១១*

[5] *ភិក្ខុ ងិន គេន ឥន្ទប្បញ្ញោ* **កម្ម ផល** *វត្តពោធិវង្ស ប្រទេសបារាំង - ឆ្នាំ ២០០០*

[6] *ភិក្ខុ ងិន គេន ឥន្ទប្បញ្ញោ* **អានាបានស្សតិ** *វត្តពោធិវង្ស ប្រទេសបារាំង - ឆ្នាំ ២០១០*

[7] Walpola Rahula - **L’enseignement du Bouddha** - Editions du Seuil - 1961

[8] NYANATILOKA - **Vocabulaire Pali – Français Des Termes Bouddhiques** - Editions ADYAR - 1995

[9] *បណ្ឌិត ម៉ែម ទីន មន* **កម្ម អ្នកសាងលោកពិត** (Kamma, The Real Creator by Dr. Mem Tin Mon)

[10] Mikhail GORBATCHEW - **Le Putsch** - Editions Olivier Orban (Octobre 1991)

[11] ភិក្ខុ ធម្មប្បញ្ញោ គង់ឌីប **អានាបានស្សតិកម្មដ្ឋាន វិបស្សនាបញ្ញាធម្មបរិយាយ**- បារីស - ព.ស. ២៥៣៨ - គ.ស ១៩៩៥ - *វត្តពោធិវង្ស ប្រទេសបារាំង*

[12] *ព្រះគ្រូ* វិមលបញ្ញា អ៊ុម ស៊ូរ *អាចារ្យព្រះរាជបណ្ណាល័យកម្ពុជា* **ព្រះអភិធម្មត្ថសង្គហៈ** Phnom Penh Imprimerie Albert Portail 1927.

<u>ស្នាដៃខ្ញុំ កាលខ្ញុំធ្វើការនៅធនាគារឯកជនមួយ នៅប្រទេសបារាំង</u>




S.G.I. : Système Général d'Information

គំរោង បំបែក CX099 ជាពីរ ដោយយក Client ចេញ ទុក Compte នៅប្រើសិន




2
PRÉSENTATION DES RÉALISATIONS 2014
Chantier Finalisation du RP – Focus sur le projet CX099
CŒUR client
REUNION D'ACTUALITES 25 NOVEMBRE 2014
Avant
Réalisations
Après
CX099
Client
Compte
Données obsolètes
Données Repositionnées
Outils à développer
Interrogation
Mise à jour unitaire
Saisie répétitive
NEW
Offres RP
CX099
Compte
La CX099 devient une transaction uniquement de niveau « compte »
BNP PARIBAS
BANQUE DE DÉTAIL EN FRANCE
17
Ce document est rédigé au présent ou au futur pour faciliter la lecture. La mise en œuvre des actions évoquées est conditionnée, le cas échéant, par les consultations réglementaires et légales, notamment des instances sociales.

## **ដោយការសង្កេត ដោយមានសតិ ធម៌ព្រះពុទ្ធ នៅតែនឹងមុខៗយើង នៅមិនឆ្ងាយទេ ។**





*ពិធីជប់លៀង នៅលើនាវា ជូនលោកសាស្ត្រាចារ្យ Jean LEGRAS នៅពេលលោកចូលនិវត្តន៍ ដោយមានការចូល រួមពី ភរិយាលោក និង សិស្សគណជាច្រើនរបស់លោក ។ លោកជាចៅហ្វាយខ្ញុំ នៅពេលខ្ញុំធ្វើនិក្ខេបបទ ។ លោកស្រី LEGRAS បានអនិច្ចកម្មមុនប្ដីនេះហើយជីវិតមិនទៀង ហើយ រូបរាងកាយក៏ប្រែប្រួលដែរ ដូច**ព្រះពុទ្ធដីកា**មែន ។*